# ទស្សនាវដ្ដីស្រាវជ្រាវ

# រាជបណ្ឌិត្យសភាកម្ពុជា

## Royal Academy of Cambodia Journal

លេខ១៣ ខែធ្នូ ឆ្នាំ២០២៤ | Vol.13-December-2024



ប្រាសាទបក្សីចាំក្រុង កសាងនៅដើមសតវត្សទី១០ រូបភាព@អាជ្ញាធរជាតិអប្សរា

រក្សាសិទ្ធិគ្រប់យ៉ាង

**នាយកការផ្សាយ**

ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច**

**និពន្ធនាយក**

ឯកឧត្តមបណ្ឌិត **យង់ ពៅ**

**គណៈកម្មការនិពន្ធ**

ឯកឧត្តមបណ្ឌិត **នូ ចាន់សុភី**
ឯកឧត្តមបណ្ឌិត **ផុន កសិកា**
ឯកឧត្តមបណ្ឌិត **អ៊ឹម បុណ្ណា**
ឯកឧត្តមបណ្ឌិត **នុត សម្បត្តិ**
ឯកឧត្តមបណ្ឌិត **គិន ភា**
ឯកឧត្តមបណ្ឌិត **មាឃ បូរ៉ា**
ឯកឧត្តមបណ្ឌិត **គី សេរីវឌ្ឍន៍**
ឯកឧត្តម **សូត្រ សំណាង**
ឯកឧត្តមបណ្ឌិត **ហ៊ាន សុខុម**
លោក **ហេង វីរិទ្ធិ**
លោក **សាន សុភាវនិត**

**លេខាធិការដ្ឋានបោះពុម្ពផ្សាយ**

លោកស្រី **កែវ ខេមរា**
លោក **ធឿន សុត្ថា**
លោក **ហេង ហុកវេន**
លោកស្រី **សំរិទ្ធ ចរិយា**
លោក **កៅ សុម៉ាឡេត**
លោក **ទ្រឿង មករា**
លោក **ភួយ បញ្ញា**

# អារម្ភកថា

ការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រ និងការបោះពុម្ពផ្សាយជាកត្តារួមចំណែកមួយក្នុងការអភិវឌ្ឍសង្គមជាតិ។ រាជបណ្ឌិត្យសភាកម្ពុជាដែលជាធនាគារខួរក្បាលរបស់ជាតិបានធ្វើការសិក្សាស្រាវជ្រាវលើមុខជំនាញជាច្រើន និងបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដីស្រាវជ្រាវ នៃរាជបណ្ឌិត្យសភាកម្ពុជាជាច្រើនលេខរួចមកហើយ។ នៅក្នុងលេខទីដប់បីនេះមានអត្ថបទជាច្រើនទៀតដែលទាក់ទងនឹងជំនាញអក្សរសិល្ប៍ វិចិត្រសិល្បៈ វិទ្យាសាស្ត្រនយោបាយ និងរដ្ឋបាលសាធារណៈជាដើម ហើយសុទ្ធសឹងជាអត្ថបទសិក្សាស្រាវជ្រាវ និងវិភាគបែបវិទ្យាសាស្ត្រ ដែលអាចជាជំនួយស្មារតីដល់អ្នកសិក្សាស្រាវជ្រាវផងដែរ។

ទស្សនាវដ្ដីស្រាវជ្រាវ នៃរាជបណ្ឌិត្យសភាកម្ពុជាបានរួមចំណែកផ្សព្វផ្សាយស្នាដៃស្រាវជ្រាវបែបវិទ្យាសាស្ត្ររបស់បណ្ឌិត្យសភាចារ្យ អ្នកសិក្សាស្រាវជ្រាវ និងអត្ថបទសិក្សាស្រាវជ្រាវរបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងបេក្ខជនបណ្ឌិតផងដែរ។ ការបោះពុម្ពផ្សាយនូវស្នាដៃសិក្សាស្រាវជ្រាវថ្មីៗគឺដើម្បីផ្ដល់នូវចំណេះដឹងបែបវិទ្យាសាស្ត្រជូនដល់សង្គមជាតិ និងជួយសម្រួលដល់ការសិក្សាស្វែងយល់របស់អ្នកស្រាវជ្រាវ ក៏ដូចជាជួយជំរុញដល់អ្នកស្រាវជ្រាវទាំងឡាយឱ្យកាន់តែមានឆន្ទៈក្នុងការស្រាវជ្រាវប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ។

គណៈកម្មការរៀបចំទស្សនាវដ្ដីសង្ឃឹមថា អត្ថបទទាំងអស់ដែលបានចុះផ្សាយក្នុងទស្សនាវដ្ដីស្រាវជ្រាវនេះនឹងក្លាយជាឯកសារដ៏សំខាន់មួយ សម្រាប់ការសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ។

គណៈកម្មការរៀបចំរង់ចាំទទួលមតិរិះគន់ក្នុងន័យស្ថាបនាពីសំណាក់អ្នកអាន និងអ្នកស្រាវជ្រាវគ្រប់មជ្ឈដ្ឋាន ដើម្បីកែលម្អនូវចំណុចខ្វះខាត និងកំហុសឆ្គងដែលអាចកើតមានឡើងដោយអចេតនាទាំងលើខ្លឹមសារ និងផ្នែកបច្ចេកទេស ឱ្យកាន់តែមានសុក្រឹតភាព៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

**គណៈកម្មការទស្សនាវដ្ដីស្រាវជ្រាវនៃរាជបណ្ឌិត្យសភាកម្ពុជា**

# មាតិកា


១. ទស្សនប្រាកដនិយម និងស្នាដៃអក្សរសិល្ប៍ បេក្ខជនបណ្ឌិត **សារ៉ន ស្រីនិត** ---------------------- ១

២. តួនាទីស្ត្រីកម្ពុជាក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅទីស្តីការគណៈរដ្ឋមន្ត្រីពីឆ្នាំ២០២៣ដល់ឆ្នាំ២០២៤ បេក្ខជនបណ្ឌិត **សរ សំឡូត** -------------------------------------------------------------------------១១

៣. យន្តការផ្តល់សេវាចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុនៅប្រទេសកម្ពុជា បេក្ខជនបណ្ឌិត **យន់ សុងហៀង** ----------------------------------------------------------------------------------------------------២៤

៤. តម្លៃនៃការអប់រំតាមរយៈចម្រៀងបំពេនៅដែនដីសណ្តទន្លេមេគង្គ បេក្ខជនបណ្ឌិត **ថាច់ សោភ័ណ** ----------------------------------------------------------------------------------------------------៤៩

៥. ក្របខ័ណ្ឌការងារសម្រាប់ជានាការអភិវឌ្ឍវិជ្ជាជីវៈធនធានមនុស្សក្នុងក្រសួងអប់រំ យុវជន និងកីឡា បេក្ខជនបណ្ឌិត **ទ្រី ចាន់** --------------------------------------------------------------------------៥៧

៦. ការគ្រប់គ្រងរដ្ឋក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បេក្ខជនបណ្ឌិត **ចាន់ ទី**------------------------ ៦៣

៧. សមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ បេក្ខជនបណ្ឌិត **អូន សំអុល**----------------------------------៧៤

៨. ការផ្សព្វផ្សាយរឿងសាមកុកនៅកម្ពុជា និស្សិត **កៅ ស៊ីវិញ**-------------------------------------- ៨៣

៩. ចម្លាក់សហសម័យទម្រង់បង្គុំ និស្សិត **អ៊ូ វណ្ណឌី** ----------------------------------------------៩២

# ទស្សនៈប្រាកដនិយម និងស្នាដៃអក្សរសិល្ប៍

បេក្ខជនបណ្ឌិត៖ **សារ៉ែន ស្រីនិត**
ជំនាញ៖ **អក្សរសិល្ប៍**

## ១. សេចក្តីផ្តើម

ការរីកចម្រើននៃចំណេះដឹងបច្ចេកវិទ្យាមនុស្ស បានជះឥទ្ធិពលដល់ដំណើរនៃវិវឌ្ឍនាការរបស់អក្សរសិល្ប៍។ បរិបទសង្គមតែងតែផ្លាស់ប្តូរដែលជាហេតុនាំឱ្យស្នាដៃអក្សរសិល្ប៍មានការប្រែប្រួលតាមនិន្នាការ និងលោកទស្សនៈរបស់អ្នកនិពន្ធ។ ប្រធានបទ កម្មវត្ថុអក្សរសិល្ប៍ ស្នាដៃរបស់អ្នកនិពន្ធក៏មានលក្ខណៈប្លែកៗពីគ្នាទៅតាមបទពិសោធ និងចំណេះដឹងរបស់គេរៀងៗខ្លួន។ កាលវិទ្យាសាស្ត្រពុំទាន់រីកចម្រើនមនុស្សរស់នៅពឹងផ្អែកលើកម្លាំងក្រៅខ្លួន មានធម្មជាតិ ជំនឿ ព្រលឹង អាទិទេព អ្នកតា ឬជុំថ្មជាវត្ថុស័ក្តិសិទ្ធិដើម្បីចូលមកដោះស្រាយបញ្ហារបស់មនុស្ស។ សង្គមក៏ចាប់ផ្តើមកត់ត្រាជាឯកសារ ការនិទាន តំណាល រហូតក្លាយជាស្នាដៃអក្សរសិល្ប៍តំណាងឱ្យសម័យកាល ឬព្រឹត្តិការណ៍សង្គមនោះ។

មនុស្សកាន់តែកើន បញ្ហាមនុស្សក៏កាន់តែច្រើន ចំណេះដឹងក៏កាន់តែរីកចម្រើន មនុស្សបង្កើតសាសនាដើម្បីអប់រំសតិស្មារតី បង្កើតច្បាប់ហាមប្រាមទង្វើខុសឆ្គងនៃតណ្ហារបស់មនុស្ស។ ផ្តើមរៀបរាប់ពីមនោសញ្ចេតនារបស់បុគ្គល ក្នុងរូបភាពជាកំហឹង ក្តីឈឺចាប់ រវើរវាយ ផ្លូវចិត្តក្នុងទម្រង់ស្រមើស្រមៃប្រលោមស្នេហា អណ្តែតអណ្តូង ឧត្តមគតិ អក្សរសិល្ប៍ចាប់កើតឡើង ជំនួសឱ្យជំនឿលើអរូបីទាំងនោះនាសម័យមុនៗ។ ដោយលុះនឹងអារម្មណ៍រវើរវាយ អណ្តែតអណ្តូង ឧត្តមគិតពេកមិនបាន មនុស្សក៏ចាប់ផ្តើមសករាជថ្មីនៃអក្សរសិល្ប៍ដើម្បីបង្ហាញពីការពិត ពីបញ្ហាផ្លូវចិត្ត ផលប្រយោជន៍ ការទាមទារឱ្យស្មើភាពក្នុងនាមមនុស្ស ដែលជាបញ្ហាចាស់ក្នុងដំណោះស្រាយថ្មីមកបង្ហាញដោយត្រង់ បង្កើតជាស្នាដៃថ្មីដែលបកស្រាយពីលក្ខណៈប្រាកដក្នុងជីវិត។

ទស្សនៈប្រាកដនិយមនេះ បញ្ហាខ្លះ រឿងខ្លះអសីលធម៌ គ្រោតគ្រាត រហូតទទួលយកមិនបាន។ សង្គមមនុស្សបដិសេធពុំទទួលយក ហើយគិតថាពុំគួរឱ្យកើតមានស្នាដៃបែបនេះ កើតឡើងនោះទេដោយហេតុថា អក្សរសិល្ប៍មានមុខងារសំខាន់គឺការអប់រំមនុស្សក្នុងសង្គម ទើបការដែលលើកបង្ហាញពីប្រាកដនិយមជាដើមចម ទោមនស្សទៅនឹងឧត្តមគតិរបស់មនុស្ស។ បញ្ហាសំខាន់ៗ នៃអក្សរសិល្ប៍ប្រាកដនិយម គឺបង្ហាញពីលក្ខណៈទូទៅ ជារួមរបស់សង្គមមនុស្ស កាលដែលលើកយកបញ្ហាតថៈក្នុងសង្គមមកបង្ហាញពុំមែនបញ្ជាក់ន័យថា វាមានលក្ខណៈប្រាកដនិយមនោះទេ ព្រោះបញ្ហាតថៈគ្រាន់តែជាលក្ខណៈដាច់ដោយឡែកខុសគ្នាទៅតាមទីកន្លែង ប្រភេទព្រឹត្តិការណ៍ ចំណែកប្រាកដនិយមប្រើបានគ្រប់ទិដ្ឋភាពមិនចំពោះ។

## ២. និយមន័យទស្សនៈប្រាកដនិយម

យោងតាមវចនានុក្រមខ្មែរឆ្នាំ២០២២ក្នុងទម្រង់ឌីជីថល ដែលរៀបរៀងឡើងដោយក្រុមប្រឹក្សាជាតិភាសាខ្មែរបានពន្យល់ថា៖

ប្រាកដនិយម [ប្រា-កត់-និ-យំ] ថា:

*១). ន. លទ្ធិឬទម្លាប់ដែលនិយមតែការជាក់ស្ដែង ដែលមានជាជាងសង្ឃឹមលើអ្វីដែលមិនទំនងជាកើតមាន: ភាពប្រាកដនិយម, ទស្សនវិស័យប្រាកដនិយម, ទស្សនៈនយោបាយប្រាកដនិយម។*

*២). (វ.វិចិ.) របនាបថនៃសិល្បៈ ឬអក្សរសិល្ប៍មួយប្រភេទ ដែលបង្ហាញនូវមនុស្សនិងអ្វីៗដូចមាននៅក្នុងជីវិតពិត វិចិត្រកម្ម ភាពយន្ត សៀវភៅជាដើម ដែលព្យាយាមធ្វើជាតំណាងឱ្យជីវិតពិតៗ។*[១]

តាមសទ្ទានុក្រមអក្សរសាស្ត្ររបស់លោក M. H. Abrams និងGeoffrey Galt Harpham បានសរសេរថា៖ «*ភាពប្រាកដនិយម និងធម្មជាតិនិយម ភាពប្រាកដនិយមត្រូវបានអនុវត្តដោយអ្នករិះគន់ផ្នែកអក្សរសាស្ត្រក្នុងវិធីចម្រុះពីរយ៉ាង៖*

*១. ដើម្បីកំណត់អត្តសញ្ញាណចន្លនមួយ នៅក្នុងការសរសេរប្រលោមលោកក្នុងកំឡុងសតវត្សទី១៩ ដែលរួមមាន Honoré de Balzac នៅប្រទេសបារាំង លោក George Eliot នៅប្រទេសអង់គ្លេស និងលោក William Dean Howells នៅអាមេរិក។*

*២. ដើម្បីកំណត់របៀបកើតឡើងដដែលៗ ក្នុងយុគសម័យ និងទម្រង់អក្សរសាស្ត្រផ្សេងៗ ដែលតំណាងឱ្យជីវិតមនុស្ស និងបទពិសោធ»។*[២]

នេះជាការកត់សម្គាល់មួយដែលយើងកំណត់ន័យចំពោះស្នាដៃអក្សរសិល្ប៍ប្រាកដនិយម តាមលក្ខណៈទី១ បង្ហាញគ្រប់ចលនាដែលកើតឡើងនៅក្នុងអំឡុងសតវត្សទី១៩ ជាស្នាដៃអក្សរសិល្ប៍បែបប្រាកដនិយម។ ចំណែកលក្ខណៈទី២ ស្នាដៃអក្សរសិល្ប៍ប្រាកដនិយម បានទៅដល់ស្នាដៃអក្សរសិល្ប៍ទាំងឡាយណាដែលលើកយកពីបញ្ហាជីវិតពិតរបស់មនុស្សមកបង្ហាញ។

ក្នុងសៀវភៅ Literary Movements for Students បានពន្យល់ថា Realism *គឺជាអក្សរសិល្ប៍ដែលសង្កត់ធ្ងន់ទៅលើអ្វីតំណាងឱ្យភាពត្រឹមត្រូវ ព័ត៌មានលម្អិតពីជីវិតសហសម័យ*។[៣]

នៅក្នុងសៀវភៅ អក្សរសិល្ប៍បារាំងសតវត្សទី១៩ របស់លោក វ៉ាន់ ឌីកាអុន បានសរសេរថា «*នៅឆ្នាំ១៨៥៦ អ្នកនិពន្ធប្រលោមលោកពីរូបគឺ សង់ផ្លើរី (Chamfeury) និងឌុយ រ៉ង់ទី(Duranty) បានបង្កើតចលនាអក្សរសិល្ប៍មួយមានឈ្មោះថា ចលនាប្រាកដនិយម ហើយដែលកំណត់ឱ្យអ្នកនិពន្ធនិងសិល្បករលើកឡើងតែពីអ្វីៗដែលឆ្លុះឱ្យឃើញការពិតមែនទែន គឺចៀសវៀងលាក់បាំងភាពគ្រោតគ្រាតចំណុចខ្សោយនានារបស់មនុស្សជាទូទៅ»*។[៤]

ក្នុងសៀវភៅ វប្បធម៌ និងអរិយធម៌ របស់លោក **សរ សារុន** ដែលអធិប្បាយបែបទស្សនៈវិជ្ជា បានសរសេរថា «*Le Réalisme ថាជាទស្សនៈវិជ្ជាមួយផ្នែកដែលឱ្យតម្លៃទៅលើអ្វីជាតថៈ(Le réel)។*

---

[១] វចនានុក្រមខ្មែរឆ្នាំ២០២២ ក្នុងទម្រង់ឌីជីថល។

[២] M. H. Abrams and Geoffrey Galt Harpham, *A Glossary of Literary,* op. cit., p.333.

[៣] Galens, David. *Literary Movements for Students*, San francisco, Second Edition, 2009.p654.

[៤] វ៉ាន់ ឌីកាអុន *អក្សរសិល្ប៍បារាំងសតវត្សទី១៩* ភ្នំពេញ, ការផ្សាយរបស់អ្នកនិពន្ធ, ឆ្នាំ២០១០ ទំព័រទី២១២។

*តថៈពុំមែនជាការពិតទេ មតិខ្លះច្រើនយល់ច្រឡំតថៈ និងសច្ច(La Vérité)។ សច្ចជាការពិតប្រាកដ តាមធម្មជាតិ ដែលធ្លាប់មានឡើង។ តថៈមាននិន្នាការទៅរកសច្ចប៉ុន្តែពុំមែនសច្ចទេ ពោលគឺជាការពិត គឺមិនមែន មិនពិតក៏មិនមែន។ តថៈគឺជាការរៀបចំឡើងឱ្យដូចជាការពិត(Réalisation)»។*[៥]

ដូចគ្នានេះដែរ ក្នុងសៀវភៅប្រជុំកវីអ្នកនិពន្ធ របស់លោកគ្រូ ម៉ុញ សារី បានសរសេរថា *«ទ្រឹស្តីអក្សរសិល្បដែលអ្នកនិពន្ធខ្លះក្នុងរវាងឆ្នាំ១៨៥០ ចង់បង្ហាញពីតថៈភាពទៅតាមអ្វីដែលពួកគេបានឃើញ យល់បាន ដោះស្រាយបាន ពន្យល់បាន សិក្សាបាន តថៈប្រវត្តិសាស្ត្រ(Histoires reélles) ប្រវត្តិសាស្ត្ររស់(Histoires vécues) ដកស្រង់ចេញពីការណ៍ផ្សេងៗ ពីឯកសារប្រវត្តិសាស្ត្រដែលពុះកញ្ជ្រោល (Histoires trés poussées) តួអង្គសាមញ្ញ មនោសញ្ចេតនា តួអង្គពិតជាក់ស្តែង ពិពណ៌នាទីកន្លែង និងរូបភាពរបស់តួឯងអង្គយ៉ាងល្អិតល្អន់ ហើយរចនាបថសាមញ្ញធម្មតា និងស្របតាមវត្ថុ(Objective)*។[៦]

ក្នុងការបង្ហាញរបស់លោកគ្រូ ម៉ុញ សារី លើឃ្លា *Histoires reélles* ដែលនិយាយពីតថៈប្រវត្តិសាស្ត្រ លោកគ្រូប្រើពាក្យ *reél* គឺមានន័យថា តថៈមិនមែនប្រាកដ Réalism នោះទេ។

នៅក្នុងសៀវភៅមូលដ្ឋានដើម្បីយល់អក្សរសាស្ត្ររបស់លោក ហ៊ុន គឹមសៀ បានសរសេរថា *«ចលនាអក្សរសាស្ត្រលោកីយ៍សច្ច Réalisme អក្សរសាស្ត្រលោកីយ៍សច្ចនេះ គឺជាចលនាមួយដែលមាននិន្នាការសេច្ច គឺស្តែងការពិតឱ្យដូចពិតមែន។ គេច្រើនយកចិត្តទុកដាក់ដល់ភាគអន់ថយ ដែលជាគុណវិបត្តិរបស់មនុស្ស ចលនាលោកីយ៍សច្ចនេះ ក៏មានចរិតប្រហែលគ្នាទៅនឹងពួកធម្មជាតិនិយមដែរ (Naturalisme) ប៉ុន្តែពួកធម្មជាតិនិយមគេមានប្រការពិសេសត្រង់ថា៖ គេសម្តែងការពិតឱ្យដូចពិតមែន ប៉ុន្តែមានថែមភាគវែកញែកវះកាត់ការធ្វើការបែងចែកប្រៀបធៀប។»*[៧]

តាមការបង្ហាញរបស់លោក ហ៊ុន គឹមសៀ លោកបានប្រើពាក្យ *Réalism ប្រែក្នុងន័យថាជាអក្សរសាស្ត្រលោកីយ៍សច្ច* ទៅទៀត។

នៅក្នុងនិក្ខេបបទរបស់បណ្ឌិត កាង ក្សុងហ៊ី បានសរសេរថា *«តថនិយម(Réalism)គឺតំណាងឱ្យអក្សរសិល្បដែលមានទស្សនៈ យោបល់ជាច្រើនទៅលើបញ្ញត្តិ និយមន័យ ហើយត្រូវបានប្រើប្រាស់នៅក្នុងទស្សនៈវិជ្ជានៅបស្ចិមប្រទេសដ៏យូរយារណាស់មកហើយ។ ម្យ៉ាងទៀត ក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរ អ្នកនិពន្ធតែងតែមានការបង្ហាញពីលក្ខណៈតថៈដូចជាសង្គមបរិយាកាស និងព្រឹត្តិការណ៍នានាក្នុងប្រវត្តិសាស្ត្រ ដែលអាចកើតឡើងនៅជុំវិញសង្គមមនុស្សពិតៗបាន ដើម្បីទាញអ្នកអានឱ្យមានចំណាប់អារម្មណ៍ និងដក់ចិត្តទៅលើស្នាដៃរបស់អ្នកនិពន្ធទាំងនោះ ក៏ប៉ុន្តែស្នាដៃទាំងនេះ មិនអាចចាត់ទុកថាសុទ្ធតែជាស្នាដៃអក្សរសិល្បបែបតថៈនិយមបានឡើយ»*។[៨]

---

[៥] សរ សារុន *វប្បធម៌ និងអរិយធម៌ខ្មែរភាគ២* ភ្នំពេញ, បណ្ណាគារពន្លឺវិទ្យា, ឆ្នាំ១៩៧០ ទំព័រទី១៤០។

[៦] ម៉ុញ សារី *ប្រជុំកវីអ្នកនិពន្ធ* ភ្នំពេញ, សាកវិទ្យាល័យភូមិន្ទភ្នំពេញ, ២០០៧ ទំព័រទី១។

[៧] ហ៊ុន គឹមសៀ *មូលដ្ឋានដើម្បីយល់អក្សរសាស្ត្រ* ដ.ឯ.ម. ទំព័រទី៨៥។

[៨] កាង ក្សុងហ៊ី *លក្ខណៈប្រលោមនិយម និងតថៈនិយមតាមរយៈស្នាដៃអក្សរសិល្បខ្មែរដើមសតវត្សទី២០* ភ្នំពេញ, រាជបណ្ឌិត្យសភាកម្ពុជា, ឆ្នាំ២០១១ ទំព័រទី៦២។

នៅត្រង់នេះខ្ញុំសូមបញ្ជាក់ថា លោកស្រីបណ្ឌិតបានប្រើពាក្យ Réalism ហើយប្រែជាខ្មែរមានន័យថា *តថៈ* ប្រសិនបើយើងសិក្សាពីពាក្យ Réalism នោះយើងបានយល់ថា បើទោះបីជាអ្នកកនិពន្ធបានលើកយកព្រឹត្តិការណ៍ ហេតុការណ៍សង្គម មកជាស្នាដៃអក្សរសិល្ប៍នោះ វាមិនទាន់គ្រប់គ្រាន់ថាស្នាដៃនោះមានលក្ខណៈ Réalism ឡើយខ្ញុំចង់សង្កត់ធ្ងន់តែលើពាក្យ Réalism ប៉ុណ្ណោះ។

សរុបមក អក្សរសិល្ប៍ប្រាកដនិយមគឺបង្ហាញពីសារជាតិធម្មជាតិរបស់មនុស្ស ក្នុងការឆ្លើយតបទៅនឹងស្ថានភាពជាក់លាក់ណាមួយ។

## ៣.ប្រភេទអក្សរសិល្ប៍ប្រាកដនិយម

### ក. អក្សរសិល្ប៍ប្រាកដនិយមសង្គមនិយម (Socialist Realism)

ស្នាដៃអក្សរសិល្ប៍ ដែលបកស្រាយទាក់ទងទៅនឹងលទ្ធិសង្គមនិយម ត្រង់ចំណុចនេះគឺយើងសិក្សាអត្ថន័យពាក្យប្រាកដនិយមផង និងសង្គមនិយមផង។ ប្រភពសំខាន់ដែលឈានដល់ការបង្កើតស្នាដៃអក្សរសិល្ប៍ប្រាកដនិយមសង្គមនិយមនេះឡើង គឺលទ្ធិសង្គមនិយមនេះឯង។

សង្គមនិយម នៅក្នុងសៀវភៅមូលដ្ឋានដើម្បីយល់អក្សរសាស្ត្រ របស់លោក ហ៊ុន គឹមសៀ បានសរសេរពីសង្គមនិយមថា «*គឺជាស្មារតីតស៊ូវណ្ណៈ ធ្វើជាមូលដ្ឋានឱ្យចលនារបស់តួអង្គនាដសកម្ម។ គោលបំណងសំខាន់គឺជាក់នយោបាយឃោសនាឡើងជួរមុខ ក្នុងចលនាមនុស្សបម្រើផលប្រយោជន៍របស់សង្គម។ ផ្នែកសិល្បៈក៏ដូចជាផ្នែកគំនូរចម្លាក់ផ្សេងៗ ត្រូវបម្រើគោលបំណងនយោបាយជាដាច់ខាត។ ផ្នែកសង្គមនិយមគេយល់ថាអក្សរសាស្ត្រគឺជាមធ្យោបាយសម្រាប់ឃោសនាបម្រើសង្គម មិនត្រូវឱ្យវាមានជរមាននៅដាច់ដោយឡែកពីសង្គមមនុស្សបានទេ ធ្វើបានបែបនេះទើបហៅថាអក្សរសាស្ត្រមានប្រយោជន៍..។ល*»។[៩]

នៅក្នុងសៀវភៅសទ្ទានុក្រមអក្សរសិល្ប៍ខ្មែរ-អង់គ្លេស-បារាំង បានពន្យល់អត្ថន័យសំនួនពាក្យតថនិយមសង្គមនិយម(អ.socialist realism, បារ. réalisme socialiste) ថា ***និន្នាការក្នុងការបង្កើតស្នាដៃអក្សរសិល្ប៍សិល្បៈ ដោយឆ្លុះបញ្ចាំងជីវភាពរស់នៅរបស់វណ្ណៈកម្មករ កសិករ ក្នុងគោលបំណងបម្រើមនោគមវិជ្ជាសង្គមនិយម។***

***ឧទាហរណ៍:***

***-រឿងគ្រូបង្រៀនស្រុកស្រែ របស់អ្នកនិពន្ធ អ៊ឹម ថុក***

***-រឿងលុះដែកថែបលត់រួចហើយ របស់អ្នកនិពន្ធ នីកូឡៃអូសស្ត្រូវស្គី(Nikolay Ostrovsky)។***[១០]

ប្រាកដនិយមសង្គមនិយមនេះ គឺបង្ហាញពីចរិតលក្ខណៈរបស់មនុស្ស ដែលកើតក្នុងសម័យសង្គមនិយម ថាតើចរិតមានអំណាចបែបណា ចរិតអ្នកក្របែបណា ដោយផ្អែកលើស្ថានភាពជាក់ស្តែងរបស់សង្គម និងព្រឹត្តិការណ៍។ ចរិតឃោរឃៅកោងកាចនៃអ្នកមានអំណាច និងភាពល្ងង់ខ្លៅទន់ខ្សោយ

---

[៩] ហ៊ុន គឹមសៀ *មូលដ្ឋានដើម្បីយល់អក្សរសាស្ត្រ* ដ.ឯ.ម. ទំព័រទី៨៧។

[១០] ក្រុមប្រឹក្សាជាតិភាសាខ្មែរ *សទ្ទានុក្រមអក្សរសិល្ប៍(ខ្មែរ-អង់គ្លេស-បារាំង)*.ដ.ឯ.ម ទំព័រទី៣០។

របស់អ្នកក្រ។ អ្នកមានអំណាច(ស្ដេច សេដ្ឋី មន្ត្រី) តែងតែជិះជាន់មើលងាយចំពោះអ្នកក្រ អ្នកតូចតាចនៅតែចាញ់ប្រៀប អ្នកក្រទន់ខ្សោយតែងតែចាញ់បោក និងរស់ក្រោមអ្នកមានអំណាច ដែលជំរុញឱ្យការប្រឆាំង និងបះបោរកើតឡើង។

ស្នាដៃរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ តួអង្គសមត្រូវថៅកែអ្នកមានអំណាច អ្នកនយោបាយជិះជាន់ កេងប្រវ័ញ្ច និងធ្វើបាប ដែលបង្ហាញពីលក្ខណៈប្រាកដនិយមក្នុងសម័យសង្គមនិយម។ សារជាតិរបស់មនុស្ស គឺឃោរឃៅ និងកាចសាហាវ ចរិតរបស់មនុស្សគឺឱ្យតម្លៃលើសម្ភារៈនិយម តំណែង តួនាទី ផលប្រយោជន៍។ តួអង្គសយ ប្រពន្ធសមស្លាប់មិនមែនដោយសារឧត្តមគតិរបស់អ្នកនិពន្ធ ឬតួអង្គណាឡើយ សយស្លាប់ព្រោះគ្មានប្រាក់ព្យាបាលជំងឺ បើយើងគិតថាមនុស្សត្រូវមានសីលធម៌ គុណធម៌ចេះជួយអ្នកដទៃ ចុះឯណាគុណធម៌របស់អ្នកជំនាញគ្រូពេទ្យដែលមានទីសង្គ្រោះជីវិតមនុស្ស តាមពិតគឺដោយសារគ្មានប្រាក់ព្យាបាល ទើបបណ្ដាលឱ្យដួចសង្គមជាក់ស្ដែង ទើបអ្នកនិពន្ធទាញប្រពន្ធសមឱ្យស្លាប់បែបនេះយ៉ាងត្រឹមត្រូវ។ មនុស្សយល់នូវក្ដីទ័លហើយ អ្វីក៏ហ៊ានធ្វើដែរ យ៉ាងណាមិញសមសម្រេចចិត្តដ៏តានតឹងទៅឆក់កាបូបប្រាក់ដើម្បីចម្អែតក្រពះមួយពេល។

**ខ.អក្សរសិល្ប៍ប្រាកដនិយមរិះគន់**( Critical Realism )

ក្នុងសៀវភៅ The meaning of Contemporary realism សរសេរដោយ Georg Lukács បង្ហាញថា «*សម្ព័ន្ធភាពរវាងសង្គមនិយម និងប្រាកដនិយមរិះគន់ ស្ថិតនៅទីតាំងមនោគមវិជ្ជាកាន់តែស៊ីជម្រៅ។ នៅក្នុងប្រភេទនៃ folk mystique ត្រូវបង្កប់អត្ថន័យតិចតួចអំពីលក្ខណៈជាតិសាសន៍វាគ្រាន់តែជាប្រទេសណាមួយឆ្លុះបញ្ចាំងពីលក្ខខណ្ឌប្រវត្តិសាស្ត្រជាក់លាក់ដែលឆ្លងកាត់។ ការពុកផុយនៃលទ្ធិកុម្មុយនីស្ត សម័យបុព្វកាល កើតមានទម្រង់ ផ្សេងគ្នានៅកន្លែងផ្សេងគ្នា។ ប្រទេសនៅអឺរ៉ុបបានបង្កើតប្រភេទនៃសក្តិភូមិរបស់ខ្លួន ការធ្លាក់ចុះនៃសក្តិភូមិ ការកើនឡើងនៃមូលធននិយម រចនាសម្ព័ន្ធពិសេសចលនាកម្មករ ទោះបីជាមានមូលដ្ឋានស្រដៀងគ្នា មានភាពខុសប្លែកគ្នាសំខាន់នៅក្នុងប្រទេសផ្សេងៗគ្នា។ ប្រាកដនិយមជាកត្តាចម្បងមួយក្នុងការបង្កើតបរិយាកាសបញ្ហា និងខាងវិញ្ញាណបុគ្គលិកលក្ខណៈរបស់មនុស្សជាពិសេសសលក្ខណៈជាតិ។*»[១១]

ក្នុងសៀវភៅរបស់និក្ខេបបទថ្នាក់បណ្ឌិតអក្សរសិល្ប៍ របស់បណ្ឌិត កាង ក្យុងហ៊ី ក៏បានសរសេរទាក់ទងទៅនឹងប្រាកដនិយមរិះគន់នេះផងដែរថា «*គឺសំដៅទៅលើគថៈនិយមបែបរិះគន់ ដែលមានទ្រឹស្តីទាក់ទងទៅនឹងសង្គមនិយម ជាមូលដ្ឋានបន្ថែមទៅលើលក្ខណៈគថៈបែបរិះគន់*»។[១២]

ស្នាដៃប្រភេទនេះនៅតែបន្តបែបសង្គមនិយម ប៉ុន្តែត្រូវបង្កើតតួអង្គតំណាងដើម្បីរិះគន់អ្នកសង្គម ឬរិះគន់សង្គមផ្ដាច់ការ និងរិះគន់អំពើអយុត្តិធម៌។ ចំពោះស្នាដៃអក្សរសិល្ប៍ខ្មែរវិញ ឧទាហរណ៍៖

រឿងទន្សាយ និងអ្នកបរទេស សត្វមានអំណាចខ្លាំងពូកែតែងតែត្រូវប្រើល្បិចបោកប្រាស់ជនទន់ខ្សោយជាងខ្លួន ដោយពាក្យលួងលោម។ មនុស្សល្អៗ ខ្លាចអំពើអាក្រក់ កាលបើការជួយយកអាសា

---

[១១] Georg Lukács *The meaning of Contemporary realism*, op. cit., p.103.

[១២] កាង ក្យុងហ៊ី *លក្ខណៈប្រលោមនិយម និងគថៈនិយមតាមរយៈអក្សរសិល្ប៍ខ្មែរដើមសតវត្សទី២០* ជ.ឯ.ម. ទំព័រទី៧៥។

មនុស្សជាអំពើបុណ្យ នោះមនុស្សនឹងនាំគ្នាធ្វើដោយមិនគិតអ្វីឡើយ។ ប៉ុន្តែយើងពុំបានដឹងថាសារជាតិធម្មជាតិពិត(ប្រាកដនិយម)របស់សត្វក្រពើ វាស៊ីសាច់មនុស្សឯណា ចុងក្រោយវាទាមទាររកចំណុចអាក្រក់របស់យើងដើម្បីឱ្យយើងចាញ់វិញ។ តួអង្គទន្សាយតំណាងអ្នកកាត់ក្តី តំណាងឱ្យការរិះគន់ អ្នកនិពន្ធបានរិះគន់ ពពួកអ្នកមានអំណាចឥទ្ធិពល សក្តិភូមិ ដែលតែងតែមានគំនិតជិះជាន់ បោកប្រាស់អ្នកទន់ខ្សោយជាងខ្លួន។

រឿងបុរសដណ្តឹងប្រពន្ធ ស្ថិតក្នុងប្រជុំរឿងព្រេងខ្មែរភាគ២ មិនខុសពីរឿងខាងលើប៉ុន្មានទេ តួអង្គបុរសតំណាងអ្នកទន់ខ្សោយ និងឪពុកម្តាយខាងស្រីតំណាងអ្នកមានអំណាច។ តួអង្គបុរសម្នាក់ទៅដណ្តឹងកូនគេ ធ្វើតាមបង្គាប់ឪពុកម្តាយ ឱ្យបុរសនោះត្រាំទឹកបីយប់បីថ្ងៃ ចៃដន្យបុរសនោះលើកដៃអាំងភ្លើងពីចម្ងាយ ឪពុកម្តាយខាងស្រីក៏បញ្ឈប់ផ្តាច់កូន។ បុរសនោះមិនសុខចិត្ត មករកទន្សាយឱ្យជួយ ទន្សាយក៏បានប្រើល្បិចដូចគ្នា ដោយស្លសម្លមិនបង់ប្រហុកទុកនៅក្បែរនោះ។ កម្តៅភ្លើងលោកថាក្តៅដល់ ចុះអំបិលប្រហុកនោះម្តេចមិនប្រៃដល់។

**ជារួមគេចង់បង្ហាញថា អ្នកមានទ្រព្យ អ្នកមានអំណាច តែងតែចង់ធ្វើអ្វីលើ អ្នកក្រខ្សត់ជាងខ្លួនមិនឱ្យតម្លៃ ត្រូវតែឈ្នះអ្នកក្រ សង្គមមនុស្សបែបនេះ។ ក៏ប៉ុន្តែក៏មានតួអង្គតំណាងជាអាជ្ញាកណ្តាលដើម្បីមកកាត់ក្តីដោយសមហេតុសមផល។**

**គ. អក្សរសិល្ប៍ប្រាកដនិយមធម្មជាតិនិយម** Naturalism

ធម្មជាតិនិយម បង្ហាញពីការពិតរបស់មនុស្ស ដោយបង្ហាញពីបរិយាកាសសង្គម មានឥទ្ធិពលលើប្រតិកម្មរបស់មនុស្សនេះជាគោលបំណងបញ្ជាក់ពីការពិត ឬធម្មជាតិពិតនៅក្នុងស្នាដៃអក្សរសិល្ប៍។ មនុស្សជាប្រភេទសត្វលំដាប់ខ្ពស់ ចរិត អាកប្បកិរិយា សភាវគតិបង្ខិតបង្ខំជាពិសេសស្រេកឃ្លាន ការជំរុញឱ្យមានការប្រមូលផ្តុំទ្រព្យសម្បត្តិ និងផ្លូវភេទ ហើយក្រោយមកត្រូវបានទទួលរងនូវកម្លាំងសង្គម សេដ្ឋកិច្ចក្នុងគ្រួសារ និងវណ្ណៈដែលមនុស្សនោះកើតមក។ អ្នកនិពន្ធប្រលោមលោក ជនជាតិបារាំង Émile Zola នៅឆ្នាំ១៨៧០ បានបង្កើតទ្រឹស្តីនេះ ដែលគាត់ហៅថា «le roman experimental» (នោះគឺជាប្រលោមលោកដែលបង្ហាញការពិសោធន៍វិទ្យាសាស្ត្រ លើអាកប្បកិរិយាក្រោមលក្ខខណ្ឌដែលបានផ្តល់ឱ្យ។ អ្នកនិពន្ធទាំងនោះ មានទំនោរជ្រើសរើសតួអង្គ ដែលបង្ហាញពីការលោភលន់ ចំណង់ផ្លូវភេទ ជនរងគ្រោះដែលគ្មានទីពឹង និងសម្ពាធសង្គម ប្រលោមលោកធម្មជាតិនិយម ក៏បង្ហាញពី«សោកនាដកម្ម»ផងដែរ។[១៣]

នៅក្នុងសៀវភៅ Critical Realism ដែលសរសេរដោយបណ្ឌិត Roy wood Sellars បាននិយាយថា «*អាកប្បកិរិយាចំពោះពិភពលោកពុទ្ធប្បវត្តិ ត្រូវគេចាត់ទុកថាឯករាជ្យព្រឹត្តិការណ៍នៃការយល់ឃើញហេតុផលជាទូទៅអាចហៅថាធម្មជាតិពិត។ ទិដ្ឋភាពផ្តែកលើភាពជាក់ស្តែងនៃជីវិត និងជីវសាស្ត្រ មានលក្ខណៈធម្មជាតិ សម្រាប់យើងដូចទៅនឹងសភាវគតិរបស់យើងដែរ។ ការយល់ឃើញជាព្រឹត្តិការណ៍ ឬ*

---

[១៣] M. H. ABRAMS *A Glossary of Literary Terms,* op. cit., p.303.

*សកម្មភាពភ្លាមៗ ហើយនេះជារូបវន្តមាននៅក្នុងវង្វង់ឯកភាពដែលមានលក្ខណៈទូទៅត្រូវបានគេស្គាល់យ៉ាងច្បាស់នៃលក្ខខណ្ឌទង្វើ ឬព្រឹត្តិការណ៍នេះមានកម្រិត»*។ [១៤]

តាមការស្រាវជ្រាវរបស់លោកបណ្ឌិត **ឈុន ផារ៉េង** មន្ត្រីស្រាវជ្រាវនៅរាជបណ្ឌិត្យសភាកម្ពុជា នៃនាយកដ្ឋានទស្សនវិជ្ជា និងសង្គម នៃវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម បានសិក្សាបង្ហាញពីលក្ខណៈធម្មជាតិមនុស្សថា៖

ទស្សនៈទី១៖ បានអះអាងថា ធម្មជាតិរបស់មនុស្ស គឺអាក្រក់ ទស្សនៈនេះគាំទ្រដោយសាវ័កគ្រិស្តសាសនា មានសន្តបុគ្គលអូហ្គូសស្ទីនជាដើម។ ដោយសារតែភាពពោរពេញដោយអំពើបាបរបស់ពួកគេនោះ គ្រប់បុគ្គលទាំងអស់មានសារជាតិពុករលួយ ឬបាបពីកំណើតពីព្រោះមនុស្សបានទទួលមរតកគឺអំពើបាបពីបុព្វបុរសរបស់ពួកខ្លួន។

ទស្សនៈទី២៖ អះអាងថា ធម្មជាតិមនុស្សគឺល្អ ទស្សនៈនេះបានគាំទ្រនិងការពារយ៉ាងខ្លាំងក្លាដោយលោក រូស្សូ លោកជឿថាធម្មជាតិមនុស្សកើតមកល្អ ប៉ុន្តែអារ្យធម៌សង្គមទេដែលពុករលួយ អំពើពាលាអាវ៉ាសែ ហើយកែប្រែមនុស្សឱ្យទៅជាអាត្មានិយមក្រអឺក្រទម មិនទុកចិត្តគ្នា និងប្រទូសរ៉ាយ។ លោក ហ៊ើប៊ឺតស្ប៊ិន (Herber Spencer) បាននិយាយថា មាគ៌ានៃការវិវត្តគឺជាការប្រែប្រួលទៅរកភាពល្អប្រសើរជាង។ ដូច្នេះមនុស្សគួរតែឈរមកម្ខាង ហើយទុកឱ្យធម្មជាតិអភិវឌ្ឍន៍ ទៅរកគោលដៅរបស់វា ព្រោះបន្តិចម្តងៗ វានឹងនាំមកនូវការអភិវឌ្ឍទាំងស្រុងទៅលើសមត្ថភាពរបស់មនុស្ស និងការសម្របសម្រួលនឹងបរិស្ថានខ្លួនទៅរកសុខដុមរមនា។

ទស្សនៈទី៣៖ អះអាងថា ធម្មជាតិរបស់មនុស្សគឺអព្យាក្រឹត គឺមិនថាល្អហើយមិនថាអាក្រក់ដែរ ប៉ុន្តែប្រកបដោយសក្តានុពល ដ៏ធំធេងចំពោះអំពើល្អ និងអំពើអាក្រក់។ មិនដូចសត្វថ្នាក់ទាបផ្សេងៗនោះទេ មនុស្សមានទំនោរបត់បែនហើយមានសមត្ថភាពរៀនសូត្របថែមទៀត។ ការក្លាយទៅជាមនុស្សល្អ ឬអាក្រក់គឺជាលទ្ធផលនៃគំនិតរបស់គេ។ គេជាភាវៈនៃការគិត ជាភាវៈមានវិចារណញ្ញាណ។

ទស្សនៈទី៤៖ អះអាងថា ធម្មជាតិរបស់មនុស្ស គឺល្អផង និងអាក្រក់ផង។ ពុំមាននរណាម្នាក់មានសុក្រឹតភាពទាំងស្រុងឡើយ ព្រោះមនុស្សមានលក្ខណៈសភាវគតិស្រេកឃ្លាន និងតម្រេកតណ្ហាដូចសត្វ លើសតែវិចារណញ្ញាណប៉ុណ្ណោះ។[១៥]

ផ្នែកខ្លះនៃកំណាព្យច្បាប់ល្បើកថ្មី របស់កវីប្រជាជន អ្នកព្រះភិរម្យភាសាអ៊ូ ហៅក្រមង៉ុយ បានលើកឡើងមួយឃ្លាថា៖

រាជបារាំងសេស កូនកុំប្រហែស កុំថ្មមរូបកាយ
ដើរគិតដេកគិត ជួញជិតជួញឆ្ងាយ បើចង់សប្បាយ
ស្រេចនៅមានទ្រព្យ។

---

[១៤] Roy wood Sellars,Ph.D. *Critical Realism* New York, Rand Mcnally &Company, 1916, p.3.

[១៥] សូមមើល៖ ឈុន ផារ៉េង ***ទស្សនវិជ្ជាសង្គម*** រាជបណ្ឌិត្យសភាកម្ពុជា ឯកសារស្រាវជ្រាវ នាយដ្ឋានទស្សនវិជ្ជា និងសង្គម នៃវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ចុះផ្សាយថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣។

រាជហ្លួងពីមុន រកស៊ីរែកពន់ មានក្រតាមភ័ព្វ
រាជ្យលោកឥឡូវ ត្រូវខំឱ្យញាប់ តែខ្ជិលច្រើនជាប់
ខ្ពោះដៃខ្ពោះជើង។
តាំងពីឆ្នាំច ចាំជាតំណ ទំនិញឡើងថ្លៃ
ចងក្បិនឱ្យតឹង ប្រឹងកុំសំចៃ សញ្ចឹងយប់ថ្ងៃ
កុំឱ្យក្រខ្សត់។
បើចង់ស្រាលខ្លួន រៀនសូត្រឱ្យមួន ឱ្យមាំឱ្យស្ទាត់
កុំចេះស្ទាក់ស្ទើរ ល្ងីល្ងើឥតបទ បើចេះប្រាកដ
ប្រាក់រត់តាមហៅ។[១៦]

មនុស្សយើងជាច្រើនតែងមើលរំលងថា សុភមង្គល ឬក្ដីសុខខ្លួនថាមិនពឹងផ្អែកលើទ្រព្យឡើយ ប៉ុន្ដែវាគ្រាន់តែជាការលួងចិត្តរបស់យើងប៉ុណ្ណោះ។ បើទ្រព្យសម្បត្តិ មាសប្រាក់ មិនសំខាន់តើមនុស្សយើងរាល់ថ្ងៃខំប្រឹងដើម្បីអ្វី? ពិតណាស់មនុស្សខំប្រឹងប្រឹងគឺដើម្បីប្រយោជន៍(ទាំងសម្ភារៈ និងស្មារតី) ឱ្យតែរីករាយជាក្ដីសុខ មានទ្រព្យក៏ជាក្ដីសុខមិនអាចខ្វះបាន ខ្មែរក៏មានសុភាពសិតអប់រំផងដែរថា មនុស្សនឹងប្រាក់ យក្សនឹងសាច់ អាចម៍នឹងឆ្កែ។ ឯត្រង់ឃ្លាថា **បើចេះប្រាកដប្រាក់រត់តាមហៅ** វាជាការពិត និងមិនអាចប្រកែកបាន មនុស្សបើកាលណាមានចំណេះ មានជំនាញពិតច្បាស់លាស់នូវអ្វីដែលខ្លួនធ្វើ ប្រាក់នឹងអាចរកបាន។ ទោះបីជាធ្វើការឱ្យគេ ឬបើករបរខ្លួនឯង បើច្បាស់ហើយមិនខ្វះទេគេចង់បានគេត្រូវការ។

ស្នាដៃល្បើកចចក រឿងនេះបង្ហាញពីគំនិត ទស្សនៈ បង្ហាញពីចរិតធម្មជាតិ និងឥរិយាបថមនុស្សដែលឆ្លើយតបទៅនឹងបរិបទជុំវិញខ្លួន។ តួអង្គចចក តំណាង ធម្មជាតិនៃមនុស្ស ដែលតែងតែចង់បាននូវអ្វីដែលខ្លួនគ្មាន ឱ្យស្របតាមការប្រែប្រួលនៃសង្គម។ តួអង្គចចក តំណាងមនុស្សក្នុងសង្គមដែលតែងតែចង់បាននូវអ្វីដែលខ្លួនគ្មាន និងចង់បាននូវអ្វីល្អថ្មីសម្រាប់ខ្លួនឯង សារជាតិខ្លះរបស់មនុស្សគឺមិនពេញចិត្តនូវអ្វីដែលខ្លួនមាននោះទេ។ មនុស្សតែងតែចង់បានអ្វីដែលថ្មីរហូត មនុស្សបច្ចុប្បន្នរត់តាមការវិវត្តន៍នៃសង្គម។

**ជារួមធម្មជាតិនិយមនេះ ទាំងល្អ ទាំងអាក្រក់ វិជ្ជមាន អវិជ្ជមាន តាំងនៅក្នុងខ្លួនមនុស្សដោយចៀសមិនផុតឡើយ។ ធម្មជាតិមនុស្សគិតពីផលប្រយោជន៍ មានបាន ចង់ល្អ លោភលន់ ស្រេកឃ្លាន ចង់លើសគេ ចង់ល្អជាងគេ។**

### ឃ. អក្សរសិល្ប៍បែបចិត្តវិទ្យា (Psychological realism)

ជាអក្សរសិល្ប៍មួយប្រភេទ ដែលបង្ហាញពីស្ថានភាពផ្លូវចិត្ត សកម្មភាពទាំងអស់ដែលកើតឡើងនៅក្នុងរឿងគឺជាលទ្ធផលនៃគំនិត និងអារម្មណ៍ខាងក្នុងនៃតួអង្គ។ ទ្រឹស្ដីចិត្តវិទ្យានេះបង្ហាញពីបុគ្គលិក

---

[១៦] ពុទ្ធសាសនបណ្ឌិត្យ៖ *ច្បាប់ក្រមង៉ុយ* ជ.ង.ម ទំព័រទី៧។

លក្ខណៈរបស់មនុស្សមានសភាវគតិ និងបំណងប្រាថ្នាដោយមិនដឹងខ្លួនរបស់មនុស្ស ប្រតិកម្មអារម្មណ៍ដើរតួនាទីកាន់តែធំនៅក្នុងអាកប្បកិរិយា និងសកម្មភាព។

អ្នកនិពន្ធស្នាដៃប្រាកដនិយមបែបចិត្តវិទ្យានេះមានដូច Leo Tolstoy តាមរយៈស្នាដៃរឿង Anna Karenina លោក George Eliot ស្នាដៃ The Mill on the Floss លោក Henry James អ្នកនិពន្ធប្រលោមលោកជនជាតិអាមេរិកនិពន្ធរឿងប្រាកដនិយមខាងផ្លូវចិត្ត ប្រលោមលោករបស់គាត់បានស្វែងយល់ពីទំនាក់ទំនងគ្រួសារ សេចក្តីប្រាថ្នាស្នេហា និងការតស៊ូអំណាច។

ក្នុងស្នាដៃអក្សរសិល្ប៍ពុទ្ធនិយម មានស្នាដៃរឿងបដាចារ ដែលនិយាយរៀបរាប់ពីបញ្ហារបស់មនុស្ស និងសកម្មភាពឆ្លើយរបស់តួងអង្គទៅនឹងហេតុការណ៍ដែលបានកើតឡើង។ ស្នាដៃនេះបង្ហាញពីទ្រឹស្តីចិត្តវិទ្យាតាមរយៈតួអង្គបដាចារតាំងពីចាប់ផ្តើមស្រឡាញ់កូនឈ្នួលខ្លួនឯងមក។ ចិត្តវិទ្យាបង្ហាញថាក្តីស្រឡាញ់មិនរើស ភេទ អាយុ វណ្ណៈឡើយ សេចក្តីស្នេហាធ្វើឱ្យមនុស្សខ្វាក់ភ្នែក នេះជាហេតុនាំឱ្យនាងបដាចាររត់តាមកូនឈ្នួលព្រោះក្តីស្រឡាញ់ចោលឪពុកម្តាយ។ សុភាសិតខ្មែរ ឃ្លានឆ្ងាញ់ស្រឡាញ់ល្អមែនទែនទៅគ្មានអ្វីល្អ និងអាក្រក់នៅទីនេះទេ តាមអារម្មណ៍របស់មនុស្សបើស្រឡាញ់អ្នកណាចូលចិត្តអ្នកណា ទោះអ្នកនោះធ្វើអ្វីក៏ដោយក៏នៅតែស្រឡាញ់នៅតែល្អដដែរ។ ពេលមានទុក្ខ អារម្មណ៍មនុស្សនឹងនឹកដល់អ្វីមុនគេ? គឺពុកម៉ែ សួរថា តើបដាចារព្យាយាមមករកពុកម៉ែនៅពេលណា? នៅពេលមានទុក្ខនេះឯង។

**សរុបមក ចិត្តវិទ្យានេះ អ្នកនិពន្ធចង់បង្ហាញពីការសម្រេចចិត្តរបស់មនុស្ស ស្ថិតក្នុងស្ថានភាពណាមួយ ជំណាក់កាលណាមួយ ដែលមនុស្សសម្រេចចិត្តហ៊ាន ឬបញ្ចេញសកម្មភាពដែលមានអន្តរកម្មនឹងសង្គមដែលគាត់កំពង់ស្ថិតនៅ។**

## ៤. សន្និដ្ឋាន

ទស្សនៈប្រាកដនិយម ការបញ្ចប់រឿងគឺបើកចំហ រឿងខ្លះបញ្ចប់ដោយមិនដោះស្រាយជម្លោះទាំងអស់ ឬផ្តល់ចម្លើយច្បាស់លាស់ទេ គឺនេះទុកឱ្យអ្នកអានសញ្ជឹងគិតខ្លួនឯង និងទទួលស្គាល់បញ្ហាប្រឈម និងការលំបាកក្នុងសង្គម រៀនពីអ្វីមួយដែលមានតម្លៃពីបទពិសោធរបស់ពួកគេ។

ទស្សនៈប្រាកដនិយមសង្កត់ធ្ងន់ទៅលើលក្ខណៈវដ្តនៃជីវិត ប្រឈមមុខកាលៈទេសៈរបស់ពួកគេ ឬទទួលយកដែនកំណត់នៃស្ថានភាពរបស់ពួកគេ ហើយមនុស្សអាចមានស្មារតីទទួលខុសត្រូវជាងមុនសម្រាប់ខ្លួនឯង និងអ្នកដទៃ មានការសម្រេចចិត្តដោយមិនស្ទាក់ស្ទើរ ក្នុងស្ថានភាពដែលមានស្រាប់តាមរយៈស្នាដៃដែលបានកើតឡើងក្នុងទស្សនៈប្រាដកនិយម។

អ្នកនិពន្ធសម័យទំនើបបច្ចុប្បន្ន គួរបង្កើតស្នាដៃដែលមានលក្ខណៈប្រាកដនិយមគ្រប់ជ្រុងជ្រោយប្រកដដោយតក្កវិជ្ជាច្បាស់លាស់ទើបរក្សាស្នាដៃបានយូរអង្វែង។ ស្ថានភាពប្រាកដនិយម ពេលខ្លះសង្គមមិនទទួលស្គាល់ ប៉ុន្តែមនុស្សក្នុងសង្គមបែរជាជិតដាម និងចង់ចាំរឿងរ៉ាវអសីលធម៌ ឬបញ្ហាមិនគប្បីទាំងនោះ ក៏ដោយសារតែបញ្ហាខ្លះគឺវាសារជាតិ និងសភាវគតិរបស់មនុស្ស ហេតុនេះ វានៅនឹងកើតឡើងជាមួយសង្គមមនុស្សជរាប ដែលហៅថាលក្ខណៈប្រាកដនិយមនេះឯង។

## គន្ថនិទ្ទេស


### ក. អត្ថបទជាភាសាខ្មែរ

១. កាង ក្បុងហ៊ី៖ *លក្ខណៈប្រលោមនិយម និងតថៈនិយមតាមរយៈអក្សរសិល្បខ្មែរដើមសតវត្សទី២០* ភ្នំពេញ និក្ខេបបទថ្នាក់បណ្ឌិត រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០១១។

២. ឃីង ហុកឌី៖ *មាលីបទអក្សរសិល្បខ្មែរសតវត្សទី១៩* ភ្នំពេញ បោះពុម្ពផ្សាយដោយបណ្ណាគារអង្គរ ឆ្នាំ២០០២

៣. ពៅ សាមី ៖ *ស្វែងយល់ពីតថៈនិយមក្នុងអក្សរសិល្បខ្មែរនាសតវត្សទី២០ តាមរយៈប្រលោមលោកលេចធ្លោមួយចំនួន* ភ្នំពេញ ឯកសារប្រើប្រាស់ផ្ទៃក្នុង ឆ្នាំ១៩៩៧។

៤. ម៉ុញ សារី៖ *ប្រជុំកវីអ្នកនិពន្ធ* ភ្នំពេញ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ឆ្នាំ២០០៧។

៥. វ៉ាន់ ឌីកាអុន៖ *អក្សរសិល្បបារាំងសតវត្សទី១៩* ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ២០១០។

៦. សរ សារុន៖ *វប្បធម៌ និងអរិយធម៌ភាគ១ ភាគ២* ភ្នំពេញ បណ្ណាគារពន្លឺវិទ្យា ឆ្នាំ១៩៧០។

៧. សួង សារុន៖ *លទ្ធិកុំមុយនីស្តនិយមវិទ្យាសាស្ត្រ* ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ១៩៨៨។

៨. សំ ពិសិដ្ឋ៖ *និន្នាការអ្នកនិពន្ធប្រលោមលោកពាក្យរាយខ្មែរ ឆ្នាំ១៩៥៣-១៩៧០* ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ២០១៥។

៩. ស៊ុំ ឈុំឡុង៖ *ទស្សនាទានអប់រំសង្គមតាមរយៈតំណាលកថា* ភ្នំពេញ រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ ២០១១។

១០. ហាក់ វ៉ាន់ដារា៖ *អក្សរសិល្បខ្មែរ១៩៧០-១៩៧៥* ភ្នំពេញ បណ្ណាគារអង្គរធំ ឆ្នាំ២០០៥។

១១. ហ៊ុន គីមសៀ៖ *មូលដ្ឋានយល់ដឹងពីអក្សរសាស្ត្រខ្មែរ* ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ១៩៦៣។

### ខ. ជាភាសាបរទេស

១២. Andrew Bennett and Nicholas Royle*: Introduction to Literatuer, Criticism and Theory*, United Kingdom 2004.

១៣. Generesius Blomen Nomer: *Realism in Gustave Flaubert is Madame Bovary*.2001.

១៤. Galens, David: *Literary Movements for Students*, Detroit Thompson,2002.

១៥. Glazener, Nancy: Reading for Realism: *The History of Literary Institution*. Durham, Duke University Press. 1997.

១៦. Harriet Martineau et al: *The Positive Philosophy of Auguste Comte*, London George Bell &Sons, 1896.

១៧. Peter Singer: *Marx*, New York, Oxford University Press, 1980.

១៨. Raman Selden. Peter Widdowson. Peter Brooker: *A Reade is Gude to Ccontemporaty Literary Theory* United Kingdom 2005.

១៩. Terry Eagleton: *Literary Theory*, The University of Minnesota Press 2003.

# តួនាទីស្ត្រីកម្ពុជានៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត នៅទីស្តីការគណៈរដ្ឋមន្ត្រីពីឆ្នាំ២០១៣ ដល់ឆ្នាំ២០២៤

បេក្ខជនបណ្ឌិត៖ **សរ សំឡូត**

ជំនាញ៖ **រដ្ឋបាលសាធារណៈ**

## ១. សេចក្តីផ្តើម

មនុស្ស ត្រូវបានកំណត់ថា ជាអាទិភាពឈរនៅលើលំដាប់ទី១ ក្នុងចំណោមអាទិភាពទាំង៥ រួមមាន មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា យោងតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សម្រាប់ឆ្លើយតបក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព និងការកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាជាប្រទេសមានចំណូលខ្ពស់ក្នុងឆ្នាំ២០៥០។ ក្នុងន័យនេះ ការចូលរួមស្មើគ្នារវាងស្ត្រីនិងបុរស ជាកត្តាពុំអាចខ្វះបានក្នុងការសម្រេចបានគោលដៅអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ជាពិសេសតួនាទីរបស់ស្ត្រីនៅក្នុងការចូលរួមដោយស្មើភាពជាមួយនឹងបុរស នៅក្នុងធ្វើសេចក្តីសម្រេចចិត្តប្រកបដោយគុណភាព និងប្រសិទ្ធភាពក្នុងមុខតំណែងជាអ្នកដឹកនាំធ្វើគោលនយោបាយសង្គមសំខាន់ៗ និងកិច្ចខិតខំប្រឹងប្រែងបង្កើនចំនួនស្ត្រីដែលមានឥទ្ធិពលក្នុងស្ថាប័ន ក្នុងការធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗ សម្រាប់គាំទ្រគោលដៅកែទម្រង់ដ៏វែងឆ្ងាយ និងស៊ីជម្រៅរបស់កម្ពុជា ដែលជាកាតាលីករជួយបង្កើនល្បឿនឱ្យសម្រេចបាននូវប្រសិទ្ធភាពនៃទំនាក់ទំនងនៅក្នុងសមភាពយេនឌ័រ និងឈានឆ្ពោះទៅរកការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ដោយមើលឃើញពីសារៈសំខាន់នៃសមភាពយេនឌ័រ ពីព្រោះថា វាគឺជាបញ្ហាមួយក្នុងចំណោមបញ្ហាឈានមុខគេជាច្រើននាពេលបច្ចុប្បន្នបានជាប្រធានបទ **"តួនាទីស្ត្រីកម្ពុជាក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅទីស្តីការគណៈរដ្ឋមន្ត្រីពីឆ្នាំ២០១៣ដល់២០២៤"** ត្រូវបានលើកយកមកសិក្សាស្រាវជ្រាវដោយផ្តោតលើបញ្ហាបីរួមមាន បញ្ហាការពិនិត្យពីស្ថានភាពទូទៅនៃយេនឌ័រ កត្តាដែលជួយគាំទ្រ និងជំរុញឱ្យស្ត្រីទទួលបានការនូវឱកាសការងារចូលរួមកាន់តែច្រើនក្នុងជួរមន្ត្រីរាជការ និងជួរថ្នាក់ដឹកនាំ និងកត្តាដែលធ្វើឱ្យមានវិសមភាពយេនឌ័រនៅក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្តនៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍខ្លួន គ្រួសារ និងសង្គមជាតិ។

ដើម្បីចូលរួមសម្រេចបានគោលដៅនេះ និក្ខេបបទ **"តួនាទីស្ត្រីកម្ពុជាក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅទីស្តីការគណៈរដ្ឋមន្ត្រីពីឆ្នាំ២០១៣ដល់ឆ្នាំ២០២៤"** ដែលទទួលបានការត្រួតពិនិត្យនិងវាយតម្លៃ២ដំណាក់កាលរួចមកហើយ ពីមជ្ឈមណ្ឌលបណ្តុះបណ្តាល និងស្រាវជ្រាវនៃរាជបណ្ឌិត្យសភាកម្ពុជា ក្នុងការលើកកម្ពស់ចំណេះដឹងយេនឌ័រក្នុងរដ្ឋបាលសាធារណៈរបស់សិស្សនិស្សិត និងប្រជាពលរដ្ឋគ្រប់វ័យដែលស្រឡាញ់ការសិក្សាស្រាវជ្រាវពេញមួយជីវិត ការពង្រឹងសមត្ថភាពការប្រកួតប្រជែង ការផ្សព្វផ្សាយ ជាពិសេសការចូលរួមធ្វើឱ្យកិត្យានុភាពរបស់ប្រទេសជាតិយើង "កម្ពុជា

ឆ្ពោះទៅការលើកកម្ពស់សន្ទស្សន៍អភិបាលកិច្ចល្អ ឱ្យកាន់តែមានភាពប្រសើរនិងទទួលបានចំណាត់ល្អ ដោយចាប់ផ្តើមពីការផ្តល់ឱកាស ការគាំទ្រ ការទទួលស្គាល់តម្លៃ និងការទទួលយកនៃការបង្ហាញពីគំនិតនៃការចូលរួមស្មើភាពគ្នារបស់ស្ត្រី និងបុរសនៅក្នុងតួនាទីនៃការធ្វើសេចក្តីសម្រេចលើគ្រប់កម្រិតទិដ្ឋភាព និងទស្សនវិស័យក្នុងការអភិវឌ្ឍប្រទេសជាតិ។

យ៉ាងណាមិញស្ត្រីកម្ពុជាត្រូវមានចំណេះដឹង និងសមត្ថភាពជាមូលដ្ឋានសំខាន់ៗ ដើម្បីអាចក្លាយជាធនធានដ៏រឹងមាំតែមិនទន់ជ្រាយដែលអាចទាញយកប្រយោជន៍ជាអតិបរមាពីសន្តិភាព និងការអភិវឌ្ឍ ដើម្បីត្រៀមជានិច្ចនៅក្នុងប្រកួតប្រជែងជាមួយបុរសក្នុងការដណ្តើមយកនូវឱកាសការងារនិងតួនាទីសំខាន់នៅមិនត្រឹមតែក្នុងវិស័យសាធារណៈ ប៉ុន្តែថែមទាំងវិស័យឯកជន ក៏ដូចជាសង្គមស៊ីវិលផងដែរ។ ស្ត្រីកម្ពុជាមិនត្រឹមតែជាស្ត្រីដែលចេះប្រើប្រាស់នូវសក្តានុពលភាពដ៏រឹងមាំ និងខ្លាំងពូកែដែលមានភាពអត់ធ្មត់ខ្ពស់ពីធម្មជាតិនិងកំណើតដែលបានផ្តល់ឱ្យ ក៏ប៉ុន្តែស្ត្រីខ្លួនឯងត្រូវមានភាពជឿជាក់និងអាចប្រើប្រាស់សមត្ថភាពដែលបានសិក្សារៀនសូត្រ និងសន្សំទុកពីសាលាតាំងពីតូចដោយចំគោលដៅប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងការទទួលខុសត្រូវខ្ពស់ដោយពុំចាំបាច់រងចាំសុំការលើកលែងនិងសម្រួលលក្ខខណ្ឌឬរងចាំសំណាងមកដល់នោះទេ ប៉ុន្តែស្ត្រីត្រូវហ៊ានតស៊ូដើម្បីសម្រេចបាននូវសិទ្ធិសេរីភាព សមភាព ស្របតាមគោលបំណង គោលដៅនិងសុបិនដែលខ្លួនមាន។ ចំណេះដឹង និងសមត្ថភាពដែលស្ត្រីមាន និងអាចជួយទៅដល់ការកសាងសេដ្ឋកិច្ចសង្គមបានយ៉ាងសកម្មប្រកបដោយភាពជឿជាក់ព្រមទាំងអាចទប់ស្កាត់នឹងឆ្លើយតបនឹងបញ្ហាប្រឈមនានាដែលមានជាយថាហេតុ។

ដោយមើលឃើញពីភាពចាំបាច់និងសារៈសំខាន់នេះ ទើបនិក្ខេបបទរបស់ស្មេរមួយនេះបានត្រូវបានរៀបចំ ចងក្រង និងសិក្សាស្រាវជ្រាវឡើងដើម្បីកំណត់អំពីសូចនាករ អថេរ ព្រមទាំងកត្តាទាំងឡាយដែលជាឧបសគ្គជះឥទ្ធិពលដល់ភាពជោគជ័យ និងគម្លាតរបស់ស្ត្រីធៀបជាមួយបុរស ក្នុងការឈោងចាប់យកនូវសុបិនធំរបស់ខ្លួនដែលអាចធ្វើបានទាំងព្រមនូវតួនាទីតូចជួយទៅដល់គ្រួសារ និងតួនាទីធំនៅក្នុងសង្គម និងលើឆាកអន្តរជាតិ។

ស្មេរសង្ឃឹមថា អ្នកពាក់ព័ន្ធទាំងអស់នឹងចូលរួមជួយផ្សព្វផ្សាយបន្តនូវគំនិតល្អៗដែលមាននៅក្នុងការសិក្សាស្រាវជ្រាវនេះក្នុងការពង្រឹងសមត្ថភាពរបស់ស្ត្រី ក្នុងគ្រប់រូបភាពដើម្បីចូលរួមប្រែក្លាយសង្គមកម្ពុជាទៅជាសង្គមដែលការផ្លាស់ប្តូរផ្នត់គំនិតយល់ដឹងស៊ីជម្រៅពីយេនឌ័រ និងជានាប្រសិទ្ធភាពនៃការចូលរួមពេញលេញ និងឱកាសស្មើភាពក្នុងភាពដឹកនាំគ្រប់កម្រិតនៃការសម្រេចចិត្តនយោបាយសេដ្ឋកិច្ចនិងជីវិតសាធារណៈ ដោយស្មើមុខស្មើមាត់ដ៏រស់រវើករវាងស្ត្រីនិងបុរសឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព។

## ២. និយមន័យ

### ២.១. តួនាទី

**"តួនាទី"** គឺជាក្របខ័ណ្ឌសម្រាប់ការសំគាល់ និងវិភាគពីរបៀបដែលបុគ្គលមានឥរិយាបទនៅក្នុងសង្គមដោយផ្អែកលើតួនាទីដែលបានកំណត់របស់ពួកគេ។

**"តួនាទី"** សំដៅលើសំណុំនៃការរំពឹងទុក ទំនួលខុសត្រូវ និងបទដ្ឋានដែលពាក់ព័ន្ធជាមួយនឹងមុខតំណែង ឬអត្តសញ្ញាណសង្គមជាក់លាក់មួយ។

**"តួនាទី"** តួនាទីសំដៅទៅលើការពិនិត្យ ពិចារណាមើល ថាតើតួនាទីទាំងនេះមានឥទ្ធិពលលើអាកប្បកិរិយា របស់បុគ្គលម្នាក់ៗ ការសម្រេចចិត្ត និងអន្តរកម្មជាមួយអ្នកដទៃក្នុងសង្គម។

នៅពីក្រោយ **"តួនាទី"** ជាសកម្មភាពរបស់មនុស្សត្រូវបានដឹកនាំដោយតួនាទីសង្គមដែលពួកគេកាន់កាប់ដែលជារឿយៗត្រូវរៀបចំឡើងដោយបទដ្ឋាន និងការរំពឹងទុកដែលកំណត់ដោយសង្គម។ តួនាទីទាំងនេះជាធម្មតាត្រូវបានចងភ្ជាប់ទៅនឹងមុខតំណែងជាក់លាក់នៅក្នុងប្រព័ន្ធសង្គម (ឧ. ឪពុកម្តាយ គ្រូបង្រៀន ប្រធាន) ហើយបុគ្គលជាញឹកញាប់ធ្វើឱ្យមានតុល្យភាពតួនាទីជាច្រើនក្នុងពេលតែមួយ ដែលអាចបង្កើតជម្លោះ (ជម្លោះតួនាទី) ឬភាពតានតឹង (ភាពតាតឹងតួនាទី) ។

គោលគំនិតសំខាន់ៗនៃតួនាទីរួមមានៈ

- **ការរំពឹងទុកលើតួនាទី៖** គឺជាបទដ្ឋានទាក់ទងនឹងរបៀបដែលបុគ្គលក្នុងតួនាទីជាក់លាក់មួយគួរមានឥរិយាបទ។
- **ការអនុវត្តតួនាទី៖** ជារបៀបដែលបុគ្គលមានឥរិយាបទក្នុងតួនាទីរបស់ពួកគេ ដែលអាចស្របគ្នា ឬផ្ទុយទៅនឹងការរំពឹងទុករបស់សង្គម។
- **ជម្លោះតួនាទី៖** ជម្លោះតួនាទីកើតមាននៅពេលដែលបុគ្គលម្នាក់ប្រឈមមុខនឹងការរំពឹងទុកដែលផ្ទុយគ្នាពីតួនាទីជាច្រើន (ឧ. ជាឪពុកម្តាយ និងនិយោជិតក្នុងពេលដំណាលគ្នា)។
- **តួនាទីតឹងតែង** (Role Strain)៖ តួនាទីតឹងតែងតែងតែជួបប្រទះនៅពេលដែលតម្រូវការនៃតួនាទីតែមួយគឺលើសលប់។
- **តួនាទីអត្តសញ្ញាណ** (Role Identity): គឺជារបៀបដែលបុគ្គលរៀបចំតួនាទីដែលខ្លួនដើរតួបង្កើតជាផ្នែកនៃគំនិតខ្លួនឯង ឬអត្តសញ្ញាណរបស់ពួកគេ។

និយមន័យផ្អែកលើវិទ្យាសាស្ត្រនយោបាយ តួនាទីត្រូវបានប្រើប្រាស់ដើម្បីពន្យល់ពីរបៀបដែលមេដឹកនាំនយោបាយ ឬរដ្ឋធ្វើសកម្មភាពដោយផ្អែកលើតួនាទីដែលពួកគេយល់ថាខ្លួនមាននៅក្នុងប្រព័ន្ធអន្តរជាតិ ដូចជាការធ្វើជាមេដឹកនាំក្នុងតំបន់ អ្នករក្សាសន្តិភាព ឬមហាអំណាចសកល។ មេដឹកនាំ និងប្រទេសត្រូវបានជះឥទ្ធិពលដោយតួនាទីរបស់ពួកគេ ដែលកំណត់គោលនយោបាយបរទេស និងក្នុងស្រុក និងអន្តរកម្មរបស់ពួកគេជាមួយរដ្ឋផ្សេងទៀត។

**"តួនាទី"** ក៏មានការឱ្យនិយមន័យដោយផ្អែកលើការប្រសព្វជាមួយចិត្តវិទ្យា សង្គមវិទ្យា និងទំនាក់ទំនងអន្តរជាតិផងដែរ ដោយផ្តល់ការយល់ដឹងអំពីអាកប្បកិរិយារបស់មនុស្សនៅក្នុងប្រព័ន្ធសង្គមដែលមានរចនាសម្ព័ន្ធនិងតួនាទីប្រសព្វគ្នាច្រើន។

## ២.២. "តួនាទីស្ត្រីនៅក្នុងការសម្រេចចិត្ត"

ការសម្រេចចិត្តមានច្រើនដូចជាជម្រើសសមហេតុផល សនិទានភាពជាប់ព្រំដែន និងស្ត្រីនិយម។ ចំពោះតួនាទីស្ត្រីនៅក្នុងការសម្រេចចិត្តក៏មានច្រើនដែរដូចជា ស្ត្រីក្នុងការសម្រេចចិត្តសាជីវកម្ម និងនយោបាយ ការរិះគន់ស្ត្រីនៅក្នុងការសម្រេចចិត្តបែបប្រពៃណី ស្ត្រីក្នុងស្ថាប័នធ្វើការសម្រេចចិត្តជាសកល និងស្ត្រីក្នុងការវិវត្តន៍ និងទំនាក់ទំនងជាមួយនឹងប្រវត្តិសាស្ត្រតាមសម័យកាលនិងដំណាក់ជាច្រើន។

## ២.២.១. ភាពខុសគ្នារវាងយេនឌ័រនៅក្នុងរបៀបឬរចនាបទនៃការសម្រេចចិត្ត

ភាពខុសគ្នារវាងយេនឌ័រនៅក្នុងការសម្រេចចិត្តមានដូចជា ផ្អែកលើការសិក្សាពីផ្នែកចិត្តសាស្ត្រ ស្ត្រី និងសហការធ្វើការសម្រេចចិត្ត និងការបដិសេធហានិភ័យជៀបនឹងទំនោរទទួលយកហានិភ័យ។ តាមរយៈ ការពិនិត្យផ្អែកលើអក្សរសាស្ត្រ មានការពិភាក្សាអំពីទិដ្ឋភាពមួយចំនួននៃភាពខុសគ្នារវាងយេនឌ័រនៅក្នុងដំណើរការការងារ ភាពជាអ្នកដឹកនាំ និងការសម្រេចចិត្ត។ ស្ត្រីចាប់អារម្មណ៍លើទំនាក់ទំនងច្រើនជាងកិច្ចការ។ បុរសចូលចិត្តបង្កើតទំនាក់ទំនងនៅពេលពួកគេកំពុងបំពេញភារកិច្ច។ ស្ត្រីតែងតែចូលចិត្តពិភាក្សាអំពីជម្រើសខ្លាំងៗ មុនពេលឈានដល់ការសម្រេចចិត្ត។ បុរសហាក់ដូចជាចូលចិត្តការសញ្ជឹងគិតស្ងាត់។ ទាក់ទងនឹងការប្រាស្រ័យទាក់ទងគ្នា ស្ត្រីមិនត្រឹមតែចូលចិត្តពិភាក្សារឿងប៉ុណ្ណោះទេ ប៉ុន្តែការប្រាស្រ័យទាក់ទងគ្នាដោយគ្មានពាក្យសំដីអាចរួមបញ្ចូលការប៉ះភ្នែកច្រើន ងក់ក្បាលដើម្បីបង្ហាញពីការព្រមព្រៀង និងការឈរទល់មុខគ្នា។ សម្រាប់បុរសខ្លះ រឿងទាំងនេះខ្លះអាចគំរាមកំហែង។ បុរសដែលនិយាយជាមួយគ្នាច្រើនតែនៅម្ខាង នៅមុំមួយដែលជាទីតាំងដែលស្រួលជាងសម្រាប់ពួកគេ។ ស្ត្រីអាចបកស្រាយរឿងនេះថាជាការសម្ងាត់ ឬមិនចាប់អារម្មណ៍។ ផ្នែកមួយទៀតដែលមានភាពខុសគ្នាខាងយេនឌ័រក្នុងការសម្រេចចិត្តគឺនៅក្នុងផ្នែកនៃការសុំជំនួយពីអ្នកដទៃ ស្ត្រីធ្វើការសម្រេចចិត្តនេះលឿនជាងបុរស។ ជាឧទាហរណ៍ ការសិក្សាមួយត្រូវបានធ្វើឡើងលើបុគ្គលិកដែលកុំព្យូទ័រនៅកន្លែងធ្វើការបានឆ្លងមេរោគspyware ៦៤% នៃស្ត្រីបានទូរស័ព្ទទៅផ្នែក IT ដើម្បីសុំជំនួយ ហើយមានតែបុរស ៣០ភាគរយប៉ុណ្ណោះ ដែលបានធ្វើដូច្នេះ (ភាពខុសគ្នារវាងយេនឌ័រក្នុងការសម្រេចចិត្ត)។ ការសិក្សាមួយផ្សេងទៀតត្រូវបានធ្វើឡើងដោយ Muyinudeen and Elsadig (២០០៨) នៅប្រទេសម៉ាសសឡេស៊ី ហើយលទ្ធផលបានបង្ហាញថា "អ្នកគ្រប់គ្រងបុរសម៉ាឡេស៊ីមានរបៀបធ្វើការសម្រេចចិត្តតាមការណែនាំយុទ្ធសាស្ត្រ និងប្រថុយប្រថាន ចំណែកអ្នកគ្រប់គ្រងស្ត្រីរបស់ពួកគេច្រើនក្នុងលទ្ធិប្រជាធិបតេយ្យ ការចូលរួម និងធម្មតា ស្ទើលធ្វើការសម្រេចចិត្តដោយទទួលយក ការយល់ស្របនិងស្ទាក់ស្ទើរជាងសមភាគីរបស់ពួកគេ។ សហគ្រិនម៉ាឡេស៊ីគឺជាអ្នកប្រថុយប្រថានច្រើនជាងសមភាគីស្ត្រីរបស់ពួកគេជាទូទៅ"។ ការសិក្សាដែលធ្វើឡើងដោយ Wing et al. (២០១០) បានបង្ហាញថា ស្ត្រីចំណាយពេលច្រើនលើការសម្រេចចិត្តជាងបុរស។ ការសិក្សាថ្មីមួយដែលធ្វើឡើងនៅប្រទេសកេនយ៉ាបានពិនិត្យលើឥទ្ធិពលនៃភាពចម្រុះនៃក្រុមប្រឹក្សាភិបាល និងការអនុវត្តយ៉ាងរឹងមាំ ហើយលទ្ធផលបានបង្ហាញថា ទំនាក់ទំនងរវាងយេនឌ័រ និងការអនុវត្តរឹងមាំគឺមានភាពវិជ្ជមាន ដែលនេះមានន័យថាក្រុមប្រឹក្សាភាពចម្រុះយេនឌ័រដំណើរការបានល្អប្រសើរ ដូចការវាស់វែងដោយ ROA (Ombaba, ២០១៦)។ យោងតាមរបាយការណ៍ McKinsey ឆ្នាំ២០០៦ រចនាប័ទ្មភាពជាអ្នកដឹកនាំរបស់ស្ត្រី មិនដូចរចនាប័ទ្មបុរសទេ គឺផ្អែកលើមនុស្សច្រើន ហើយអាចត្រូវបានពិពណ៌នាថាជាគំរូ។ វាត្រូវបានបញ្ជាក់ផងដែរថា ស្ត្រីផ្តល់នូវការរំពឹងទុកច្បាស់លាស់ និងរង្វាន់។ ដូចគ្នានេះដែរ ការសិក្សាមួយពីឆ្នាំ២០១២ ដែលរៀបចំដោយ Zenger Folkman បង្ហាញថា ស្ត្រីត្រូវបានគេវាយតម្លៃថាមានសមត្ថភាពជាង នៅពេលចាប់ផ្តើមគំនិត ការអភិវឌ្ឍន៍ខ្លួនឯង ភាពស្មោះត្រង់ និងការបើកបរដើម្បីទទួលបានលទ្ធផល។ ស្ត្រីមានភាពប្រថុយប្រថានជាង (Weber, Blais, and Betz, 2002) មានភាពរសើបក្នុងសង្គមខ្ពស់

និងមានប្រតិកម្មដោយអារម្មណ៍។ បុរសមានទំនុកចិត្តច្រើនជាង មានសុទិដ្ឋិនិយមជាង និងមានប្រតិកម្មដោយសកម្មភាព (Patel, ២០១៣)។ ស្ត្រីមានប្រតិកម្មផ្លូវចិត្តច្រើនជាងបុរស ជាពិសេសនៅក្នុងស្ថានភាពអវិជ្ជមាន។ ដូច្នេះនៅពេលដែលត្រូវការការឆ្លើយតបជាបន្ទាន់ បុរសមានប្រតិកម្មដោយសកម្មភាព ចំណែកឯប្រតិកម្មរបស់ស្ត្រីគឺមានអារម្មណ៍ (Gorska, ២០១៦)។ អ្នកស្រាវជ្រាវជាច្រើនទាក់ទងនឹងភាពជាបុរសជាមួយនឹងរចនាប័ទ្មភាពជាអ្នកដឹកនាំ ដែលផ្តោតលើភារកិច្ច និងភាពជាស្ត្រីជាមួយនឹងរចនាប័ទ្មភាពជាអ្នកដឹកនាំដែលផ្តោតលើទំនាក់ទំនង (Shanmugam et al )។ យោងទៅតាម Eagly & Johannesen-Schmidt (២០០១) បុរសគឺកាន់តែមានការអះអាង មានមហិច្ឆតា ឈ្លានពាន ឯករាជ្យ មានទំនុកចិត្តលើខ្លួនឯង និងមានការប្រកួតប្រជែងក្នុងការសម្រេចចិត្ត និងដំណើរការការងារ។ មនុស្សស្រីកាន់តែស្រលាញ់ ចេះជួយគ្នា ចិត្តល្អ ចេះអាណិតអាសូរ ចេះប្រាស្រ័យទាក់ទងគ្នា និងសុភាព នៅក្នុងស្ថានភាពការងារ ស្ត្រីទទួលយកមុខតំណែងរបស់អ្នកដទៃ គាំទ្រអ្នកដទៃ និងរួមចំណែកដល់ដំណោះស្រាយនៃបញ្ហាទំនាក់ទំនង និងអន្តរបុគ្គល។ ការស្រាវជ្រាវដ៏គួរឱ្យចាប់អារម្មណ៍មួយផ្សេងទៀតបានបង្ហាញថាស្ត្រីមិនពឹងផ្អែកលើវិចារណញាណញឹកញាប់ជាងបុរសទេ ដូច្នេះ ស្ត្រីគឺគ្រាន់តែជាការជំរុញទិន្នន័យ និងការវិភាគដូចបុរស ប្រសិនបើមិនមានច្រើនជាងនេះទេ។ នៅក្នុងគំរូនៃការសិក្សាចំនួន ៣២ ដែលមើលពីរបៀបដែលបុរស និងស្ត្រីគិតអំពីបញ្ហា ឬធ្វើការសម្រេចចិត្ត ការសិក្សាចំនួន ១២ បានរកឃើញថា ស្ត្រីបានទទួលយកវិធីសាស្ត្រវិភាគញឹកញាប់ជាងបុរស មានន័យថាស្ត្រីបានងាកទៅរកទិន្នន័យជាប្រព័ន្ធ ខណៈដែលបុរសមានទំនោរចង់ទៅជាមួយនឹងវៀនរបស់ពួកគេ ការចាប់អារម្មណ៍ ឬ

ប្រតិកម្មវិចារណញាណ។ ការសិក្សាចំនួន ២០ ផ្សេងទៀតបានរកឃើញថា មិនមានភាពខុសគ្នារវាងស្ទីលនៃការគិតរបស់បុរស និងស្ត្រីនោះទេ។ មិនមានការសិក្សាណាមួយបានរកឃើញថា ស្ត្រីមានទំនោរទៅរកភាពវៃឆ្លាតក្នុងរចនាប័ទ្មនៃការសម្រេចចិត្តរបស់ពួកគេ (Caprino, ២០១៦) ។ [១]

**អ្នកដឹកនាំ និងបុគ្គលិកត្រូវធ្វើសេចក្ដីសម្រេចលើការងារជាច្រើនដូចជា**




**ដំណើរការនៃការធ្វើសេចក្ដីសម្រេច**




---

[១] https://www.researchgate.net/publication/340592891_Gender_Differences_in_Decision-making_and_Leadership_Evidence_from_Armenia

តាមបណ្តាទស្សនៈខាងលើយើងអាចនិយាយបានថា តួនាទីក្នុងការធ្វើរសេចក្តីសម្រេច គឺពិតជាតួនាទីដែលអាចសម្រេចយកជម្រើសល្អបំផុត ក្នុងចំណោមជម្រើសនានាដែលមាន ព្រមទាំងរួមបញ្ចូលផងដែរនូវការសម្រេចចិត្តដែលមានតុល្យភាពយេនឌ័រនិងសារៈសំខាន់នៃភាពចម្រុះ។ ដូច្នេះ អ្នកដឹកនាំត្រូវមានសមត្ថភាពក្នុងការធ្វើសេចក្តីសម្រេចដែលល្អ និងមានប្រសិទ្ធភាពដើម្បីឈានទៅសម្រេចបានគោលបំណង និងគោលដៅរបស់ស្ថាប័ន។ ការធ្វើសេចក្តីសម្រេចចិត្ត កំណត់នូវប្រសិទ្ធភាពស្ថាប័ន ការសម្រេចត្រឹមត្រូវនាំទៅរកការរីកចម្រើននិងជួយឱ្យស្ថាប័នជោគជ័យ ការសម្រេចចិត្តខុស នាំឱ្យការងារបរាជ័យ និងធ្វើឱ្យស្ថាប័នកាន់តែខ្សោយទៅៗ ហើយអ្នកដឹកនាំធ្វើសេចក្តីសម្រេចប្រកបដោយគុណភាពនឹងធ្វើឱ្យបុគ្គលិកពេញចិត្តនឹងការងាររបស់ខ្លួន ដែលនាំឆ្ពោះទៅជោគជ័យក្នុងការបំពេញភារកិច្ចដែលអ្នកដឹកនាំបានប្រគល់ឱ្យ។

## ២.៣. បញ្ហាប្រឈមនិងការរំពឹងទុកតួនាទីស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅទីស្តីការគណៈរដ្ឋមន្ត្រី

### ២.៣.១. បញ្ហាប្រឈម

ទោះបីជាមានការរីកចម្រើនក៏ដោយ ស្ត្រីនៅក្នុងទីស្តីការគណៈរដ្ឋមន្ត្រី តែងតែប្រឈមមុខនឹងបញ្ហាវប្បធម៌ និងស្ថាប័ន។ តួនាទីយេនឌ័រប្រពៃណី ការរំពឹងទុកក្នុងសង្គម និងការចូលប្រើប្រាស់បណ្តាញថាមពលក្រៅផ្លូវការមានកម្រិតអាចរារាំងសមត្ថភាពរបស់ពួកគេ ក្នុងឥទ្ធិពលលើការសម្រេចចិត្តគោលនយោបាយសំខាន់ៗ។

អ្នកដឹកនាំស្ត្រីជាញឹកញាប់ត្រូវរុករកបរិយាកាសនយោបាយដែលនៅតែជាបុរស ដែលសំឡេងរបស់ពួកគេមិនអាចតែងតែមានទម្ងន់ស្មើគ្នា បើប្រៀបធៀបទៅនឹងសមភាគីបុរសរបស់ពួកគេ។

### ២.៣.២. ការរំពឹងទុក

**-ការកើនឡើងតួនាទីតំណាងជាស្ត្រី៖** រដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាបង្កើនតំណាងស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្ត រួមទាំងនៅថ្នាក់រដ្ឋមន្ត្រីផងដែរ។ នៅឆ្នាំ ២០២៣ ស្ត្រីបានកាន់តំណែងសំខាន់ៗជាច្រើននៅក្នុងទីស្តីការគណៈរដ្ឋមន្ត្រី ទោះបីជាចំនួនសរុបរបស់ពួកគេនៅតែទាបជាងបុរសក៏ដោយ។ ក្រសួងកិច្ចការនារីបានដើរតួយ៉ាងសំខាន់ក្នុងការតស៊ូមតិ ដើម្បីបង្កើនបន្ថែមចំនួនស្ត្រីបន្ថែមទៀតនៅក្នុងភាពជាអ្នកដឹកនាំ ហើយរដ្ឋមន្ត្រីស្ត្រីបានចូលរួមក្នុងវិស័យសំខាន់ៗដូចជា វប្បធម៌ ពាណិជ្ជកម្ម និងកិច្ចការនារី។

**-ការតស៊ូមតិនិងឥទ្ធិពលគោលនយោបាយ៖** រដ្ឋមន្ត្រីស្ត្រីបានចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់គោលនយោបាយទាក់ទងនឹងសមភាពយេនឌ័រ ការការពារគ្រួសារ និងសុខុមាលភាពសង្គម។ ឥទ្ធិពលរបស់ពួកគេត្រូវបានបង្ហាញឱ្យឃើញ ជាពិសេសក្នុងការជំរុញឱ្យមានកំណែទម្រង់ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាផ្អែកលើយេនឌ័រ កែលម្អសុខភាពមាតា និងទារក និងលើកកម្ពស់ឱកាសអប់រំសម្រាប់ក្មេងស្រី។ តាមរយៈតួនាទីរបស់ពួកគេ ស្ត្រីទាំងនេះក៏បានផ្តោតលើការដោះស្រាយវិសមភាពយេនឌ័រនៅក្នុងពលកម្មការងារ ដោយស្វែងរកការបង្កើតគោលនយោបាយដែលធ្វើអោយប្រសើរឡើង

នូវលក្ខខណ្ឌការងារសម្រាប់ស្ត្រី និងគាំទ្រដល់ការចូលរួមរបស់ពួកគេក្នុងវិស័យដែលគ្រប់គ្រងដោយបុរសជាប្រពៃណី។

**- ប្រព័ន្ធកូតា និងឆន្ទៈនយោបាយ៖** ប្រទេសកម្ពុជាបានអនុវត្តកូតាយេនឌ័រនៅគ្រប់កម្រិតរបស់រដ្ឋាភិបាល ហើយមានការពិភាក្សាជាបន្តបន្ទាប់អំពីការពង្រីកទាំងនេះ ដើម្បីធានាឱ្យមានការចូលរួមរបស់ស្ត្រីកាន់តែច្រើននៅក្នុងទីស្ដីការគណៈរដ្ឋមន្ត្រី។ ទោះជាយ៉ាងណាក៏ដោយ ការសម្រេចបានសមភាពយេនឌ័រនៅកម្រិតខ្ពស់បំផុតនៃការសម្រេចចិត្តទាមទារមិនត្រឹមតែកូតាផ្លូវការប៉ុណ្ណោះទេ ប៉ុន្តែក៏មានការផ្លាស់ប្តូរឆន្ទៈនយោបាយ និងអាកប្បកិរិយាវប្បធម៌ចំពោះការដឹកនាំរបស់ស្ត្រីផងដែរ។

**- ឥទ្ធិពល និងកិច្ចសហប្រតិបត្តិការអន្តរជាតិ៖** អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ រួមទាំងអង្គការសហប្រជាជាតិ និងអង្គការក្រៅរដ្ឋាភិបាល បានគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការលើកកម្ពស់ស្ត្រីក្នុងតួនាទីធ្វើការសម្រេចចិត្ត។ កម្មវិធីដែលផ្តោតលើការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ និងការកសាងសមត្ថភាពសម្រាប់ស្ត្រីក្នុងវិស័យនយោបាយ គឺជាកត្តាសំខាន់ក្នុងការរៀបចំស្ត្រីសម្រាប់តំណែងខ្ពស់ជាងនេះ។

**- ការរៀបចំនិងការអនុវត្តគោលនយោបាយ៖** ក្តីសង្ឃឹមដើម្បីសម្រេចបានសមភាពយេនឌ័រ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រីនិងកុមារីទាំងអស់ ក្នុងនាមជាថ្នាក់ដឹកនាំជាតិត្រូវរៀបចំនិងអនុវត្តគោលនយោបាយដ៏ទូលំទូលាយ ដោយតម្រូវឱ្យមានការរួមបញ្ចូលនូវការដោះស្រាយវិសមភាពខាងនយោបាយ សេដ្ឋកិច្ច និងសង្គម ស្របគ្នាជាមួយការលើកកម្ពស់ការអប់រំ ការការពារពីអំពើហិង្សា និងឱកាសស្មើគ្នា។ ជាពិសេសត្រូវចេះក្លែងធ្វើគោលដៅនេះនៅក្នុងក្របខ័ណ្ឌហ្គេមទ្រឹស្តី។

- យុទ្ធសាស្ត្រសំខាន់ៗតាមដំណាក់កាលរួមមាន៖

### ក.សកម្មភាពនីតិបញ្ញត្តិ

សេចក្តីព្រាង និងការអនុវត្តច្បាប់ដែលមានគោលបំណងផ្តល់ប្រាក់បៀវត្សរ៍ស្មើៗគ្នា ទប់ស្កាត់អំពើហិង្សាផ្អែកលើយេនឌ័រ និងធានាឱ្យមានតំណាងនៅក្នុងតួនាទីនយោបាយ និងអ្នកដឹកនាំ និងការពង្រឹងការការពារផ្លូវច្បាប់ប្រឆាំងនឹងការរើសអើង។

### ខ. ការពង្រឹងសេដ្ឋកិច្ច

បង្កើតកម្មវិធីដើម្បីគាំទ្រដល់សហគ្រិនស្ត្រី ផ្តល់លទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ និងលើកទឹកចិត្តសមភាពនៅកន្លែងធ្វើការ រួមទាំងការឈប់សម្រាកលំហែមាតុភាពដែលមានប្រាក់ឈ្នួល និងម៉ោងធ្វើការដែលអាចបត់បែនបាន ព្រមទាំងលើកកម្ពស់លទ្ធភាពទទួលបានការងារស្មើៗគ្នា និងប្រាក់ឈ្នួលស្មើគ្នាសម្រាប់ការងារស្មើគ្នា។

### គ. កំណែទម្រង់អប់រំ

ធានាថាកុមារីទាំងអស់ទទួលបានការអប់រំប្រកបដោយគុណភាព និងឥតគិតថ្លៃ ផ្តោតលើការបង្កើនការចុះឈ្មោះចូលរៀនក្នុងវិស័យ STEM (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា)។

### ឃ. ការចូលប្រើប្រាស់សេវាថែទាំសុខភាព

ផ្តល់សេវាថែទាំសុខភាពដែលមានតម្លៃសមរម្យ និងអាចចូលដំណើរការបានជាពិសេសសម្រាប់ស្ត្រី រួមទាំងសុខភាពបន្តពូជ និងធ្វើការលើការកាត់បន្ថយអត្រាមរណភាពមាតា និងធានាការថែទាំសុខភាពត្រឹមត្រូវអំឡុងពេលមានផ្ទៃពោះ និងសម្រាលកូន។

### ង. បញ្ចប់អំពើហិង្សាផ្អែកលើយេនឌ័រ

ពង្រឹងកិច្ចខិតខំប្រឹងប្រែងអនុវត្តច្បាប់ ដើម្បីទប់ស្កាត់និងឆ្លើយតបទៅនឹងអំពើហិង្សាក្នុងគ្រួសារ ការជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ និងបើកយុទ្ធនាការផ្សព្វផ្សាយទូទាំងប្រទេសស្តីពីសិទ្ធិ និងការការពាររបស់ស្ត្រី។

### ច. បទដ្ឋានសង្គម និងការយល់ដឹង

លើកកំពស់សមភាពយេនឌ័រក្នុងប្រព័ន្ធផ្សព្វផ្សាយ វប្បធម៌ និងសង្គមដោយការប្រឈមមុខនឹងគំរូដែលបង្កគ្រោះថ្នាក់ និងលើកកម្ពស់គំរូវិជ្ជមាន និងចូលរួមក្នុងការសន្ទនារបស់សហគមន៍ដែលប្រកាន់យកយេនឌ័រ ដើម្បីរុះរើនូវរចនាសម្ព័ន្ធអយ្យកោ។

## ៣. ទស្សនវិស័យនៃតុល្យភាពយេនឌ័រនៅក្នុងមុខងារ និងទំនួលខុសត្រូវជីវិត

-ទស្សនៈរបស់ Charlie Munger ស្តីពីតុល្យភាពការងារ និងជីវិត លោកបានសង្កត់ធ្ងន់យ៉ាងខ្លាំងលើការសម្រេចបាននូវជីវិតដែលមានតុល្យភាពដោយការអនុវត្តការវិនិច្ឆ័យត្រឹមត្រូវនិងផ្តល់អាទិភាពដល់អ្វីដែលសំខាន់បំផុតនិងមានអត្ថន័យ និងជៀសវាងនូវការមមាញឹកដែលមិនចាំបាច់ និងបន្តការរៀនសូត្រដើម្បីធានាការបំពេញការងារផ្ទាល់ខ្លួន និងវិជ្ជាជីវៈ។

-ទស្សនៈរបស់ Matsuo Basho "កុំស្វែងរកដើរតាមគន្លងអ្នកប្រាជ្ញ ស្វែងរកអ្វីដែលពួកគេបានស្វែងរក"។

-នៅព្រះរាជាណាចក្រកម្ពុជា ក៏ដូចជានៅលើសកលលោក មេដឹកនាំប្រទេស គឺជាវីរបុរសរបស់ជាតិ។ នៅក្នុងសង្គម ទស្សនវិទូ អ្នកវិទ្យាសាស្ត្រ ប្រវត្តិវិទូ តារាវិទូ គ្រូបង្រៀន គ្រូពេទ្យ វិស្វករ អភិបាលខេត្ត អភិបាលស្រុក មេឃុំ មេភូមិ ប្រធានក្រុម អាជ្ញាធរដែនដី ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត យុវទូតតំណាងគ្រប់វិស័យ គឺមេដឹកនាំសហគមន៍ពួកគាត់ គឺជាជនគំរូសម្រាប់ប្រជាពលរដ្ឋ។ ដើម្បីជីវិត ស្ត្រីនិងបុរសគ្រប់រូបកើតមករមែងមានក្តីស្រមៃដែលជាជម្រើសការងារសម្រាប់ជីវិតរបស់ពួកគេរៀងៗខ្លួន។ ស្ត្រីនិងបុរសគឺជាដៃគូការងារ និងស្នេហាដែលបំពេញកង្វះខាតនិងន័យជីវិតឱ្យគ្នាទៅវិញទៅមកដោយមិនអាចខ្វះបាន ប្រៀបបីដូចជាកាយនិងចិត្ត ទឹកហើយនិងត្រី។ ស្ត្រីនិងបុរស អាចធ្វើជា ប្រធានាធិបតី នាយករដ្ឋមន្ត្រី គ្រូបង្រៀន គ្រូពេទ្យ វិស្វករ កម្មករបានដូចគ្នា។ ស្ត្រីនិងបុរស អាចមើលថែកូន និងមនុស្សចាស់ បានដូចគ្នា។ ពុំមានរឿងអ្វីដែលបុរសធ្វើបាន ហើយស្ត្រីធ្វើពុំបាននោះទេ។ ប៉ុន្តែមានការងារមួយដែលស្ត្រីធ្វើបាន ហើយបុរសធ្វើពុំបានគឺការពពោះកូន។ កូនស្រីក៏អាចរៀនសូត្របានខ្ពង់ខ្ពស់និងមានភាពក្លាហានដូចកូនប្រុស ហើយកូនប្រុសក៏អាចជួយការងារផ្ទះបានដែរ ប្រសិនបើកូនស្រី ឬកូនប្រុសធ្វើបានល្អជាង ហេតុអ្វីក៏សង្គមមានការបែងចែក ឬរើសអើងថា ការងារនេះជារបស់កូនស្រី ឬ

ក៏កូនប្រុសទៅវិញ? ហេតុអ្វីក៏ពុំសម្លឹងមើលទៅសមត្ថភាពរបស់កូន ជាជាងការឱ្យតម្លៃថាស្ត្រី គួរធ្វើនេះ ឬធ្វើនោះ។ ហេតុអ្វីក៏សង្គមខ្លះ មានការបែងចែកជាបិតាធិបតេយ្យនិយម ឬមាតាធិបតេយ្យនិយម? ចុះសង្គមនៅកម្ពុជាវិញយ៉ាងណាដែរ? ពិតណាស់ នៅលើផែនដីដ៏អស្ចារ្យនេះមានតែមនុស្សពីរភេទទេ គឺមនុស្សស្រី និងប្រុស ហើយមនុស្សស្រី និងមនុស្សប្រុសមានសិទ្ធ និងឱកាសស្មើៗគ្នា ក្នុងការប្រកបមុខរបរចិញ្ចឹមជីវិត ជ្រើសរើសនូវអាជីពដ៏មានកិត្តិយស ដែលសង្គមឱ្យតម្លៃខ្លាំង និងស្របទៅតាមបំណងប៉ងប្រាថ្នា ការស្រលាញ់ពេញចិត្ត ហើយមានការគាំទ្រ និងផ្តល់នូវឱកាសពីសង្គម គ្រួសារ និងជាពិសេសពីដៃគូជីវិតរបស់ខ្លួន។ ជារៀងរាល់ថ្ងៃ ស្ត្រីនៅទូទាំងពិភពលោកកំពុងតស៊ូដើម្បីសិទ្ធិ និងការតំណាងរបស់ពួកគេនៅក្នុងសង្គម សេដ្ឋកិច្ច វប្បធម៌និងនយោបាយ។ ហេតុនេះហើយទើប តួនាទីស្ត្រីនៅក្នុងភាពជាអ្នកដឹកនាំ បានក្លាយជាប្រធានបទដ៏មានប្រជាប្រិយមួយ ដែលបានទាក់ទាញចំណាប់អារម្មណ៍ពីសង្គម ជាពិសេស គឺពីថ្នាក់ដឹកគ្រប់លំដាប់ថ្នាក់ និងស្ត្រីខ្លួនឯងតែម្តង។ តួនាទីរបស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំមានតម្លៃខ្លាំងណាស់ សម្រាប់ជាសក្ខីកម្មដល់ក្មេងៗជំនាន់ក្រោយ ដែលចងក្រងជាឯកសារថា ស្ត្រីដូចជាខ្លួនគេ មានសមត្ថភាពអាចដឹកនាំខ្លួន គ្រួសារ សង្គមនិងប្រទេសជាតិបាន។ ជាពិសេសអាចមានចំណូលដូចបុរស មានសំឡេង ហើយមានអំណាចធ្វើការសម្រេចចិត្តសំខាន់ៗ ដែលកំណត់អនាគតរបស់ពួកគេ និងកូនៗរបស់គេ។ ដោយសារតែការលើកកម្ពស់ ការគាំទ្រ និងសមត្ថភាពពិតប្រាកដរបស់ពួកគេ ស្ត្រីវ័យក្មេងនឹងមានក្តីសុបិនធំ ការសម្រេចការធំបាន។ ស្ត្រីគឺជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងជាមូលធនដ៏សំខាន់មិនអាចខ្វះបាន ក្នុងការអភិវឌ្ឍប្រទេសដូចមាននៅក្នុងផែនការអភិវឌ្ឍន៍ជាតិនារីរតនៈ ដែលបានកំណត់ដោយក្រសួងកិច្ចការនារី។ នៅក្នុងយុគសម័យសាកលភាវូបនីយកម្ម និងសេដ្ឋកិច្ចឌីជីថលនេះ យើងទាំងអស់គ្នាដឹងថា ស្ត្រី គឺជាដៃគូស្មើភាពគ្នាជាមួយបុរស ហើយបានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់សុខុមាល ភាពគ្រួសារ សេចក្តីថ្លៃថ្នូសង្គម ការអភិវឌ្ឍសហគមន៍ និងការរួមចំណែកក្នុងការកសាងសេដ្ឋកិច្ចប្រទេសជាតិឱ្យមានភាពរីកចម្រើនលឿនលឿនដូចអារ្យកប្រទេស។ ជាក់ស្តែង តួនាទីស្ត្រីកម្ពុជាក្នុងភាពជាអ្នកដឹកនាំ នៅទីស្តីការគណៈរដ្ឋមន្ត្រី និងស្ថាប័នប្រតិបត្តិផ្សេងៗ ដែលគឺជាទីកន្លែងនៃក្តីសុបិន្តប្រាថ្នា ស្រមើស្រមៃការងាររបស់ក្មេងស្រី ឬនិស្សិតស្រីនៅក្នុងប្រទេសកម្ពុជា នៅពេលដែលត្រូវគេសួរថា តើធំឡើង ឬរៀនចប់ទៅ តើអ្នកចង់ធ្វើការងារអ្វី? មានមនុស្សមិនតិចទេដែលសុបិន្តចង់ធ្វើការងារនៅស្ថាប័នកំពូលសំខាន់ៗ។ ពិតណាស់ សមភាពយេនឌ័រ គឺជាភាពគ្មានការរើសអើង ដោយយកភេទរបស់បុគ្គលមកធ្វើជាមូលដ្ឋានក្នុងការបែងចែកធនធាន ឬការទទួលផលប្រយោជន៍ និងសេវាកម្មនានា ហើយសមភាពយេនឌ័រអាចវាស់វែងបានដោយពិនិត្យលើកាលានុវត្តភាពស្មើគ្នា ឬការទទួលផលប្រយោជន៍ស្មើគ្នា។ ហើយយេនឌ័រវិញ គឺជាការសំដៅទៅលើតួនាទី ឥរិយាបថនិងតម្លៃនានាដែលវប្បធម៌និងសង្គមបានកំណត់ឱ្យបុរសនិងស្ត្រីអនុវត្តដោយឡែកពីគ្នា ហើយតួនាទីឥរិយាបថ និងគុណតម្លៃទាំងនេះកំណត់នូវអាកប្បកិរិយានិងទំនាក់ទំនងរវាងបុរសនិងស្ត្រី។ តួនាទី ឥរិយាបថ និងគុណតម្លៃទាំងនេះត្រូវបានបង្កើតឡើងនិងថែរក្សាដោយស្ថាប័នសង្គមនានា ដូចជា គ្រួសារ សាលារៀន វត្តអារាម សហគមន៍ សារព័ត៌មាន និងរដ្ឋាភិបាល។

## ៤. ស្ថានភាពយេនឌ័រនៅកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកការងារយេនឌ័រ គឺជាកិច្ចការដ៏សំខាន់សំខាន់ក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចហើយបានជំរុញឱ្យមានការបញ្ជ្រាបយេនឌ័រ នៅក្នុងគោលនយោបាយ និងកម្មវិធីទាំងឡាយជាបន្តបន្ទាប់។ តាមរយៈ កិច្ចខិតខំប្រឹងប្រែងនេះ រាជរដ្ឋាភិបាល បានទទួលជោគជ័យគួរឱ្យកត់សម្គាល់ ដែលបានកាត់បន្ថយគម្លាតយេនឌ័រលើគ្រប់វិស័យ ជាពិសេសការបង្កើនសមាមាត្រស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្ត កិច្ចការពារផ្លូវច្បាប់សុខភាព និងការលើកកម្ពស់ការចូលរួមរបស់ស្ត្រីនិងកុមារក្នុងការអប់រំ និងការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ជាពិសេសបង្កើនចំនួនស្ត្រីជាមន្ត្រីរាជការនៅគ្រប់ផ្នែក និងគ្រប់កម្រិត តាមរយៈកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ នារយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ រាជរដ្ឋាភិបាលបានផ្តល់ឱកាសការងារជាច្រើនសម្រាប់ប្រជាពលរដ្ឋកម្ពុជា ក្នុងនោះនារីរាប់សែននាក់បានទទួលការងារដែលមានប្រាក់កម្រៃនៅក្នុងវិស័យផ្សេងៗទាំងក្នុងប្រទេស និងក្រៅប្រទេស ជាពិសេសនៅតាមបណ្តារោងចក្រកាត់ដេរ និងការចេញទៅបម្រើការងារនៅតាមបណ្តាប្រទេសផ្សេងៗ។ ចំពោះអត្រាការចូលរួមកម្លាំងពលកម្មស្ត្រី ៧៧,២% និងបុរស ៨៨,៥% ហើយអត្រាអ្នកមានការងារធ្វើស្ត្រី ៤៨,១៨% បុរស ៥១,៨១% គិតត្រឹមឆ្នាំ ២០១៥។[២] ប្រាក់កម្រៃដែលទទួលបានពីការងារទាំងនេះគឺជាប្រភពចំណូលមួយភាគធំក្នុងការជួយទ្រទ្រង់ និងលើកស្ទួយជីវភាពគ្រួសារ។ ប៉ុន្តែទន្ទឹមនឹងភាពជឿនលឿនទាំងនេះ ឱកាសការងារនៅមានកម្រិត បើធៀបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ។ ស្ត្រីដែលមានជំនាញបច្ចេកទេសវិជ្ជាជីវៈ ពិតប្រាកដនៅមានចំនួនតិចតួច។ ជំនាញដែលបានផ្តល់មិនទាន់ឆ្លើយតបតាមតម្រូវការទីផ្សារ ហើយសិទ្ធិនិងផលប្រយោជន៍របស់ពលករ ជាពិសេស ពលការិនី ក៏នៅមានចំណុចដែលត្រូវកែលម្អជាច្រើនផងដែរ។

## ៥. ការប្រើប្រាស់ឧបករណ៍ដើម្បីសម្រេចបានជោគជ័យក្នុងការសិក្សាស្រាវជ្រាវ

### ៥.១. របៀបនៃការគណនាការចូលរួមក្នុងតួនាទីរបស់ស្ត្រីក្នុងជួរថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៅទីស្តីការគណៈរដ្ឋមន្ត្រី (Method of Computation Participation Rate of Female Officials Working at the Council of Minister)[៣]

$$\text{អត្រាចំនួនមន្ត្រីរាជការជាស្ត្រីនៅទីស្តីការ} = \frac{\text{ចំនួនមន្ត្រីរាជការជាស្ត្រី} \times 100}{\text{ចំនួនមន្ត្រីរាជការសរុប(ទាំងប្រុសនិងស្រី)}}$$

$$\text{អត្រាចំនួនតួនាទីស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត} = \frac{\text{ចំនួនមន្ត្រីរាជការជាស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត} \times 100}{\text{ចំនួនមន្ត្រីរាជការជាស្ត្រីសរុប}}$$

---

[២] សៀវភៅផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ទីស្តីការគណៈរដ្ឋមន្ត្រី ២០១៧-២០២០។

[៣] https://ilostat.ilo.org/resources/concepts-and-definitions/description-labour-force-participation-rate/

### ៥.២. កម្រងសំណួរអនឡាញ

កម្រងសំណួរមួយចំនួន គ្រោងនឹងរៀបចំឡើងដើម្បីស្នើសុំការអនុញ្ញាតសាកសួរដោយផ្ទាល់ឬអនឡាញ (google form) ពីថ្នាក់ដឹកនាំនិងមន្ត្រីនៅទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីឆ្លើយបតបង្ហះបញ្ជាំងជាមួយទំនាក់ទំនងនៃបណ្តាកត្តាដែលជះឥទ្ធិពលដល់ការធ្វើសេចក្តីសម្រេចចិត្តដូចមានក្នុងរូប៖




### ៥.៣. ការវិភាគដោយផ្អែកលើទ្រឹស្តី មូលដ្ឋានច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា និងការរួមបញ្ចូលជាមួយសមភាពយេនឌ័រក្នុងរដ្ឋបាលសាធារណៈនាពេលបច្ចុប្បន្ន




ការចូលរួមរបស់ស្ត្រីក្នុងជីវិតសាធារណៈមិនមែនជាកង្វល់នាពេលថ្មីៗនេះទេ ៤១ឆ្នាំ បន្ទាប់ពីការអនុម័ត CEDAW ២៥ឆ្នាំបន្ទាប់ពីការបើកដំណើរការកម្មវិធី Beijing Platform for Action និងប្រាំឆ្នាំបន្ទាប់ពីការចាប់ផ្តើមរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ស្ត្រីនៅតែមានភាពខ្វះខាតក្នុងការសម្រេចចិត្តក្នុងជីវិតសាធារណៈនៅគ្រប់ៗគ្នានៃតំបន់ពិភពលោក។ ការពង្រីក "សមភាពយេនឌ័រក្នុងជីវិតសាធារណៈ" ដើម្បីរួមបញ្ចូលការគ្រប់គ្រងសាធារណៈ សូចនាករនៃការចូលរួមរបស់ស្ត្រី និងការសម្រេចចិត្តក្នុងជីវិតសាធារណៈគឺមានភាពចាំបាច់ពីព្រោះវា បានផ្តោតជាសំខាន់លើ

តំណាងស្ត្រីក្នុងមុខតំណែងនយោបាយ ដូចជាប្រមុខរដ្ឋ និងរដ្ឋាភិបាល សមាជិកសភា និងគណៈរដ្ឋមន្ត្រី។ ការចូលរួមរបស់ស្ត្រី និងភាពជាអ្នកដឹកនាំ នៅក្នុងមុខតំណែងក្នុងវិស័យសាធារណៈនៅមានកម្រិត។ របៀបវារៈនៃការអភិវឌ្ឍន៍ឆ្នាំ២០៣០ ឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាពគឺជាយានជំនិះ ដើម្បីពង្រីកទាំងខ្លឹមសារ និងការវាស់វែងសមភាពយេនឌ័រក្នុងជីវិតសាធារណៈដើម្បីរួមបញ្ចូលក្នុងសាធារណៈរដ្ឋបាល។ ដាក់ស្តែងសូចនាករ SDG 16.7.1(b) ពិតជាតំណាងឱ្យការវាស់វែងនៅក្នុងសេវាសាធារណៈទាក់ទងនឹងភេទ អាយុ ពិការភាព និងចំនួនប្រជាជនស្ថានភាពក្រុមនៃមន្ត្រីរាជការសាធារណៈ និងវាយតម្លៃអំពីសមាមាត្រនៃក្រុមទាំងនេះនៅក្នុងសង្គមទាំងមូល។[៤]

## ៥.៤. ការពិនិត្យនិងវាយតម្លៃ

ដើម្បីសម្រេចបាននូវដំណើរឆ្ពោះទៅរកលទ្ធផលស្រាវជ្រាវ ក៏ដូចជាការឆ្លើយតបទៅនឹងបញ្ហាគោលបំណង គោលដៅនៃការសិក្សាស្រាវជ្រាវនិក្ខេបបទនេះ ទាមទារឱ្យមានការវាយតម្លៃ ការយល់ដឹង និងឆន្ទៈមោះមុត ក្នុងការសម្រេច និងអនុវត្តឱ្យបានការបង្កើតសេចក្តីសម្រេច និងគោលនយោបាយ។ ជំហានដំបូងដែលនឹងត្រូវអនុវត្តមុនគេដើម្បីលើកកម្ពស់សមភាពយេនឌ័រ ក្នុងតួនាទីនៃការធ្វើសេចក្តីសម្រេចនោះគឺ:

- លើកកម្ពស់សមភាពយេនឌ័រនិងផ្លាស់ប្តូរផ្នត់គំនិតយេនឌ័រដ៏ស៊ីជម្រៅ គឺសំដៅទៅដល់ការមានគោលនយោបាយគ្រប់គ្រាន់ និងអនុម័តច្បាប់ដែលចែងអំពីសមភាពប្រាក់ឈ្នួល សិទ្ធិនៅកន្លែងធ្វើការ និងវិធានការប្រឆាំងនឹងការរើសអើង។
- យុទ្ធនាការជាតិប្រឆាំងនឹងអំពើហិង្សាផ្អែកលើយេនឌ័រ គឺសំដៅទៅដល់ការអនុវត្ត ការការពារ និងក្របខណ្ឌច្បាប់ឱ្យកាន់តែរឹងមាំប្រឆាំងនឹងអំពើហិង្សាលើស្ត្រី ខណៈពេលដែលចាប់ផ្តើមយុទ្ធនាការលើកកម្ពស់ការយល់ដឹងថ្នាក់ជាតិ។
- គំនិតផ្តួចផ្តើមពង្រឹងអំណាចសេដ្ឋកិច្ចរបស់ស្ត្រី គឺសំដៅទៅដល់ការបង្កើតមូលនិធិ និងកម្មវិធីគាំទ្រ និងការពង្រឹងសមត្ថភាពដើម្បីបង្កើនលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានហិរញ្ញវត្ថុ ភាពជាសហគ្រិន និងមុខតំណែងជាអ្នកដឹកនាំ៕

---

[៤] Sustainable Development Goal (SDG) 16 aims to promote peaceful and inclusive societies for sustainable development, provide access to justice for all, and build effective, accountable and inclusive institutions at all levels. Its target 16.7 demands global and national commitments to ensure responsive, inclusive, participatory and representative decision-making at all levels. One of its indicators, 16.7.1, measures the proportions of positions (by sex, age, persons with disabilities and population groups) in public institutions in (a) national and local legislatures, (b) public service, and (c) judiciary, compared to national distributions. In June 2019 SDG 16.7.1b was reassigned to the Tier 2 level indicators, initiating a process of reporting of sex-disaggregated data on public administration in all member states. UNDP, 2019f; UNDP, 2021a.

# ឯកសារយោង

១. រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
២. វចនានុក្រម សម្ដេចសង្ឃ ជួន ណាត
៣. សយ រាសី កំណែទម្រង់រដ្ឋបាលសាធារណៈ ២០០៧
៤.ប៉ាន់ វុត្ថា សៀវភៅទស្សនវិជ្ជា (ការគិតៈ មនុស្ស និងច្បាប់សង្គម) ភ្នំពេញ ២០១៨
៥. Bernardin ,H. John & Russell, Joyce E.A.1993, Human Resource Management. Mcgrass-Hill, Inc.
៦. Hans Bjorn Olsen, 2007, *Decentralisation And Local Governance,* SDC
៧. NCDD, 2009, Manual for basic principles in sub national administration
៨. Rondenelli Dennis A., 2007, *Governments Serving People: The Changing Roles of Public Administration in Democratic Governance*. 7th Global Forum on Reinventing Government, 26-29 June 2007,Vienna, Austria.
៩. Boon Siong NEO and Geraldine CHEN, 2007 "DYNAMIC GOVERNANCE" Nanyang Technological University, Singapore.
១០. Ivancewich, John M. & Konopaske, Robert, 2013, Human Resource Management. Twelfth Edition, McGranw-hill International.
១១. Shafritz, Jay M. and Reusell E.W., 1997, *Introducing Public administration*. An imprint of Addison Wesley Longman, Inc.
១២. T. Keban, Yeremias, 2008, *Enam Dimensi Strategis ADMINISTRASI PUBLIK: Konsep, Teory and Isu*
១៣. Hayati Djatmiko, Yayat, 2002, Organizational Behavior, Penerbit ALFABETA, Bandung.
១៤. Lembaga Administrasi Negara, (LAN), 2000, Accountability and Good Governance, Jakarta, Indonesia.
១៥. Dictionary of Public Administration
១៦. United Nations, New York 2016, Integrating a Gender Perspective into Statistics, Studies in Methods, Series F No. 111, Department of Economic and Social Affairs, Statistics Division
១៧. OECD, The Pursuit of Gender Equality: An Uphill Battle, Paris, 2017
១៨. Women in Politics: 2012. Map. Available from www.ipu.org/pdf/publications/wmnmap12_en.pdf.
១៩. United Nations Development Fund for Women (2009). Progress of the World's Women 2008/2009:Who Answers to Women? Gender and Accountability. New York.
១៩. https://www.unicef.org/gender-equality/gender-action-plan-2022-2025
២០. ក្រុមការងារបញ្ជ្រាបយេនឌ័រនៃទីស្ដីការគណៈរដ្ឋមន្ត្រីឆ្នាំ២០១៧, សៀវភៅផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ នៃទីស្ដីការគណៈរដ្ឋមន្ត្រី ២០១៧-២០២០
២១.**បណ្ឌិត សឿន សោភ័ណ** និង អនុបណ្ឌិត សរ សំឡូត ឆ្នាំ២០២១, **ទ្រឹស្ដីរដ្ឋបាលសាធារណៈ**

# យន្តការផ្តល់សេវាចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ នៅប្រទេសកម្ពុជា

បេក្ខជនបណ្ឌិតៈ **យន់ សុងហៀង**
ជំនាញ៖ **រដ្ឋបាលសារណៈ**

## ១. សេចក្តីផ្តើម

### ១.១ ប្រវត្តិនៃការចុះបញ្ជីកម្មផ្ទេរសិទ្ធិលើអចលនវត្ថុកម្ពុជា

ក្រោមរដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់ភូមិបាលឆ្នាំ២០០១ រដ្ឋទទួលខុសត្រូវលើការការពារ ***សិទ្ធិកម្មសិទ្ធិឯកជន***។ បុគ្គលម្នាក់អាចនឹងត្រូវដកហូតសិទ្ធិកម្មសិទ្ធិ លុះណាតែការដកហូតនោះត្រូវបានធ្វើឡើងដើម្បីជាប្រយោជន៍សាធារណៈ និងបន្ទាប់ពីបានទទួលការបង់ថ្លៃលើសំណងដោយសមរម្យ និងយុត្តិធម៌[1]។ ភស្តុតាងជាក់ស្តែងបំផុតនៃកម្មសិទ្ធិ គឺបណ្ណកម្មសិទ្ធិដីធ្លី ប៉ុន្តែប្រជាជនកម្ពុជាជាច្រើនដែលជាម្ចាស់ដី នៅតែមិនមានបណ្ណកម្មសិទ្ធិផ្លូវការ និងពឹងផ្អែកលើ "ប្លង់ទន់" ជំនួសវិញ។ នៅពេលគ្មានបណ្ណកម្មសិទ្ធិផ្លូវការ ម្ចាស់ដីប្រឈមនឹងហានិភ័យជាច្រើននៃជម្លោះដីធ្លី។ នៅឆ្នាំ២០១៤ អង្គការលីកាដូបានរាយការណ៍ថាប្រជាជនជិត ៥០០០០នាក់ បានពាក់ព័ន្ធក្នុងជម្លោះដីធ្លី។[2] រដ្ឋាភិបាលបដិសេធតួលេខទាំងនេះ ដោយអះអាងថា មានជម្លោះដីធ្លីតែ ៧៥០ករណី ប៉ុណ្ណោះ នៅឆ្នាំ២០១៤។ អ្នកសិក្សាស្រាវជ្រាវរាយការណ៍ថា ប្រជាពលរដ្ឋក្រីក្រ អ្នកទទួលការអប់រំតិចតួច សហគមន៍ជនជាតិដើម និងស្ត្រីគឺទំនងជាស្ថិតក្នុងក្រុមនៃបុគ្គលងាយរងគ្រោះពីអសន្តិសុខកម្មសិទ្ធិដីធ្លីខ្លាំងជាងគេ។

យោងប្រកាសអន្តរក្រសួងលេខ១៤៣៤២ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលពុំទាន់ចុះបញ្ជីសម្រាប់ដីក្រៅក្រុង ឬជនបទដែលមានទំហំចាប់ពី ៥០០ម៉ែត្រការ៉េ ដល់ក្រោម ១ ០០០ម៉ែត្រការ៉េសម្រាប់ប្រជាពលរដ្ឋខ្មែរ។ ការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលពុំទាន់ចុះបញ្ជីសម្រាប់ដីក្រៅក្រុង ឬជនបទដែលមានទំហំចាប់ពី ៥០០ម៉ែត្រការ៉េដល់ក្រោម ១ ០០០ម៉ែត្រការ៉េ

- តម្លៃសេវាអតិបរមា ៖ ៦០ ០០០ រៀល ក្នុង ១លើក
- រយៈពេលអតិបរមា ៖ ១៥ថ្ងៃ (ថ្ងៃធ្វើការ)

---

[1] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ មាត្រា ៤៤; ច្បាប់ភូមិបាល ឆ្នាំ ២០០១ មាត្រា ៥។

[2] អង្គការលីកាដូ. ២០១៥. "*ការងើបឡើងជាថ្មីនៃជម្លោះដីធ្លី គួរត្រូវដោះស្រាយ ជៀសជាងបដិសេធ.*" ថ្ងៃទី ១៩ ខែកុម្ភៈ, ចូលអាននៅថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០២៤។

ដើម្បីទទួលបានសេវាការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យ ដែលពុំទាន់ចុះបញ្ជីសម្រាប់ដីក្រៅក្រុង ឬជនបទ អ្នកប្រើប្រាស់សេវាត្រូវយកភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ៖

១. ពាក្យស្នើសុំ

២. អត្តសញ្ញាណបណ្ណ លិខិតឆ្លងដែនភាគីទាំងសងខាង (ថតចម្លង) ០១ច្បាប់

៣.សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ (ករណីរៀបអាពាហ៍ពិពាហ៍) ០២ច្បាប់

៤. ឯកសារបញ្ជាក់អត្តសញ្ញាណ (លីវ មេម៉ាយ ពោះម៉ាយ....)០១ច្បាប់

៥. សំបុត្រទិញលក់

៦. ឯកសារប្រវត្តិដី ០១ច្បាប់

៧. បង្កាន់ដៃបង់ពន្ធ

**នីតិវិធីនៃការផ្តល់សេវា៖**

នីតិវិធីនៃការផ្តល់សេវាការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យ ដែលពុំទាន់ចុះបញ្ជីសម្រាប់ដីក្រៅក្រុង ឬជនបទ មានចំនួន ១៦ដំណាក់កាលដូចខាងក្រោម ៖

១. អតិថិជនដាក់ពាក្យស្នើសុំសេវានៅមន្ត្រីផ្តល់ទទួលព័ត៌មានដែលនៅផ្នែកជួរមុខ

២. អតិថិជនទទួលបង្កាន់ដៃទទួលពាក្យពីមន្ត្រីផ្តល់ព័ត៌មាន

៣. មន្ត្រីផ្តល់ទទួលព័ត៌មានបញ្ជូនពាក្យស្នើសុំទៅបេឡាករ

៤. អតិថិជនអញ្ជើញទៅបង់ប្រាក់ថ្លៃសេវានៅបេឡាករ

៥. អតិថិជនទទួលបង្កាន់ដៃបង់ប្រាក់ថ្លៃសេវា

៦. មន្ត្រីផ្តល់ទទួលព័ត៌មានបញ្ជូនពាក្យស្នើសុំទៅប្រធានការិយាល័យ

៧. ប្រធានការិយាល័យបញ្ជូនទៅមន្ត្រីបច្ចេកទេសដែលនៅផ្នែកជួរក្រោយ

៨. មន្ត្រីបច្ចេកទេសធ្វើដំណើរទៅទីតាំងស្នើសុំដើម្បីពិនិត្យនិងវាយតម្លៃ

៩. មន្ត្រីបច្ចេកទេសត្រូវធ្វើរបាយការណ៍បន្ទាប់ពីពិនិត្យនិងវាយតម្លៃរួច

១០. បញ្ជូនរបាយការណ៍មកប្រធានការិយាល័យ

១១. ប្រធានការិយាល័យដាក់របាយការណ៍ជូនអភិបាលរងដើម្បីពិនិត្យបន្ត

១២. បន្តដាក់របាយការណ៍ជូនអភិបាលដើម្បីពិនិត្យនិងសំរេចចុងក្រោយ

១៣. មន្ត្រីរដ្ឋបាលក្រុង ស្រុក ខណ្ឌ ធ្វើការចុះលេខ

១៤. បញ្ជូនអាជ្ញាបណ្ណទៅប្រធានការិយាល័យបន្ទាប់ពីចុះលេខរួច

១៥. បញ្ជូនអាជ្ញាបណ្ណបន្តទៅមន្ត្រីផ្តល់ទទួលព័ត៌មានដែលនៅផ្នែកជួរមុខ

១៦. ផ្តល់អាជ្ញាបណ្ណដែលជាលទ្ធផលជូនអតិថិជន។

ទីកន្លែងកន្លែងដែលផ្តល់សេវា គឺការិយាល័យច្រកចេញចូលតែមួយខណ្ឌ ស្រុក។

### ១.១.១.ការចុះបញ្ជីដីធ្លី

បន្ទាប់ពីអនុក្រឹត្យលេខ ៤៦ និងលេខ ៤៨ ត្រូវបានអនុម័ត្រកាលពីថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ការចុះបញ្ជីដីធ្លីជាប្រព័ន្ធនិងដាច់ដោយដុំ បានចាប់ផ្តើម។ កម្មវិធីនេះ បានផ្តល់បណ្ណកម្មសិទ្ធិ ចំនួន ២,៦ លានច្បាប់ និង ៦០០ ០០០ច្បាប់ ជូនប្រជាពលរដ្ឋ តាមលំដាប់លំដោយ នៅត្រឹមខែធ្នូ ឆ្នាំ ២០១៤។ ជាមួយនឹងការចុះបញ្ជីដីធ្លី និងការចេញបណ្ណកម្មសិទ្ធិ នៅក្រោមក្របខណ្ឌនៃបទបញ្ជាលេខ ០១ ដែលបានចាប់ផ្តើមនៅខែមិថុនា ឆ្នាំ២០១២ និងនៅត្រឹមខែធ្នូ ឆ្នាំ២០១៤ បណ្ណកម្មសិទ្ធិចំនួន ៦១០ ០០០ច្បាប់ ត្រូវបានចេញជូនប្រជាពលរដ្ឋ។

### ១.១.២ ការចុះបញ្ជីដីធ្លីជាប្រព័ន្ធ និងការចុះបញ្ជីដីធ្លីដាច់ដោយដុំ

ការចុះបញ្ជីដីធ្លី ត្រូវបានធ្វើឡើងតាមកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី (LASSP) របស់ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់។ មានទម្រង់ពីរនៃការចុះបញ្ជីដីធ្លី ដែលត្រូវបានបង្កើតឡើងក្នុងក្របខ័ណ្ឌគតិយុត្តៈ ការចុះបញ្ជីដីធ្លីជាប្រព័ន្ធ និងការចុះបញ្ជីដីធ្លីដាច់ដោយដុំ។ ការចុះបញ្ជីដីធ្លីជាប្រព័ន្ធជាដំណើរការដែលស្រុក ឬឃុំទាំងមូលត្រូវបានកំណត់សម្រាប់ការវិនិច្ឆ័យ។ ក្រុមការងារចុះបញ្ជីដីធ្លី ចុះវាស់ដី និងកំណត់ព្រំដែនក្បាលដី វាយតម្លៃឯកសារកម្មសិទ្ធិ ពិនិត្យឯកសារកាន់កាប់ និងវិនិច្ឆ័យលើកម្មសិទ្ធិ។ *អនុក្រឹត្យលេខ៤៦ ស្តីពីនីតិវិធីបង្កើតផែនទីសន្ទស្សន៍សុរិយោដី និងការចុះបញ្ជីដីធ្លី* បង្កើតបានជាដំណើរការចុះបញ្ជីដីធ្លីជាប្រព័ន្ធ។ នៅឆ្នាំ ២០១៤ ការចុះបញ្ជីដីធ្លីជាប្រព័ន្ធបានចុះបញ្ជីដីជាង ៣លានក្បាលដី និងផ្តល់បណ្ណកម្មសិទ្ធិជាង ២,៥ លានច្បាប់។[៣]

ការចុះបញ្ជីដីធ្លីដាច់ដោយដុំ អាចធ្វើឡើងបាន ប៉ុន្តែមានតម្លៃថ្លៃ ហើយប្រជាជនភាគច្រើនមិនមានលទ្ធភាពនោះទេ។ នៅត្រឹមឆ្នាំ ២០១៤ បណ្ណកម្មសិទ្ធិ ៦០៣ ៣០២ ត្រូវបានផ្តល់ជូនប្រជាពលរដ្ឋតាមរយៈដំណើរការនេះ។[៤]

ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់បានធ្វើឱ្យមានវឌ្ឍនភាពជាច្រើនក្នុងការបង្កើតក្របខ័ណ្ឌគិតយុត្តិ និងការបែងចែកបណ្ណកម្មសិទ្ធិដីធ្លីជាង ៣,៨ លាន ប៉ុន្តែកម្មវិធីចុះបញ្ជីដីធ្លីបានប្រឈមនឹងបញ្ហាជាច្រើន។ នៅឆ្នាំ២០០៩ ទាំងសហគមន៍ និងក្រុមសង្គមស៊ីវិលបានចាប់ផ្តើមបង្ហាញក្តីបារម្ភថា អ្នករស់នៅក្នុងតំបន់មួយចំនួនមិនអាចទទួលបានបណ្ណកម្មសិទ្ធិដីធ្លីឡើយ ទោះបីជាមានទីតាំងស្ថិតក្នុងតំបន់វិនិច្ឆ័យក៏ដោយ។ គោលជំហររបស់រាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងបញ្ហានេះ គឺថាម្ចាស់ដីទាំងនោះ គឺជាអ្នកតាំងទីលំនៅដោយខុសច្បាប់។ យ៉ាងនេះក្តី ចំណុចនេះតែងត្រូវបានជំទាស់ដោយពលរដ្ឋពាក់ព័ន្ធ។ សង្គមស៊ីវិលនៅតែមានក្តីបារម្ភថា តំបន់មួយចំនួននៅតែត្រូវបានផាត់ចេញពីដំណើរការចុះបញ្ជីដីធ្លី ជាពិសេស សហគមន៍ដែលស្ថិតក្នុងតំបន់ដែលដីមានហាងឆេង ឬដីត្រូវបាន

---

[៣] ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ (ឆ្នាំ២០១៤) "សេចក្តីជូនដំណឹង" ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៤។

[៤] ក្រុមការងារអធិការកិច្ចរបស់ធនាគារពិភពលោក (ឆ្នាំ២០០៩) "*កម្ពុជា: គម្រោងការគ្រប់គ្រងនិងរដ្ឋបាលដីធ្លី (ឆ្នាំ២០០៩)*." ចូលអាននៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៤។

កំណត់សម្រាប់ការអភិវឌ្ឍ[៥]។ បញ្ហាមួយទៀតដែលត្រូវបានគូសបញ្ជាក់ក្នុងការសិក្សាវាយតម្លៃរបស់សង្គមស៊ីវិល និងម្ចាស់ជំនួយជាច្រើន គឺការជួញដូរដីចុះបញ្ជីភាគច្រើនមិនត្រូវបានចុះបញ្ជីជាបន្តបន្ទាប់។ ចំណុចនេះបានបង្កបញ្ហាជានិរន្តរ ដោយសារតែការចុះបញ្ជីដីធ្លីអាចកាន់តែមិនច្បាស់លាស់ឡើង។[៦]

### ១.១.៣ ការផ្តល់បណ្ណកម្មសិទ្ធិដីធ្លីតាមបទបញ្ជាលេខ ០១

នៅឆ្នាំ ២០១២ បន្ទាប់ពីការសម្រេចបទបញ្ជាលេខ ០១ បប ស្តីពីវិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច នាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសគាំទ្របទបញ្ជានេះថា លោកនឹងដាក់ចេញយុទ្ធនាការចុះវាស់វែងដីធ្លី និងផ្តល់បណ្ណកម្មសិទ្ធិដល់ប្រជាជនដែលរស់នៅលើដីរដ្ឋ រួមទាំង ដីព្រៃ ដីសម្បទានសេដ្ឋកិច្ច និងដីព្រៃសម្បទាន។ការផ្តល់បណ្ណកម្មសិទ្ធិតាមបទបញ្ជាលេខ ០១ គឺខុសប្លែកពីដំណើរការចុះបញ្ជីដីធ្លីជាប្រព័ន្ធ។ វាត្រូវបានបង្កើតឡើងនៅក្រៅក្របខ័ណ្ឌការចុះបញ្ជីដីធ្លីផ្លូវការ និងទទួលបានមូលនិធិជាឯកជនពីនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ដោយប្រើប្រាស់យុវជនស្ម័គ្រចិត្តចុះវាស់វែង និងចុះបញ្ជីដីធ្លីរហូតដល់ឆ្នាំ ២០១៥។[៧] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨ បានបង្ហាញកាលពីខែកក្កដា ឆ្នាំ២០១៤ ថា ដីចំនួន ៣៨០ ០០០ ក្បាលដីត្រូវបានចុះបញ្ជី និងផ្តល់បណ្ណកម្មសិទ្ធិ។ យ៉ាងនេះក្តី នៅត្រឹមខែធ្នូ ឆ្នាំ២០១៤ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់រាយការណ៍ថា បណ្ណកម្មសិទ្ធិជាង ៦១០០០០ច្បាប់ ត្រូវបានផ្តល់ជូនប្រជាពលរដ្ឋ ហើយដីចំនួន ៧១០០០០ ក្បាលដីត្រូវបានចុះវាស់វែង និងដាក់បង្ហាញ តាមគំនិតផ្តួចផ្តើមនៃបទបញ្ជាលេខ ០១។ កម្មវិធីនេះគឺសកម្មបំផុត រហូតដល់ការបោះឆ្នោតឆ្នាំ២០១៣ ជាពេលដែលដំណើរការនេះយឺតយ៉ាងខ្លាំង។ ការផ្តល់បណ្ណកម្មសិទ្ធិបន្តធ្វើឡើងវិញនៅខែធ្នូ ឆ្នាំ២០១៣ ហើយកម្មវិធីនេះត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយកំណែទម្រង់ដីធ្លីរបស់រដ្ឋាភិបាលកម្ពុជា។

អ្នកសិក្សាស្រាវជ្រាវ បានលើកជាសំណួរ និងសេចក្តីបារម្ភនានាអំពីវិធីសាស្ត្រ និងការអនុវត្តយុទ្ធនាការនេះ ដែលតែងត្រូវបានមើលឃើញថា មានលក្ខណៈនយោបាយ និងយោធា។ ក្រៅពីនេះប្រព័ន្ធផ្សព្វផ្សាយបានរាយការណ៍ពីហេតុការណ៍នានា ដែលប្រជាជនមួយចំនួនត្រូវបានបដិសេធពីការ

---

[៥] ម៉ាក ហ្គ្រីមឌីជ កុល ល័ក្ខកញ្ញា និង ឌីពីកា សឺចាន់ (ឆ្នាំ២០១២). *"ការទទួលបានកម្មសិទ្ធិដីធ្លីនៅកម្ពុជា: ការសិក្សាលើការចុះបញ្ជីជាប្រព័ន្ធ នៅខេត្តចំនួនបី និងរាជធានី នៃប្រទេសកម្ពុជា."* វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា http://library.opendevelopmentcambodia.net:8080/newgenlibctxt/View?CatId=2469&OwnLibId=1&LibraryId=1&From=Library។

[៦] ក្រុមប្រឹក្សាភិបាលអភិវឌ្ឍន៍និងស្តារកម្ពុជា និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ឆ្នាំ២០១១). *"កំណត់ត្រាសង្ខេបនៃកិច្ចចរចារ ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍រវាងរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាឡឺម៉ង់ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នៅទីក្រុងប៊ន កាលពីថ្ងៃទី ១៣-១៤ ខែធ្នូ ឆ្នាំ២០១១."* ចូលអាននៅថ្ងៃទី ៣០ ខែមីនាឆ្នាំ២០២៤។

[៧] អូន ភាព (ឆ្នាំ២០១៤). *"និស្សិតស្ម័គ្រចិត្តចូលនិវត្តន៍ពីកម្មវិធីផ្តល់កម្មសិទ្ធិដីធ្លីរបស់រដ្ឋាភិបាល."* ឌឹ ខេបូឌា ដេលី. ថ្ងៃទី ២៦ ខែធ្នូ។

វាស់វែងដី ដោយសារតែដីរបស់ពួកគាត់ជាដីជម្លោះ ហើយការចុះបញ្ជីសិទ្ធិកម្មសិទ្ធិសមូហភាពសម្រាប់សហគមន៍ជនជាតិដើមភាគតិចត្រូវបានផ្អាក។[៨]ម្យ៉ាងវិញទៀត ហេតុការណ៍ជាច្រើនត្រូវបានរាយការណ៍ពាក់ព័ន្ធនឹងដីដែលត្រូវបានវាស់វែង និងមានការសន្យាផ្តល់បណ្ណកម្មសិទ្ធិ ប៉ុន្តែវិញ្ញាបនប័ត្រកម្មសិទ្ធិ មិនត្រូវបានផ្តល់ឱ្យទេ។

ជាសរុបមក យោងតាមក្រសួងរៀបចំដែន នគររូបនីយកម្ម និងសំណង់ បណ្ណកម្មសិទ្ធិជាង ៣,៨លានច្បាប់ ត្រូវបានចេញជូនប្រជាពលរដ្ឋ ហើយដីជាង ១លានហិកតា ត្រូវបានកាត់ចេញពីដីរដ្ឋ និងយកមកធ្វើចំណាត់ថ្នាក់សារជាថ្មី។[៩] រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាមានបំណងចុះបញ្ជីដីកាន់កាប់ជាឯកជនទាំងអស់នៅប្រទេសកម្ពុជា។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាមានបំណងពន្លឿនការចុះបញ្ជីដីធ្លី និងការចេញបណ្ណកម្មសិទ្ធិ ដោយផ្តល់អាទិភាពទៅឱ្យការផ្តល់កម្មសិទ្ធិដីនៅក្នុងតំបន់គ្មានជម្លោះ។

## ១.២. យន្តការនៃការអនុវត្ត

### ១.២.១ រចនាសម្ព័ន្ធគណៈកម្មការសុរិយោដី

គណៈកម្មការសុរិយោដីមានរចនាសម្ព័ន្ធ ៣ថ្នាក់គឺ (១) គណៈកម្មកាសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌដែលដោះស្រាយវិវាទដោយការសម្រុះសម្រួល (២) គណៈកម្មការសុរិយោដីថ្នាក់រាជធានីខេត្ត ដែលដោះស្រាយវិវាទដោយការសម្រុះសម្រួល និងធ្វើសេចក្តីសម្រេច និង (៣) គណៈកម្មការសុរិយោដីថ្នាក់ជាតិដែលដោះស្រាយវិវាទដោយធ្វើសេចក្តីសម្រេច និង/ឬធ្វើការសម្រុះសម្រួលតាមការចាំបាច់។

### ១.២.២ ឋានានុក្រមនៃផែនការរៀបចំដែនដី

ស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនិងផ្អែកលើមូលដ្ឋាននៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនិងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំសង្កាត់ សមត្ថកិច្ចក្នុងការផ្តួចផ្តើមរៀបចំការសម្របសម្រួល និងការសម្រេចលើផែនការរៀបចំដែនដី មាន ៤កម្រិតថ្នាក់រដ្ឋបាលគឺ៖

### ក. ផែនការរៀបចំដែនដីថ្នាក់ជាតិ និងតាមតំបន់

ផ្តួចផ្តើម និងរៀបចំឡើងដោយគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ ដែលដឹកនាំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលមានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច២០(ម្ភៃ)ឆ្នាំ និងសម្រេចដោយព្រះរាជក្រឹត្យ ហើយអាចធ្វើការកែសម្រួលក្រោយរយៈពេល

---

[៨] ក្រុមប្រឹក្សាសម្រាប់គោលនយោបាយដីធ្លី, សេចក្តីបង្គាប់លេខ២០ ស្តីពី***ការអនុវត្តបទបញ្ជា លេខ០១ របស់រាជរដ្ឋាភិបាល*** (ឆ្នាំ២០១២)៖ ទំព័រ២៦។

[៩]ក្រសួងរៀបចំដែន នគររូបនីយកម្ម និងសំណាង់ (ខែធ្នូ ឆ្នាំ២០១៤)។

១០(ដប់) ឆ្នាំម្តងតាមសំណើរបស់រាជរដ្ឋាភិបាល លើកលែងតែមានការចាំបាច់ទើបអាចធ្វើការកែសម្រួលមុនរយៈពេលនេះ[10]។

**ខ. ថ្នាក់រាជធានី ខេត្ត**

មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីសម្រាប់ រាជធានីហើយនៅថ្នាក់ខេត្តមានតែផែនការរៀបចំដែនដីថ្នាក់ខេត្ត។ គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្តជាអ្នកផ្តួចផ្តើមរៀបចំការងារទាំងនេះដោយមានការឯកភាព ពីក្រុមប្រឹក្សារាជធានី ខេត្ត។ ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដីថ្នាក់រាជធានីនិង ផែនការរៀបចំដែនដីថ្នាក់ខេត្ត ដែលមានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច២០ (ម្ភៃ)ឆ្នាំ អាចធ្វើការកែសម្រួលក្នុងរយៈពេល ៥ឆ្នាំម្តង និងត្រូវសម្រេចដោយអនុក្រឹត្យ បន្ទាប់ពីការយល់ព្រមពីគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ។

**គ. ថ្នាក់ក្រុង ស្រុក ខណ្ឌ**

មានប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ហើយនៅថ្នាក់ស្រុកខណ្ឌមានតែប្លង់គោលប្រើប្រាស់ដីប៉ុណ្ណោះ។ ការផ្តួចផ្តើមការងារទាំងនេះ ត្រូវផ្តើមចេញពីគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលមានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច១៥ (ដប់ប្រាំ)ឆ្នាំ និងអាចធ្វើការកែសម្រួលក្នុងរយៈពេល ៤ឆ្នាំម្តង ដោយមានការឯកភាពពីក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងការយល់ព្រមពីក្រុមប្រឹក្សារាជធានីខេត្ត តាមរយៈគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានីខេត្ត និងត្រូវសម្រេចដោយគណៈកម្មាធិការរៀបចំដែនដី និងនគរូបនី-យកម្មថ្នាក់ជាតិ។

**ឃ. ថ្នាក់ឃុំ សង្កាត់**

ផែនការប្រើប្រាស់ដីត្រូវផ្តួចផ្តើមរៀបចំដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានការសម្របសម្រួល និងគាំទ្របច្ចេកទេសពីគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ និងមានចក្ខុវិស័យសម្រាប់រយៈពេលពី ១០ទៅ១៨ឆ្នាំ និងអាចធ្វើការកែសម្រួលក្នុងរយៈពេល ៥ឆ្នាំម្តងតាមការចាំបាច់។ ផែនការប្រើប្រាសដីឃុំ សង្កាត់ ត្រូវមានការឯកភាពពីក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងការសម្រេចពីក្រុមប្រឹក្សាជាតិបន្តតាមរយៈគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានីខេត្ត ស្របតាមស្មារតីនៃអនុក្រឹត្យ លេខ៧២ ស្តីពីផែនការប្រើប្រាស់ដីក្នុងឃុំ សង្កាត់។

**១.២.៣ មូលដ្ឋានគតិយុត្តនៃការចុះបញ្ជីដីធ្លី**

ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា៣ បានចែងថា «ជនគ្រប់រូបត្រូវគោរពទ្រព្យសម្បត្តិរបស់រដ្ឋ និងកម្មសិទ្ធិឯកជនស្របច្បាប់លើអចលនវត្ថុ។ ការគ្រប់គ្រងផ្នែករដ្ឋបាលសុរិយោដីលើអចលនវត្ថុដែលជា

---

[10] ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់, *គោលនយោបាយដីធ្លី*, ឆ្នាំ២០១៥ ទំព័រ៣៨។

ទ្រព្យសម្បត្តិរបស់រដ្ឋ និងការចេញបណ្ណកម្មសិទ្ធិលើអចលនវត្ថុទូទាំងព្រះរាជាណាចក្រកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់»។ ជាមួយនេះ មាត្រា២៦៦ ក៏បានកំណត់ថា «កម្មសិទ្ធិលើអចលនវត្ថុត្រូវបានធានាដោយរដ្ឋ។ រដ្ឋបាលសុរិយោដីក្រោមការគ្រប់គ្រងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាស្ថាប័នមានសមត្ថកិច្ច ក្នុងការធ្វើអត្តសញ្ញាណកម្មទ្រព្យ កសាងប្លង់សុរិយោដី ចេញបណ្ណកម្មសិទ្ធិ ចុះបញ្ជីដី និងផ្តល់ព័ត៌មានដល់ជនទាំងឡាយអំពីស្ថានភាពក្បាលដីទាក់ទងទៅនឹងប្រភេទទំហំ កម្មសិទ្ធិករ និងបន្ទុកផ្សេងៗដែលមានលើក្បាលដីនោះ»។ ការគ្រប់គ្រងដីឬរដ្ឋបាលដីធ្លីនៅព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តតាមប្រព័ន្ធចុះបញ្ជីដី ក្នុងសៀវភៅគោលបញ្ជីដីធ្លី និងប្លង់សុរិយោដី នៅរដ្ឋបាលសុរិយោដីនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ប្រព័ន្ធនេះមានភាពខុសប្លែកពីប្រទេសមួយចំនួនដែលគ្រប់គ្រងដីធ្លីដោយប្រើប្រព័ន្ធកត់ត្រា ដែលក្នុងនោះការបង្កើត ការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្សធ្វើឡើងទៅតាមការព្រមព្រៀងរវាងភាគីពាក់ព័ន្ធ។ ផ្អែកលើគោលការណ៍នេះ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាក៏បានចែងបញ្ជាក់ក្នុងមាត្រា១៣៨ និងមាត្រា១៣៥ថា «ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀងមិនអាចតតាំងនឹងតតិយជនបាន និងមិនមានអានុភាពឡើយ បើមិនបានចុះបញ្ជីដោយយោងតាមបញ្ញត្តិនៃច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀតស្តីពីការចុះបញ្ជី»។

ការចុះបញ្ជីអចលនទ្រព្យ គឺជាបញ្ហាគន្លឹះក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្រជាជាតិមួយ ទាំងទ្រព្យរបស់រដ្ឋទាំងទ្រព្យរបស់បុគ្គលឯកជន។ បច្ចុប្បន្ន ការចុះបញ្ជីដីធ្លីផ្អែកទៅលើសិទ្ធិភោគៈស្របច្បាប់ដែលប្រជាពលរដ្ឋបានកាន់កាប់និងប្រើប្រាស់ជាក់ស្តែង ដោយអនុវត្តទៅតាមស្មារតីនៃអនុក្រឹត្យលេខ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ឬហៅថាការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ[១១] ឬទៅតាមស្មារតីនៃអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ តាមការស្នើសុំពីបុគ្គលម្ចាស់សិទ្ធិ[១២]។ នីតិវិធី និងដំណើរការនៃការចុះបញ្ជីដីធ្លីទាំងនេះជានីតិវិធីមានតម្លាភាព ដោយតម្រូវឱ្យមានការចូលរួមកំណត់ទីតាំង និងព្រំប្រទល់ក្បាលដីពីអ្នកអះអាងថាជាម្ចាស់លើអចលនទ្រព្យ មានការព្រមព្រៀងពីអ្នកជាប់ព្រំ និងឆ្លងកាត់ការបិទផ្សាយជាសាធារណៈរយៈពេល ៣០ថ្ងៃនូវទិន្នន័យដែលប្រមូលបានសម្រាប់ការចុះបញ្ជីផ្សេងៗ។ ការចុះបញ្ជីគឺផ្អែកទៅលើព័ត៌មានរបស់អ្នកអះអាងថាជាម្ចាស់ទ្រព្យដែលអាចជាទ្រព្យរួមប្តីប្រពន្ធ ទ្រព្យកូន( នីតិជន ) ជាទ្រព្យដោយឡែករបស់ប្តី ឬរបស់ប្រពន្ធ ទ្រព្យលីវ ទ្រព្យសមូហភាព ទ្រព្យរបស់នីតិបុគ្គលដែលមាននីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈ។ ទន្ទឹមនឹងនេះ ទាក់ទងនឹងការចុះបញ្ជី ក៏មានប្រកាសអន្តរក្រសួងរវាងក្រសួងយុត្តិធម៌

---

[១១] រាជរដ្ឋាភិបាល អនុក្រឹត្យលេខ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី *នីតិវិធីនៃការកសាងប្លង់សុរិយោដីនិងសៀវភៅគោលបញ្ជីដីធ្លីឬហៅថាការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ។*

[១២] អនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី *ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ តាមការស្នើសុំពីបុគ្គលម្ចាស់សិទ្ធិ។*

និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ លេខ៥៩ ប្រក.ដ.ន.ស/១១ ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១១ ស្តីពី "ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី និងលេខ៣០ កយ.ជនស.ប្រក/១៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី»[១៣]។

## ក. ប្រសិទ្ធភាពនិងបញ្ហាប្រឈមក្នុងការចុះបញ្ជីដីធ្លី

ការចុះបញ្ជីដីធ្លី គឺជាផ្នែកដ៏សំខាន់មួយ ដែលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។ តាមការវិភាគលើសំណាកនៃគ្រួសារប្រកបរបរកសិកម្មបានបង្ហាញថា ហានិភ័យនៃភាពក្រីក្ររបស់គ្រួសារនានានឹងអាចកាត់បន្ថយ នៅពេលមានកំណើនលទ្ធភាពនៃការប្រើប្រាស់ដីធ្លី ជាពិសេស នៅពេលដែលមានការធានាកម្មសិទ្ធិ តាមរយៈការចេញបណ្ណកម្មសិទ្ធិលើដីធ្លី។ ការវិភាគក៏បានរកឃើញផងដែរថា ក្រៅពីការកែលម្អដីធ្លី ការរៀបចំប្រព័ន្ធស្រោចស្រព និងការផ្តល់ចំណេះដឹងអំពីការដាំដុះ នៅមានកត្តាអថេរមួយចំនួនទៀត ដែលមានឥទ្ធិពលខ្លាំងក្លាផងដែរលើភាពក្រីក្រ នោះគឺកត្តាសមាសភាពនៃគ្រួសារ និងមុខជំនួញប្រចាំគ្រួសារ។ ដូច្នេះ កំណែទម្រង់ដីធ្លី គប្បីផ្សារភ្ជាប់ជាមួយនឹងកម្មវិធីកំណែទម្រង់ដទៃទៀត ជាពិសេស ខាងផ្នែកកសិកម្ម និងកម្មវិធីបង្កើតមុខរបរ ទើបការកាត់បន្ថយភាពក្រីក្រមានប្រសិទ្ធភាពខ្ពស់។ ក្នុងដំណើរការចុះបញ្ជីដីធ្លី ក្រុមការងារចុះទីតាំងជាក់ស្តែងដែលចុះធ្វើអត្តសញ្ញាណកម្មដីនិងម្ចាស់ដី នៅតាមតំបន់វិនិច្ឆ័យ តែងជួបនឹងបញ្ហាប្រឈមមួយចំនួន ជាអាទិ៍៖

- ប្រជាពលរដ្ឋជាម្ចាស់អចលនវត្ថុខ្លះ ជាម្ចាស់ស្របច្បាប់ ខ្វះលិខិតនិង/ឬឯកសារណាមួយផ្សេងៗបញ្ជាក់ភាពស្របច្បាប់
- ការចូលរួមរបស់អ្នកកាន់កាប់ដី ឬស្ថាប័នដែលមានអាណត្តិកាន់កាប់ដីរដ្ឋនៅមានកម្រិត
- ការដោះស្រាយវិវាទដីធ្លីក្នុងតំបន់វិនិច្ឆ័យមានភាពយឺតយ៉ាវ និងច្រើនតែកកស្ទះ
- តំបន់រងទឹកជំនន់នៅជុំវិញបឹងទន្លេសាប នារដូវវស្សាមានភាពមិនច្បាស់លាស់
- ដីចំណីទន្លេ ព្រែក ស្ទឹង បឹងបួរ នៅមិនទាន់បានកំណត់ដាក់លាក់តាមទីតាំងខ្លះ
- ការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិអាចជួបនឹងកង្វះសំណុំលិខិតពេញលេញជាមូលដ្ឋានពីសំណាក់ម្ចាស់ចំណែកឯកជន[១៤]។

## ខ. វិធានការពិសេសនៃការចុះបញ្ជីដីធ្លី

នៅខែឧសភា ឆ្នាំ២០១៦ ប្រឈមនឹងស្ថានភាពមិនច្បាស់លាស់ នៃការកាន់កាប់ដីព្រៃ និងទំនាស់ដីធ្លីនៅតាមតំបន់មួយចំនួនរវាងប្រជាជននិងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដែលធ្វើឱ្យសម្បទានិក

---

[១៣] ប្រកាសអន្តរក្រសួងលេខ៥៩ ប្រក.ដ.ន.ស/១១ ចុះថ្ងៃទី៣ ខែ ឧសភា ឆ្នាំ២០១១ ស្តីពី ***ការចុះបញ្ជីអចលនវត្ថុ ទាក់ទង និងក្រមនីតិវិធីរដ្ឋប្បវេណី*** និង លេខ៣០ កយ.ជនស.ប្រក/១៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពី***នីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី។***

[១៤] ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់, ***គោលនយោបាយដីធ្លី***, ឆ្នាំ២០១៥ ទំព័រ២៥។

មិនអាចអនុវត្តគម្រោងអភិវឌ្ឍរបស់ខ្លួនបានតាមផែនការ ហើយប្រជាជនក៏មានភាពស្ទាក់ស្ទើរ ក្នុងការប្រើប្រាស់ដីឱ្យអស់ផលិតភាពនៃដី រាជរដ្ឋាភិបាលបានសម្រេចចាត់វិធានការពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ដោយដាក់ចេញនូវបទបញ្ជាលេខ០១បប ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ ក្នុងគោលដៅអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់នូវគោលនយោបាយ និងរាល់លក្ខខណ្ឌនៃសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ស្តីពីការផ្តល់សម្បទានដីសេដ្ឋកិច្ច[១៥] ដោយអនុវត្តតាមនយោបាយរូបមន្តស្បែកខ្លា មិនឱ្យប៉ះពាល់ដីធ្លីសហគមន៍ និងដីវភាពរស់នៅរបស់ប្រជាជន ព្រមទាំងផ្អាកជាបណ្តោះអាសន្ននូវការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មីៗ។ នេះជាការពង្រឹងការអនុវត្តគោលនយោបាយ និងបទដ្ឋានគតិយុត្តដែលមានជាធរមាន ដោយរៀបចំកម្មវិធី និងសកម្មភាពជាក់ស្តែងសម្រាប់អនុវត្ត។ ក្នុងការអនុវត្តបទបញ្ជាលេខ០១នេះ រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មការត្រួតពិនិត្យការអនុវត្តនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី ដឹកនាំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ដើម្បីត្រួតពិនិត្យនិងផ្តល់មតិជូនប្រមុខរាជរដ្ឋាភិបាលសម្រេចលើសំណើសុំកាត់ដី ដែលស្ថិតក្នុងតំបន់ដីព្រៃសម្បទានដីសម្បទានសេដ្ឋកិច្ច និងដីរដ្ឋដែលមានពីការដកហូតដោយអាជ្ញាធរខេត្ត ដើម្បីចែកជូនប្រជាជនដែលបានកាន់កាប់ជាក់ស្តែង។ ការអនុវត្តបទបញ្ជាលេខ ០១បប គឺជាកំណែទម្រង់ដីធ្លីក្នុងទ្រង់ទ្រាយធំមួយដែលត្រូវបានយកចិត្តទុកដាក់ជាពិសេសពីប្រមុខរាជរដ្ឋាភិបាល ដោយប្រើប្រាស់គ្រប់មធ្យោបាយ និងលទ្ធភាពកម្លាំងមន្ត្រីជំនាញ ព្រមទាំងកម្លាំងវីរយុវជនស្ម័គ្រចិត្ត ក្នុងការធ្វើអត្តសញ្ញាណកម្មដី អត្តសញ្ញាណកម្មអ្នកដែលបានកាន់កាប់ និងប្រើប្រាស់ដីជាក់ស្តែង ដើម្បីសម្រេចកាត់ចេញពីរដ្ឋ ធ្វើអនុបយោគតាមករណីនៃក្បាលដីរដ្ឋនីមួយៗ និងធ្វើប្រទានកម្មជូនដល់ប្រជាជនជាអ្នកផលិត។ យុទ្ធនាការកែទម្រង់ដីធ្លីនេះមានវិសាលភាពគ្របដណ្តប់ ២១ខេត្ត ក្នុងចំណោមរាជធានី ខេត្តទាំង២៥។ ទន្ទឹមនឹងយុទ្ធនាការធ្វើប្រទានកម្មពីរដ្ឋដោយការផ្តល់បណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាជន រាជរដ្ឋាភិបាលបានចេញសារាចរណែនាំលេខ ០២ សរណន ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣ ដើម្បីផ្តល់បណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាជនដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះដាក់ស្តែងនាវដូវសម្រកនៅតំបន់វាលទំនាបដែលលិចទឹកនៃផ្ទៃដីដែលទទួលរបបទឹកទន្លេមេគង្គ រហូតដល់ព្រំប្រទល់ខេត្តកណ្តាល លើកលែងតំបន់លិចទឹកជុំវិញបឹងទន្លេសាប[១៦]។ ដូច្នេះ ប្រជាជនដែលបានទទួលបណ្ណកម្មសិទ្ធិ ត្រូវប្រើប្រាស់ អាស្រ័យផល និងចាត់ចែងដីជាកម្មសិទ្ធិ របស់ខ្លួនឱ្យស្របតាមវិធានដីក្នុងទំហំដែលច្បាប់បានកម្រិត។ ក្នុងការអនុវត្តនយោបាយចាស់សកម្មភាពថ្មី ដីរដ្ឋដែលបានឆ្កៀលចេញពីតំបន់សម្បទាន ដីសេដ្ឋកិច្ច ពីដីសម្បទានព្រៃឈើ ឬពីដីព្រៃដែលមានដីកាដកហូត ដើម្បីធ្វើប្រទានកម្មជូនប្រជាជន ហើយនៅសល់ពីការធ្វើប្រទានកម្មនេះ នឹងត្រូវរក្សាទុកជាព្រៃបម្រុងទុកអចិន្ត្រៃយ៍ ឬ ទុកសម្រាប់សហគមន៍ប្រើប្រាស់នៅពេលមានកំណើនប្រជាជននាពេលខាងមុខ។

[១៥] រាជរដ្ឋាភិបាល បទបញ្ជាលេខ០១បប ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ ស្តីពី ***ការផ្តល់សម្បទានដីសេដ្ឋកិច្ច។***

[១៦] រាជរដ្ឋាភិបាល, សារាចរណែនាំលេខ០២ សរណន ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣ស្តីពី *ការផ្តល់បណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាជនដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះដាក់ស្តែង។*

## គ. ការចុះបញ្ជីក្បាលដីនិងអគារសហកម្មសិទ្ធិ

ដើម្បីគ្រប់គ្រងអគារសហកម្មសិទ្ធិ និងធានាសិទ្ធិកម្មសិទ្ធិស្របច្បាប់របស់អ្នកកាន់កាប់ ចំណែកឯកជននៃអគារសហកម្មសិទ្ធិ រាល់ចំណែកឯកជន នៃអគារសហកម្មសិទ្ធិ ត្រូវធ្វើការចុះបញ្ជី ដោយអនុលោមតាមស្មារតីនៃអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ[១៧]។

អគារសហកម្មសិទ្ធិ សំដៅលើសំណង់ ឬអគារដែលមានអ្នកកាន់កាប់ច្រើននាក់រស់នៅ ដូចជាខុនដូ ផ្ទះល្វែង ភូមិគ្រឹះ ពាក់កណ្តាលភូមិគ្រឹះ និងប្រភេទផ្ទះផ្សេងទៀតដែលមានរចនាសម្ព័ន្ធជាប់ៗគ្នា។ ដោយសារតែមានម្ចាស់ច្រើននាក់ដូច្នេះ នីតិវិធីនៃចុះបញ្ជីចំណែកកម្មសិទ្ធិក៏ធ្វើឡើងខុសពីអចលនទ្រព្យធម្មតាដែរ។

អគាសហកម្មសិទ្ធិដែលចុះបញ្ជីចំណែកឯកជនបាន ត្រូវតែជាអគារដែលបញ្ចប់ការសាងសង់ ១០០% និងបានរៀបចំខណ្ឌជញ្ជាំងចំណែកឯកជនរួចរាល់តាមប្លង់អនុញ្ញាត។ សហកម្មសិទ្ធករដែលកំពុងកាន់កាប់ ឬជួលអចិន្ត្រៃយ៍នៅលើចំណែកឯកជននៃអគារសហកម្មសិទ្ធិនេះ ត្រូវមកដាក់ពាក្យស្នើសុំចុះបញ្ជីជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ច តាមនីតិវិធីដូចខាងក្រោមនេះ៖

### ក. ឯកសារពាក់ព័ន្ធ

នៅពេលធ្វើការស្នើសុំ ម្ចាស់ចំណែកឯកជននៃអគាសហកម្មសិទ្ធិត្រូវភ្ជាប់មកជាមួយនូវឯកសារចាំបាច់ ដូចជា៖

- លិខិតអនុញ្ញាតសាងសង់
- វិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវនៃសំណង់ ឬលិខិតបិទការដ្ឋានសំណង់ ឬលិខិតបញ្ជាក់ការសាងសង់
- ឯកសារប្លង់ស្ថាបត្យកម្មលម្អិតនៃអគារសហកម្មសិទ្ធិដោយបញ្ជាក់ពីចំនួនជាន់ ចំនួនចំណែកឯកជនដោយមានលេខយោង និងពត៌មានអំពីចំណែករួមនៃអគារ
- បទបញ្ជាផ្ទៃក្នុង
- ឯកសារបញ្ជាក់អត្តសញ្ញាណសហកម្មសិទ្ធិករ
- ឯកសារពាក់ព័ន្ធផ្សេងទៀត ប្រសិនបើមាន។

ម្ចាស់ចំណែកឯកជននោះ ត្រូវមកបំពេញពាក្យស្នើសុំនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ដែលអគារសហកម្មសិទ្ធិនោះស្ថិតនៅ។ ក្រោយមកមន្ត្រីនៅទីនោះនឹងចេញបង្កាន់ដៃទទួលពាក្យជូនអ្នកស្នើសុំ។

[១៧] អនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពី *ការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ*

## ខ. ការត្រួតពិនិត្យ

### ១. ការិយាល័យភូមិបាលក្រុង ស្រុក ខណ្ឌ

មន្ត្រីនៅការិយាល័យភូមិបាល ត្រូវពិនិត្យទម្រង់ និងឯកសារភ្ជាប់ឱ្យបានត្រឹមត្រូវ ហើយបញ្ជូនពាក្យស្នើសុំចុះបញ្ជីទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីខេត្ត ក្នុងរយៈពេល ៣ថ្ងៃធ្វើការយ៉ាងយូរ ដើម្បីពិនិត្យ និងសម្រេច។ ក្រោយពីមន្ទីរសុរិយោដីសម្រេចឱ្យអនុវត្តការចុះបញ្ជី មន្ត្រីនៅការិយាល័យភូមិបាល ត្រូវជូនដំណឹងទៅដល់អ្នកស្នើសុំក្នុងរយៈពេល ១សប្តាហ៍ មុននឹងចុះប្រមូលទិន្នន័យ។ បន្ទាប់មក មន្ត្រីភូមិបាល អ្នកអភិវឌ្ឍអចលនវត្ថុ និងសហកម្មសិទ្ធិករ នឹងចុះទៅផ្ទៀងផ្ទាត់ និងប្រមូលទិន្នន័យក្នុងរយៈពេល០១ សប្តាហ៍យ៉ាងយូរ។ ទិន្នន័យទាំងអស់នឹងត្រូវបញ្ជូនមន្ទីរសុរិយោដីដើម្បីបន្តនីតិវិធី។

### ២.មន្ទីរសុរិយោដីរាជធានី ខេត្ត

មន្ត្រីជំនាញនៅមន្ទីរ នឹងត្រួតពិនិត្យលើទិន្នន័យនោះ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវ។ ក្នុងករណីមានភាពមិនច្បាស់លាស់ មន្ទីរអាចចាត់មន្ត្រីជំនាញចុះស៊ើបអង្កេតបញ្ជាក់បន្ថែមក្នុងរយៈពេលយ៉ាងយូរ ១សប្តាហ៍។

## គ. ការបិទផ្សាយ

ក្រោយពិនិត្យ មន្ទីរសុរិយោដី នឹងសម្រេចឱ្យការិយាល័យភូមិបាល ធ្វើការបិទផ្សាយជាសាធារណៈនូវលទ្ធផលនៃការប្រមូលទិន្នន័យរយៈពេល១សប្តាហ៍ នៅសាលាឃុំ សង្កាត់ ដែលអចលនវត្ថុនោះស្ថិតនៅ។ ការបិទផ្សាយនេះ គឺដើម្បីឱ្យសហកម្មសិទ្ធិករទាំងអស់ និងអ្នកមានផលប្រយោជន៍អាចតវ៉ា ឬស្នើកែតម្រូវ[១៨]។

## ឃ. ការចុះបញ្ជី

ក្នុងករណីដែលមានវិវាទ ការិយាល័យភូមិបាលត្រូវព្យាយាមសម្រុះសម្រួល ឬបញ្ជូនករណីវិវាទនេះទៅកាន់តុលាដោះស្រាយតាមផ្លូវច្បាប់ បើករណីមិនមានការឯកភាពគ្នា។ ដោយឡែក ករណីគ្មានបណ្តឹងតវ៉ា មន្ទីរសុរិយោដីរាជធានី ខេត្ត នឹងចុះបញ្ជីកម្មសិទ្ធិឱ្យអ្នកស្នើក្នុងរយៈពេល ១សប្តាហ៍យ៉ាងយូរ។ ការចុះបញ្ជី និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់នេះ ត្រូវបង់ថ្លៃសេវានៅមន្ទីរសុរិយោដីចំនួន ១ ៦០០ ០០០ រៀល ដែលមានសុពលភាពជាអចិន្ត្រៃយ៍។

ប្រភេទអគារសហកម្មសិទ្ធិ ដែលបានសាងសង់មុនថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ការស្នើសុំមិនតម្រូវឱ្យមានវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវនៃសំណង់ លិខិតបិទការដ្ឋានសំណង់ ឬឯកសារប្លង់ស្ថាបត្យកម្មលម្អិតនៃអគារសហកម្មសិទ្ធិឡើយ។ ដោយឡែក ចំពោះអគារណា ដែលសាងសង់ក្រោយ

---

[១៨] https://construction-property.com/km/what-are-the-procedures-to-register-a-private-unit-of-co-owned-buildings/

ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ រហូតដល់អនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ ២០០៩ ចូលជាធរមាន ហើយពុំមានលិខិតអនុញ្ញាតសាងសង់ តម្រូវឱ្យធ្វើនិយតកម្មលើប្លង់ស្ថាបត្យកម្ម ជាមុខសិន[១៩]។

## ឃ. គោលការណ៍នៃការអនុវត្តសិទ្ធិរបស់សហកម្មសិទ្ធិករ

ការផ្តល់កម្មសិទ្ធិជូនសហកម្មសិទ្ធិករ គឺផ្តល់តែលើចំណែកឯកជននៃអគារសហកម្មសិទ្ធិប៉ុណ្ណោះ ឯចំណែករួម ត្រូវរក្សាទុកសម្រាប់ប្រើប្រាស់ជារួម ដោយសហកម្មសិទ្ធិករទាំងអស់។ ក្បាលដីដែលសំណង់អគារសហកម្មសិទ្ធិតាំងនៅត្រូវចុះបញ្ជីជាក្បាលដីតែមួយ នៅរដ្ឋបាលសុរិយោដី។ នៅពេលដែលអ្នកវិនិយោគ ឬអ្នកអភិវឌ្ឍសំណង់អចលនវត្ថុធ្វើការផ្ទេរលើកដំបូង នៃចំណែកឯកជនណាមួយជូនទៅសហកម្មសិទ្ធិករណាម្នាក់ អ្នកវិនិយោគ ឬអ្នកអភិវឌ្ឍសំណង់ អចលនវត្ថុត្រូវប្តូរប្រភេទក្បាលដីនោះឱ្យទៅជាក្បាលដីសហកម្មសិទ្ធិ និងត្រូវមានបទបញ្ជាផ្ទៃក្នុងពាក់ព័ន្ធនឹងការគ្រប់គ្រងអគារសហកម្មសិទ្ធិភ្ជាប់ជាមួយ។ បន្ទាប់មក វិនិយោគិនឬអ្នកអភិវឌ្ឍសំណង់អគារសហកម្មសិទ្ធិត្រូវប្រគល់បណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនៃក្បាលដីឱ្យទៅរដ្ឋបាលសុរិយោដីធ្វើលេខាចារឹកនិងរក្សាទុក ហើយរដ្ឋបាលសុរិយោដីត្រូវចេញជូនជាជំនួសមកវិញនូវវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជនទាំងអស់ នៃអគារសហកម្មសិទ្ធិ។ ដូច្នេះ មុននឹងប្រកាសលក់ឬជួលចំណែកឯកជននៃអគារសហកម្មសិទ្ធិ អ្នកសាងសង់អគារសហកម្មសិទ្ធិ ត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងមួយដែលមានចែងអំពីសិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់សហកម្មសិទ្ធិករលើចំណែកឯកជន និងលើកំណែករួម ការចាត់ចែងលើចំណែកឯកជន ការគ្រប់គ្រងអគារសហកម្មសិទ្ធិ និងសមាមាត្រនៃការចំណាយលើការជួសជុល ការថែទាំនិងការចំណាយផ្សេងៗ។ ក្នុងករណីដែលអគារសហកម្មសិទ្ធិចុះទ្រុឌទ្រោម មិនអាចស្នាក់នៅបាន ឬទទួលរងមហន្តរាយដោយប្រការណាមួយ សហកម្មសិទ្ធិករទាំងអស់អាចឯកភាពគ្នាជួសជុលឬសាងសង់ឡើងវិញ ហើយបន្ទុកនៃចំណាយត្រូវស្របតាមសមាមាត្រទៅនឹងតម្លៃនៃឡូត៍នីមួយៗ តាមបទបញ្ជាផ្ទៃក្នុងរបស់អគារសហកម្មសិទ្ធិ ឬតាមការព្រមព្រៀងគ្នាកន្លងមក ជាកិច្ចសន្យាដោយឡែក។ ក្នុងការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិក្នុងសៀវភៅគោលបញ្ជី ត្រូវកត់ត្រាទិន្នន័យលម្អិតអំពីចំណែកឯកជន នៃអគារសហកម្មសិទ្ធិនិងម្ចាស់កម្មសិទ្ធិ ដែលតម្រូវឱ្យមានការរៀបចំកម្មវិធីកុំព្យូទ័រដោយឡែកសម្រាប់បញ្ចូលទិន្នន័យទាំងនេះ[២០]។

## ង. ការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស

ជនបរទេសដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់ អាចមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ ស្របតាមច្បាប់ជាធរមាន ជាសហកម្មសិទ្ធិពិសេសចាប់ពីជាន់ទីមួយ

---

[១៩] *-ដ-ឯ-ម-។*

[២០] ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់, *គោលនយោបាយដីធ្លី*, ឆ្នាំ២០១៥ ទំព័រ២៧។

ឡើងទៅ និងមិនឱ្យលើសពីចិតសិបភាគរយ(៧០%) នៃចំណែកឯកជនទាំងអស់នៃអគារសហកម្មសិទ្ធិនីមួយៗ។ សហកម្មសិទ្ធិករពិសេសទទួលបាននូវរាល់សិទ្ធិដូចសហកម្មសិទ្ធិករសញ្ជាតិខ្មែរដែរ លើកលែងតែសិទ្ធិលើដីធ្លីដែលអគារសហកម្មសិទ្ធិតាំងនៅ។ ប៉ុន្តែ ក្នុងករណីដែលអគារសហកម្មសិទ្ធិរងនូវមហន្តរាយណាមួយ សហកម្មសិទ្ធិករពិសេសក៏មានសិទ្ធិ ទទួលបាននូវផលប្រយោជន៍ពីសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើចំណែករួម ស្របតាមសមាមាត្រទៅនឹងផ្ទៃក្រឡានៃទំហំចំណែកឯកជនរបស់ខ្លួន ឬតាមការព្រមព្រៀងគ្នាពីមុនឬតាមបទបញ្ជាផ្ទៃក្នុង[២១]។

### ច. ការចុះបញ្ជីដីកម្មសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិច

ច្បាប់ភូមិបាលឆ្នាំ២០០១ ទទួលស្គាល់ដីរបស់ជនជាតិដើមភាគតិច ជាដីកម្មសិទ្ធិសមូហភាពរបស់សហគមន៍។ លក្ខខណ្ឌជាក់លាក់នៃការប្រើប្រាស់ដីត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរប្រពៃណី ឬគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិច ឬយន្តការនៃការធ្វើសេចក្តីសម្រេចចិត្តរបស់សហគមន៍។ ដូច្នេះ របបកម្មសិទ្ធិសមូហភាពរបស់សហគមន៍មានលក្ខណៈប្លែកពីកម្មសិទ្ធិឯកជន ពីព្រោះក្បាលដីទាំងឡាយរបស់សហគមន៍ មានចំណែកខ្លះជាដីឯកជនរបស់រដ្ឋ និងចំណែកខ្លះទៀតជាដីសាធារណៈរបស់រដ្ឋ។ ផ្អែកលើលក្ខណៈពិសេសនេះ អនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ក្នុងការចុះបញ្ជីដីកម្មសិទ្ធិសមូហភាព ដែលមាន៖

- ដីឯកជនរបស់រដ្ឋ ជាដីដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន(ដីលំនៅឋាន) និងដី ដែលសហគមន៍ប្រកបរបរកសិកម្មប្រពៃណី (ដីដាំដុះដាក់ស្តែងនិងដីស្រែចម្ការ)។
- ដីសាធារណៈរបស់រដ្ឋ ជាដីដែលមានការកំណត់ទីតាំង ទំហំ ព្រំប្រទល់ជាក់លាក់ និង សិទ្ធិប្រើប្រាស់ ដូចដែលសហគមន៍បានអនុវត្តកន្លងមក ដូចជា ដីបម្រុងចាំបាច់ក្នុងការដូរវេនដំណាំ ដីព្រៃអារក្សដែលអាចមានមួយឬច្រើនកន្លែងនិងមានទំហំសរុបមិនលើសពី៧ហិកតា និងដីកប់ខ្មោច (ដីបញ្ចុះសព) ដែលមានទំហំសរុបមិនលើសពី៧ហិកតា។

ចំពោះដីរដ្ឋក្រៅពីការរៀបរាប់ខាងលើ ត្រូវចុះបញ្ជីជាដីរដ្ឋឱ្យទៅអាជ្ញាធរដែលមាន អាណត្តិកាន់កាប់ដីនោះ ប៉ុន្តែសហគមន៍ជនជាតិដើមភាគតិចមានសិទ្ធិបន្តការប្រើប្រាស់ និងអាស្រ័យផលតាមទំនៀមទម្លាប់ប្រពៃណី ដូចដែលពួកគាត់ធ្លាប់អនុវត្តកន្លងមក។ ដីទាំងនោះ មានដូចជាដីព្រៃសម្រាប់ប្រមូលអនុផលព្រៃឈើ ដីប្រភពទឹក[២២]។

## ១.២.៤ ផែនការសកម្មភាពនៃគោលនយោបាយដីធ្លី

ការគ្រប់គ្រងដីធ្លីនៅកម្ពុជាជួបនឹងផលវិបាកធ្ងន់ធ្ងរ ដោយសារតែឯកសារពាក់ព័ន្ធនឹងដីធ្លីត្រូវបានបំផ្លាញចោលទាំងស្រុងក្នុងរបបប្រល័យពូជសាសន៍។ នៅពេលដែលទីផ្សារដីធ្លីចាប់មានសន្ទុះ បាតុភាព

---

[២១] *ជ-ឯ-ម* ទំព័រទី២៧។

[២២] *ជ-ឯ-ម* ទំព័រទី២៨។

នៃការរំលោភលើដីរដ្ឋ ការដណ្ដើមកាន់កាប់ដី និងទំនាស់ដីធ្លីកើតមានជាបន្តបន្ទាប់ដែលទាមទារឱ្យមានការខិតខំពន្លឿនការចុះបញ្ជីដីធ្លី។ ម្យ៉ាងទៀត ការយឺតយ៉ាវក្នុង ការកំណត់តំបន់ប្រើប្រាស់ដី និងការធ្វើផែនការប្រើប្រាស់ដីនៅទីតាំងដែលមានសក្ដានុពល សេដ្ឋកិច្ចនិងនៅទីប្រជុំជន ទីក្រុងមួយចំនួនធ្វើឱ្យការអភិវឌ្ឍមិនទាន់មានភាពរលូនល្អ។ ប្រឈមនឹងបញ្ហាទាំងនេះ គោលដៅជាក់លាក់មួយចំនួនត្រូវបញ្ចូលទៅក្នុងផែនការសកម្មភាពនៃគោលនយោបាយដីធ្លីតាមអនុវិស័យនីមួយៗ៖

### ក. អនុវិស័យរដ្ឋបាលដីធ្លី

ដើម្បីធានាប្រសិទ្ធភាពនៃរដ្ឋបាលដីធ្លី ចាំបាច់ត្រូវមានវិធានការពង្រឹងសិទ្ធិលើដីធ្លីនិងសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ដែលគ្របដណ្ដប់លើរាល់សកម្មភាពនៃការបង្កើត ការផ្ទេរ និង ការកាន់កាប់ជាសិទ្ធិប្រត្យក្សផ្សេងទៀត ដែលមានចែងក្នុងច្បាប់ទាំងឡាយរបស់កម្ពុជា ក្នុងច្បាប់ភូមិបាល ក្រមរដ្ឋប្បវេណីច្បាប់ពាក់ព័ន្ធនឹងសហកម្មសិទ្ធិ និងបទដ្ឋានគតិយុត្តទាក់ទងនឹងកម្មសិទ្ធិ។ ក្នុងចំណោមសិទ្ធិប្រត្យក្សទាំងនេះ រាប់បញ្ចូលទាំងសិទ្ធិកម្មសិទ្ធិ សិទ្ធិកាន់កាប់ សិទ្ធិភោគ សិទ្ធិជួលអចិន្ត្រៃយ៍ សិទ្ធិអាស្រ័យផលសិទ្ធិប្រើប្រាស់និងអាស្រ័យនៅ សិទ្ធិសេវភាព សិទ្ធិឃាត់ទុក ឯកសិទ្ធិ សិទ្ធិលើការដាក់ប្រាតិភោគ ហ៊ីប៉ូតែក និងសិទ្ធិប្រាតិភោគដោយអនុប្បទាន។ សិទ្ធិលើដីធ្លីទាំងនេះ គ្របដណ្ដប់ផងដែរគ្រប់សិទ្ធិលើដីធ្លីរបស់ប្រជាជនគ្រប់រូបដែលមានកន្លងមក ហើយមានការទទួលស្គាល់ និងធានាដោយបទដ្ឋានគតិយុត្តជាធរមានរបស់កម្ពុជា។ ដើម្បីពង្រឹងសុវត្ថិភាពនៃការកាន់កាប់ដីធ្លី រដ្ឋបាលសុរិយោដី ត្រូវជំរុញការចុះបញ្ជីកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុ និងធ្វើការផ្ទេរសិទ្ធិលើអចលនទ្រព្យទាំងនោះជាផ្លូវការទប់ស្កាត់និងដោះស្រាយវិវាទដីធ្លី ដើម្បីធានានូវទំនុកចិត្តនិងប្រសិទ្ធភាពនៃទីផ្សារដីធ្លី[២៣]។

### ខ. ក្របខណ្ឌគតិយុត្តនៃការកាន់កាប់ដីធ្លី

ពាក់ព័ន្ធនឹងសិទ្ធិលើការកាន់កាប់ដីធ្លី ច្បាប់ភូមិបាលក៏ដូចជាក្រមរដ្ឋប្បវេណីបានកំណត់ប្រភេទកម្មសិទ្ធិលើអចលនទ្រព្យ និងប្រភេទសិទ្ធិកាន់កាប់ដីផ្សេងៗទៀត ជាអាទិ៍៖

**សិទ្ធិកម្មសិទ្ធិ** សំដៅលើសិទ្ធិដែលកម្មសិទ្ធិករនោះអាចប្រើប្រាស់ អាស្រ័យផល និង ចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនដោយសេរីបាននៅក្នុងទំហំដែលច្បាប់បានកម្រិត។ ការកាន់កាប់ដីធ្លីចាប់ពីឆ្នាំ១៩៨៩មក ត្រូវបានទទួលស្គាល់ជាការកាន់កាប់ដីបែបភោគៈ ដែលអាចឈានទៅជាកម្មសិទ្ធិប្រសិនបើភោគីនោះជាភោគីស្របច្បាប់ គឺបានចូលកាន់កាប់ដោយពិតប្រាកដ គ្មានហិង្សា ដឹងឮជាសាធារណៈ គ្មានអាក់ខាននិងដោយសុច្ចរិត មុនខែសីហា ឆ្នាំ២០០១ ហើយដីនោះមិនមែនជាផ្នែកនៃដីដែលជាសម្បត្តិសាធារណៈរបស់រដ្ឋ។ ដូច្នេះបើភោគៈស្របច្បាប់ អនុវត្តបាន៥ឆ្នាំរួចហើយ ភោគីអាចស្នើសុំទៅរដ្ឋបាលសុរិយោដី ដើម្បីធ្វើការចុះបញ្ជីទ្រព្យរបស់ខ្លួននៅក្នុងសៀវភៅគោលបញ្ជីដីធ្លី និងទទួលបានបណ្ណកម្មសិទ្ធិលើអចលនទ្រព្យនោះ។ កម្មសិទ្ធិឯកត្តជន សំដៅលើកម្មសិទ្ធិដែលគ្រប់គ្រងដោយបុគ្គល

---

[២៣] *ជ-ឯ-ម* ទំព័រទី២១។

ម្នាក់ជារូបវន្តបុគ្គល ឬជានីតិបុគ្គល (ក្រុមហ៊ុនឯកជនដែលមានសញ្ជាតិជាខ្មែរ ស្ថាប័នរដ្ឋ ឬគ្រឹះស្ថានសាធារណៈ)។ ឯកម្មសិទ្ធិរបស់បុគ្គលច្រើននាក់លើទ្រព្យទាំងមូលដោយសាមគ្គីគ្នា ត្រូវចាត់ជាកម្មសិទ្ធិអវិភាគ។

**សហកម្មសិទ្ធិ** សំដៅលើកម្មសិទ្ធិរបស់បុគ្គលច្រើននាក់អនុវត្តសិទ្ធិឯកជនផ្តាច់មុខលើភាគខ្លះនៃទ្រព្យដែលជាចំណែកឯកជន ហើយភាពដទៃខ្លះទៀត ដែលជាចំណែករួម ជាភាគប្រើប្រាស់រួម។ សហកម្មសិទ្ធិករមានសិទ្ធិពេញលេញក្នុងការផ្ទេរ ជួល ឬដាក់ប្រាតិភោគនូវ ចំណែកឯកជនរបស់ខ្លួនដោយមិនបំពានឬរំខានដល់ការប្រើប្រាស់ចំណែករួមនៃសហកម្មសិទ្ធិករដទៃទៀត។ កម្មសិទ្ធិសាធារណៈជាកម្មសិទ្ធិរបស់រដ្ឋឬរបស់សមូហភាពដែនដីសាធាណៈ របស់គ្រឹះស្ថានសាធារណៈឬនីតិបុគ្គលនៃនីតិសាធារណៈ និងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ ដូចជា ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ជាទ្រព្យដែលមិនអាចលក់ដូរបាននិងមិនអាចកំណត់អាជ្ញាយុកាលបាន។ ប៉ុន្តែនៅពេលដែលទ្រព្យនោះបាត់បង់ផលប្រយោជន៍សាធារណៈ ទ្រព្យនោះអាចត្រូវចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋតាមច្បាប់អនុបយោគ សម្រាប់គោលដៅប្រើប្រាស់ផ្សេងៗ។ ការធ្វើអនុបយោគដី គឺជាការប្តូរចំណាត់ថ្នាក់ដីពីឋានៈដីសាធារណៈរបស់រដ្ឋទៅជាដីឯកជនរបស់រដ្ឋ ដែលអាចធ្វើទៅបានដោយត្រូវភ្ជាប់សំណុំឯកសារពាក់ព័ន្ធមានជាអាទិ៍ ទីតាំងដី ព្រំប្រទល់ដែលមាននិយាមកាច្បាស់លាស់ ការវាយតម្លៃពីការបាត់បង់ផលប្រយោជន៍សាធារណៈនៃដីនោះ ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធផង។ ដោយបច្ចុប្បន្ន ពុំទាន់មានច្បាប់ស្តីពីការធ្វើអនុបយោគ ការប្តូរចំណាត់ថ្នាក់ពីដីសាធារណៈរបស់រដ្ឋទៅជាដីឯកជនរបស់រដ្ឋអាចធ្វើឡើងដោយអនុក្រឹត្យ ដោយផ្អែកលើព្រះរាជក្រឹត្យស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងនីតិបុគ្គលសាធារណៈ។ ចំពោះការប្តូរចំណាត់ថ្នាក់ដី ពីដីឯកជនរបស់រដ្ឋ ទៅជាដីសាធារណៈរបស់រដ្ឋវិញ គឺអាចធ្វើឡើងជាស្វ័យប្រវត្តិដោយអនុក្រឹត្យ។ កម្មសិទ្ធិសមូហភាព ជាកម្មសិទ្ធិរួមរបស់បុគ្គលច្រើននាក់ ដែលមានបុព្វសិទ្ធិរៀងៗខ្លួនលើ ទ្រព្យនោះ ដូចជា កម្មសិទ្ធិរបស់សាសនា និងកម្មសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច។ កម្មសិទ្ធិរបស់វត្តអារាម ដែលដាក់ឱ្យពុទ្ធសាសនិកប្រើប្រាស់ក្រោមការថែទាំរបស់គណៈកម្មការវត្តមិនអាចលក់ដូរឬធ្វើអំណោយហើយគ្មានកំណត់អាជ្ញាយុកាល[២៤]។ ចំពោះកម្មសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច មានមួយផ្នែកជាដីឯកជនរបស់រដ្ឋដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន និងដីដាំដុះដាក់ស្តែង និងមួយផ្នែកទៀតជាដីសាធារណៈរបស់រដ្ឋ ដូចជាដីសម្រាប់ដូរវេនដំណាំ ក្នុងការធ្វើកសិកម្ម ប្រពៃណី ដីព្រៃអារក្ស និងដីកប់ខ្មោច។ កម្មសិទ្ធិជាសិទ្ធិប្រត្យក្សខ្ពស់បំផុតនៃសិទ្ធិលើអចលនទ្រព្យ។ ក្រៅពីសិទ្ធិកម្មសិទ្ធិនៅមានសិទ្ធិប្រត្យក្សផ្សេងទៀតលើអចលនទ្រព្យដូចជា សិទ្ធិកាន់កាប់ សិទ្ធិប្រត្យក្សប្រើប្រាស់ និងអាស្រ័យផល និងសិទ្ធិប្រាតិភោគប្រត្យក្ស។ សិទ្ធិប្រត្យក្សប្រើប្រាស់ និងអាស្រ័យផល និងសិទ្ធិប្រាតិភោគ ប្រត្យក្ស ជាសិទ្ធិប្រត្យក្សមានកម្រិតផ្សេងពីកម្មសិទ្ធិ។ សិទ្ធិប្រត្យក្សប្រើប្រាស់និង

[២៤] *ជ-ឯ-ម* ទំព័រទី២២

អាស្រ័យផល មានជាអាទិ៍ សិទ្ធិផលុបភោគ សិទ្ធិជួលអចិន្ត្រៃយ៍ សិទ្ធិប្រើប្រាស់ និងអាស្រ័យនៅ និងសេវភាព។ ទោះជាយ៉ាងណា សិទ្ធិរបស់កម្មសិទ្ធិករលើអចលនទ្រព្យតែងតែផ្សារភ្ជាប់ទៅនឹងកាតព្វកិច្ច និងការកម្រិតសិទ្ធិខ្លះលើអចលនទ្រព្យនោះ។ ដោយគោរពទៅតាមវិធាននៃការប្រើប្រាស់ដីដែលច្បាប់ភូមិបាលឆ្នាំ២០០១ មិនបានចែងលម្អិតសិទ្ធិទាំងនេះអាចនឹងត្រូវបានកម្រិតដោយផ្អែកលើផលប្រយោជន៍សាធារណៈឬបញ្ចូលផលប្រយោជន៍ទាំងនោះតាមទីកន្លែងខ្លះ ឬតាមពេលវេលាខ្លះ ដូចជា សិទ្ធិលើនៅដេវប្រាំងក្នុងតំបន់ជុំវិញបឹងទន្លេសាប និងបឹងធម្មជាតិនានា សិទ្ធិលើដីវាលទំនាបនិងដីជម្រាលច្រាំងប្រព័ន្ធទន្លេមេគង្គ សិទ្ធិលើអចលនទ្រព្យមួយដោយបុគ្គលច្រើននាក់បែងចែកតាមចំណែកវាល[២៥]។

**សិទ្ធិនិងការទទួលខុសត្រូវទាក់ទងនឹងកម្មសិទ្ធិនិងសិទ្ធិប្រត្យក្សផ្សេងទៀត** មានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍ និងអភិបាលកិច្ចល្អលើការងារដីធ្លី។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់នូវសិទ្ធិកម្មសិទ្ធិ និងសិទ្ធិប្រត្យក្សកាន់កាប់ផ្សេងៗលើអចលនវត្ថុ ដែលសិទ្ធិទាំងនេះត្រូវភ្ជាប់ជាមួយនឹងការទទួលខុសត្រូវនិងកាតព្វកិច្ច។ ផ្អែកលើទស្សនៈនេះរាជរដ្ឋាភិបាលមានវិធានការដាក់លាក់ក្នុងការៈ

- ធានានូវរាល់សកម្មភាពទាក់ទងនឹងសិទ្ធិកម្មសិទ្ធិ និងសិទ្ធិកាន់កាប់ផ្សេងៗ ហើយការប្រើសិទ្ធិទាំងនោះនឹងមិនផ្លាស់ប្តូរនូវបុព្វសិទ្ធិ និងកាតព្វកិច្ចដែលមានស្រាប់ ស្របទៅនឹងច្បាប់ជាតិនិងច្បាប់អន្តរជាតិ។
- បញ្ជាក់ជូនម្ចាស់កម្មសិទ្ធិ និងម្ចាស់សិទ្ធិកាន់កាប់ផ្សេងៗទៀត ដែលបានទទួលស្គាល់រួចហើយថា សិទ្ធិកម្មសិទ្ធិឬសិទ្ធិកាន់កាប់ផ្សេងៗតែងផ្សារភ្ជាប់នឹងការកម្រិតដោយសិទ្ធិដទៃផ្សេងទៀត និងដោយវិធានការដែលរាជរដ្ឋាភិបាលមានភាពចាំបាច់ក្នុងការបម្រើផលប្រយោជន៍សាធារណៈដូចជា វិធានការលើកកម្ពស់សុខុមាលភាពប្រជាជនទៅតាមច្បាប់កំណត់ រួមទាំងការការពារបរិស្ថានស្របតាមច្បាប់ជាធរមាន។
- ផ្តល់នូវការគាំទ្រដល់ប្រជាជនគ្រប់រូប ដោយគ្មានការរើសអើង និងការគាំទ្រជា ពិសេសដល់ស្ត្រីភេទ និងប្រជាជនដែលមានភាពលំបាក ក្នុងការទទួលបាននូវសិទ្ធិកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ផ្សេងៗសម្រាប់ការទ្រទ្រង់ជីវភាពរស់នៅរបស់ខ្លួន ដើម្បីទទួលបាននូវសេវានានា និងការចូលរួមក្នុងដំណើរការទាំងឡាយណា ដែលអាចប៉ះពាល់ដល់សិទ្ធិកាន់កាប់របស់ពួកគាត់។

## ១.៣. នីតិវិធីនៃការចុះបញ្ជីដីធ្លី

### ១.៣.១ នីតិវិធីចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ

ការចុះបញ្ជីក្បាលដីនេះត្រូវបានបែងចែកជា ២ផ្នែកផ្សេងគ្នា គឺការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ និងការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ។ និតិវិធីក្នុងការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធសូមអានទីនេះ!

- ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ សម្រេចបាន ៤ ៥១១ ៩៤៣ បណ្ណ។

---

[២៥] *ដ-ឯ-ម* ទំព័រទី២៣

- ចំណែកការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ សម្រេចបានប្រមាណជា ៦១៥ ៨៧៦បណ្ណ។ ក្នុងនោះការចុះបញ្ជីដីរដ្ឋ មាន ១ ៧៧៦បណ្ណ។ ដីឯកជន មាន ៦១៣ ៤២៣បណ្ណ និងដីសហគមន៍ជនជាដើមភាគតិច មាន ៦៤៨បណ្ណ។

## ១.អ្វីទៅជាការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ?

ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ជាការចេញប្លង់កម្មសិទ្ធិ (ប្លង់រឹង) ដែលត្រូវធ្វើឡើងតាមរយៈការស្នើសុំរបស់ម្ចាស់ដីផ្ទាល់។ ខាងក្រោមនេះ គឺជានិតិវិធី ៥ ដំណាក់កាលនៃការស្នើសុំចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំៈ

### ក. ការដាក់ពាក្យស្នើសុំ

ដូចបានលើកឡើងខាងលើស្រាប់ ម្ចាស់ដីជាអ្នកស្នើសុំធ្វើប្លង់កម្មសិទ្ធិនេះដោយផ្ទាល់។ ក្នុងការដាក់ពាក្យ ម្ចាស់ដីត្រូវដាក់ពាក្យសុំទៅការិយាល័យសុរិយោដី ស្រុក/ខណ្ឌ ដែលដីនេះតាំងនៅ។ ប៉ុន្តែមុននឹងសុំដល់ថ្នាក់ស្រុក/ខណ្ឌ ម្ចាស់ដីត្រូវធ្វើលិខិតបញ្ជាក់ ចេញពីមេឃុំ/ចៅសង្កាត់ ដើម្បីបញ្ជាក់អំពីអត្តសញ្ញាណនៃការប្រើប្រាស់ដី និងការទទួលស្គាល់ពីថ្នាក់មូលដ្ឋានជាមុនសិន។

### ខ. ការវាស់វែងដី

បន្ទាប់ពីទទួលបានពាក្យស្នើសុំ និងពិនិត្យឃើញថាមានភាពត្រឹមត្រូវហើយ មន្ត្រីជំនាញសុរិយោដី នឹងចុះវាស់វែង និងកំណត់ព្រំដី ដោយមានការចូលរួមពីម្ចាស់ដីដោយផ្ទាល់។ ទោះយ៉ាងណាការវាស់វែងអាចធ្វើទៅបាន ប្រសិនបើមិនមានការជំទាស់តវ៉ាពីម្ចាស់ដី ដែលមានព្រំប្រទល់ជាប់គ្នា។ ក្នុងករណីមានវិវាទកើតឡើង ភាគទាំងសងខាងអាចដោះស្រាយគ្នាបាននៅត្រឹមថ្នាក់មូលដ្ឋាន ដោយមានគណៈកម្មឃុំ/សង្កាត់ ជាអ្នកសម្របសម្រួល។

### គ. ការផ្សព្វផ្សាយជាសាធារណៈ

បន្ទាប់ពីបានកំណត់ និងកសាងប្លង់រួចរាល់ អាជ្ញាធរនឹងបិទផ្សាយជាសាធារណៈ អំពីព័ត៌មាននៃដី (ដូចជាឈ្មោះម្ចាស់ដី ទំហំ ទីតាំង និងព្រំដីជាដើម) ក្នុងរយៈពេល៣០ថ្ងៃ ដើម្បីឱ្យម្ចាស់ដី ឬអ្នកពាក់ព័ន្ធ អាចត្រួតពិនិត្យ និងតវ៉ាសុំកែប្រែ ក្នុងករណីមានភាពមិនត្រឹមត្រូវ។

### ឃ. ការវិនិច្ឆ័យ និងសម្រេច

ប្រសិនមិនមានការជំទាស់ណាមួយទេ មន្ត្រីជំនាញនឹងចុះឈ្មោះម្ចាស់ដីទៅក្នុងសៀវភៅគោលបញ្ជីដីធ្លី និងរៀបចំធ្វើរបាយការណ៍សម្រាប់សុរិយោដីថ្នាក់ខេត្ត/ក្រុង។ បន្ទាប់ពីពិនិត្យឃើញថាត្រឹមត្រូវហើយនោះ ប្រធានមន្ទីរសុរិយោដីខេត្ត/ក្រុង នឹងចុះហត្ថលេខាលើបណ្ណកម្មសិទ្ធិជាស្ថាពរ។

### ង. ការប្រគល់បណ្ណ

នេះជាដំណាក់កាលចុងក្រោយនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ។ អាជ្ញាធរនឹងប្រគល់បណ្ណកម្មសិទ្ធិជូនម្ចាស់ដីដោយផ្ទាល់ទៅតាមការបរិច្ឆេទណាមួយ ដែលបានកំណត់។

២. តើការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំត្រូវបង់ពន្ធប្រថាប់ត្រាដែរឬទេ?

ពន្ធប្រថាប់ត្រាចំនួន៤% ត្រូវអនុវត្តចំពោះការស្នើសុំចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ ហើយពន្ធ ៤%នេះ ត្រូវបានអនុវត្តរាល់ប្រតិបត្តិការផ្ទេរកម្មសិទ្ធិពីម្ចាស់មួយទៅម្ចាស់មួយផ្សេងទៀត។

ទោះយ៉ាងណាក៏ដោយ ជាក់ស្តែងគេមើលឃើញថាការទិញលក់មួយចំនួន ត្រូវធ្វើឡើងត្រឹមថ្នាក់មូលដ្ឋាន ហើយម្ចាស់ដីមួយចំនួនមិនទាន់ចុះបញ្ជីដីនៅឡើយ។ តាមច្បាប់ រាល់ការទិញលក់ច្រើនដង ហើយមិនមានការបង់ពន្ធប្រថាប់ត្រានោះ ម្ចាស់ចុងក្រោយជាអ្នកទទួលខុសត្រូវបង់ពន្ធទាំងអស់។

ប៉ុន្តែដោយពិនិត្យឃើញថា ប្រជាពលរដ្ឋដែលជាអ្នកទទួលសិទ្ធិកាន់កាប់អចលនទ្រព្យចុងក្រោយ (អ្នកទិញ) ដែលត្រូវតម្រូវឱ្យមានការបង់ពន្ធប្រថាប់ត្រាច្រើនតំណ នៅមានចំនួនច្រើននៅឡើយ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានសម្រេចបន្តអនុវត្តន៍គោលការណ៍បង់ពន្ធប្រថាប់ត្រាចំនួនមួយដងនៅក្នុងឆ្នាំ២០១៩ ចំពោះការផ្ទេរកម្មសិទ្ធិ ឬកម្មសិទ្ធិកាន់កាប់អចលនទ្រព្យពុំបានចុះបញ្ជី (គ្មានបណ្ណកម្មសិទ្ធិ) និងកម្មសិទ្ធិបានចុះបញ្ជី(មានបណ្ណកម្មសិទ្ធិ)។

## ១.៣.២ នីតិវិធីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ

ក្រោយពីរបបខ្មែរក្រហមដួលរលំទៅ រាល់បណ្ណកម្មសិទ្ធិលើដីធ្លី នៅទូទាំងប្រទេសត្រូវបាត់បង់ទាំងអស់។ ច្បាប់បានកំណត់លុបចោលរាល់របបកម្មសិទ្ធិទាំងអស់ ដែលមានមុនឆ្នាំ១៩៧៩។ ដើម្បីរៀបចំកសាងបញ្ជីដីធ្លី និងចេញបណ្ណកម្មសិទ្ធិដីធ្លី នៅទូទាំងប្រទេសឡើងវិញ ច្បាប់បានកំណត់បង្កើតនីតិវិធីពិសេសមួយ គឺ "ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ"។

ការចុះបញ្ជីដីធ្លី មានលក្ខណៈជាប្រព័ន្ធ គឺជាការចុះបញ្ជីដីធ្លី ដែលកើតចេញពីគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាល ដោយមិនចាំបាច់មានការស្នើសុំពីម្ចាស់ដីឡើយ។ រដ្ឋាភិបាលជាអ្នកកំណត់ជ្រើសរើសភូមិឬឃុំណាមួយ ដែលត្រូវធ្វើការចុះបញ្ជីដីធ្លី។ នីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនេះត្រូវចែកចេញជា ៥ដំណាក់កាលសំខាន់ៗ៖

**ដំណាក់កាលទី១៖ ត្រៀមរៀបចំ** នៅក្នុងដំណាក់កាលនេះ រដ្ឋាភិបាលនឹងត្រូវធ្វើការប្រកាសកំណត់តំបន់វិនិច្ឆ័យថា តើត្រូវធ្វើការចុះបញ្ជីដីធ្លី នៅក្នុងឃុំណាមួយ។ នៅក្នុងដំណាក់កាលនេះ អាជ្ញាធរត្រូវធ្វើការជូនដំណឹងដល់ប្រជាពលរដ្ឋ នៅក្នុងឃុំឱ្យបានជ្រាបអំពីការចុះបញ្ជីដីធ្លីនេះ ដើម្បីឱ្យប្រជាពលរដ្ឋត្រៀមខ្លួនចូលរួមក្នុងដំណើរការនេះ។ គណៈកម្មការមួយត្រូវបង្កើតឡើង ដើម្បីជួយដល់ដំណើរការនៃការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ។ គណៈកម្មការនេះមានសមាសភាពដូចតទៅ៖

- អភិបាលខេត្ត-ក្រុង ជាប្រធាន
- អភិបាលស្រុក-ខ័ណ្ឌ ជាសមាជិក
- ប្រធានក្រុមបច្ចេកទេសវាស់វែង ជាសមាជិក
- មេឃុំ-ចៅសង្កាត់ ឬតំណាងក្រុមប្រឹក្សាឃុំ-សង្កាត់ ជាសមាជិក
- គ្រប់មេភូមិទាំងអស់ នៅក្នុងឃុំ-សង្កាត់ ជាសមាជិក
- ចាស់ព្រឹទ្ធាចារ្យ ២រូប ដែលស្គាល់ប្រវត្តិដី នៅក្នុងឃុំ ជាសមាជិក

**ដំណាក់កាលទី២៖ វាស់វែង និងកសាងប្លង់សុរិយោដី** ម្ចាស់ដី គឺជាអ្នកកំណត់ព្រំ ជាមួយអ្នកជិតខាង។ ចំណែក មន្ត្រីបច្ចេកទេសគ្រាន់តែជាអ្នកចុះទៅវាស់វែងទៅតាមព្រំដែលចង្អុលបង្ហាញ ដោយម្ចាស់ដីតែប៉ុណ្ណោះ។ ដូច្នេះ នៅក្នុងដំណាក់កាលនេះ ការចូលរួមចំណែកពីម្ចាស់ដីមានសារៈសំខាន់ណាស់។ ម្ចាស់ដីក៏ត្រូវត្រៀមនូវឯកសារចាំបាច់មួយចំនួនផងដែរ។ ឯកសារទាំងនេះរួមមាន សំបុត្រកំណើត អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ សំបុត្រអាពាហ៍ពិពាហ៍ បណ្តាំមរតក សាលក្រមតុលាការ លិខិតទិញ-លក់។ល។

**ដំណាក់កាលទី៣៖ ផ្សព្វផ្សាយ** អាជ្ញាធរត្រូវធ្វើការបិទផ្សាយជាសាធារណៈនូវប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី ដើម្បីឱ្យប្រជាពលរដ្ឋពាក់ព័ន្ធអាចធ្វើការត្រួតពិនិត្យ និងតវ៉ាសុំធ្វើការកែប្រែ ប្រសិនបើមានកន្លែងមិនត្រឹមត្រូវ។ គួរបញ្ជាក់ថា នៅក្នុងដំណើរការចុះបញ្ជីនេះ ប្រសិនបើកើតមានវិវាទណាមួយដូចជា វិវាទរឿងព្រំដីជាដើម ភាគីជម្លោះអាចសុំឱ្យគណៈកម្មការរដ្ឋបាលជួយដោះស្រាយ និងសម្រុះសម្រួលឱ្យដោយមិនចាំបាច់ប្តឹងផ្តល់គ្នាទៅដល់តុលាការនោះទេ។

**ដំណាក់កាលទី៤៖ វិនិច្ឆ័យ និងសម្រេច** ដំណាក់ កាលនេះ គឺមានពាក់ព័ន្ធតែជាមួយស្ថាប័នរដ្ឋតែប៉ុណ្ណោះ។ ផុតរយៈពេល ៣០ថ្ងៃ ដែលបើកឱ្យមានការតវ៉ា មន្ត្រីមានសមត្ថកិច្ចត្រូវធ្វើការពិនិត្យទៅលើប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី ដែលត្រូវចុះក្នុងសៀវភៅគោលបញ្ជីដីធ្លី។ ដីទាំងឡាយណាដែលមិនជាប់មានទំនាស់ ហើយមិនមែនចូលជាដីរបស់រដ្ឋនឹងត្រូវចុះក្នុងសៀវភៅគោលបញ្ជីដីធ្លី ហើយប្រធានមន្ទីរភូមិបាលខេត្ត-ក្រុង នឹងចុះហត្ថលេខាលើបណ្ណកម្មសិទ្ធិស្ថាពរ។

**ដំណាក់កាលទី៥៖ ការចែកបណ្ណ** ជាដំណាក់កាលចុងក្រោយ។ ក្រោយពីអាជ្ញាធរចុះហត្ថលេខាចេញបណ្ណហើយ បណ្ណទាំងនេះនឹងត្រូវចែកជូនដល់ម្ចាស់ដីវិញ។ ម្ចាស់ដីត្រូវទៅទទួលបណ្ណ ដោយផ្ទាល់ដៃ ហើយបណ្ណនេះ គឺជាបណ្ណកម្មសិទ្ធិស្ថាពរ។

### ១.៣.៣ នីតិវិធីចុះបញ្ជីដីបំពេញបន្ថែម

ក្រោយពីបានបញ្ចប់នីតិវិធីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ក្នុងតំបន់មួយចំនួនរួចមកនៅមានក្បាលដីខ្លះស្ថិតក្នុងតំបន់វិនិច្ឆ័យ ប៉ុន្តែម្ចាស់នៃក្បាលដីទាំងនោះមិនបានមកចូលរួមបំពេញបែបបទដើម្បីទទួលបានសិទ្ធិពេញលេញតាមកាលកំណត់។ ក្បាលដីទាំងនេះមានស្ថានភាពខុសៗគ្នា មួយចំនួនត្រូវបានផ្តល់បណ្ណសំគាល់សិទ្ធិរួចហើយតាមនីតិវិធីចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ឯមួយចំនួនទៀតត្រូវបានកាន់កាប់ត្រឹមត្រូវប៉ុន្តែមិនទាន់ត្រូវបានផ្តល់បណ្ណសំគាល់សិទ្ធិនៅឡើយ។ ទោះក្នុងករណីណាក៏ការកាន់កាប់ស្របច្បាប់ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទាំងនេះ ត្រូវតែបានសម្រួលឱ្យចុះចូលក្នុងសៀវភៅគោលបញ្ជីដីធ្លី ដើម្បីធានាសិទ្ធិពេញលេញតាមផ្លូវច្បាប់។

ក្នុងការសំរួលដោះស្រាយបញ្ហាខាងលើ ក្រសួងបានកំណត់នូវគោលការណ៍ និងនីតិវិធីនៃការចុះបញ្ជីដីបំពេញបន្ថែម ដូចតទៅ៖

- ម្ចាស់អចលនវត្ថុដែលមិនបានចូលរួមបំពេញបែបបបទ តាមកាលកំណត់ក្នុងពេលប្រកាសតំបន់វិនិច្ឆ័យ និងកិច្ចដំណើរការអនុវត្តនីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ដោយមានមូលហេតុសមស្របត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីដីមកការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល(ការិ.ដនសភ.) តាមរយៈមេឃុំ ចៅសង្កាត់ នៃឃុំ សង្កាត់ដែលជាទីតាំងនៃដីស្ថិតនៅ

- មេឃុំ ចៅសង្កាត់ត្រូវពិនិត្យលក្ខណៈសមស្រប ផ្តល់យោបល់ និងបញ្ជូនសំណុំរឿងមកការិយាល័យ ដនសភ.ស្រុក ខណ្ឌ។

- បើការិយាល័យជំនាញពិនិត្យឃើញសមស្រប រាយការណ៍ជូនអភិបាលស្រុក ខណ្ឌ ដើម្បីផ្តល់យោបល់ និង សហការចុះពិនិត្យទិដ្ឋភាពបច្ចេកទេស និងរដ្ឋបាលគតិយុត្ត ហើយកំណត់ព្រំ វាស់វែង និងកសាងទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ដែលបានស្នើសុំ។

បើក្បាលដីស្នើចុះបញ្ជីស្ថិតនៅចន្លោះក្បាលដីដែលបានចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធរួចហើយព្រំនៃក្បាលដីនោះមិនចាំបាច់ធ្វើការកំណត់ជាថ្មីទៀតទេ។ ចំពោះក្បាលដីដែលមិនទាន់បានកំណត់ព្រំជាផ្លូវការ ជាមួយក្បាលដីជាប់ព្រំគ្នាសោះ ឬបានកំណត់ព្រំខ្លះចាំបាច់ត្រូវធ្វើការកំណត់ព្រំដែលនៅសេសសល់តាមនីតិវិធី។ ត្រូវស្រង់យកចំណែកពាក់ព័ន្ធនឹងការចុះបញ្ជីបំពេញបន្ថែមនេះពីប្លង់សុរិយោដីដែលជាលទ្ធផលនៃការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធលើកមុន មកគូសបំពេញព្រំប្រទល់ដែលទើបកំណត់ក្រោយ ហើយដាក់លេខក្បាលដីតពីលេខលើកមុន។

- ក្រោយពីរៀបចំសំណុំឯកសារគ្រប់គ្រាន់ ត្រូវបិទផ្សាយជាសាធារណៈនូវទិន្នន័យដែលប្រមូលបានក្នុងរយៈពេល ៣០ថ្ងៃ នៅសាលាសង្កាត់ និងនៅការិយាល័យ ដនសភ. ស្រុក ខណ្ឌ។ រាល់ការជំទាស់ ឬតវ៉ា ត្រូវធ្វើនៅការិយាល័យ ដនសភ.ស្រុក ខណ្ឌ។ ការកែតម្រូវអាចធ្វើបានតាមសមត្ថកិច្ច និងគោលការណ៍ដែលបានកំណត់ដោយអនុក្រឹត្យពាក់ព័ន្ធ។

- ការិយាល័យដនសភ. ត្រូវធ្វើរបាយការណ៍បូកសរុប ផ្តល់យោបល់ និងបញ្ជូនសំណុំរឿងមកអភិបាលស្រុក ខណ្ឌ ដើម្បីសុំយោបល់ ហើយបញ្ជូនបន្តមកមន្ទីរដនសស.ខេត្ត ក្រុង ពិនិត្យបន្ថែមលើលក្ខណៈបច្ចេកទេសរួចទើបបញ្ជូនទៅសាលាខេត្ត ក្រុង សុំយោបល់សម្រេច។

- នៅពេលដែលអភិបាលខេត្ត ក្រុងយល់ព្រមហើយ សំណុំឯកសារនៃការវិនិច្ឆ័យត្រូវបញ្ជូនមកមន្ទីរ ដនសស.វិញ ដើម្បីធ្វើការចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី និងក្នុង Digital file ហើយបោះពុម្ពបណ្ណ ចុះហត្ថលេខា រួចប្រគល់ជូនអ្នកស្នើសុំ។ ករណីអភិបាលខេត្ត ក្រុងមិនយល់ព្រម ឬច្រានចោលត្រូវបញ្ជាក់ឱ្យច្បាស់អំពីមូលហេតុដែលមិនយល់ព្រម ឬច្រានចោលនោះ ដើម្បីឆ្លើយតបទៅអ្នកស្នើសុំវិញ និងទុកជាឯកសារ។

## ១.៣.៤ នីតិវិធីចុះបញ្ជីដីបន្ត

រយៈកន្លងមកឯកសារសុរិយោដីត្រូវបានកសាង និងកាន់កាប់តាមពីររបៀប គឺរបៀប ចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ និងរបៀបចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ។....ឯកសារ មូលដ្ឋាននៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ មានទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី បញ្ជីឈ្មោះម្ចាស់ដី

ប្លង់សុរិយោដី និងឯកសារណាបផ្សេងៗ។ រីឯឯកសារមូលដ្ឋាននៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ មានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ប្រកាសជូនដំណឹងពីការចុះធ្វើអង្កេតវាស់វែង កំណត់ហេតុអង្កេតដី និងឯកសារណាបផ្សេងៗ។ ឯកសារទាំងនោះ ទោះបីមានការណែនាំជាបន្តបន្ទាប់ក៏ដោយក្រសួងសង្កេតឃើញថា ការកាន់កាប់ឯកសារសុរិយោដី នៅមិនទាន់ឯកភាពគ្នា និងមានភាពសុក្រឹតនៅឡើយ។

ដើម្បីឱ្យមានភាពរលូនក្នុងការងារ ពិសេសពាក់ព័ន្ធនឹងការងារចុះបញ្ជីដីបន្ត ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ សូមធ្វើការណែនាំដល់គ្រប់មន្ទីររៀបចំ ផែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ដូចតទៅ :

• ត្រូវបន្តពង្រឹងណែនាំដល់មន្ត្រីក្រោមឱវាទ ជាអាទិ៍ ថ្នាក់ដឹកនាំការិយាល័យរៀបចំដែនដី នគ-រូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ មន្ត្រីទទួលបន្ទុកកាន់កាប់ឯកសារ (មន្ត្រីអភិរក្សសុរិយោដី) ឱ្យខិតខំយកចិត្តទុកដាក់បង្កើនស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការកសាង ឯកសារមូលដ្ឋាន ដូចជាកិច្ចសន្យាលក់ លិខិតអំណោយផ្តាច់ ការបញ្ជាក់អំពីប្រភេទទ្រព្យ ការបញ្ជាក់អំពីអត្តសញ្ញាណម្ចាស់ទ្រព្យ និងកិច្ចសន្យាដាក់បន្ទុកលើអចលនវត្ថុជាដើម ធ្វើការផ្ទៀងផ្ទាត់ ត្រួតពិនិត្យសុពលភាព ភាពត្រឹមត្រូវ និងគ្រប់គ្រាន់នៃឯកសារ។

• ត្រូវបន្តពង្រឹងការកាន់កាប់ឯកសារមូលដ្ឋាន ដោយត្រូវធ្វើចរន្តការក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ ឬសៀវភៅគោលបញ្ជីដី ផែនទីមានលក្ខណៈដាច់ដោយដុំ និងប្លង់សុរិយោដីនូវរាល់ការប្រែប្រួលគតិយុត្ត ឬលក្ខណៈរូបនៃក្បាលដី កសាងតារាងរាយឈ្មោះម្ចាស់ដីតាមលំដាប់អក្សរ(T.A=Tableau Alphabétique des propriétaires) ពង្រឹងការងារបណ្ណសារដ្ឋាន...។

• ត្រូវយកចិត្តទុកដាក់សំរបសំរួលគ្នារវាងការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ និងការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ដោយៈ

- ចំពោះការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធត្រូវប្រមូលបណ្ណចាស់ (បណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬបណ្ណស្លាបមាន់ ចេញដោយអតីតការិយាល័យសុរិយោដីខេត្ត ក្រុង ឬបណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុចេញដោយអតីតនាយកដ្ឋានសុរិយោដី ឬអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ) ដែលបានចេញហើយក្នុងតំបន់ធ្វើការវិនិច្ឆ័យ នៅពេលចែកវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ រួចធ្វើតារាង(គំរូលេខ ១) ផ្ញើជូននាយកដ្ឋានអភិរក្សដើម្បីចាត់ការតាមនីតិវិធីអភិរក្សសុរិយោដី។ ម្យ៉ាងទៀត ចំពោះវិញ្ញាបនប័ត្រគំរូចាស់ដែលបានចេញរួចកន្លងមក នៅពេលមានការផ្លាស់ប្តូរប្រែប្រួលសិទ្ធិ ឬលក្ខណៈរូបនៃក្បាលដី ត្រូវប្រមូលមកវិញ ហើយចេញវិញ្ញាបនប័ត្រគំរូថ្មីជំនួសវិញ។ ឯវិញ្ញាបនប័ត្រចាស់ត្រូវគូសឆ្នូត ឬបោះត្រាមោឃភាព ហើយរក្សាទុកជាឯកសារ រួចធ្វើតារាងសម្រង់អចលនវត្ថុផ្ញើជូននាយកដ្ឋានអភិរក្សសុរិយោដី ផ្នែកប្រព័ន្ធព័ត៌មានដី (LIS) នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងការិយាល័យរៀបចំ ដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ដើម្បីធ្វើចរន្តការក្នុងឯកសារសុរិយោដីឱ្យបានស្របគ្នា។

បន្ទាប់ពីសេចក្ដីណែនាំនេះត្រូវបានសំរេចហើយ ផ្នែកប្រព័ន្ធព័ត៌មានដី (LIS) និងមន្ទីរ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ត្រូវផ្ញើឯកសារសុរិយោដីនៃតំបន់ចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធទាំងអស់ មានប្លង់សុរិយោដី សៀវភៅគោលបញ្ជីដី បញ្ជីឈ្មោះម្ចាស់ដី ទៅនាយកដ្ឋានអភិរក្សសុរិយោដី ដើម្បីតាមដានការវិវត្តន៍នៃក្បាលដី ត្រួតពិនិត្យការធ្វើលេខាចារឹកលើឯកសារ និងជាមូលដ្ឋានក្នុងការផ្ដល់ព័ត៌មានដល់ជនទាំងឡាយដែលបានមកទាក់ទងសាកសួរ។

- ចំពោះការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ បន្ទាប់ពីទទួលបានឯកសារ នាយកដ្ឋានអភិរក្សត្រូវចាត់ធ្វើលេខាចារឹកក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ និងតារាងរាយឈ្មោះម្ចាស់ដីតាមលំដាប់អក្សរ រួចផ្ញើតារាងសម្រង់អចលនវត្ថុផ្ញើជូនផ្នែកប្រព័ន្ធព័ត៌មានដី(LIS) នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ដើម្បីធ្វើចរន្តការឱ្យបានស្របគ្នាក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ និងតារាងរាយឈ្មោះម្ចាស់ដីតាមលំដាប់អក្សរ។

### ១.៣.៥ ការចុះបញ្ជីបន្ត ការធ្វើលេខាចារឹក ការចុះបញ្ជីសិទ្ធិប្រត្យក្ស

ការចុះបញ្ជីបន្តត្រូវអនុវត្តលើរាល់ការផ្ទេរ ការបង្កើត និងការកែប្រែនូវសិទ្ធិប្រត្យក្សដែលហៅថាការធ្វើចរន្តទិន្នន័យសុរិយោដី។ ការចុះបញ្ជីផ្ទេរសិទ្ធិប្រត្យក្សអាចធ្វើឡើងដោយ (១) តាមពាក្យសុំរបស់គូភាគី រួមមាន កិច្ចសន្យាលក់ កិច្ចសន្យាដូរ កិច្ចសន្យាប្រទានកម្ម ការបែងចែកមរតក និង(២) តាមលិខិតផ្ទុកផ្ដាក់របស់តុលាការ រួមមាន លិខិតផ្ទុកផ្ដាក់ឱ្យផ្ទេរកម្មសិទ្ធិ ផ្ទេរសិទ្ធិចូល អចិន្ត្រៃយ៍ ឬផ្ទេរផលុបភោគតាមការលក់ដោយបង្ខំ លិខិតផ្ទុកផ្ដាក់ឱ្យផ្ទេរហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគ។ ការកម្រិតចំពោះការចុះបញ្ជីកម្មសិទ្ធិ រួមមាន (១) ការដាក់បន្ទុក ដូចជា ផលុបភោគ សេវភាព សិទ្ធិប្រើប្រាស់និងអាស្រ័យនៅ ការជួលអចិន្ត្រៃយ៍ និងសម្បទានដីសេដ្ឋកិច្ច (២) ការធានាសងបំណុល ដូចជា ការដាក់ប្រាតិភោគ ហ៊ីប៉ូតែក ឯកសិទ្ធិ និង(៣) ការផ្ទុកផ្ដាក់ (ការដាក់បន្ទុក) ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ឬការរឹបអូសជាបណ្ដោះអាសន្ន។ ការកែប្រែសិទ្ធិ មានដូចជាការកែប្រែសិទ្ធិកាន់កាប់ឬសិទ្ធិភោគៈមកជាសិទ្ធិកម្មសិទ្ធិ ការកែប្រែពីទ្រព្យរួមឬពីសហកម្មសិទ្ធិ ឬពីកម្មសិទ្ធិអវិភាគ មកជាកម្មសិទ្ធិឯកត្តជន។

### ១.៣.៦ ការចុះបញ្ជីបន្តលើសម្បទានដីសេដ្ឋកិច្ចឬលើដីជួលអចិន្ត្រៃយ៍

ការផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍ ឬការផ្ទេរសិទ្ធិលើសម្បទានដីសេដ្ឋកិច្ចមិនមែនជាការផ្ទេរដី ដែលវិនិយោគិនបានទទួលសិទ្ធិជួល ឬសិទ្ធិសម្បទានដីពីរដ្ឋនោះឡើយ។ សិទ្ធិលើសម្បទានដីសេដ្ឋកិច្ចជាសិទ្ធិស្របច្បាប់ដែលបានចែងក្នុងឯកសារគតិយុត្ត ចេញដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីកាន់កាប់និងប្រើប្រាស់ដីតាមលក្ខខណ្ឌជាក់លាក់ក្នុងរយៈពេលមួយជាកំណត់ តាមកិច្ចសន្យាដែលបានបង្កើតសម្បទាននោះ។ សិទ្ធិសម្បទានដីសេដ្ឋកិច្ចឬសិទ្ធិជួលអចិន្ត្រៃយ៍ មិនអាចឈានដល់ការបង្កើតនូវសិទ្ធិកម្មសិទ្ធិលើដីដែលបានផ្ដល់ជាសម្បទានឬជួលនោះបានទេ ហើយមានតែអចលនវត្ថុដែលបានចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីរួចហើយ ទើបអាចជាកម្មវត្ថុនៃការធ្វើសម្បទានសេដ្ឋកិច្ច ឬការជួលអចិន្ត្រៃយ៍បាន។ តាមមាត្រា៦នៃអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧ ស្ដីពីការដាក់ប្រាតិភោគ ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង(ការជួលអចិន្ត្រៃយ ផ្ទេរសិទ្ធិសម្បទានដីសេដ្ឋកិច្ចបានចែងកំណត់ថា "រាល់ការដាក់បញ្ចាំឬការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង (ការជួលអចិន្ត្រៃយ៍)

ឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច ត្រូវធ្វើលេខាចារឹកនៅលើបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬលើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់" ហើយមាត្រា៨ បានបញ្ជាក់បន្ថែមថា នៅពេលដែលភតិកៈឬសម្បទានិកស្លាប់ ទាយាទរបស់មតកជនអាចបន្តសិទ្ធិក្នុងកិច្ចសន្យាជួលឬសម្បទានដី បានត្រឹមតែក្នុង រយៈពេលនៃកិច្ចសន្យាជួលឬកិច្ចសន្យាសម្បទានដីតែប៉ុណ្ណោះ។ រូបវន្តបុគ្គល ឬនីតិបុគ្គលឬក្រុមមនុស្សដែលទទួលការអនុញ្ញាតឱ្យជួលដីពីរដ្ឋ អាចជួលបន្តទៅឱ្យតតិយជនបាន បើមានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចជាមុន[២៦]។ ទោះជាយ៉ាងណាក៏ដោយអ្នកជួលបន្តមិនអាចក្លាយជាកម្មសិទ្ធិករនិងគ្មានសិទ្ធិទាមទារសិទ្ធិកម្មសិទ្ធិលើអចលនទ្រព្យដែលជួលបន្តនោះបានឡើយ។ ប៉ុន្តែម្ចាស់បំណុលមានសិទ្ធិប្តឹងកូនបំណុលដែលបានដាក់ប្រាតិភោគសិទ្ធិសម្បទានបន្ត ឬសិទ្ធិជួលបន្តទៅតុលាការ ដើម្បីដោះស្រាយស្របតាមច្បាប់ និងនីតិវិធីជាធរមាន យកមកសងបំណុលតាមបុព្វសិទ្ធិ និងសិទ្ធិដែលខ្លួនមានជាងម្ចាស់បំណុលដទៃទៀត ត្រឹមតែក្នុងអំឡុងពេលដែលមានចែងក្នុងកិច្ចសន្យាជួលឬកិច្ចសន្យាសម្បទានដីតែប៉ុណ្ណោះ។ ម្ចាស់បំណុលគ្មានសិទ្ធិទាមទារនូវសិទ្ធិចាត់ចែងលើអចលនទ្រព្យ ដែលកូនបំណុលរបស់ខ្លួនបានទទួលជួលឬសម្បទានពីតតិយជនបានឡើយ។ ការចុះបញ្ជីបន្ត ជានីតិវិធីចាំបាច់ និងត្រូវបង់សេវាសុរិយោដីចូលថវិការដ្ឋ។ ដោយឡែកការចុះបញ្ជីបន្តក្នុងករណីផ្ទេរផ្ទួននោះត្រូវបង់សេវាសុរិយោដីនិងបង់ពន្ធប្រថាប់ត្រាថែមទៀត។ ការខកខានមិនបានធ្វើការចុះបញ្ជីបន្តតាមផ្លូវការ នាំឱ្យម្ចាស់សិទ្ធិដែលទទួលកាន់កាប់បន្តមិនអាចចាត់ចែងទ្រព្យនោះក្នុងការជួលឬការដាក់ប្រាតិភោគផ្សេងៗបានឡើយ ពីព្រោះឈ្មោះម្ចាស់ដើមនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី មានសិទ្ធិប្រឆាំងតវ៉ានឹងតតិយជនបាន។

ការចុះបញ្ជីបន្ត ឬការធ្វើបច្ចុប្បន្នភាពទិន្នន័យសុរិយោដីមានជាប់ពាក់ព័ន្ធនឹងការបង់ពន្ធផ្សេងៗ ជាពិសេស ពន្ធប្រថាប់ត្រា ការបញ្ជាក់លើលិខិតស្នាមផ្សេងៗដោយអាជ្ញាធរមូលដ្ឋាន និងនីតិវិធីនៃការធ្វើបច្ចុប្បន្នភាពទិន្នន័យសុរិយោដី។ ដើម្បីផ្តល់សេវាសាធារណៈឱ្យកាន់តែមានភាពងាយស្រួល មានតម្លាភាព គណនេយ្យភាព និងនៅជិតប្រជាជន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានរៀបចំការិយាល័យច្រកចេញចូលតែមួយនៅទីស្តីការក្រសួង និងនៅតាមមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដី រាជធានី ខេត្ត ដោយមានការបិទផ្សាយជាសាធារណៈនូវតារាងថ្លៃសេវា និងសោហ៊ុយចាំបាច់ផ្សេងៗ ដែលអតិថិជនត្រូវបង់និងរយៈពេលនៃការផ្តល់សេវាជូនអតិថិជន។ ទន្ទឹមនឹងនេះ នៅតាមការិយាល័យរៀបចំ ដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ដែលពុំទាន់មានលទ្ធភាពបង្កើតច្រកចេញចូលតែមួយបាន ក៏មានបិទផ្សាយនូវតារាងសេវាជូនសាធារណជនផងដែរ។ ដូច្នេះ មន្ត្រីពាក់ព័ន្ធនឹងការងារទាំងនេះនឹងខិតខំអនុវត្តភារកិច្ចរបស់ខ្លួនប្រកបដោយតម្លាភាព និងតាមគោលការណ៍ដែលបានតំណត់។ ចំពោះការធ្វើលេខាចារឹក ដែលមិនពាក់ព័ន្ធនឹងការបង់ពន្ធដារ ក៏ត្រូវអនុវត្តគោលការណ៍ នៃការផ្តល់សេវាសាធារណៈ ដោយតម្លាភាព និងនៅជិតប្រជាជន ដោយមានតារាងកំណត់តម្លៃសេវាទៅតាមទំហំការងារ និងរយៈពេលនៃការសម្រេចការងារ។

---

[២៦] អនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧ ស្តីពី *ការដាក់ប្រាតិភោគ ការផ្ទេរនូវសិទ្ធិលើការជួល រយៈពេលវែង។*

# គន្ថនិទ្ទេស

១. ព្រះរាជក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២

២. *អនុក្រឹត្យ ៧២នីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីក្នុងឃុំ សង្កាត់* រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៥

៣. *អនុក្រឹត្យ ៧៧ ការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម រាជធានីខេត្ត ក្រុង ស្រុកខណ្ឌ* រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២

៤. *អនុក្រឹត្យលេខ ៤៦ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី* រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២

៥. *អនុក្រឹត្យលេខ ៤៧ ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី រាជធានីភ្នំពេញ* ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២

៦. *អនុក្រឹត្យលេខ ៤៨ ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ* រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២

៧. *អនុក្រឹត្យលេខ ៦២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី* រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩

៨. *អនុក្រឹត្យ ស្តីពី វិធាន និង នីតិវិធីនៃការធ្វើអនុប្រយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ* រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦

៩. *អនុក្រឹត្យលេខ១៨៤ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលស្រុក*រាជធានីភ្នំពេញ ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩

១០. *អនុក្រឹត្យលេខ១១៨ អនក្រ.បក ស្តីពី ការគ្រប់គ្រងដីរដ្ឋ* ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥

១១.*អនុក្រឹត្យលេខ១១៤ អនក្រ.បក ស្តីពី ការដាក់ប្រាតិភោគ ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង* ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧

១២.*អនុក្រឹត្យលេខ៤៨ អនក្រ.បក ស្តីពី ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ តាមការស្នើសុំពីបុគ្គលម្ចាស់សិទ្ធិ* ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២

១៣. *អនុក្រឹត្យលេខ១១៨ ស្តីពីការគ្រប់គ្រងដីរដ្ឋ* ឆ្នាំ២០០៥

១៤. *អនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ*

១៥. *សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាល ស្តីពី គោលនយោបាយដីធ្លី* រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ ២០០៩

១៦. *ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់, គោលនយោបាយដីធ្លី,* ឆ្នាំ២០១៥

១៧. *ប្រកាសអន្តរក្រសួងលេខ៣១២_ស្តីពីការលើកលែងការបង់កម្រៃសេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់* រាជធានីភ្នំពេញ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣

១៨. *សេចក្តីជូនដំណឹងស្តីពីការបន្តគោលការណ៍លើកលែងពន្ធ ការអនុគ្រោះពន្ធបន្ថែមទៀត ការពន្យារ និងការព្យួរការអនុវត្តពន្ធសម្រាប់វិស័យអចលនទ្រព្យ*រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមករា ឆ្នាំ២០២៤

១៩. *ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់, ឯកសារណែនាំអនុវត្ត ស្តីពី ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់* ឆ្នាំ២០០៩

២០. *ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់, ឯការបណ្តុះបណ្តាលការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ* ,ឆ្នាំ២០០៨

២១. *ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់, កម្រងឯកសារសម្រាប់ផ្សព្វផ្សាយបំរើឱ្យកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី,* ឆ្នាំ២០១២

២២. *ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់, ឯការបណ្តុះបណ្តាលការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ* ,ឆ្នាំ២០០៨

២៣. ក្រសួងយុត្តិធម៌និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រកាសអន្តរក្រសួងលេខ០២ ប្រករ.០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពី*ការកំណត់សមត្ថកិច្ចរបស់តុលាការនិងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី*

២៤. ក្រសួងមហាផ្ទៃ *សៀវភៅព័ត៌មានរាជធានី ខេត្ត* ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤

២៥. ប្រកាសអន្តរក្រសួងលេខ៥៩ ប្រក.ដ.ន.ស/១១ ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការចុះបញ្ជីអចលនវត្ថុ ទាក់ទង និងក្រមនីតិវិធីរដ្ឋប្បវេណី និង លេខ៣០ កយ.ជនស.ប្រក/១៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពី *នីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី*

២៦. ប្រកាសស្តីពី *តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង និងតួនាទី ភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ,* ឆ្នាំ១៩៩៩

២៧. បទបញ្ជាលេខ០១បប ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ ស្តីពី *ការផ្តល់សម្បទានដីសេដ្ឋកិច្ច*

២៨. សារាចរណែនាំលេខ០២ សរណន ស្តីពី *ការផ្តល់បណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាជនដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះដាក់ស្តែង* ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣

# តម្លៃអប់រំតាមរយៈចម្រៀងបំពេនៅដែនដីសណ្តទន្លេមេគង្គ

បេក្ខជនបណ្ឌិត៖ ថាច់ សាភ័ណ
ជំនាញ៖ អក្សរសិល្ប៍

## ១- សេចក្តីផ្តើម

ឆ្លងតាមការរួមរស់ជាមួយជនជាតិឯទៀតក្នុងសហគមន៍ដ៏យូរអង្វែង ជនជាតិខ្មែរបានបង្កើតនូវខឿនវប្បធម៌សិល្បៈប្រជាប្រិយដ៏វិសេសវិសាល និងសម្បូរបែបដោយមានខ្លឹមសារប្រកបដោយមនុស្សសាស្ត្រយ៉ាងជ្រាលជ្រៅ និងមានតួនាទីដ៏សំខាន់មិនអាចខ្វះបាននៅក្នុងជីវភាពប្រចាំថ្ងៃ។ ក្នុងនោះមានចម្រៀងបំពេប្រកបដោយលក្ខណៈសម្បូរបែប បង្កប់នូវតម្លៃអំពីខ្លឹមសារ និងទម្រង់សិល្បៈដែលផ្សារភ្ជាប់ជាមួយជីវភាពរស់នៅក្នុងសហគមន៍។

អាចសន្និដ្ឋានបានថា ចម្រៀងបំពេខ្មែរមានតួនាទីដ៏សំខាន់ក្នុងការឆ្លុះបញ្ចាំងអត្តសញ្ញាណវប្បធម៌របស់ជនជាតិខ្មែរ និងបង្កប់តម្លៃអប់រំយ៉ាងជ្រៅសម្រាប់ប្រៀនប្រដៅកូនចៅជំនាន់ក្រោយ។ តាំងពីបុរាណកាលមក ចម្រៀងបំពេបានជ្រួតជ្រាបក្នុងជីវភាពប្រចាំថ្ងៃរបស់មនុស្ស ជាអាហារផ្នែកខាងស្មារតីដែលប្រជាជនមិនអាចខ្វះបាន។ តែបច្ចុប្បន្ននេះ ទំនោរនៃសមាហរណកម្មអន្តរជាតិមួយថ្ងៃកាន់តែបើកទូលាយ បញ្ហាជះឥទ្ធិពលនៃអរិយធម៌បច្ឆិមប្រទេស ការរីកចម្រើននៃប្រពន្ធផ្សព្វផ្សាយសោតទស្សន៍ កម្មវិធីសិល្បៈថ្មីពេញនិយមបានផ្សាយលើកញ្ចក់ទូរទស្សន៍ និងលើបណ្តាញសង្គម ធ្វើឱ្យចម្រៀងបំពេខ្មែរនៅដីសណ្តទន្លេមេគង្គនៃប្រទេសវៀតណាម កំពុងតែប្រឈមមុខនឹងការលំបាកជាច្រើន។ ចម្រៀងបំពេមួយថ្ងៃកាន់តែបាត់បង់សាបរលាបទៅជាបណ្តើរៗ ដោយសារមិនមានឯកសារសរសេរជាក់លាក់សម្រាប់បង្ហាត់បង្រៀនក្មេងៗជំនាន់ក្រោយ យុវវ័យមានទំនោរចូលចិត្តតន្ត្រីសម័យ និងទទួលយកនៃតន្ត្រីបរទេស។ ក្មេងៗជំនាន់ក្រោយក៏ភ្លេចអំពីតន្ត្រីប្រជាប្រិយប្រភេទនេះ ដោយសារការរីកចម្រើននៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងការណែនាំ បង្ហាត់បង្រៀនអំពីចម្រៀងបំពេ។ ដូច្នេះហើយ ការប្រមែប្រមូល និងកត់ត្រាទុក នៃបទភ្លេងនិងទំនុកចម្រៀងបំពេខ្មែរ ដើម្បីជាឯកសារសម្រាប់បង្រៀនក្មេងៗជំនាន់ក្រោយ គឺជាយុទ្ធសាស្ត្រដ៏សំខាន់មួយក្នុងការថែរក្សាតម្លៃវប្បធម៌និងតម្លៃអប់រំនៃចម្រៀងបំពេខ្មែរ ដែលកិច្ចការមិនអាចប្រកែកបានឡើយ។

ក្នុងអត្ថបទស្រាវជ្រាវនេះ យើងខ្ញុំសិក្សាស្រាវជ្រាវដែលបានធ្វើការប្រមូលទិន្នន័យ និងធ្វើការវិភាគអត្ថន័យខ្លឹមសារអប់រំតែបទចម្រៀងបំពេដែលប្រមូលបានពីប្រជាជនខ្មែរដែលកំពុងរស់នៅនៅភាគខាងត្បូងប្រទេសវៀតណាម។

## ២- និយមន័យចម្រៀងបំពេ

ចម្រៀងប្រជាប្រិយ គឺចម្រៀងដែលអ្នកស្រុក អ្នកភូមិគេនិយមចូលចិត្តរាប់អាន ជាពិសេសពួកក្រមុំកម្លោះ។ ចម្រៀងប្រភេទនេះពួកយុវកសិករខ្មែរយើង ដែលនៅលីវគេតែងតែស្រែកច្រៀងផ្តោះផ្តងឆ្លងឆ្លើយពីស្រែមួយទៅស្រែមួយ ក្នុងគោលបំណងបង្ហាញពីមនោសញ្ចេតនាខ្លួន។[១]

---

[១] ជុំ យុនសុជាតា *ប្រវត្តិអក្សរសិល្ប៍* វិទ្យាស្ថានជាតិអប់រំ, ភ្នំពេញ ឆ្នាំ២០១៣ ទំព័រ២៨។

ចម្រៀងបំពេគឺជាបទចម្រៀងដែលជួយឱ្យកុមារគេងលក់ស្រួល។ ភាគច្រើនទំនុកច្រៀងមកពីច្បាប់ក្រម ពាក្យទូន្មាន សុភាសិត ឬដកស្រង់ចេញពីកំណាព្យប្រជាប្រិយ ឬចម្រៀងដែលបន្សល់ទុកផ្ទាល់មាត់ពីជីដូនទៅម្ដាយ ជំនាន់មុនទៅជំនាន់ក្រោយ។ ដូច្នេះហើយ បទចម្រៀងទាំងនេះមានលក្ខណៈចម្រុះ និងស្ទើរតែគ្រប់គ្រួសារមានរបៀបច្រៀងខុសៗគ្នា។

ចម្រៀងបំពេគឺជាចម្រៀងមួយស្ថិតក្នុងចម្រៀងប្រជាប្រិយ។ បទនេះគេច្រើនយកទៅបង្ហាញនៅក្នុងពិធីផ្សេងៗដូចជា ពិធីពលកម្ម ពិធីលើសកម្មភាពគ្រួសារ ពិធីមង្គលការជាដើម។ បទបំពេមានក្នុងអក្សរសិល្ប៍ មានក្នុងល្ខោនបាសាក់ ល្ខោនយីកេ និងក្នុងជីវភាពរស់នៅ។ បទចម្រៀងបំពេមានបំណងអប់រំមនុស្ស ដែលការអប់រំនោះប្រកបទៅដោយមនោសញ្ចេតនា និងមានភាពទន់ភ្លន់តែម៉ឺងម៉ាត់ ចម្រៀងបំពេស្រទន់ពីរោះរណ្ដំអាចលួងលោមកូនចៅ តាយាយ ប្ដីប្រពន្ធ គូសង្សារឱ្យមានអារម្មណ៍ស្រស់ស្រាយសប្បាយចិត្ត បំបាត់អស់ទុក្ខកង្វល់ ការក្រេវក្រោធឱ្យរសាយអស់។ មិនតែប៉ុណ្ណោះ ចម្រៀងបំពេបានបង្ហាញពីវប្បធម៌ប្រពៃណីសង្គមរស់នៅរបស់ខ្មែរ និងបានបណ្ដុះនូវមនោសញ្ចេតនាយុវជនឱ្យស្រឡាញ់ជាតិមាតុភូមិ ស្រឡាញ់មាតាបិតា មានក្រមសីលធម៌ត្រឹមត្រូវ និងមានសុជីវធម៌ក្នុងការរស់នៅ។

## ៣- ចម្រៀងបំពេក្នុងវប្បធម៌ខ្មែរ

ចម្រៀងបំពេមិនត្រឹមតែជាចម្រៀងសម្រាប់លួងលោម បំពេអារម្មណ៍នោះទេ បទបំពេនៅបានរួមបញ្ចូលនូវតម្លៃវប្បធម៌ខ្មែរទៀតផង។ យើងសង្កេតឃើញថា ទោះបីជាអ្នកច្រៀងបំពេមិនមែនជាអ្នកចម្រៀងក៏ដោយ គាត់ក៏អាចច្រៀងបទបំពេបានដែរ ព្រោះចម្រៀងនេះមិនផ្ដោតសំខាន់ទៅលើទឹកដមនៃសំឡេងនោះទេ។ ចម្រៀងបំពេគឺពីរោះចេញពីចិត្តនិងបេះដូងរបស់អ្នកច្រៀង។ ពុំនោះសោតចម្រៀងបំពេមិនត្រឹមតែច្រៀងសម្រាប់បំពេកូនឱ្យដេកនោះទេ ថែមទាំងច្រៀងបំពេមនុស្សពេញវ័យ ចាស់ទុំច្រៀងក្នុងពិធីរៀបអាពាហ៍ពិពាហ៍ .....។

វ័យទារក និងវ័យកុមារ៖ វ័យនេះជាវ័យដែលសំខាន់ណាស់ព្រោះទារកនៅតូចប្រៀបបាននឹងក្រដាសស ដូច្នេះហើយទាមទារឱ្យម្ដាយឪពុកត្រូវយកចិត្តទុកដាក់ការមើលថែឱ្យបានដិតដល់។ សម្រាប់ជនជាតិខ្មែរចម្រៀងបំពេកូនគឺជាតន្ត្រីមួយប្រភេទ ដែលប្រកបដោយអត្ថន័យដ៏ខ្ពង់ខ្ពស់បំផុត ព្រោះវាជាការបេបោសអង្អែលការអង្វរករ សេចក្ដីស្នេហារបស់ម្ដាយឪពុក និងជាគុណបំណាច់ទៅលើកូនរបស់ខ្លួនដែលស្រឡាញ់ស្មើជីវិតរបស់ម្ដាយឪពុក។ ពេលនេះទារកត្រូវការថ្នមថ្នាក់ ម្ល៉ោះហើយទំនុកច្រៀងតែងលើកឡើងភ្លាមៗតាមការនឹកឃើញជាក់ស្ដែង ស្របតាមហេតុការណ៍នោះ គឺលួងលោមយ៉ាងណាឱ្យទារកបានស្ងប់ចិត្តលង់លក់ទៅ។

សម្រាប់យុវតីចូលម្លប់៖ ពិធីចេញម្លប់ចូលម្លប់នេះពីសម័យដើមចាត់ជាមង្គលមួយយ៉ាងធំដែរសម្រាប់ស្ត្រីខ្មែរ។ បុព្វបុរសខ្មែរបង្កើតពិធីនេះសម្រាប់ឱ្យកូនស្រីចាប់អារម្មណ៍ពីលំដាប់ថ្នាក់ប្រចាំជីវិតដែលត្រូវឈានឡើងដោយឱ្យប្រឹងប្រែងតស៊ូជានិច្ចដើម្បីវឌ្ឍនភាព។ កុមារីចូលដល់វ័យពេញក្រមុំ ការកំណត់របស់សង្គមខ្មែរស្ថិតនៅត្រង់ការមករដូវជាលើកទីមួយ ដែលគេនិយមហៅថាគ្រប់ការ។ សម្រាប់វ័យនេះពេលដែលកំពុងឈានឡើងនាងមានលក្ខណៈប្លែក អត្តចរិតចួនឆាប់ខឹង ចួនអៀនខ្មាស ចួនចូលចិត្តស្ងប់ស្ងាត់នៅតែម្នាក់ឯងព្រួយចិត្តដោយឥតមូលហេតុ។

## ៤- ចម្រៀងបំពេរួមចំណែកអប់រំសង្គម

### ក- ចម្រៀងបំពេអប់រំសីលធម៌ គុណធម៌ និងសច្ចធម៌

ចម្រៀងបំពេជាប្រភេទចម្រៀងដ៏ពិសេសមួយ និងបានបង្កើតឡើងតាំងពីយូរលង់ណាស់មកហើយ។ ហេតុដូច្នេះហើយចម្រៀងបំពេតែងតែមានលក្ខណៈនិងតម្លៃអប់រំទារក និងកុមារដែលមិនអាចខ្វះបានក្នុងជីវភាពរស់នៅនិងវប្បធម៌នៃជនជាតិខ្មែរ។ ឆ្លងតាមពាក្យពេចន៍និងសំនៀងរបស់ខ្លួន អ្នកម្ដាយ ជីដូនឬជីតាបានជួយឱ្យកូនៗ និងចៅៗ មានបុគ្គលិកលក្ខណៈ អាកប្បកិរិយាល្អ ក្នុងការប្រាស្រ័យទាក់ទងគ្នារវាងមនុស្សនិងមនុស្ស ព្រមទាំងជាមួយនឹងធម្មជាតិ។ បណ្ដុះក្នុងអារម្មណ៍របស់ទារក និងកុមារនូវក្រមសីលធម៌ត្រឹមត្រូវ ចរិតមេត្តា មានចិត្តចេះសន្ដោសប្រោសប្រណី មានគំនិតចេះស្រឡាញ់អំពើល្អ ចៀសវាងអំពើអាក្រក់ ចេះស្រឡាញ់ជាតិមាតុភូមិ។

តាំងពីនៅក្មេងក្ដី ក្មេងៗទាំងនេះបានជ្រួតជ្រាប និងដឹងពីសេចក្ដីលំបាក ការនឿយហត់ របស់ឪពុកម្ដាយក្នុងការថែទាំ ចិញ្ចឹមបីបាច់ថ្នមថ្នាក់ខ្លួនតាំងពីកើតរហូតធំដឹងក្ដីដែលឆ្លងតាមបទបំពេ៖

**បំពេ**

កូនអើយគេងទៅពៅអើយកុំយំ　　បាយកកទឹកឃ្មុំហូបហើយគេងលក់
ឱ្យម្ដាយបង្ហើយត្បាញកន្ទេលកក់　　ដាំស្លែត្រសក់ចិញ្ចឹមពិសី។
កូនអើយគេងទៅស្អែកថ្ងៃថ្មី　　កូនទៅយកជ័យជូនជាតិខេមរា
កូនធំដឹងក្ដីទៅសាលា　　កូនធ្វើកិច្ចការឱ្យម្ដាយសង្ឃឹម។
ជីញ្ជក់តុកកែចូរឯងឈប់យំ　　ទុកឱ្យកូនខ្ញុំសម្ងំគេងលក់។
ឱ្យម្ដាយបង្ហើយត្បាញកន្ទេលកក់　　ដាំស្លែត្រសក់ចិញ្ចឹមពិសី។[២]

ចម្រៀងបំពេទូន្មានឱ្យកុមារចេះគោរពដឹងគុណនូវគុណតម្លៃ តំណក់ញើសឈាម ការហត់នឿយ និងទឹកចិត្តស្រឡាញ់កូនស្ងួនរបស់ម្ដាយឪពុក ហើយធ្វើឱ្យកុមារយល់ដឹងច្បាស់ការ និងខិតខំលត់ដំ ខិតខំធ្វើការជួយឪពុកម្ដាយ រៀនសូត្រឱ្យបានល្អ ដើម្បីក្លាយជាមនុស្សមានប្រយោជន៍ក្នុងសង្គម។ ក្នុងទំនុកបទចម្រៀងអ្នកម្ដាយខិតខំអប់រំកូនចេះស្រឡាញ់គ្នាទៅវិញទៅមក ស្រឡាញ់ការងារ ចេះជួយធ្វើការឪពុកម្ដាយ ខិតខំរៀនសូត្រ...។ ទោះបីហត់នឿយយ៉ាងណាឪពុកម្ដាយមិនដែលត្អូញត្អែរឡើយ ខិតខំធ្វើការរកស៊ីដើម្បីរកប្រាក់ចិញ្ចឹមកូន ឱ្យកូនមានសេចក្ដីសុខ មានអនាគតថ្លៃថ្លា។

**បទបំពេចៅ**

អាវ៉ាអើយដេកទៅ　ណាចៅកុំយំ　ទម្រាំបាយងំ　ញ៉ាំហើយដើរលេង។
ជីដូននិងចៅ　និត្យនៅតែផ្ទះ　ម្ដាយនាងនឿយណាស់　ដកហើយស្ទូងផង។
ទាំងជើងទាំងដៃ　ទាំងមាត់ស្រែកកង　សូរសព្ទរំពង　បង្អើលចាបពូក។[៣]

---

[២] ថាច់ ធីសុខស្រាង នៅស្រុកចូវថាញ់ ខេត្តត្រាវិញ ឆ្នាំ២០២៤។

[៣] ច្រៀងដោយ ថាច់ ធីហា នៅសង្កាត់ទី ខេត្តត្រាវិញ ឆ្នាំ២០២៤។

បទចម្រៀងបំពេមានតម្លៃអប់រំយ៉ាងជ្រាលជ្រៅសម្រាប់កូនចៅ។ ឆ្លងតាមបទនេះដែរ ចង់អប់រំកូនចៅត្រូវចេះគោរពដឹងគុណឪពុកម្តាយដែលជាអ្នកមានគុណដ៏លើសលប់គ្មានអ្វីប្រៀបបាន និងត្រូវតែតបស្នងសងគុណលោកទាំងទ្វេ។ តាំងពីកើតមកឪពុកម្តាយខិតខំរកស៊ី មិនខ្លាចនឿយហត់ ទោះបីភ្លៀងក្តៅ យប់ថ្ងៃលោកមិនដែលថ្ងូរ ធ្វើគ្រប់ការងារដើម្បីរកលុយចិញ្ចឹមកូនស្ងួន។ មិនតែប៉ុណ្ណោះលោកនៅទាំងខ្លាចកូនល្ងង់ខ្លៅ ជូនកូនទៅរៀនសព្វមុខវិជ្ជា ដើម្បីឱ្យកូនមានចំណេះដឹង ក្លាយជាអ្នកប្រាជ្ញ ឱ្យមានអនាគតរុងរឿងនិងថ្លៃថ្លា។ អប់រំកូនចៅរស់នៅត្រូវចេះស្តាប់បង្គាប់ការទូន្មានឪពុកម្តាយ។ ពេលធំឡើងត្រូវចេះជួយធ្វើកិច្ចការផ្ទះ សម្រាលការងារឱ្យឪពុកម្តាយ។

### ខ- ចម្រៀងបំពេអប់រំការស្នេហាជាតមាតុភូមិ

**បំពេកូន**

| | |
|---|---|
| កូនអើយគេងទៅណាពៅពិសី | កូនកុំគិតអីម៉ែថ្នមបំពេ |
| កើតមកជាមនុស្សត្រូវចេះរិះរេ | រៀនសូត្រនឹងគេឱ្យមានរស្មី។ |
| កើតជាកូនប្រុសថែឈ្មោះមេបា | ចេះថែរក្សាការពារទឹកដី |
| រក្សាត្រកូលព្រោះកូនជាស្រី | ថែប្រពៃណីជាតិយើងឱ្យគង់។[៤] |

ចម្រៀងបំពេជាស់តឿនក្រើនរំលឹកដល់យុវជនឱ្យចេះស្រឡាញ់ការពារជាតិ និងថែរក្សានូវសម្បត្តិវប្បធម៌របស់ជាតិ ស្រឡាញ់សម្បត្តិធម្មជាតិ ចេះអត់ធ្មត់ ចេះទទួលខុសត្រូវក្នុងជីវិត ចេះស៊ូទ្រាំនឹងការលំបាក មានការរស់នៅឱ្យបានថ្លៃថ្នូរ ប្រកបដោយគុណធម៌ សុចរិតធម៌ និងសច្ចធម៌។ បទបំពេជាស់សតិឱ្យខិតខំសិក្សារៀនសូត្រ ដើម្បីឱ្យមានចំណេះដឹងខ្ពង់ខ្ពស់សម្រាប់ជួយជាតិនាពេលអនាគត។

### គ- ចម្រៀងបំពេអប់រំចរិយាសាស្ត្រ

ស្ត្រីខ្មែរគឺជាអ្នកដែលមានសិល្បៈខ្ពស់ក្នុងការចរចាក៏ដូចជាលើកទឹកចិត្ត ហើយស្ត្រីជាមេគ្រួសារជាមង្គលរបស់ប្តី និងគ្រួសារ ស្ត្រីផ្តល់សិរីសួស្តីជោគជ័យដល់គ្រួសារនិងស្វាមី។ បទបំពេអប់រំដល់ស្ត្រីចេះរ៉ាប់រងគ្រួសារ ជាមេផ្ទះត្រូវចេះគោរពស្រឡាញ់ប្តី ស្មោះស្ម័គ្រកក្តីភាព។ ស្ត្រីនាំឱ្យស្វាមីនិងសង្គមគ្រួសាររីកចម្រើននិងធ្វើឱ្យគ្រួសារមានភាពកក់ក្តៅនិងសុភមង្គល។ អប់រំស្ត្រីជាអ្នកជួយយឹតយោងស្វាមីនិងកូនចៅឱ្យបានខ្ពង់ខ្ពស់ មានកិត្តិយសបុណ្យស័ក្តិ ព្រមទាំងជាអ្នកមានតួនាទីយ៉ាងសំខាន់ដើម្បីជួយលើកស្ទួយជីវភាពគ្រួសារឱ្យកាន់តែធូរធារសម្បូរសប្បាយប្រកបដោយសុភមង្គលដូចបទបំពេខាងក្រោម៖

**បំពេកូន**

| | |
|---|---|
| កូនមាសម្តាយកូនអើយចាំស្តាប់ | ម៉ែច្រៀងរ៉ាយរ៉ាប់ប្រាប់កូនស្រី |
| ឥឡូវពេលនេះម៉ែឱ្យមានប្តី | តាមប្រពៃណីច្បាប់បូរាណ។ |
| ម៉ែមានកិត្តិយសដោយសារកូនស្រី | កេរ្តិ៍ឈ្មោះល្បាញល្បីកូនរក្សាបាន |
| ញាតិមិត្តបងប្អូនគេតែងរាប់អាន | មិនដែលរំខានឱ្យថ្នាក់ចិត្តឡើយ។ |

---

[៤] ច្រៀងដោយ ថាច់ ធីសោភា នៅឃុំផុងភូ ស្រុកកូវកែ ខេត្តត្រាវិញ ឆ្នាំ២០២៤។

ពាក្យចាស់ពោលថាភ្នក់ភ្លើងទាំងបី កូនអើយកូនស្រីម្ដាយផ្ដាំកូនហើយ
ភ្នក់ភ្លើងទីមួយគឺកូនហ្នឹងហើយ កូនមិនត្រូវឡើយនាំចេញទៅក្រៅ។
ភ្នក់ភ្លើងទីពីរកូនត្រូវចាំស្ដាប់ ពាក្យពេចន៍សាសព្វនៃឪពុកម្ដាយ
កុំយករឿងគាត់ទៅបរិយាយ នាំក្ដីក្រហាយដល់ញាតិប្រុសស្រី។
ភ្នក់ភ្លើងទីមួយហើយនឹងទីពីរ កូនស្រស់ធរីត្រូវមានខន្ដី
ភ្នក់ភ្លើងទាំងអស់សុទ្ធតែមានន័យ ភ្នក់ភ្លើងទីបីគឺភ្លើងគ្មានផ្សេង។[៥]

## ឃ- ចម្រៀងបំពេរអប់រំក្នុងគ្រួសារ ក្នុងសាលារៀន

ដោយដឹងថានៅលើលោកនេះគ្មានអ្វីប្រសើរជាងចំណេះវិជ្ជា ព្រោះថាវិជ្ជាជាទ្រព្យគាប់ប្រសើរ វិជ្ជាជាស្ពានឈានទៅអនាគតរុងរឿង វិជ្ជាធ្វើឱ្យមនុស្សមានភាពថ្លៃថ្នូរ អ្នកមានចំណេះវិជ្ជាជ្រៅជ្រះអាចធ្វើអ្វីៗទាំងពួងបានដូចបំណង។ យល់ឃើញច្បាស់អំពីសារប្រយោជន៍នៃចំណេះវិជ្ជា ហេតុនេះហើយបទចម្រៀងប្រជាប្រិយតែងតែផ្ដោតទៅលើខ្លឹមសារ អត្ថន័យអប់រំកូនចៅឱ្យចេះខិតខំរៀនសូត្រ ដើម្បីឱ្យមានចំណោះដឹងខ្ពង់ខ្ពស់ ដើម្បីជាទ្រព្យសម្រាប់អនាគតថ្ងៃក្រោយ បានថ្លៃថ្លារុងរឿងនិងមានជីវភាពរស់នៅល្អប្រសើរ។

### បំពេកូន

កូនអើយកុំយំ ម្ដាយនៅបំពេ ដើម្បីមាសស្នេហ៍ម្ដាយមិនគិតប្រាណ
ការងារតូចធំខំធ្វើឱ្យបាន សុំតែកល្យាណកូនម្ដាយធំឆ្លាត។
ធំឡើងរៀនសូត្រគ្រប់សព្វវិជ្ជា ប្រកបការងារណាដែរត្រឹមត្រូវ
បំណងអ្នកម្ដាយសុំតែពាលពៅ ពីនេះតទៅផុតទុក្ខលំបាក។[៦]

ពាក្យចាស់ពោលថាក្ដាមចាស់វាសក រីឯមនុស្សចាស់ស្លាប់ ឪពុកម្ដាយពេលចាស់ទៅគាត់ស្លាប់ មិនអាចនៅថែទាំកូនរហូតបានឡើយ។ សត្វដុះស្លាបគ្រប់វានឹងហើរទៅព្រៃព្រឹក្សាចិញ្ចឹមជីវិតដោយខ្លួនឯង។ ដូច្នេះហើយទឹកចិត្តឪពុកម្ដាយជានិច្ចកាលតែងតែគិតអនាគតឱ្យកូនៗ បានជាគាត់ប្រៀនប្រដៅកូនឱ្យខិតខំរៀនសូត្រ និងតម្រែតម្រង់ទិសឱ្យកូនៗតាំងពីនៅតូចក្ដី ដើម្បីជំរុញកម្លាំងចិត្ត ក៏ដូចជាបង្កើតទំនុកចិត្តឱ្យកូនខំប្រឹងដើម្បីឆ្លងផុតព្យុះជីវិត។

### បំពេ

ឱណាកូនអើយកូនកុំយំ បាយកកទឹកឃ្មុំហូបហើយដើរលេង
លេងជិតកូនកុំលេងឆ្ងាយ ស្ដាប់ម្ដាយហៅប្រើរែកទឹកឬបុកអង្ករ។
ពេលកូនដាំស្លចូរចងចាំ បើបាយកូនដាំកុំយកអុសឫស្សី
ព្រោះភ្លើងឆេះខ្លាំងមិនដូចចិត្តអី បាយនោះណាស្រីខ្លោចហើយឆៅផង។[៧]

---

[៥] ច្រៀងដោយ ថាច់ ធី សោភា នៅឃុំផុងកូ ស្រុកកូរ៉ែ ខេត្តត្រាវិញ ឆ្នាំ២០២៤។

[៦] ច្រៀងដោយ ថាច់ ស្រស់ នៅឃុំដួងចូវ ស្រុកយៀនហាយ ខេត្តត្រាវិញ ឆ្នាំ២០២៤។

[7] ថាច់ ធីសី នៅស្រុកចូវថាញ់ ខេត្តគៀនយ៉ាង ឆ្នាំ២០២៣។

ចម្រៀងប្រជាប្រិយក្រៅពីមុខងារសម្រាប់លួងលោមឱ្យកុមារគេងលង់លក់ស្កប់ស្កល់ នៅមានមុខងារសម្រាប់ប្រៀនប្រដៅកូនចៅ អំពីបទពិសោធន៍ក្នុងជីវិតរស់នៅសម្រាប់កុមារតាំងពីនៅក្មេងវ័យទៀតផង។ យ៉ាងណាមិញដូចបទបំពេខាងលើនេះ បង្ហាញឱ្យឃើញថា ពីដើមនំចំណី ម្ហូបអាហារមិនបានសម្បូរហូរហៀរដូចជាសព្វថ្ងៃនេះទេ មានចំណីគ្រប់សព្វបែបយ៉ាងមានទឹកដោះគោ ផ្លែឈើ..... កុមារមានតែបាយមួយមុខសម្រាប់ហូបតែប៉ុណ្ណោះ ពេលថ្ងៃជ្រេបន្តិចបើឃ្លានហូបបាយកកជាមួយនឹងទឹកឃ្មុំ។ ទន្ទឹមនឹងនោះដែរ បទនេះបានបង្ហាញពីទឹកចិត្តម្តាយ ក្នុងការអប់រំបង្ហាប់បង្ហាញកូនចៅអំពីមេរៀនជីវិត។ ពេលធំឡើងកូនចៅចេះជួយកិច្ចការផ្ទះជាមួយឪពុកម្តាយ ក្នុងនោះដូចជារែកទឹកដាក់ពាង ជួយបុកអង្ករ សម្រាប់ដាំបាយ ជួយធ្វើម្ហូបម្តាយជាដើម។ មេរៀនដ៏សំខាន់មួយទៀតនោះពេលដែលកូនដាំបាយ កាលបើចង់ឱ្យបាយឆ្អិនឆ្ងាញ់ ការរើសអុសមកដុតនោះសំខាន់ណាស់។ ចាស់ៗពីដើមគាត់បានផ្តាំថា កាលបើដាំបាយកុំយកអុសឫស្សី ព្រោះថាអុសនេះវាឆេះខ្លាំងអាចធ្វើឱ្យបាយយើងខ្លោច ហើយវាគ្មានរងើកអាចធ្វើឱ្យបាយយើងឆៅ។ ហេតុនេះហើយយើងគួរយកអុសឈើមកដាំ ព្រោះវាមានរងើកច្រើនធ្វើឱ្យបាយយើងឆ្អិនសព្វ មិនឆៅហើយមានរសជាតិឆ្ងាញ់ទៀតផង។

## ៥. សន្និដ្ឋាន

ក្នុងដំណើរការអភិវឌ្ឍវប្បធម៌សហគមន៍ ស្ទើរតែគ្រប់ជាតិសាសន៍សុទ្ធតែមានចម្រៀងបំពេ។ ជាតិសាសន៍នីមួយៗមានទម្រង់ចម្រៀងបំពេ និងអារម្មណ៍មនោសញ្ចេតនាក្នុងពេលច្រៀងផ្សេងៗគ្នាតាមអត្តសញ្ញាណវប្បធម៌រៀងៗខ្លួន។ ចម្រៀងបំពេជាបទចម្រៀងរបស់អ្នកម្តាយដែលច្រៀងបំពេកូន ហើយវាបានក្លាយទៅជាផ្នែកមួយដ៏សំខាន់នៃចម្រៀងប្រជាប្រិយ និងបានរួមចំណែកយ៉ាងសំខាន់ក្នុងការអប់រំអំពីអាកប្បកិរិយាមនុស្ស អប់រំគុណធម៌ សច្ចធម៌ និងសីលធម៌ អប់រំអំពីចរិយាសាស្ត្រសម្រាប់ស្ត្រី ការគោរពដឹងគុណឪពុកម្តាយអ្នកដែលមានគុណចំពោះខ្លួន អំពីការខិតខំសិក្សារៀនសូត្រ អប់រំមនុស្សឱ្យចេះស្រឡាញ់ជាតិមាតុភូមិ ចេះស្រឡាញ់យុត្តិធម៌ សច្ចភាព ចេះរួបរួមសាមគ្គីគ្នា ជួយគ្នាទៅវិញទៅមកក្នុងគ្រួសារនិងសង្គម។

ចម្រៀងបំពេបានបង្ហាញពីទំនាក់ទំនងរវាងវប្បធម៌ប្រពៃណី និងការអប់រំផ្លូវចិត្ត និងសីលធម៌ដ៏ល្អរវាងសមាជិកគ្រួសារ និងអ្នកជិតខាង ហើយតែងណែនាំកុមារឱ្យឈានដល់ភាពស្រស់ស្អាត គុណតម្លៃដ៏ថ្លៃថ្នូរសម្រាប់ជីវិតនិងស្មារតីភ្លឺថ្លា ដែលអ្នកម្តាយនាំមកឱ្យកូនតាំងពីតូច។ ជាក់ច្បាស់ណាស់ សំឡេងច្រៀងដ៏លួងលោមរបស់អ្នកម្តាយគឺជាប្រភពវប្បធម៌ដែលចិញ្ចឹមបីបាច់ថែរក្សា និងបង្កើតព្រលឹង និងអារម្មណ៍មនោសញ្ចេតនារបស់កុមារ។ តាមរយៈបទចម្រៀងរបស់អ្នកម្តាយ មានរឿងថ្មីជាច្រើនកើតឡើងក្នុងអារម្មណ៍របស់កូន។ ចម្រៀងបំពេមិនត្រឹមតែលួងលោមកូនឱ្យគេងលក់ប៉ុណ្ណោះទេ នូវទាំងមានគុណតម្លៃពិសេសក្នុងការអប់រំសីលធម៌ សុជីវធម៌ និងបុគ្គលិកលក្ខណៈរបស់មនុស្ស។

សម្រាប់កុមារ ចម្រៀងបំពេគឺជាកត្តាមួយដែលបង្កើតជាអត្តសញ្ញាណវប្បធម៌ជាតិ ជាប្រភពទឹកដោះដែលចិញ្ចឹមស្មារតី និងជាស្ពានតភ្ជាប់ចិត្តរបស់កុមារជាមួយនឹងមេរៀនអំពីជីវិតសង្គម ព្រោះវាមានភាពទាក់ទាញសម្រាប់កុមារ ដើម្បីអភិវឌ្ឍន៍សីលធម៌ សាមគ្គីភាព ពង្រីកការយល់ដឹង ស្រឡាញ់ធម្មជាតិ ស្រឡាញ់មាតុភូមិ ដោយហេតុនេះបានរួមចំណែកក្នុងការអប់រំកុមារអំពីប្រពៃណីវប្បធម៌ជាតិខ្មែរ។

យើងអាចនិយាយបានថាចម្រៀងបំពេគឺជាកត្តាមួយដែលរួមចំណែកដល់ការបង្កើត និងអភិវឌ្ឍបុគ្គលិកលក្ខណៈ ជួយឱ្យកុមារឱ្យយល់ឃើញពីតម្លៃនៃតន្ត្រីប្រជាប្រិយ និងឥទ្ធិពលនៃបទភ្លេងទៅលើជីវិតរស់នៅក្នុងសង្គម ជំរុញសតិអារម្មណ៍ទៅលើការឱ្យតម្លៃ ការថែរក្សា និងលើកកម្ពស់នៃតម្លៃសិល្បៈក្នុងខឿនវប្បធម៌ប្រពៃណីជាតិ។ ក្រៅពីនោះជួយកុមារឱ្យយល់កាន់តែច្បាស់អំពីលក្ខណៈនៃបទចម្រៀងប្រជាប្រិយខ្មែរ ហើយបង្រៀនឱ្យចេះសាមគ្គីភាព ស្រលាញ់គ្នា គោរពគ្រូ និងមិត្តភ័ក្តិ ស្រលាញ់ធម្មជាតិ ស្រលាញ់សន្តិភាព ជាពិសេសអប់រំកូនៗឱ្យចេះស្រលាញ់គ្រួសារ ស្រឡាញ់មាតុភូមិ។

# គន្ថនិទ្ទេស


១. កែប វ៉ាន់ឌី *អរិយធម៌ខ្មែរមន* ភ្នំពេញឆ្នាំ១៩៧៣។

២. កែវ ណារុំ *តន្ត្រីនៅប្រទេសខ្មែរ* ភ្នំពេញ ឆ្នាំ២០១១។

៣. ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ *លំនាំសង្ខេបនៃភ្លេងខ្មែរ* ពុទ្ធសាសនាបណ្ឌិត ភ្នំពេញ ឆ្នាំ១៩៨៤។

៤. ខ្លូត ធីតា *ទិដ្ឋភាពទូទៅនៃគំនិតខ្មែរ* ភ្នំពេញ រោងពុម្ពពុទ្ធសាសនាបណ្ឌិត្យ ឆ្នាំ១៩៩៦។

៥. គង់ សុខហេង *អក្សរសាស្ត្រខ្មែរ* ភ្នំពេញបោះពុម្ពលើកទី២ ឆ្នាំ២០១១។

៦. គឹម សារឿន *ទស្សនៈអប់រំអក្សរសិល្ប៍ប្រជាប្រិយ* គ្រឹះស្ថានបោះពុម្ពផ្សាយបឹងទន្លេសាប ឆ្នាំ២០១១។

៧. ជាវណ្ណី និងទុយ យូឃីម *អក្សរសិល្ប៍ខ្មែរ* រាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ ឆ្នាំ២០២៤។

៨. ត្រឹង ងា *អរិយធម៌ខ្មែរ* ភ្នំពេញបោះពុម្ពលើកទី៣ ឆ្នាំ១៩៧៤។

៩. ថន ចាន់ពិសី *ចម្រៀងបំពេរបស់ប្រជាជនខ្មែរ* និក្ខេបបទបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ឆ្នាំ២០២២។

១០. យ៉ាប់ មេត្តា *ច្បាប់អប់រំ* ភ្នំពេញ ឆ្នាំ២០០៦។

១១. សខន - សាម៉ន *វិជ្ជាមេផ្ទះចែងអំពីការអប់រំស្ត្រី* ពុទ្ធសាសនាបណ្ឌិត ឆ្នាំ១៩៦៤។

១២. ស៊ុំ ឈុំទ្បុង *ឯកសារបង្រៀនអក្សរសិល្ប៍ប្រជាប្រិយខ្មែរ* រាជបណ្ឌិត្យសភាកម្ពុជា ភ្នំពេញ ឆ្នាំ២០១៥។

១៣. ស៊ុំឈុំទ្បុង *តួនាទីនៃអក្សរសិល្ប៍ប្រជាប្រិយក្នុងការរួមចំណែកជាវិភាគទានសង្គម* និក្ខេបបទថ្នាក់បណ្ឌិត រាជបណ្ឌិត្យសភាកម្ពុជា ភ្នំពេញ ២០២១។

១៤. PGS TS. Phạm Tiết Khánh *អភិរក្សនិងពង្រីកតម្លៃវប្បធម៌នៃចម្រៀងប្រជាប្រិយខ្មែរណាមបូ* NXB Văn hóa dân tộc, 2021.

# ក្របខ័ណ្ឌការងារសម្រាប់ធានាការអភិវឌ្ឍវិជ្ជាជីវៈធនធានមនុស្ស ក្នុងក្រសួងអប់រំ យុវជន និងកីឡា

បេក្ខជនបណ្ឌិតៈ ទ្រី ចាន់
ជំនាញៈ **រដ្ឋបាលសាធារណៈ**

ដើម្បីកំណត់កម្រិតក្របខ័ណ្ឌការងារ សម្រាប់ធានាការអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំឱ្យបានច្បាស់លាស់ ក្រសួងអប់រំ យុវជន និងកីឡាត្រូវកំណត់កម្រិតស្វ័យភាពរបស់បុគ្គលិកអប់រំ រៀបចំដាក់ឱ្យអនុវត្តក្របខ័ណ្ឌការងារសម្រាប់អភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំ លើកកកម្ពស់ការសិក្សាពេញមួយជីវិត រៀបចំយន្តការប្រកបដោយប្រសិទ្ធភាព គាំទ្របុគ្គលិកអប់រំនៅនឹងកន្លែងបំពេញការងារ និងរៀបចំកែលម្អរចនាសម្ព័ន្ធគ្រប់គ្រងធនធានមនុស្សនៅតាមអង្គភាព។

## ១. កំណត់កម្រិតស្វ័យភាពរបស់បុគ្គលិកអប់រំ

ការកំណត់ក្របខ័ណ្ឌការងារសម្រាប់ធានាការអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំគឺ មានសារៈសំខាន់ខ្លាំងណាស់ ដើម្បីធានានិន្នភាពការងារនៅក្នុងអង្គភាព ក៏ដូចជាការពង្រឹងសមត្ថភាពបុគ្គលិកម្នាក់ៗឱ្យកាន់តែមានទំនួលខុសត្រូវខ្ពស់នៅក្នុងការបំពេញការងារ។ ការកំណត់ និងអនុវត្តកម្រិតស្វ័យភាពរបស់បុគ្គលិកអប់រំម្នាក់ៗ ត្រូវដឹងអំពីតួនាទី និងភារកិច្ចចាំបាច់ដោយខ្លួនឯង ដោយមិនចាំបាច់ថ្នាក់ដឹកនាំអង្គភាពបញ្ជាថាត្រូវធ្វើអ្វី មិនត្រូវធ្វើអ្វីនោះទេ។ យើងឃើញថាបុគ្គលិកនៅក្នុងក្រសួងអប់រំ យុវជន និងកីឡានៅតាមអគ្គាធិការដ្ឋាន អគ្គនាយកដ្ឋាន នាយកដ្ឋាន និងការិយាល័យជំនាញនីមួយៗបានកំណត់នូវរចនាសម្ព័ន្ធនៃគ្រប់គ្រងនិងដឹកនាំធនធានមនុស្ស រួមជាមួយការកំណត់នូវតួនាទី និងភារកិច្ចដែលមន្ត្រីម្នាក់ៗត្រូវតែបំពេញការងារ។ មន្ត្រីដែលមកបំពេញការងារត្រូវមានស្វ័យភាពថាខ្លួនមានសមត្ថភាពទៅលើជំនាញមួយណា ហើយខ្វះខាតលើផ្នែកណា ដើម្បីឱ្យប្រធានស្ថាប័ន អង្គភាព ត្រូវរៀបចំបណ្តុះបណ្តាលអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកឱ្យបានទាន់ពេលវេលា ឆ្លើយតបទៅនឹងកន្លែងការងារ។ ដើម្បីឆ្លើយតបទៅនឹងការកំណត់កម្រិតស្វ័យភាពរបស់បុគ្គលិកអប់រំ នាយកដ្ឋានជំនាញនានាត្រូវរៀបចំឱ្យមានពណ៌នាអំពីមុខតំណែង និងលក្ខណៈសម្បត្តិនៃមុខតំណែងទៅដល់នាយកដ្ឋានបុគ្គលិក។ នៅក្នុងការកំណត់កម្រិតស្វ័យភាពរបស់បុគ្គលិកអប់រំនៅតាមនាយកដ្ឋានជំនាញនីមួយៗ បុគ្គលិកមួយចំនួនមានសមត្ថភាពបំណិនវិជ្ជាជីវៈគ្រប់គ្រាន់ និងសញ្ញាបត្រខ្ពស់ចាប់ពីបរិញ្ញាបត្រ ឌីប្លូម៉ាកម្រិតខ្ពស់ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត តាមតួលេខ នៅក្នុងរយៈពេល ៥ឆ្នាំនេះ យើងឃើញថាបុគ្គលិកដែលមានបរិញ្ញាបត្រមានចំនួន ៣៨,៦៤ភាគរយ បរិញ្ញាបត្រជាន់ខ្ពស់ ៣១,៨៣ភាគរយ និងសញ្ញាបត្របណ្ឌិតចំនួន ១,៣៨ភាគរយ សរុបរួមបុគ្គលិកអប់រំមានសញ្ញាបត្រកម្រិតខ្ពស់មាន ៧១,៨៥ភាគរយ[១]។ ហើយម្យ៉ាងទៀត

---

[១] ក្រសួងអប់រំ យុវជន និងកីឡាស្ថិតិបុគ្គលិកអប់រំតាមស្ថានភាពបច្ចុប្បន្ន កាំប្រាក់ កម្រិតវប្បធម៌ អាយុ ក្របខ័ណ្ឌ ភ្នំពេញ ឆ្នាំ២០១៣-២០១៤ ដល់ឆ្នាំ២០១៧-២០១៨។

កម្រិតវិជ្ជាជីវៈរបស់បុគ្គលិកអប់រំដែលជាគ្រូបង្រៀនកម្រិតឧត្តមមានចំនួន ៥៦,២៩ភាគរយ ក្នុងចំណោមបុគ្គលិកសរុបទាំងអស់។ បើតាមតួលេខនេះបុគ្គលិកភាគច្រើនមានសញ្ញាបត្រកម្រិតខ្ពស់ និងកម្រិតវិជ្ជាជីវៈជាគ្រូកម្រិតឧត្តម បំពេញការងារនៅក្នុងអង្គភាពប្រកបដោយស្វ័យភាពនៅក្នុងការបំពេញការងារ បើបុគ្គលិកបំពេញការងារត្រូវនឹងជំនាញសញ្ញាបត្រ និងឧបនិស្ស័យការងារទៀត រឹតតែល្អប្រសើរ ប៉ុន្តែទាមទារបុគ្គលិកអប់រំដែលមានសញ្ញាបត្រមិនត្រូវជំនាញត្រូវស្វ័យសិក្សាបន្ថែមទៀត ដើម្បីអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួនឱ្យកាន់តែល្អប្រសើរ។ យើងឃើញបុគ្គលិកអប់រំ ២៨,១៥ភាគរយទៀត មិនមានលទ្ធភាពនៅក្នុងការកម្រិតនូវស្វ័យភាពរបស់ខ្លួននៅក្នុងការបំពេញការងារបានដោយសារតែសញ្ញាបត្រ កម្រិតវប្បធម៌ និងកម្រិតវិជ្ជាជីវៈនៅទាប ជាក់ស្តែងយើងឃើញថាបុគ្គលិកអប់រំដែលមិនទាន់បានបញ្ចប់បឋមសិក្សា រៀននៅបឋមសិក្សា មិនទាន់បញ្ចប់មធ្យមសិក្សា មធ្យមសិក្សាបឋមភូមិ មិនទាន់បញ្ចប់មធ្យមសិក្សាទុតិយភូមិ មធ្យមសិក្សាទុតិយភូមិ និងមិនទាន់បញ្ចប់បរិញ្ញាបត្រ។ បុគ្គលិកកម្រិតវិជ្ជាជីវៈមត្តេយ្យ គ្រូបឋមសិក្សា គ្រូកីឡា គ្រូមធ្យមសិក្សាសរុបចំនួន ៤៣,៧១ភាគរយ។ ទន្ទឹមនឹងនេះ បុគ្គលិកដែលផ្លាស់ប្តូរកន្លែងការងារនៅតាមរាជធានី ខេត្តចូលមកក្នុងអង្គភាពជំនាញនៅក្នុងក្រសួងអប់រំ យុវជន និងកីឡា មិនត្រូវនឹងជំនាញឯកទេស និងមិនត្រូវនឹងភារកិច្ចរបស់នាយកដ្ឋាននោះផងដែរ ដែលត្រូវការបណ្តុះបណ្តាលជំនាញរយៈពេលយូរ។

## ២. រៀបចំដាក់ឱ្យអនុវត្តក្របខ័ណ្ឌការងារសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំ

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវវាយតម្លៃ និងគ្រប់គ្រងឱ្យច្បាស់លាស់នូវគ្រប់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈដើម្បីទទួលស្គាល់ជាផ្លូវការ ឬប្រគល់សញ្ញាបត្រសមមូល គ្រប់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈត្រូវបានផ្តល់វិញ្ញាបន បញ្ជាក់ និងបញ្ចូលនៅក្នុងប្រព័ន្ធគ្រប់គ្រងធនធានមនុស្សដែលទទួលខុសត្រូវនៅក្នុងការរៀបចំដាក់ឱ្យអនុវត្តក្របខ័ណ្ឌការងារសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិក ដោយនាយកដ្ឋានបុគ្គលិកត្រូវបញ្ចប់សកម្មភាពនៅក្នុងឆមាសទី១ ឆ្នាំ២០១៧ ចំណាយថវិកានៅក្នុងការរៀបចំប្រព័ន្ធនេះ ៣៤៤២៤ដុល្លារ[២]។ យើងឃើញការអនុវត្តជាក់ស្តែងនៅក្នុងក្រសួងអប់រំ យុវជន និងកីឡាក្នុងរយៈពេល ៥ឆ្នាំនេះ នាយកដ្ឋានជំនាញនានាដែលបានរៀបចំបណ្តុះបណ្តាល ឬបំប៉នរយៈពេលខ្លី បានចេញជាវិញ្ញាបនបត្រជូនទៅដល់បុគ្គលិកអប់រំ ដូចជា ការបំប៉នមន្ត្រីដែលមិនមែនជាអធិការដែលមាន ៦ម៉ូឌុល ការបំប៉នវគ្គគ្រប់គ្រង និងដឹកនាំនាយក នាយករងបឋមសិក្សា និងមធ្យមសិក្សា ការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុដល់មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ បណ្តុះបណ្តាលជំនាញព័ត៌មាន និងទំនាក់ទំនងសាធារណៈ។ល។ ដើម្បីទទួលបាននូវវិញ្ញាបនបញ្ជាក់ការសិក្សា នាយកដ្ឋានជំនាញបានរៀបចំកម្មវិធីបណ្តុះបណ្តាលច្បាស់លាស់ ដោយបានរៀបចំធ្វើតេស្តមុននឹងបណ្តុះបណ្តាល និងក្រោយពេលបណ្តុះបណ្តាល ដើម្បីធ្វើការវាយតម្លៃទៅលើសមត្ថភាពសិក្ខាកាមដែលចូលរួមវគ្គបណ្តុះ

---

[២] ក្រសួងអប់រំ យុវជន និងកីឡា **ផែនការសកម្មភាពស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ** ភ្នំពេញ ឆ្នាំ២០១៦ ទំព័រ១៨។

បណ្តាលនៅក្នុងការបញ្ជាក់អំពីសមត្ថភាពរបស់ពួកគេ ដែលសម្រេចបានក្រោយពីការបណ្តុះបណ្តាល។ បន្ទាប់ពីទទួលបានជោគជ័យលើជំនាញវិជ្ជាជីវៈ ថ្នាក់ដឹកនាំក្រសួងបានប្រគល់វិញ្ញាបនបត្រជាផ្លូវការជូនដល់បុគ្គលិកអប់រំទាំងនោះដើម្បីយកទៅប្រើប្រាស់ជាផ្លូវការ។ ចំពោះមធ្យមសិក្សាទុតិយភូមិ សញ្ញាបត្របរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ក្រសួងបានលើកទឹកចិត្តទៅដល់បុគ្គលិកអប់រំ ដើម្បីទទួលបានសញ្ញាបត្រទាំងនេះ ក្រសួងវាយតម្លៃ និងគ្រប់គ្រងច្បាស់លាស់ដោយកំណត់នូវប្រព័ន្ធក្រេឌីតនៅក្នុងការបណ្តុះបណ្តាលដូចជា បណ្តុះបណ្តាលគ្រូកម្រិតមូលដ្ឋានឆ្ពោះទៅកម្រិតបរិញ្ញាបត្រតាមប្រព័ន្ធពន្លឿន បណ្តុះបណ្តាលអធិការអប់រំថ្មី បណ្តុះបណ្តាលនាយកសាលា បណ្តុះបណ្តាលគ្រូបឋមសិក្សាដែលមានសញ្ញាបត្រមធ្យមសិក្សាបឋមភូមិឱ្យទៅជាគ្រូអប់រំមូលដ្ឋាន បណ្តុះបណ្តាលគ្រូឧទ្ទេសនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគឱ្យសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្តុះបណ្តាលបរិញ្ញាបត្រជាន់ខ្ពស់នៅវិទ្យាស្ថានជាតិអប់រំ។ល។

ដើម្បីអនុវត្តក្របខ័ណ្ឌការងារសម្រាប់អភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំឱ្យមានគុណភាព សមត្ថភាព និងប្រសិទ្ធភាពឱ្យក្លាយជាមូលធនមនុស្សសម្រាប់អភិវឌ្ឍអង្គភាពរបស់ខ្លួន ក្រសួងអប់រំ យុវជន និងកីឡាត្រូវផ្តល់អាទិភាពទៅដល់គ្រូឧទ្ទេស នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនឱ្យទទួលបានវិជ្ជាជីវៈលើកកម្ពស់សមត្ថភាពរបស់ខ្លួនឱ្យមានកម្រិតយ៉ាងទាបបរិញ្ញាបត្រជាន់ខ្ពស់ នេះជាផែនការនៃការអភិវឌ្ឍធនធានមនុស្សដែលត្រូវបានរៀបចំដោយនាយកដ្ឋានបុគ្គលិក នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ វិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានគរុកោសល្យភ្នំពេញ វិទ្យាស្ថានគរុកោសល្យបាត់ដំបង មជ្ឈមណ្ឌលគរុកោសល្យភូមិភាគនិងសាលារៀនគរុកោសល្យខេត្ត។ ក្របខ័ណ្ឌនេះចាប់ផ្តើមនៅត្រីមាសទី១ ឆ្នាំ២០១៧ ចំណាយថវិកា ២៦២០០០ដុល្លារ។ ជាក់ស្តែងតាមស្ថិតិទិន្នន័យនៃប្រព័ន្ធគ្រប់គ្រងធនធានមនុស្សនៃនាយកដ្ឋានបុគ្គលិកបានបង្ហាញពីគ្រូឧទ្ទេសនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនទទួលបានវិជ្ជាជីវៈលើកកម្ពស់សមត្ថភាពឱ្យមានកម្រិតយ៉ាងទាបបរិញ្ញាបត្រជាន់ខ្ពស់ ទិន្នន័យបានបង្ហាញដូចតទៅ៖

| គ្រឹះស្ថាន | បរិញ្ញាបត្រជាន់ខ្ពស់ | | | | |
|---|---|---|---|---|---|
| | ២០១៣-១៤ | ២០១៤-១៥ | ២០១៥-១៦ | ២០១៦-១៧ | ២០១៧-១៨ |
| | សរុប | សរុប | សរុប | សរុប | សរុប |
| វិទ្យាស្ថានជាតិអប់រំ | ៧៦ | ៨៦ | ៩៣ | ១០៩ | ១០៥ |
| វិទ្យាស្ថានគរុកោស្យភ្នំពេញ | ២១ | ២២ | ២៥ | ២៩ | ៤៦ |
| វិទ្យាស្ថានគរុកោស្យបាត់ដំបង | ០៤ | ០៤ | ០៥ | ១៣ | ៣១ |
| មជ្ឈគរុ.ភូមិភាគកំពង់ចាម | ១០ | ១១ | ១១ | ១១ | ១៩ |
| មជ្ឈគរុ.ភូមិភាគកណ្តាល | ០៨ | ២០ | ២១ | ២១ | ២១ |
| មជ្ឈគរុ.ភូមិភាគព្រៃវែង | ០៩ | ០៩ | ១២ | ១២ | ១២ |
| មជ្ឈគរុ.ភូមិភាគតាកែវ | ០១ | ០៣ | ០៥ | ០៥ | ០៤ |
| សាលាគរុ.និងវិក្រឹត្យការកំពង់ចាម | ០៥ | ០៥ | ០៥ | ០៥ | ០៥ |

| | | | | | |
|---|---|---|---|---|---|
| សាលាគរុ.និងវិក្រឹត្យការតាកែវ | ០៣ | ០៣ | ០៣ | ០៣ | ០៣ |
| សាលាគរុ.និងវិក្រឹត្យការព្រៃវែង | ០១ | ០២ | ០៣ | ០៣ | ០៥ |
| សាលាគរុ.និងវិក្រឹត្យការកំពង់ឆ្នាំង | ០២ | ០០ | ០១ | ០០ | ០០ |
| សាលាគរុ.និងវិក្រឹត្យការប.មានជ័យ | ០១ | ០០ | ០០ | ០០ | ០១ |
| សាលាគរុ.និងវិក្រឹត្យការកណ្ដាល | ០៦ | ០៦ | ០៧ | ០៨ | ០៩ |
| សាលាគរុ.និងវិក្រឹត្យការកំពង់ស្ពឺ | ០២ | ០១ | ០១ | ០១ | ០០ |
| សាលាគរុ.និងវិក្រឹត្យការកំពង់ធំ | ០១ | ០១ | ០២ | ០១ | ០២ |
| សាលាគរុ.និងវិក្រឹត្យការកំពត | ០០ | ០០ | ០០ | ០០ | ០០ |
| សាលាគរុ.និងវិក្រឹត្យការព្រះវិហារ | ០០ | ០០ | ០០ | ០០ | ០០ |
| សាលាគរុ.និងវិក្រឹត្យការក្រចេះ | ០០ | ០០ | ០០ | ០០ | ០០ |
| សាលាគរុ.និងវិក្រឹត្យការពោធិ៍សាត់ | ០២ | ០២ | ០២ | ០២ | ០៣ |
| សាលាគរុ.និងវិក្រឹត្យការសៀមរាប | ០៦ | ០៦ | ០៦ | ០៨ | ០៨ |
| សាលាគរុ.និងវិក្រឹត្យការព្រះសីហនុ | ០០ | ០០ | ០១ | ០៥ | ០៤ |
| មជ្ឈគរុ.ភូមិភាគស្ទឹងត្រែង | ០១ | ០១ | ០១ | ០១ | ០១ |
| សាលាគរុ.និងវិក្រឹត្យការស្វាយរៀង | ០១ | ០២ | ០៣ | ០៤ | ០៥ |

(ប្រភពទិន្នន័យHRMIS ឆ្នាំ ២០១៤,២០១៥,២០១៦,២០១៧,២០១៨)

ផ្អែកតាមតារាងទិន្នន័យខាងលើនេះបានបង្ហាញឱ្យយើងឃើញថា គ្រូឧទ្ទេសនៅវិទ្យាស្ថានជាតិអប់រំអភិវឌ្ឍវិជ្ជាជីវៈកម្រិតយ៉ាងទាបថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់រយៈពេល ៥ឆ្នាំ មានការកើនឡើងរហូត ចំណែកវិទ្យាស្ថានគរុកោសល្យភ្នំពេញ និងបាត់ដំបង ក៏គួរឱ្យកើតសរសើរផងដែរ នៅឆ្នាំ២០១៧-២០១៨ វិទ្យាស្ថានគរុកោសល្យភ្នំពេញគ្រូឧទ្ទេសដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ពី២១នាក់ទៅ៤៦នាក់ ចំណែកវិទ្យាស្ថានគរុកោសល្យបាត់ដំបង គ្រូឧទ្ទេសដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ពី ៤នាក់ទៅ៣១នាក់។ ចំណែកគ្រូឧទ្ទេសនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគដែលមានកំពង់ចាម កណ្ដាល ព្រៃវែង បានព្យាយាមប្រឹងប្រែងអភិវឌ្ឍជីវៈទទួលសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានកើនច្រើនជាបន្តបន្ទាប់ លើកលែងតែមជ្ឈមណ្ឌលភូមិភាគខេត្តតាកែវ គ្រូឧទ្ទេសដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ទាបជាងគេ។ ចំពោះសាលាគរុកោសល្យ និងវិក្រឹត្យការខេត្តមានខេត្តសៀមរាប និងខេត្តកណ្ដាល ដែលគ្រូឧទ្ទេសខិតខំប្រឹងប្រែងរៀនសូត្រ ដើម្បីទទួលបរិញ្ញាបត្រជាន់ខ្ពស់ច្រើនជាងគេ។ ហើយសាលាគរុកោសល្យ និងវិក្រឹត្យខេត្ត កំពត ក្រចេះ ព្រះវិហារ គ្រូឧទ្ទេសហាក់បីដូចជាមិនខ្វាយខ្វល់នៅក្នុងការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឡើយគឺសូន្យនាក់។ ដូច្នេះដើម្បីសម្រេចបណ្ដុះបណ្ដាលធនធានមនុស្សឱ្យមានគុណភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ លុះត្រាតែមូលធនមនុស្សនៅសាលារៀនបណ្ដុះបណ្ដាលគ្រូត្រូវលើកកម្ពស់អភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួនយ៉ាងទាបបរិញ្ញាបត្រជាន់ខ្ពស់ ឬបណ្ឌិត។

ទន្ទឹមនឹងការលើកកម្ពស់គុណវុឌ្ឍិគ្រូឧទ្ទេសសាលាបណ្តុះបណ្តាលគ្រូ ក្រសួងក៏បានរៀបចំផែនការអភិវឌ្ឍវិជ្ជាជីវៈដល់បុគ្គលិកអប់រំដែលមានតួនាទីជាអ្នកគ្រប់គ្រងផងដែរ ឱ្យបានទទួលការអភិវឌ្ឍវិជ្ជាជីវៈលើកម្ពស់សមត្ថភាពរបស់ខ្លួនឱ្យមានកម្រិតយ៉ាងទាបបរិញ្ញាបត្រជាន់ខ្ពស់ផងដែរ។ នៅក្នុងរយៈពេល ៥ឆ្នាំនេះ ថ្នាក់ដឹកនាំនៅអគ្គាធិការដ្ឋាន អគ្គនាយកដ្ឋាន នាយកដ្ឋាន និងការិយាល័យនៅទីស្តីក្រសួងមានបរិញ្ញាបត្រជាន់ខ្ពស់ស្ទើរតែទាំងអស់ និងបណ្ឌិតមួយចំនួនទៀតផង។

## ៣. លើកកម្ពស់ការសិក្សាពេញមួយជីវិត

ដើម្បីអនុវត្តក្របខ័ណ្ឌការងារសម្រាប់ជានាការអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំ ក្រសួងអប់រំ យុវជន និងកីឡាត្រូវរៀបចំវគ្គបណ្តុះបណ្តាលភ្ជាប់ទៅនឹងការលើកទឹកចិត្ត និងប្រព័ន្ធក្រេឌីតដែលបុគ្គលិកអប់រំអាចជ្រើសរើសបានតាមរយៈការលើកកម្ពស់ការសិក្សាពេញមួយជីវិត ដើម្បីអភិវឌ្ឍវិជ្ជាជីវៈឱ្យឆ្លើយតបទៅនឹងបច្ចេកវិទ្យាដែលកំពុងតែរីកចម្រើននាពេលបច្ចុប្បន្ន និងទៅអនាគត។ ក្រសួងបានរៀបចំវគ្គបណ្តុះបណ្តាលខ្លីៗ វគ្គមធ្យម និងវគ្គវែងដោយចេញនូវវិញ្ញាបនបត្រ សញ្ញាបត្រ ដើម្បីលើកទឹកចិត្តទៅដល់បុគ្គលិកអប់រំទាំងអស់ឱ្យខិតខំប្រឹងប្រែងអភិវឌ្ឍនូវវិជ្ជាជីវៈរបស់ខ្លួន ទោះបីជាមានអាយុច្រើនប៉ុនណាក៏ដោយ ការរៀនសូត្រពង្រីកនូវចំណេះដឹងមិនមានដែនកំណត់គិតពីអាយុនោះទេ។

## ៤. រៀបចំយន្តការប្រកបដោយប្រសិទ្ធភាពគាំទ្របុគ្គលិកអប់រំនៅនឹងកន្លែង

តាមទិន្នន័យពីប្រព័ន្ធគ្រប់គ្រងធនធានមនុស្សនៃនាយកដ្ឋានបុគ្គលិករបស់ក្រសួងអប់រំ យុវជន និងកីឡាបានបង្ហាញឱ្យយើងឃើញថា ធនធានមនុស្ស ដែលបម្រើការងារនៅតាមនាយកដ្ឋានជំនាញនានានៅទីស្តីការក្រសួងមានចំនួនយ៉ាងច្រើនមកបំពេញការងារខុសទៅសញ្ញាបត្រជំនាញឯកទេសរបស់ខ្លួន។ ប៉ុន្តែនាយកដ្ឋានជំនាញមិនមានជម្រើសនៅក្នុងការមិនទទួលយកបុគ្គលិកអប់រំដែលខុសជំនាញនោះទេ ដោយសារតែនាយកដ្ឋានទាំងនោះខ្វះបុគ្គលិក រួមជាមួយនឹងវប្បធម៌អន្តរាគមន៍ពីអ្នកដែលមានតួនាទីធំៗជាដើម ដើម្បីដោះស្រាយបញ្ហានេះ និងលើកកម្ពស់ការអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំ នាយកដ្ឋានជំនាញត្រូវរៀបចំយន្តការប្រកបដោយប្រសិទ្ធភាពគាំទ្របុគ្គលអប់រំនៅនឹងកន្លែង ក្នុងការបំពេញតម្រូវការ និងពង្រឹងសមត្ថភាពវិជ្ជាជីវៈ ដោយអនុវត្តការងារជាក់ស្តែងតែម្តង តាមរយៈធ្វើការបណ្តើររៀនបណ្តើរ ទ្រឹស្តីផ្សាភ្ជាប់ទៅនឹងការអនុវត្ត។ យើងឃើញថា នាយកដ្ឋានជំនាញជាច្រើនបានប្រើប្រាស់យន្តការនេះនៅក្នុងការអនុវត្តក្របខ័ណ្ឌការងារជានា សម្រាប់ជានាការអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំ និងការប្រើប្រាស់ធនធានមនុស្សនៅក្នុងអង្គភាពឱ្យអស់ពីលទ្ធភាព ដើម្បីបញ្ចៀសនូវបុគ្គលិកដែលមិនមានសមត្ថភាពនៅក្នុងការបំពេញការងារក្នុងអង្គភាព។

## ៥. កែលម្អរចនាសម្ព័ន្ធគ្រប់គ្រងធនធានមនុស្សនៅតាមអង្គភាព

ដើម្បីអនុវត្តក្របខ័ណ្ឌការងារ សម្រាប់អភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំឱ្យបានល្អប្រសើរនៅក្នុងការគ្រប់គ្រងធនធានមនុស្សនៅក្នុងក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានជំនាញនានាត្រូវតែកែលម្អរចនាសម្ព័ន្ធគ្រប់គ្រង បែបបទបំពេញការងារឱ្យស្របទៅនឹងគោលនយោបាយធនធានមនុស្សរបស់

រដ្ឋបាលសាធារណៈ គោលនយោបាយស្តីពីការគ្រប់គ្រងអភិវឌ្ឍធនធានមនុស្ស និងកម្មវិធីកំណែទម្រង់សាធារណៈ២០១៥-២០១៨។ យើងបានបង្ហាញពីរចនាសម្ព័ន្ធនៃការគ្រប់គ្រងធនធានមនុស្សនៅតាមអគ្គាធិការដ្ឋាន អគ្គនាយកដ្ឋាន នាយកដ្ឋាន និងការិយាល័យជំនាញ យើងឃើញថា រចនាសម្ព័ន្ធនៃការគ្រប់គ្រងទាំងនោះមិនទាន់សមស្របទៅទំហំការងារ ដោយថ្នាក់ដឹកនាំនៅ លើមានចំនួនច្រើន បែបជាអង្គភាពមានចំនួនតិច ប៉ុន្តែអង្គភាពខ្លះមានការងារច្រើនតែបែបជារចនាសម្ព័ន្ធនៃថ្នាក់ដឹកនាំមានចំនួនតិចទៅវិញ ហាក់បីដូចមិនមានសមធម៌នៅក្នុងរចនាសម្ព័ន្ធនៃការគ្រប់គ្រងទៅវិញ។ ដូច្នេះការកែលម្អរចនាសម្ព័ន្ធនៅតាមអង្គភាពពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីជំរុញឱ្យអង្គភាពនោះឆ្ពោះទៅរកការរីកចម្រើននានាពេលខាងមុខ និងរដ្ឋកាត់បន្ថយការចំណាយនូវថវិកាខ្ជះខ្ជាយ។

# ការគ្រប់គ្រងរដ្ឋក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

បេក្ខជនបណ្ឌិត៖ **ចាន់ ទី**
ជំនាញ៖ **វិទ្យាសាស្ត្រនយោបាយ**

## ចំណុចខ្លាំងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ចំណុចខ្លាំងនៃរបបគ្រប់គ្រងកម្ពុជាប្រជាធិបតេយ្យ រួមមាន៖[១] ១.ផ្តាច់ពួកមូលធននិយម ២.លុបបំបាត់វណ្ណៈសក្តិភូមិ ៣.មិនរណបបរទេសណាមួយ ៤.បណ្តុះស្មារតីស្រឡាញ់បក្សតែមួយគត់ប៉ុណ្ណោះ ៥.កសិកម្មនិងប្រព័ន្ធធារាសាស្ត្ររីកចម្រើន ៦.ប្រើប្រាស់មនុស្សដោយគ្មានការគៅ ៧.កម្ពុជាប្រជាធិបតេយ្យបានថែរក្សាសម្បត្តិធម្មជាតិខ្មែរបានជាប្រវត្តិសាស្ត្រ។

### ១. ការវាយរំលំរបបមូលធន

របបមូលធននិយម ឬវណ្ណៈគហបតី គឺជាក្រុមអ្នកគ្រប់គ្រងឯកជនលើមធ្យោបាយផលិតកម្ម ដែលមានពលករ កម្មករ គឺជាអ្នកទ្រទ្រង់ លក់កម្លាំងកាយឱ្យទៅពួកគេដើម្បីទទួលប្រាក់ឈ្នួលត្រឡប់មកវិញ។[២] គោលនយោបាយកសាងសង្គមនិយមសមូហភាពរបស់កម្ពុជាប្រជាធិបតេយ្យគឺលុបបំបាត់របបមូលធនឱ្យនៅសល់តែវណ្ណៈកម្មករ កសិករប៉ុណ្ណោះ។ ខ្មែរក្រហមចាត់ទុកទីផ្សារទំនិញ គ្រាន់តែជាការដោះដូររវាងវត្ថុ និង វត្ថុ ហើយជាការដោះដូររវាងកម្លាំងពលកម្មជាមួយម្ចាស់សហគ្រាស។ ជំហានដំបូងសហករណ៍កម្រិតខ្ពស់តម្រូវឱ្យប្រជាជនធ្វើការរួម ហូបរួម និងមធ្យោបាយផលិតកម្មរួមគ្នា លុបបំបាត់ការចាយលុយ គ្មានការលក់កម្លាំងពលកម្មដើម្បីដោះដូរ។ កម្មករពុំមានកម្មសិទ្ធិឯកជន ហើយមិនមានមធ្យោបាយផលិតផ្ទាល់ខ្លួនឡើយ។ ដរាបណាវណ្ណៈមូលធននៅតែមាន ពួកម្ចាស់ដី ម្ចាស់សហគ្រាស និងកម្មករ កសិករ កើតមានទំនាស់ផលប្រយោជន៍ចៀសមិនរួច។ ពួកមូលធនចង់ឱ្យកម្មករធ្វើការច្រើនម៉ោង ឯប្រាក់ឈ្នួលពុំសមកម្លាំងពលកម្មដែលពួកគេបានធ្វើ។ ញើសឈាមរបស់ពួកគេ ត្រូវបានពួកមូលធនគាបសង្កត់ កេងប្រវ័ញ្ច។ នេះជាអំពើអយុត្តិធម៌ ខ្មែរក្រហមមិនអាចទុកវណ្ណៈមូលធនក្នុងសង្គមឡើយ ព្រោះរបបមូលធនមិនខ្វល់ខ្វាយចំពោះវណ្ណៈកម្មករនោះទេ ពួកគេគិតទៅលើតែរឿងម្យ៉ាងគឺ ទទួលបាននូវប្រាក់ចំណេញច្រើន ហើយធ្វើការចំណាយទៅលើពួកកម្មករតិច ដែលធ្វើឱ្យពួកគេបាត់បង់នូវមេត្តាធម៌ សីលធម៌ និងគុណធម៌សង្គម។ ពួកវណ្ណៈកម្មករបន្តជួបនូវការជិះជាន់កេងកម្លាំងពលកម្មកាន់តែខ្លាំង ឯជីវភាពប្រចាំថ្ងៃវិញជួបបញ្ហាខ្វះខាតក្នុងការផ្គត់ផ្គង់ដល់ការរស់នៅ អាហារហូបចុកមិនគ្រប់គ្រាន់។ វាគឺជាពេលវេលានៃការតស៊ូវណ្ណៈមួយបានកើតឡើង។ ពួកវណ្ណៈនាយទុនចង់រក្សានូវរបបមូលធនរបស់ខ្លួនឱ្យនៅស្ថិតស្ថេរ ដោយសារពួកគេចង់រក្សាប្រយោជន៍ អំណាច និងឥទ្ធិពលរបស់ខ្លួន

---

[១] សុខ ទូចៈ អនុសាសន៍ **បណ្ឌិតសភាចារ្យ សុខ ទូច** ក្នុងកម្មវិធីការពារសាកល្បងនិក្ខេបបទ បេក្ខជនបណ្ឌិត **ចាន់ ទី** ជំនាញវិទ្យាសាស្ត្រនយោបាយ ជំនាន់៤ វគ្គ១ រាជបណ្ឌិត្យសភាកម្ពុជា ថ្ងៃ០៧ ខែកុម្ភៈ ឆ្នាំ២០២៤

[២] Bruce R. Scott: ***The Political Economy of Capitalism***, Democracy and Development, June 27, 2006, page 2

ទៅលើពួកកម្មករ។ ឆ្នាំ១៩៧៦ កម្ពុជាប្រជាធិបតេយ្យបានជំរុញសហករណ៍កម្រិតខ្ពស់ទូទាំងប្រទេស លុបបំបាត់របបមូលធននិយម ដើម្បីឱ្យកម្មករកសិករបែងចែកផលលាភស្មើៗគ្នាដោយដាក់ជាកម្មសិទ្ធិសមូហភាព។

"ការផ្លាស់ប្តូរវណ្ណៈជារឿងមួយដ៏ល្អសម្រាប់សង្គមផងដែរ ព្រោះថា កាលណាបើវណ្ណៈសង្គមនៅតែមានដូចជា ពួកមូលធនកេងប្រវ័ញ្ចអ្នកក្រនោះ ការស្មើភាពគ្នាកាន់តែអន់ថយ ហើយអ្នកមានចេះតែមាន បែរឯអ្នកក្រចេះតែក្រទៅ ក្រទៅ អត់ឃ្លាន បាត់បង់ជម្រក បញ្ហាទាំងនេះអាចទាញឱ្យសង្គមគ្មានសណ្តាប់ធ្នាប់ បាត់បង់សន្តិសុខសង្គម និងមិនមានការរីកចម្រើន។ **កាល់ ម៉ាក្ស** បានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើប្រាក់បៀវត្សរ៍របស់ពួកវណ្ណៈកម្មករ ជាកម្រិតនៃប្រាក់ខែ ដែលគេទទួលបានត្រឹមតែមួយគ្រប់សម្រាប់ផ្គត់ផ្គង់គ្រួសារ ហើយវាមិនសមស្របទៅនឹងការបញ្ចេញនូវកម្លាំងផលិតរបស់គេស្ទើរតែពេញមួយថ្ងៃនោះទេ។ ជាការពិតណាស់ពួកវណ្ណៈកម្មករ គឺជាអ្នកជីករណ្តៅកប់ពួកមូលធននិយម ព្រោះតែវណ្ណៈនេះជាស្នូល និងជាដៃជើងរបស់ពួកវណ្ណៈមូលធនក្នុងការបង្កើតនូវខឿនសេដ្ឋកិច្ច និងដំណើរនយោបាយរបស់សង្គម។ ជារួម ទ្រឹស្តីរបស់**ម៉ាក្ស**គឺចង់បានសង្គមមួយ ដែលមនុស្សរស់នៅមានភាពថ្លៃថ្នូរដូចគ្នាក្នុងនាមជាមនុស្ស។ ទ្រឹស្តីកុម្មុយនីស្តរបស់លោកត្រូវបានទស្សនវិទូលោក **ឡេនីន** និង **ម៉ៅ សេទុង** មកកែប្រែ ហើយយល់ថាទ្រឹស្តីនេះអាចអនុវត្តន៍ក្នុងប្រទេសក្រីក្រ ប្រទេសកំពុងអភិវឌ្ឍន៍បាន ដែលនាំឱ្យទ្រឹស្តីនេះក្លាយជាទ្រឹស្តីដ៏អាក្រក់មួយសម្រាប់ពិភពលោក។" [៣]

កម្ពុជាប្រជាធិបតេយ្យ បានបំបាត់ចោលទាំងស្រុងការកេងប្រវ័ញ្ចទៅលើកម្លាំងផលិតរបស់ពួកកម្មករដោយជោគជ័យ ប្រជាជនធ្វើការក្នុងក្របខ័ណ្ឌសមូហភាព។ ទំនាស់វណ្ណៈលែងមាន។ ពួកគេរួមគ្នាធ្វើពលកម្ម លែងគិតគូរ លែងថ្លឹងថ្លែងអំពីផលកម្រៃទទួលបានទៀតហើយ។

## ២. ការវាយរំលំរបបសក្តិភូមិ

របបសក្តិភូមិ (Feudalism) គឺជារបបសង្គមដែលឱ្យតម្លៃខ្ពស់ទៅលើពួកអភិជន ដោយគេចាត់ទុកក្រុមនេះ ថាជាមនុស្សដែលកើតចេញពីសារកែរបស់ព្រះ ឬមនុស្សទេព ហើយពួកនេះគ្រប់គ្រងអំណាចជាម្ចាស់ដីរហូតទៅដល់ម្ចាស់ទាសករទៀត។ គេបែងចែកមនុស្សជា ៤ស្រទាប់ រួមមានៈសក្តិភូមិ មូលធន នាយទុន និងទេសករ(កម្មករ កសិករ)។[៤] វណ្ណៈកម្មករ កសិករ មានច្រើនលើសលប់ក្នុងចំណោមប្រជាជនខ្មែរទូទាំងប្រទេស។ កម្មាភិបាលខ្មែរក្រហម ពិសេសកងកម្លាំងប្រយុទ្ធភាគច្រើនកើតចេញពីវណ្ណៈកសិករដែលត្រូវបានរបបសក្តិភូមិតាមចាប់ចងធ្វើបាបគៀបសង្កត់កេងប្រវ័ញ្ច។ ជាក់ស្តែង ព្រឹត្តិការណ៍បង្ក្រាប សម្លាប់រង្គាលនៅស្រុកសំឡូត ប្រជាជនអ្នកតស៊ូខ្មែរចងកំហឹងនឹងពួកមូលធនសក្តិភូមិរបស់រដ្ឋាភិបាល **សម្តេច នរោត្តម សីហនុ**។

---

[៣] កាល់ម៉ាក្សៈ **មូលធននាំដល់របបកុម្មុយនីស្តថ្មី** ការផ្សាយរបស់គេហទំព័រ ថ្មីៗ ១៩ មិថុនា ២០១៦។

[៤] *ពាក្យបច្ចេកសព្ទរបស់គណៈកម្មការបច្ចេកទេសវិទ្យាសាស្ត្រនយោបាយដាក់ជូនក្រុមប្រឹក្សាជាតិ ភាសាខ្មែរអនុម័ត ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២២។*

ដោយមើលឃើញអំពើអយុត្តិធម៌សង្គម និងទុក្ខវេទនាប្រជាជនខ្មែរ របបកម្ពុជាប្រជាធិបតេយ្យ បានដាក់ចេញនូវគោលនយោបាយ លុបបំបាត់គ្រប់ទម្រង់នៃរបបជិះជាន់។ ពេលដែល **សម្តេច សីហនុ** វិលចូលកម្ពុជាវិញនៅឆ្នាំ១៩៧៣ គឺជាសញ្ញាណដំបូងនៃការដួលរលំរបបសក្តិភូមិនៅកម្ពុជា។ នៅតាមតំបន់រំដោះជាច្រើនពីខេត្តស្ទឹងត្រែងដល់ខេត្តសៀមរាប **សម្តេចនិងមហេសី** ត្រូវបានទទួលបដិសណ្ឋារកិច្ចដូចកម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់ដទៃទៀតដែរ។ លោកទាំងពីរគឺជាកម្មាភិបាលបដិវត្តន៍ក្រោមការដឹកនាំដោយបក្សកុម្មុយនីស្តកម្ពុជា។ ចន្លោះពីឆ្នាំ១៩៧៥ដល់១៩៧៩ សង្គមកម្ពុជាលើកតម្កើងឱ្យតម្លៃប្រជាជនមូលដ្ឋាន អង្គការជឿជាក់លើប្រជាកសិករក្រីក្រតំបន់ចម្កាត់មាត់ញកស្រុកស្រែចំការ។ វណ្ណៈកម្មករ កសិករក្រីក្រទាំងនោះគឺជាសត្រូវនឹងវណ្ណៈមូលធន នាយទុន សក្តិភូមិ ហើយបានក្លាយទៅជាអ្នកត្រួតត្រាលើវណ្ណៈមូលធន នាយទុន សក្តិភូមិវិញម្តង។

### ៣. ឯករាជ្យភាពនៃរបបកម្ពុជាប្រជាធិបតេយ្យ

"រដ្ឋកម្ពុជាជារដ្ឋមួយឯករាជ្យ ឯកភាព សន្តិភាព អព្យាក្រិត មិនចូលបក្សសម្ព័ន្ធណា អធិបតេយ្យប្រជាធិបតេយ្យក្នុងបូរណភាពដែនដីរបស់ខ្លួន។[៥]" កម្ពុជាប្រជាធិបតេយ្យមិនចំណុះឱ្យបរទេសណាឡើយ ពិសេសប្រទេសជិតខាងដែលមានប្រវត្តិជួរចត់នឹងកម្ពុជា ថ្នាក់ដឹកនាំខ្មែរក្រហមមានការប្រុងប្រយ័ត្ន និងបារម្ភខ្ពស់បំផុត។ កម្ពុជាមានព្រំប្រទល់ជាប់ប្រទេសថៃ វៀតណាម និងឡាវ។ **ប៉ុល ពត** បារម្ភបំផុតចំពោះព្រំដែនខាងលិចជាប់ថៃ និងខាងកើតជាប់វៀតណាម។ "ជម្លោះចាប់ផ្តើមកើតមានជាពិសេសតាមព្រំប្រទល់កម្ពុជា-ថៃ និង កម្ពុជា-វៀតណាម។[៦]" ខាងលិច "ខ្មែរក្រហមបានគំរាមកំហែងសន្តិសុខដែនអធិបតេយ្យ បូរណភាពដែនដីរដ្ឋបាលនាយករដ្ឋមន្ត្រី **ក្រៀងសាក់ឆាម៉ាណាន** (Kriangsak Chamanan) រហូតដល់ឯកអគ្គរដ្ឋទូតស៊ុយអ៊ែត **អូប៊េ ហ្សង់គ្រីស្តុប** (Oberg Jean-Christophe) ប្រចាំប្រទេសថៃបានចូលមកប្រទេសកម្ពុជាធ្វើទស្សនកិច្ច នៅចុងខែធ្នូ ឆ្នាំ១៩៧៧ រយៈពេល ២ថ្ងៃ ហើយសារព័ត៌មានថៃបានរាយការណ៍ថា នេះជាការព្យាយាមដើម្បីធ្វើអាជ្ញាកណ្តាលរវាងកម្ពុជាថៃ។[៧]" នៅខាងកើត ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យយល់ឃើញថា វៀតណាមចង់លេបយកប្រទេសកម្ពុជាទាំងមូលតែម្តង។ ខ្មែរក្រហមបានត្រៀមខ្លួនរួចជាស្រេច ដើម្បីធ្វើសង្គ្រាមជាមួយប្រទេសវៀតណាមក្នុងបុព្វហេតុដ៏ត្រឹមត្រូវមួយ។ ខែមករា និងខែកុម្ភៈ ឆ្នាំ១៩៧៨ ខ្មែរក្រហមបានបើកកិច្ចអន្តរាគមន៍យោធានៅតាមបណ្តោយព្រំដែនដោយរុលចូលកាប់សម្លាប់ប្រជាជន និងបំផ្លិចបំផ្លាញភូមិករលើទឹកដីប្រទេសវៀតណាមទៀត។ [៨]"

---

[៥] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ៖ ជំពូក១ **អំពីរដ្ឋ** មាត្រា១ ។

[៦] WILFRED BURCHETT: THE CHINA CAMBODIA VIETNAM TRIANGLE, Vanguard books, Printed in the USA, 1981, page 170

[៧] ស្តេហ្វេន ច.ម៉ូរីស៖ ***ហេតុម្តេចវៀតណាមលុកលុយកម្ពុជា*** វប្បធម៌នយោបាយនិងបុព្វហេតុនៃសង្គ្រាម ប្រែសម្រួល ដោយ **អួន វីរៈ** ភ្នំពេញ រោងពុម្ពជោគជ័យ ឆ្នាំ២០១៣ ទំព័រ១៤១ ។

[៨] David P. Chandler: **Brother Number One**, A Political Biography of Pol Pot, Revised Edition, page142

ទំនាក់ទំនងរវាងកម្ពុជា និងបណ្តាប្រទេសសង្គមនិយមនានា រួមទាំងមហាអំណាចចិនផង កម្ពុជាប្រជាធិបតេយ្យធ្វើឡើងយ៉ាងប្រុងប្រយ័ត្នជាទីបំផុត។ ជំនួយចិនដ៏ច្រើនសន្ធឹកសន្ធាប់តម្រូវឱ្យកម្ពុជាមានការតបស្នងសងគុណបំណាច់ ដោយកម្ពុជាបានចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីនាំចេញកៅស៊ូ ផលិតផលកសិកម្ម និងផលិតផលមានតម្លៃជាច្រើនទៅកាន់ប្រទេសចិន។ "កប៉ាល់ដឹកសុទ្ធតែអង្ករនិងកៅស៊ូដែលមានពាសពេញនៅកំពង់សោមយកចេញទៅអស់។"[៩] ទំនាក់ទំនងកម្ពុជាចិនគ្រាន់តែដើម្បីស្វែងរកផលប្រយោជន៍រៀងៗខ្លួនប៉ុណ្ណោះ ពុំមានភាពស្មោះត្រង់ ឬមិត្តភាពស្លាប់រស់ពិតប្រាកដនឹងគ្នានោះទេ។ "យើងត្រូវប្រយ័ត្នប្រយែងជាមួយប្រទេសចិន។ ពិតមែនហើយដែលថាយើងជំពាក់គុណគេធំណាស់ ហើយគេជាប្រទេសមហាអំណាចមួយដ៏ធំ ប៉ុន្តែគេចង់ឱ្យយើងក្លាយជាប្រទេសរណបគេ។"[១០]

គ្រប់ចំណុចដូចបានរៀបរាប់មកខាងលើ កម្ពុជាប្រជាធិបតេយ្យបានដឹងពីផលវិបាកនានានៃជំនួយរបស់ចិន ឬផលវិបាកនៃជំនួយបរទេសមិនថាប្រទេសតូចឬធំ។ ដូចនេះ ប្រព័ន្ធគ្រប់គ្រងរដ្ឋក្នុងរបបកម្ពុជាប្រជាធិបតេយ្យឈរលើគោលការណ៍ឯករាជ្យ ស្វ័យម្ចាស់ការ ខ្លួនទីពឹងខ្លួនដូចបានចែងក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួន មិនរណបបរទេសណាមួយឡើយ។

## ៤. ការបណ្តុះស្មារតីស្មោះស្ម័គ្រលើអង្គការបដិវត្តន៍

គ្រប់ទម្រង់នៃការរស់នៅ ឬកម្មវិធីប្រពៃណីជាតិ ត្រូវកែប្រែនិងផ្តោតសំខាន់លើស្មារតីបដិវត្តន៍រៀបចំឡើងដោយអង្គការ ដើម្បីបង្ហាញពីភាពស្ម័គ្រស្មោះចំពោះអង្គការបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យប៉ុណ្ណោះ។ អាពាហ៍ពិពាហ៍ ការងារ គ្រួសារ សាច់ញាតិ បងប្អូន កូនចៅ ត្រូវលះបង់សម្រាប់អង្គការបដិវត្តន៍ទាំងអស់។

### ក. អាពាហ៍ពិពាហ៍

ប្រពៃណីដ៏ល្អផូរផង់នៃការរៀបពិធីមង្គលការក្នុងសង្គមខ្មែរមានតាំងពីយូរលង់ណាស់មកហើយ។ ជាទំនៀមទម្លាប់ អាពាហ៍ពិពាហ៍នីមួយៗត្រូវបានរៀបចំឡើងច្រើនថ្ងៃ យ៉ាងប្រិតប្រៀងតាមដំណាក់កាល ហើយធ្វើឡើងរវាងកូនកំលោះកូនក្រមុំតែមួយគូប៉ុណ្ណោះ។ "កូនកំលោះក្រមុំចំនួនពី ៣ ទៅ ១០គូក្នុងពិធីតូច ហើយពិធីធំមានពី ៣០ ទៅ ៥០ គូ ឬ រហូតដល់ជាង ១០០គូ ត្រូវរៀបចំប្រារព្ធឡើងក្នុងពិធីរួមក្នុងពេលតែមួយ។ យុវជន យុវនារីពុំមានសិទ្ធិជ្រើសរើសគូស្រករតាមបំណងរបស់ខ្លួនទេ។ អង្គការ ឬសង្គមគ្រួសារត្រូវរៀបចំឡើងដោយអង្គការដែលអះអាងថាជាឪពុកម្តាយរបស់មនុស្សគ្រប់រូប។ នារីមួយចំនួនត្រូវបង្ខំឱ្យរៀបការជាមួយយុទ្ធជនពិការដែលរងរបួសក្នុងសង្គ្រាម។ បើគេជំទាស់នឹងបំណងអង្គការ គេត្រូវទទួលទណ្ឌកម្ម ដោយបញ្ជូនទៅការដ្ឋានឆ្ងាយដាច់ស្រយាលពីលំនៅឋាន ឱ្យធ្វើការងារជាទម្ងន់

[៩] ប៊ែន គៀរនិនៈ **របប ប៉ុល ពត** ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍ មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រែសម្រួលដោយ **ឡាយ ពុទ្ធារ៉ា** និង **ទីយាយុ** ទំព័រ២០០។

[10] ប៊ែន គៀរនិនៈ **របប ប៉ុល ពត** ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍ មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រែសម្រួលដោយ **ឡាយ ពុទ្ធារ៉ា** និង **ទីយាយុ** ទំព័រ១៩៩។

ឬសម្លាប់ចោល។ ថ្ងៃរៀបការបុរសនារីទាំងអស់ត្រូវឈរជាពីរជួរតាមគូបែរមុខរកគ្នា។ "បន្ទាប់មកប្រធានភូមិបញ្ជាឱ្យគូទាំងនោះចាប់ដៃគ្នា ហើយធ្វើការប្តេជ្ញាចិត្តបម្រើអង្គការអស់មួយជីវិត។[១១]" បន្ទាប់ពីបញ្ចប់ពិធីរៀបការគ្រួសារថ្មីបានទទួលការអនុញ្ញាតឱ្យរស់នៅជាមួយគ្នាតែពីរបីថ្ងៃប៉ុណ្ណោះ បន្ទាប់មកត្រូវទៅធ្វើការតាមការដ្ឋានរៀងខ្លួនវិញ។ អាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យពុំមានញាតិរបស់កូនកម្លោះកូនក្រមុំចូលរួមឡើយ។ "ឪពុកម្តាយរបស់មិត្តមិនមកចូលរួមពិធីនេះទេ ។ យើងជាឪពុកម្តាយផ្សំផ្គុំឱ្យមិត្តនិងបងប្អូនប្រុសស្រីរបស់មិត្តទាំងអស់គ្នា។[១២]" អង្គការគឺជាមេបា ជាម្តាយឪពុកកូនកំលោះកូនក្រមុំ។ គ្រប់គ្នាត្រូវមានស្វាមីភក្តិចំពោះអង្គការ សូម្បីត្រូវលះបង់ជីវិត។

### ខ. សញ្ចេតនាគ្រួសារ

គោលការណ៍កសាងសង្គមនិយមរបស់ខ្មែរក្រហម ម្តាយ ឪពុក ប្តីប្រពន្ធ កូន ចៅ សាច់ញាតិត្រូវរស់នៅទីកន្លែងផ្សេងគ្នាដើម្បីបំពេញការងារក្នុងសហករណ៍ ជីកទំនប់ លើកប្រឡាយ នៅតាមការដ្ឋាននានា។ លើសពីនេះទៅទៀត បងប្អូនសាច់ញាតិ ឬមនុស្សក្នុងសង្គមលែងទុកចិត្តគ្នា ខ្លាចគ្នាទៅវិញទៅមក។ អង្គការភ្នែកម្នាស់បណ្តុះប្រជាជនប្រុសស្រីក្មេងចាស់ឱ្យរាយការណ៍រាល់កំហុសតូចធំរបស់មនុស្សជុំវិញខ្លួន។ ដូចនេះ កូនបង្កើតក៏អាចជាភ្នាក់ងាររបស់អង្គការ លាតត្រដាងកំហុសឪពុកបង្កើតខ្លួនដែរ។ "ក្មេងៗមួយចំនួន នៅពេលបានទទួលការអប់រំបំពាក់បំប៉នគោលមាគ៌ានយោបាយដ៏ក្រហមឆ្អិនឆ្អៅពីអង្គការខ្មែរក្រហមរួចមក ក្មេងខ្លះត្រូវបានអង្គការបញ្ជាឱ្យសម្លាប់ម្តាយឪពុករបស់ខ្លួនក៏មានដែរ។ អង្គការបានបញ្ចុះបញ្ចូលក្មេងៗឱ្យខិតខំប្រឹងប្រែងធ្វើការងារបម្រើអង្គការ បើមាននរណាប្រឆាំងនឹងត្រូវយកទៅធ្វើទារុណកម្ម។"[១៣]

ទាក់ទងនឹងការបណ្តុះស្មារតីកុមារឱ្យស្មោះស្ម័គ្រនឹងអង្គការនេះ ទស្សនាវដ្តីស្វែងរកការពិត លេខ២២២ ទំព័រទី១០ បានរៀបរាប់៖ កុមារទាំងអស់ត្រូវអង្គការដាក់ឱ្យរស់នៅក្នុងមន្ទីរកុមារ ហើយកុមារទាំងនេះ មិនដែលទទួលបានការមើលថែពីឪពុកម្តាយនោះទេ។ ពេលព្រឹកកុមារទាំងអស់ត្រូវដើរទៅធ្វើការ និងល្ងាចត្រឡប់មកសម្រាកនៅកងកុមារវិញ។ កុមារណាដែលលួចរត់ទៅជួបឪពុកម្តាយដោយគ្មានការអនុញ្ញាតត្រូវតែទទួលពិន័យជាក់ជាពុំខាន។ អង្គការក៏បានប្រាប់ទៀតថា «មានតែអង្គការមួយគត់ដែលជាឪពុកម្តាយរបស់កុមារទាំងអស់គ្នា។ ហេតុនេះ យើងជាកុមារត្រូវតែស្រឡាញ់ និងស្មោះត្រង់ចំពោះអង្គការតែមួយគត់»។ អង្គការបានបញ្ចុះបញ្ចូលកុមារឱ្យនិយាយរឿងឪពុកម្តាយរបស់ខ្លួនប្រាប់អង្គការ។ ដោយស្ថិតក្នុងវ័យជាកុមារមិនយល់រាក់ជ្រៅ កុមារខ្លះបានប្រាប់ដល់អង្គការគ្រប់

---

[១១] ក្រសួងអប់រំយុវជននិងកីឡា៖ ប្រវត្តិវិទ្យាថ្នាក់ទី១២ គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ អគារ១៤៨ មហាវិថីព្រះនរោត្តម ឆ្នាំបោះពុម្ព២០១១ ភ្នំពេញ ទំព័រ១៤៩។

[១២] កោះសន្តិភាព៖ **អាពាហ៍ពិពាហ៍សម័យខ្មែរក្រហមខុសពីទំនៀមទម្លាប់ខ្មែរ** បរិច្ឆេទចុះផ្សាយ ថ្ងៃទី២០ ខែមេសា ឆ្នាំ ២០១៧ ម៉ោង១១:០០។

[១៣] ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា៖ ទស្សនាវដ្តីស្វែងរកការពិត លេខ២២០៨ ខែមេសា ឆ្នាំ២០១៧ ទំព័រ៣៤ ។

រឿងដែលខ្លួនបានដឹងពីអតីតភាពរបស់ឪពុកម្ដាយ។ គ្រួសារមួយចំនួនត្រូវខ្មែរក្រហមយកទៅកម្ទេចបន្ទាប់ពីកូនៗរបស់គេរាយការណ៍ឱ្យអង្គការ។ ការដែលមិនហ៊ាននិយាយអំពីការងាររបស់ឪពុកម្ដាយកាលពីសង្គមមុននោះ គឺរួចផុតពីទណ្ឌកម្មនានា។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គ្មានការងារណាមួយសម្រាប់បម្រើឱ្យផលប្រយោជន៍ឯកជននោះទេ។ ប្រជាជនរស់នៅដោយបង្ខំ ជាសហករណ៍ រស់នៅរួមមិនមានកម្មសិទ្ធឯកជន និង ខិតខំកសាងខ្លួនឱ្យក្លាយជាកសិករជាន់ខ្ពស់។[១៤]

## ៥. ប្រព័ន្ធកសិកម្មកម្ពុជាប្រជាធិបតេយ្យ

ខ្មែរក្រហមពឹងផ្អែកលើវិស័យកសិកម្ម ដើម្បីឈានឆ្ពោះទៅរកការកសាងសង្គមនិយមស្អាតស្អំមួយមានឧស្សាហកម្មជឿនលឿនក្នុងរយៈពេលខ្លី។ ផែនការកសិកម្ម ជីកប្រឡាយ លើកទំនប់ រៀបចំប្រព័ន្ធធារាសាស្ត្រ ជាចំណុចអាទិភាពរបស់ពួកគេ។ "ពន្លឺចម្បងបំផុតរបស់យើងក្នុងវិស័យកសិកម្មគឺពឹងពាក់ខ្លួនឯង គឺជាកម្លាំងស្នូល។"[១៥]

សញ្ញាជាតិ តាមមាត្រាទី១៧ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ បានចែងយ៉ាងច្បាស់ថា សញ្ញាជាតិ មានប្រព័ន្ធស្រែ និងប្រឡាយទឹកជានិមិត្តរូបនៃកសិកម្មជឿនលឿន រោងចក្រជានិមិត្តរូបនៃឧស្សាហកម្ម មានកម្រងកួរស្រូវរាងជាស្នែងក្របីព័ទ្ធពីក្រៅ ហើយមានអក្សរនៅពីក្រោម «**កម្ពុជាប្រជាធិបតេយ្យ**»។

ទិន្នផលស្រូវត្រូវតែច្រើនជាងមុន ៣ដង ប្រហាក់ប្រហែល ៣តោនក្នុងមួយហិកតា នៅលើផ្ទៃដីកសិកម្មទូទាំងប្រទេសកម្ពុជា។ យ៉ាងណាមិញ ផែនការកសិកម្មនេះសម្រេចជោគជ័យជាបន្តបន្ទាប់ ប៉ុន្តែក្នុងល្បឿនយឺត ព្រោះថា ប្រព័ន្ធគ្រប់គ្រងរដ្ឋនៅថ្មីថ្មោងពេកមិនទាន់មានបទពិសោធន៍គ្រប់គ្រាន់ ជីវភាពហូបចុកប្រជាជននៅខ្វះខាត ហើយស្ថានភាពស្រុកទេសទៀតសោតក៏ទើបតែឆ្លងផុតពីសង្គ្រាមផ្ទៃក្នុងផង។ "ដើម្បីសម្រេចបាននូវការបង្កើនផលិតកម្មស្រូវដ៏ច្រើនសន្ធឹកសន្ធាប់នេះ ខ្មែរក្រហមបានខិតខំដោះស្រាយបញ្ហាប្រព័ន្ធធារាសាស្ត្រនៅក្នុងប្រទេស ដោយបានធ្វើការបង្កើតឱ្យមានប្រព័ន្ធប្រឡាយទំនប់ទឹក ធ្វើជាអាងស្តុក និង បែងចែកទឹកឱ្យបានពេញមួយឆ្នាំ។"[១៦]

មរតកក្នុងវិស័យកសិកម្មនិងប្រព័ន្ធធារាសាស្ត្រក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានបន្សល់ទុករហូតដល់បច្ចុប្បន្ន មានដូចជា៖ ភ្លឺស្រែនានាមានរាងជាក្រឡាចក្រត្រង្គ ទំនប់១មករា ទំនប់ស្ទឹងជីនិត (ស្រុកបារាយណ៍ខេត្តកំពង់ធំ) អាងកំពីងពួយ(ស្រុកបាណន់ ខេត្តបាត់ដំបង) និងអាងត្រពាំងថ្ម (ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ)ជាដើម។

---

[១៤] សច្ចធម៌ប្រវត្តិសាស្ត្រ៖ ពាក្យ«**សហករណ៍**»ក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានន័យដូចម្ដេច? ២៨ សីហា ឆ្នាំ២០២១ ម៉ោង៧:៥៧។

[១៥] មជ្ឈមណ្ឌលឯកសារកម្ពុជា៖ ***ការអត់ឃ្លាននិងការស្លាប់ហួសប្រមាណក្នុងរបបកម្ពុជាប្រជាធិបតេយ្យ*** សម្លេងយុត្តិធម៌ អំពើប្រល័យពូជសាសន៍ និង ការអត់ឃ្លានក្នុងរបបខ្មែរក្រហម សំណុំរឿង០០២ វគ្គ២ តុលាការខ្មែរក្រហម ទំព័រ៦។

[១៦] មជ្ឈមណ្ឌលឯកសារកម្ពុជា៖ ***ការអត់ឃ្លាននិងការស្លាប់ហួសប្រមាណក្នុងរបបកម្ពុជាប្រជាធិបតេយ្យ*** សម្លេងយុត្តិធម៌ អំពើប្រល័យពូជសាសន៍ និង ការអត់ឃ្លានក្នុងរបបខ្មែរក្រហម សំណុំរឿង០០២ វគ្គ២ តុលាការខ្មែរក្រហម ទំព័រ៦។

## ៦. ការប្រើមនុស្សដោយគ្មានការតវ៉ា

បក្សកុម្មុយនីស្តកម្ពុជា ប្រើអំណាចផ្តាច់ការធ្វើឱ្យប្រជាជនក្នុងសហករណ៍ ឬក្នុងការដ្ឋានភ័យខ្លាចមិនហ៊ានតវ៉ាប្រឆាំងនឹងគោលនយោបាយដាច់ខាតរបស់អង្គការបដិវត្តន៍ឡើយ។ ថ្នាក់លើតម្រូវឱ្យប្រជាជនក្នុងសហករណ៍ធ្វើការងារតាមផែនការដែលបានកំណត់។ វាគឺជាគម្រោងការងារធំៗហើយត្រូវសម្រេចឱ្យបានក្នុងរយៈពេលខ្លីផង ទោះបីចំណីអាហារសម្រាប់ប្រជាជនមិនគ្រប់គ្រាន់និងមានពេលវេលាសម្រាកតិចតួចក្តី។ ឧទាហរណ៍៖ សហករណ៍ស្រុកត្រាំកក់ ស្ថិតនៅស្រុកត្រាំកក់ តំបន់១៣ ភូមិភាគនិរតី (បច្ចុប្បន្នខេត្តតាកែវ) ប្រជាជនត្រូវបានគេបង្ខំដោយចេតនាឱ្យធ្វើការងារក្រោមបរិយាកាសនៃការគ្រប់គ្រង ការគំរាមកំហែង ភាពភ័យខ្លាច ការអត់អាហារ និងរើសអើង។[១៧] "**សហករណ៍ត្រាំកក់** ស្ថិតក្រោមការត្រួតត្រាផ្ទាល់ពីគណៈស្រុក(លេខាស្រុក)។ សម្រាប់សហករណ៍នេះមានការផ្លាស់ប្តូរគណៈស្រុកជាញឹកញាប់ ពិសេសចាប់ពីខែមីនាឆ្នាំ១៩៧៧ ដល់ខែធ្នូ ឆ្នាំ១៩៧៨។"[១៨] ការងារស្នូលរបស់សហករណ៍គឺការលើកទំនប់ ជីកប្រឡាយ និងធ្វើស្រែចម្ការតាមផែនការអង្គការកំណត់។ គ្មានឡើយការតវ៉ា "គ្រាន់តែហើបមាត់តែបន្តិច គេយកទៅបាត់ ឬយកទៅសម្លាប់ចោល។"[១៩] ផលវិបាកខាងរូបកាយមានមនុស្សស្លាប់ជាច្រើននាក់ដោយអត់អាហារ ដោយជំងឺ និងដោយទម្ងន់ការងារ។ ឯផលវិបាកផ្លូវចិត្តវិញ មានផលប៉ះទង្គិចខ្លាំងជុំវិញការលុបបំបាត់គ្រប់ទម្រង់នៃសិទ្ធិសេរីភាពឯកជនប្រជាជន។

ប្រជាជនថ្មីដែលជម្លៀសចេញពីទីប្រជុំជន បានទទួលរងផលប៉ះពាល់ទាំងនេះច្រើនជាងប្រជាជនមកពីតំបន់ជនបទដែលគេហៅថាប្រជាជនមូលដ្ឋាន ឬប្រជាជនចាស់។ ពួកគេត្រូវបានរឹតត្បិតសេរីភាពក្នុងការដើរហើរ ត្រូវចូលរួមប្រជុំទិតៀន និងស្វ័យទិតៀន បាត់បង់រចនាសម្ព័ន្ធគ្រួសារដែលមាន និងទទួលរងការគំរាមកំហែងបញ្ជូនទៅអប់រំ ចាប់ខ្លួន ឬ បាត់ខ្លួន។

ទោះយ៉ាងណាក្តីប្រធានសហករណ៍ លេខាស្រុក ឬ គណៈស្រុកត្រាំកក់ពុំបានខ្វាយខ្វល់ពីទុក្ខវេទនាប្រជាជនឡើយ ហើយសម្រុកធ្វើតាមផែនការអង្គការរហូតទទួលបានការកោតសរសើរពីមជ្ឈិម។ "នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៧៧ គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាបានជូនទង់ក្រហមកិត្តិយសដល់ស្រុកត្រាំកក់ជាការទទួលស្គាល់ថា ស្រុកនេះជាស្រុកគំរូមួយក្នុងចំណោមស្រុកគំរូទាំងបីនៅទូទាំងប្រទេសកម្ពុជាប្រជាធិបតេយ្យ ក្នុងផ្នែកនៃការការពារប្រទេសធ្វើបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមក្នុងការបំពេញភារកិច្ចរបស់បក្ស ដើម្បីបាននូវស្រូវ៣តោនក្នុងមួយហិកតា និងក្នុង

---

[១៧] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាកាកម្ពុជា៖ **សេចក្តីសង្ខេបសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក. សំណុំរឿង ០០២/០២** ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨/សាធារណៈ ទំព័រ១១។

[១៨] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះសាលាដំបូងៈ សវនាការលើកទី២៥៤ សំណុំរឿងព្រហ្មទណ្ឌលេខៈ ០០២/១៩-០៩-២០០៧/អវតក/អជសជ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៥ ទំព័រ៦០។

[១៩] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាកាកម្ពុជា៖ **អង្គជំនុំជម្រះសាលាដំបូង/សវនាការលើកទី២២៥** សំណុំរឿងព្រហ្មទណ្ឌលេខៈ ០០២/១៩-០៩-២០០៧/អវតក/អជសជ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ទំព័រ១៣។

ការតស៊ូវណ្ណៈយ៉ាងក្លៀវក្លា សស្រាក់សស្រាំ នៅក្នុងស្រុកនេះទាំងមូល។"[២០] នៅមានការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់១មករា និងការដ្ឋានវាលយន្តហោះកំពង់ឆ្នាំង បានប្រើប្រាស់ដោយគ្មានការតវ៉ានូវកម្លាំងមនុស្សរាប់ម៉ឺននាក់ ដើម្បីសម្រេចតាមផែនថ្នាក់លើបញ្ជា។

## ៧. ការរក្សាធនធានធម្មជាតិកម្ពុជា

"ប្រទេសកម្ពុជា គឺជាដែនដីសុវណ្ណភូមិដែលសម្បូរទៅដោយធនធានធម្មជាតិគ្រប់ប្រភេទ។ គេចាត់ទុកប្រទេសនេះថា ជាដែនដីសុវណ្ណភូមិ ព្រោះប្រទេសមួយនេះធ្លាប់សម្បូរទៅដោយធម្មជាតិលើគោក ក្នុងទឹក និងក្រោមបាតសមុទ្រ។ ជាក់ស្តែង នៅក្នុងខេត្តបាត់ដំបង ប៉ៃលិន រតនៈគីរី កំពង់ធំ ព្រះវិហារ មណ្ឌលគីរី សម្បូរទៅដោយព្រៃឈើ រ៉ែមាស រ៉ែត្បូង រ៉ែដែក និងធនធានមានតម្លៃមួយចំនួនផ្សេងទៀត។ នៅក្រោមបាតសមុទ្រ បាតទន្លេ កម្ពុជាត្រូវបានគេវាយតម្លៃថាសម្បូរទៅដោយមច្ឆាជាតិទឹកប្រៃ និងទឹកសាប។ កាលពីពេលមុន ប្រជាជនខ្មែរនាំគ្នានិយាយថា ទីណាមានទឹក ទីនោះមានត្រី។"[២១]

ការថែរក្សាធនធានធម្មជាតិ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានលក្ខណៈល្អប្រសើរ។ ព្រៃឈើ និងមច្ឆាជាតិមានពាសពេញផ្ទៃដីប្រទេសកម្ពុជា។ លក្ខណៈសម្បត្តិនេះ ស្មេរធ្វើការសម្ភាសន៍សាក្សី[២២] អតីតកងទ័ពស្ម័គ្រចិត្តវៀតណាមម្នាក់លោក **ង្វៀន ប៊ិញ** កើតឆ្នាំ១៩៥៤ បានរៀបរាប់៖ ចុងខែធ្នូ ឆ្នាំ១៩៧៨ ពួកយើងបានទៅដល់ស្រុកលំផាត់ ខេត្តរតនគីរី ជាទីន្លែងគ្របដណ្តប់ដោយព្រៃក្រាស់ឃ្មឹក សម្បូរសត្វព្រៃ និង អនុផលធម្មជាតិច្រើនយ៉ាង។ វាជាលើកទី១ហើយ ដែលខ្ញុំបានឃើញផ្ទាល់នឹងភ្នែកនូវសត្វខ្លាខិន ជ្រូកពោន ស្វាត្រោស និង ខ្ទីង។ ហើយ ដើមខែមករា ឆ្នាំ១៩៧៩ ពួកយើងបានមកដល់ទីរួមខេត្តក្រចេះ។ អ្នកនាសាទបានឱ្យត្រីឆ្កោកពួកយើងហូបជារៀងរាល់ថ្ងៃ។ នៅមានត្រីក្រាយ ត្រីកាហែ ត្រីឆ្ពិន ត្រីផ្កាចារ.. សម្បូរណាស់។ ដូចគ្នាដែរ ភូមិសាស្រ្តកំពង់ចាម.. ប្រភេទត្រីនៅទន្លេបិទ ទីនោះមានច្រើនដែលខ្ញុំមិនស្គាល់ឈ្មោះ។

បទសម្ភាសន៍ដាច់ដោយឡែកមួយផ្សេងទៀត ទាក់ទងការរក្សាសម្បត្តិធម្មជាតិក្នុងរបបខ្មែរក្រហម ស្មេរបានសម្ភាន៍លោកស្រី **សុង ឌុម** កើតឆ្នាំ១៩៦០ ជាអ្នកស្រុកខេត្តកំពង់ចាម និងជាអតីតជំនួយការពេទ្យទាហានក្នុងកងរណសិរ្សសង្គ្រោះជាតិកម្ពុជា។ បច្ចុប្បន្ន លោកស្រីជាមន្ត្រីចូលនិវត្តន៍។ ខែមីនាឆ្នាំ១៩៧៧ លោកស្រី **ឌុម** និង ចលនាតស៊ូខ្មែរជាច្រើននាក់បានភៀសខ្លួនចូលទឹកដីវៀតណាម(ខេត្ត **ប៊ិញភឿក**)។ នៅប្រទេសវៀតណាម លោកស្រីបានហាត់រៀនវិជ្ជាពេទ្យដើម្បីត្រៀមខ្លួនចាំឱកាសវិលត្រឡប់

---

[២០] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា៖ **កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ(វគ្គ២)** ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ សវនាការលើកទី២២៥ ទំព័រ១១។

[២១] គេហទំព័រ ថ្មីៗ៖ ខ្មែរមានធនធានធម្មជាតិ និង កេរតំណែលវប្បធម៌ច្រើន ដោយ **គី សុខលីម** ចេញផ្សាយថ្ងៃទី១៤ មិថុនា ឆ្នាំ២០១៥ ។

[២២] បទសម្ភាសន៍ ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៤ នឹងលោក **ង្វៀន ប៊ិញ** ជាមន្ត្រីចូលនិវត្សន៍ អតីតកងទ័ពស្ម័គ្រចិត្តវៀតណាម ផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត។

មកកម្ពុជាវិញ។ ទំនាក់ទំនងកម្ពុជាវៀតណាមមានសភាពកាន់តែអាក្រក់ទៅៗ រហូតឈានដល់ផ្ទុះអាវុធជាទ្រង់ទ្រាយធំរវាងប្រទេសទាំងពីរនាចុងឆ្នាំ១៩៧៨។ ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ កងកម្លាំងរណសិរ្សសង្គ្រោះជាតិកម្ពុជារំដោះបានទីក្រុងភ្នំពេញ។ ថ្ងៃទី៨ ខែមករា ឆ្នាំ១៩៧៩ កងកម្លាំងរណសិរ្សរំដោះបានខេត្តសៀមរាបដោយផ្នែក។ លោកស្រី **ខុម** ត្រូវបានចាត់តាំងឱ្យធ្វើជាគ្រូពេទ្យប្រចាំស្រុកសូត្រនិគម មើលថែ និងព្យាបាលយុទ្ធជនក្នុងសមរភូមិមុខ។ លោកស្រី **ខុម** រៀបរាប់ថា៖ *ស្រុកសូទ្រនិគម និយាយដោយឡែក ខេត្តសៀមរាបនិយាយជារួម ជាតំបន់ព្រៃក្រាស់កំពុងប្រទាញប្រទង់ជាមួយកម្លាំងខ្មែរក្រហម។ ក្រៅពីខ្មាំង* ***(ប៉ុល ពត)*** *ពួកយើងប្រឈមមុខនឹងគ្រោះថ្នាក់ដោយសារជំងឺគ្រុនចាញ់និងសត្វសាហាវ។ ព្រៃឈើដ៏ក្រាស់ទាំងនេះគឺជាឧបសគ្គធំបំផុតសម្រាប់កងកម្លាំងរដ្ឋាភិបាលយើងរុលទៅមុខ។*

នៅមានបទសម្ភាសន៍ជាច្រើនទៀត ដែលមានខ្លឹមសារប្រហាក់ប្រហែលបទសម្ភាសន៍ទាំងពីរខាងលើនេះ។ ដូច្នេះ យើងអាចសន្និដ្ឋានបានថា ធនធានធម្មជាតិប្រទេសកម្ពុជា ក្រោយរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ពុំត្រូវបានបំផ្លិចបំផ្លាញដោយសកម្មភាពមនុស្សទេ ឬអាចនិយាយបានថា របបកម្ពុជាប្រជាធិបតេយ្យថែរក្សាធនធានធម្មជាតិកម្ពុជាបានល្អប្រសើរ។

## សន្និដ្ឋាន

**ចំណុចខ្លាំងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ**រួមមាន៖ សង្គមសមូហភាពតាមរយៈផ្ដាច់ពួកមូលធននាយទុន សក្ដិភូមិនិយម ឱ្យនៅសល់តែកម្លាំងពលកម្មនៃវណ្ណៈកម្មករ កសិករ ឬពួកអធនប៉ុណ្ណោះ។ កម្ពុជាប្រជាធិបតេយ្យ រៀបចំសង្គមប្រជាជនឱ្យរស់នៅជាសហករណ៍ លើកទំនប់ ជីកប្រឡាយ រុះផ្ទះធំមកធ្វើផ្ទះតូច ទោះការអនុវត្ត មិនស្មើគ្នាទាំងស្រុងក្ដី។ កម្ពុជាប្រជាធិបតេយ្យប្រើអំណាចផ្ដាច់ការ ប្រើមនុស្សដោយគ្មានការតវ៉ា ហើយគ្រប់គ្នាត្រូវស្មោះស្ម័គ្រចំពោះអង្គការតែមួយគត់(កូនហ៊ានសម្លាប់ឪពុក បើឪពុកហ៊ានក្បត់អង្គការ)។ ខ្មែរក្រហមកសាងសង្គមជាតិស្អាតស្អំមួយ ដោយគ្មានអំពើកេងបន្លំ ឬពុករលួយ ហើយអ្នកក្រអាចត្រួតអ្នកមានបាន។ វិស័យកសិកម្មវិញ ខ្មែរក្រហមរៀបចំប្រព័ន្ធធារាសាស្ត្រ ក្រឡាចត្រង្គ ខិតខំធ្វើស្រែទទួលបានទិន្នផលខ្ពស់។ លើសពីនេះ ខ្មែរក្រហមបានបើកទំព័រប្រវត្តិសាស្ត្រថ្មីនៃការការពារ ថែរក្សាសម្បត្តិធម្មជាតិខ្មែរបានយ៉ាងល្អផងដែរ។

# គន្ថនិទ្ទេស

## ឯកសារភាសាខ្មែរ


- គិន ភា៖ *គ្រប់គ្រងរដ្ឋនិងនយោបាយប្រៀបធៀប* មេរៀនបណ្ដុះបណ្ដាលថ្នាក់បណ្ឌិតវិទ្យាសាស្ត្រនយោបាយនៃរាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០២០
- ឱខាំបូលី៖ *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)* ភ្នំពេញ មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ២០០៧
- ប៊ិនខៀនិន៖ ***របបប៉ុលពត ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍***ប្រែសម្រួលដោយ៖ **ឡាយ ពុទ្ធារ៉ា** និង **ទី ឃាយុ** មជ្ឈមណ្ឌលឯកសារកម្ពុជា១៩៩៣
- យង់ ពៅ៖ ***វិភាគភូមិសាស្ត្រនយោបាយ*** មេរៀនបណ្ដុះបណ្ដាលថ្នាក់បណ្ឌិតវិទ្យាសាស្ត្រនយោបាយ **រាជបណ្ឌិត្យសភាកម្ពុជា**ឆ្នាំ២០២០
- វ៉ាន់ឌី កាអុន៖ ***សុបិន និង ការពិត*** ភាគ១ សមាគមកម្ពុជាអាស៊ី ឆ្នាំ២០១៧ រដ្ឋធម្មនុញ្ញកម្ពុជាប្រជា-ធិបតេយ្យ៖ជំពូកទី១**អំពីរបបរដ្ឋ**មាត្រា១
- នរោត្តម សីហនុ៖ *My War with CIA.* Printed( ? ) year( ? )
- ឥន សុផល៖ ***កម្ពុជាក្នុងសង្គ្រាមវៀតណាម១៩៥៤-១៩៧៥*** និក្ខេបបទវិទ្យាសាស្ត្រនយោបាយ **រាជបណ្ឌិត្យសភាកម្ពុជា** ភ្នំពេញ ២០១០ ទំព័រ២៨៤


## ឯកសាភាសាបរទេស


- Chandler David: ***Brother Number One***. A political Biography of Pol Pot, United States of America, 1992
- Chandler David: ***The Tragedy of Cambodia History***, Politics, War and Revolution Since 1945, Published by OS Printing House Bangkok, Thailand,1991
- Chanda Nayan: ***Brother Enemy***, The War after the War. San Diego, Ca: Harcourt Brace Jovanovich, 1986.
- David Boucher & Paul Kelly: ***Political Thinkers***. First Published, 2003
- Elizabeth Becker: ***When The War Was Over*** CAMBODIA AND KHMER ROUGE REVOLUTION Public affair New York
- François Ponchaud***: Cambodia Year Zero***. Translated from the French by Nancy Amphoux, HOLT RINE HART and WINSTON NEW YORK 1978
- HARISH C. MEHTA & JULIE B. MEHTA: ***STRONG MAN***, The Extraordinary Life of HUN SEN, Marshall Cavendish Editions.


## របាយការណ៍ស្រាវជ្រាវ


- https://www.britannica.com/topic/state-sovereign-political-entity
- https://www.bbc.com/news/world-asia-pacific-10685769

- https:/langeongsan.vn/huong-toi-ky-nicm-90-nam-ngay-truyen-thong- nganh tuyen-giao thong-tin-tu-licu/nguyen-ai-quoc-va-con-duong-dua-chu- nghia- mac-lenin vào-viet-nam-530907.html
- https://www.rfi.fi km/cambodia-Biographie Khiev Samphan particl
- http://truongleduan.quangtri.gov.vn/vi/hoat-dong-khoa-hoc/bao-ve-nen-lang- tu tuong-cua-dang tim-hieu-ve-chu-nghia-muc-lenin-va-mot-so-khai-niem-lien- quan 337.html
- https://youtu.be/CQ9 BMshyiw

# សមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ

បេក្ខជនបណ្ឌិត៖ **អូន សំអុល**
ជំនាញ៖ **រដ្ឋបាលសាធារណៈ**

## ១- សេចក្តីផ្តើម

ពាក្យរដ្ឋបាលសាធារណៈត្រូវបានគេប្រើប្រាស់តាំងពីសម័យបុរាណកាល ពេលដែលមនុស្សមានអារ្យធម៌។ នៅពេលដែលមនុស្សចាប់ផ្តើមចេះរស់នៅជាសង្គម មានការចាត់ចែង និងជាពេលវេលា ដែលមនុស្សចាប់ផ្តើមធ្វើការងាររដ្ឋបាល ព្រោះជាពេលដែលពួកគេចេះរស់នៅផ្តុំគ្នាជាសង្គម។ [១]

ការឱ្យអត្ថន័យទៅលើពាក្យរដ្ឋបាលសាធារណៈមានច្រើនយ៉ាង និងមានលក្ខណៈស្មុគស្មាញ។ ខាងក្រោមនេះ គឺជាអត្ថន័យនៃពាក្យនេះ ដោយអ្នកប្រាជ្ញមួយចំនួន៖[២]

តាម Raul P.de Guzmen បានលើកឡើងថា «នៅទីណាមានរដ្ឋាភិបាល នៅទីនោះមានរដ្ឋបាលសាធារណៈ» ដែលវាគឺជាសកម្មភាពសហប្រតិបត្តិការរបស់ពលរដ្ឋ ដើម្បីសម្រេចឱ្យបាននូវគោលដៅរដ្ឋាភិបាល។

Robert Presthus បានឱ្យអត្ថន័យថា រដ្ឋបាលសាធារណៈ ជាសកម្មភាពដែលជាប់ពាក់ព័ន្ធទៅនឹងក្របខណ្ឌស្ថាប័នរបស់រដ្ឋាភិបាល មជ្ឈដ្ឋានសេដ្ឋកិច្ច សង្គមកិច្ចនិងនយោបាយ និងអាកប្បកិរិយារបស់បុគ្គលគ្រប់រូប ដែលកាន់កាប់ក្បាលម៉ាស៊ីនរបស់រដ្ឋ។ លោកក៏បានបញ្ជាក់ថែមទៀតថា «រដ្ឋបាលសាធារណៈជាទិដ្ឋភាពនៃការគ្រប់គ្រងដែលធ្វើឡើងដោយភ្នាក់ងាររបស់រដ្ឋាភិបាលនៅគ្រប់លំដាប់ថ្នាក់»។

បើតាមទស្សនៈរបស់ ឆេនដ៏ល័រ (Chandler) និង ប្លាណូ (Plano) (1988:29) បានលើកឡើងថា រដ្ឋបាលសាធារណៈគឺជាដំណើរនៃការគ្រប់គ្រង សម្របសម្រួលនូវធនធាននិងបុគ្គលិក ដើម្បីបង្កើតអនុវត្ត និងគ្រប់គ្រងនូវរាល់សេចក្តីសម្រេចនៅក្នុងគោលនយោបាយសាធារណៈ [៣]។

ទស្សនៈ Karl Polanyi រដ្ឋបាលសាធារណៈជាទូទៅត្រូវបានចាត់ទុកថាជាការងារនៃរដ្ឋាភិបាល ដែលមានមុខងារយ៉ាងសំខាន់នៅក្នុងប្រទេសមួយ។ ស្ថានភាពសេដ្ឋកិច្ចប្រទេសមួយអាស្រ័យយ៉ាងខ្លាំងទៅលើថាមវន្តនៃរដ្ឋបាលសាធារណៈ [៤]។

ទស្សនៈរ៉ូនឌីនែលី (Rondinelli; 2007) បច្ចុប្បន្នមុខងាររដ្ឋបាលសាធារណៈត្រូវតែតម្រង់ទិសទៅរកការបម្រើប្រជាពលរដ្ឋក្នុងគោលបំណងទទួលបាននូវអភិបាលកិច្ចបែបប្រជាធិបតេយ្យ។

ជារួម រដ្ឋបាលសាធារណៈគឺជា «ការគ្រប់គ្រង និងចាត់ចែងកិច្ចការនានាដោយអង្គការរដ្ឋ ដើម្បីបម្រើប្រយោជន៍ទូទៅ»។ ក្នុងន័យនេះ វាជាដៃគូស្ថាបនិកមួយនៃនយោបាយក្នុងការដឹកនាំកិច្ចការរដ្ឋបាល

---

[១] សឿន សោភ័ណ *សេចក្តីផ្តើមរដ្ឋបាលសាធារណៈ* សាកលវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងនីតិសាស្ត្រឆ្នាំ២០១៩ ទំព័រ៥២។

[២] ង៉ឹយ ធឿន *រដ្ឋបាលសាធារណៈ* សាលាភូមិន្ទរដ្ឋបាល ឆ្នាំ២០១៩ ទំព័រ ១១។

[៣] អ៊ុំ ប៉ុម *រដ្ឋបាលសាធារណៈឆ្នាំ១៩៥៣-១៩៧០* រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០១១ ទំព័រ ៨-១០។

[៤] Keban, 2004 ដែលបានដកស្រង់ដោយសយ រាសី *កំណែទម្រង់រដ្ឋបាលសាធារណៈ* ឆ្នាំ២០១១ ទំព័រ ៧។

ទូទៅជូនប្រជាពលរដ្ឋ។ វាក៏ជាឧបករណ៍ដ៏ស័ក្តិសិទ្ធិនៃការបម្រើប្រជាពលរដ្ឋរបស់រដ្ឋាភិបាល ព្រមទាំងជាយន្តការសម្រាប់បំផុសការចូលរួមរបស់ប្រជាជនក្នុងការគ្រប់គ្រងរបស់ រដ្ឋាភិបាលផងដែរ [៥]។

តាមបណ្តាទស្សនៈខាងលើ យើងអាចនិយាយថា រដ្ឋបាលសាធារណៈជាឆ្អឹងខ្នងនៃប្រទេសជាតិដែលជួយជំរុញវិស័យសេដ្ឋកិច្ចឱ្យមានការរីកចម្រើន លើកកម្ពស់អភិបាលកិច្ចល្អ បង្កើតនិងពង្រឹងលទ្ធិប្រជាធិបតេយ្យ ព្រមទាំងការលើកកម្ពស់គុណភាពសេវាសាធារណៈ ដែលជាបច្ច័យនាំឱ្យប្រទេសជាតិមានស្ថិរភាព និងមានការរីកចម្រើន [៦]។

## ២- បញ្ញត្តិអំពីសមិទ្ធកម្ម

### ២.១- និយមន័យ

បើឱ្យនិយមន័យបែបភាសាបាលី ពាក្យសមិទ្ធកម្ម ប្រែថា អំពើឬការងារដែលបានសម្រេច បានបញ្ចប់ហើយ។ ពាក្យនេះអានថា /សាក់-មឹត-ធៈ-កាំ/ ន. [៧]។

នៅក្នុង Oxford Dictionary(1998:606) Performance ស្មើនឹងពាក្យជាបច្ចេកទេសភាសាខ្មែរថាសមិទ្ធកម្ម មានន័យថា ការប្រតិបត្តិ ឬការបំពេញភារកិច្ចមួយ "The execution or fulfillment of a duty"។ រីឯវចនានុក្រមគ្រប់គ្រងធនធានមនុស្សនិងបុគ្គលិក (2006:196) បានឱ្យនិយមន័យថា សមិទ្ធកម្ម គឺជារបៀបដែលនរណាម្នាក់ ឬអ្វីមួយបានប្រព្រឹត្តរួចហើយ។

ពាក់ព័ន្ធនឹងពាក្យសមិទ្ធកម្មនេះ បើតាមទស្សនៈ Bernardin និង Russel (1993:379) លោកទាំងពីរបានកំណត់ថា សមិទ្ធកម្មគឺជាកំណត់ត្រាស្តីពីលទ្ធផលដែលសម្រេចបាននៅក្រោយពេលដែលការងារមួយ ឬសកម្មភាពមួយត្រូវបានដំណើរការនៅក្នុងរយៈពេលមួយកំណត់។ Anne Ketelaar, Nick Manning and Edouard Turkis (2007) ក៏បានលើកឡើងផងដែរថា សមិទ្ធកម្ម គឺសំដៅដល់ជាតុចេញ លទ្ធផលដែលអាចវាស់វែងបាន ឬលទ្ធផលផ្សេងៗទៀត ដែលបានមកពីបណ្តាសកម្មភាពរបស់វិស័យសាធារណៈ។ ចំណែកលោក សយ រាសី (2018:31) បានដកស្រង់ចាកពី (T.Keban, 2008:210) បានឱ្យដឹងថា ជាទូទៅសមិទ្ធកម្មត្រូវបានគេឱ្យន័យថាជាកម្រិតនៃការសម្រេចលទ្ធផល។

នៅក្នុងការសិក្សាស្តីពីរដ្ឋបាលសាធារណៈ សមិទ្ធកម្មនេះត្រូវបានប្រើប្រាស់ចាប់តាំងពីសម័យ Woodrow Wilson ដែលបានសង្កត់ធ្ងន់ទៅលើប្រសិទ្ធភាពនៅក្នុងការបង្កើតប្រព័ន្ធរដ្ឋបាល និង F. W. Taylor ដែលបានជំរុញឱ្យបុគ្គលិកធ្វើការឱ្យមានប្រសិទ្ធភាព [៨]។

---

[៥] ង៉ើយ ធឿន *រដ្ឋបាលសាធារណៈ* សាលាភូមិន្ទរដ្ឋបាល ឆ្នាំ២០១៩ ទំព័រ ២។

[៦] សយ រាសី *កំណែទម្រង់រដ្ឋបាលសាធារណៈ* រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០១៧ ទំព័រ ៩។

[៧] រាជបណ្ឌិត្យសភាកម្ពុជា *វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ* ការផ្សាយរបស់វិទ្យាស្ថានភាសាជាតិ ព.ស.២៥៦១ គ.ស. ២០១៧ ទំព័រ ៧២៧។

[៨] សយ រាសី *ទ្រឹស្តីរដ្ឋបាលសាធារណៈ* រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០១៨ ទំព័រ ៣១

Armstrong (2006:7) បានលើកឡើងថា សមិទ្ធកម្មត្រូវបានគេកំណត់ជាញឹកញាប់ថាជាសមិទ្ធផល(Output) មានន័យថា ជាសមិទ្ធផលនៃគោលដៅបែបបរិមាណ។ សមិទ្ធកម្មនេះ មិនគ្រាន់តែជាអ្វីដែលមនុស្សសម្រេចបាននោះទេ គឺរាប់បញ្ចូលទាំងវិធីដែលគេប្រើប្រាស់ ដើម្បីសម្រេចបាន។ សមិទ្ធកម្មខ្ពស់ គឺជាលទ្ធផលចេញពីអាកប្បកិរិយាសមរម្យ និងចាំបាច់ ព្រមទាំងប្រសិទ្ធភាពនៃការប្រើប្រាស់ចំណេះដឹង ជំនាញ និងសមត្ថភាពដែលត្រូវការ។ ដូច្នេះ ការគ្រប់គ្រងសមិទ្ធកម្មត្រូវតែពិនិត្យមើលលើវិធីដែលគេប្រើប្រាស់ដើម្បីសម្រេចបាននូវលទ្ធផលនោះ ព្រោះថា ការធ្វើដូច្នេះផ្តល់នូវព័ត៌មានចាំបាច់ ដើម្បីពិចារណានូវអ្វីដែលត្រូវធ្វើក្នុងគោលបំណងកែលម្អលទ្ធផលទាំងនោះ។

ចំណែក Aguinis (2019: 121) សមិទ្ធកម្មជាការរួមបញ្ចូលគ្នានៃកត្តាពីរសំខាន់ៗ គឺអាកប្បកិរិយា និងសកម្មភាព (អ្វីដែលបុគ្គលិកប្រព្រឹត្ត) និងលទ្ធផលនិងផលិតផល (សមិទ្ធផល ដែលកើតចេញពីអាកប្បកិរិយរបស់បុគ្គលិក)។ អាកប្បកិរិយា និងសកម្មភាពជាចំណែកនៃប្រសិទ្ធភាពការងាររបស់បុគ្គលិកដែលធ្វើការជាមួយបុគ្គលិកដទៃទាំងក្នុងនិងក្រៅអង្គភាព ក្នុងឥរិយាបថមួយធ្វើឱ្យប្រសិទ្ធផលប្រសើរឡើង ចែករំលែកព័ត៌មាននិងធនធានអភិវឌ្ឍន៍ ប្រសិទ្ធភាពទំនាក់ទំនងការងារ កសាងការមូលមតិគ្នា និងការគ្រប់គ្រងជម្លោះក្នុងន័យស្ថាបនា។ ចំណែកឯលទ្ធផលនិងផលិតផលសំដៅទៅលើសមិទ្ធផលដែលកើតចេញពីអាកប្បកិរិយា និង សកម្មភាពវាស់វែងនៃការអនុវត្តការងាររបស់បុគ្គលិក។

រូបភាពទី១ ៖ការរួមបញ្ចូលគ្នារវាងអាកប្បកិរិយានិងសកម្មភាព និង លទ្ធផលនិងផលិតផល




ប្រភព៖ Aguinis, H. (2019: 122) Performance Management For Dummies.John Wiley & Sons, Inc., 2019

## ២.២- ប្រភេទនៃសមិទ្ធកម្ម

### ២.២.១- សមិទ្ធកម្មរបស់បុគ្គល

ជាប្រភេទសមិទ្ធកម្មដែលបានបង្ហាញអំពីការបំពេញការងាររបស់បុគ្គលម្នាក់ៗ ដែលបានកំណត់ដោយក្រុម ឬអង្គភាព។ Garry Dessler (2017:278-283) បានកំណត់វិធីសាស្ត្រមួយចំនួន ដើម្បីវាយតម្លៃលើសមិទ្ធកម្មរបស់បុគ្គល ដូចខាងក្រោម៖

- វិធីសាស្ត្រកំណត់មាត្រដ្ឋានតាមក្រាហ្វិច គឺជាវិធីសាស្ត្រសាមញ្ញនិងពេញនិយមបំផុតសម្រាប់វាយតម្លៃសមិទ្ធកម្ម។ យើងអាចស្វែងយល់វិធីសាស្ត្រនេះ តាមរបៀបផ្សេងៗជាច្រើនដូចជា ទិដ្ឋភាពការងារ បុគ្គលិកលក្ខណៈរបស់បុគ្គល(ការទំនាក់ទំនងឬការងារជាក្រុម) និងចំណាត់ថ្នាក់នៃការអនុវត្ត

ការងារចាប់ពីក្រោម ការរំពឹងទុករហូតដល់ការអនុវត្តជាគំរូ ឬពីកម្រិតមិនពេញចិត្ត រហូតដល់កម្រិតការងារឆ្នើម។ អ្នកគ្រប់គ្រងផ្ទាល់ធ្វើការវាយតម្លៃបុគ្គលិកក្រោមឱវាទរបស់ខ្លួន ដោយការគូសជារង្វង់ឬសញ្ញាគ្រីសលើពិន្ទុដែលពិពណ៌នាយ៉ាងស័ក្តិសមបំផុត ចំពោះការអនុវត្តការងាររបស់បុគ្គលិកលើលក្ខណៈវិនិច្ឆ័យនីមួយៗ ព្រមទាំងបូកសរុបអត្រាពិន្ទុទាំងនោះ។

- វិធីសាស្ត្រដាក់ចំណាត់ថ្នាក់ជាជម្រើស គឺជាវិធីសាស្ត្រដែលចំណាត់ថ្នាក់បុគ្គលិកពីល្អបំផុតទៅអាក្រក់បំផុត ចំពោះលក្ខណៈវិនិច្ឆ័យនៃសមិទ្ធកម្មនីមួយៗ។ ជាដំបូងបុគ្គលិកក្រោមឱវាទទាំងអស់ដែលយើងដឹងអំពីការអនុវត្តការងាររបស់គេត្រូវបានវាយតម្លៃ ចំណែកបុគ្គលិកដែលយើងមិនបានដឹងពីការអនុវត្តការងាររបស់គេ មិនត្រូវបានវាយតម្លៃនោះទេ។ ក្នុងទម្រង់បែបនេះ យើងកំណត់ឱ្យឃើញបុគ្គលិកណាដែលមានការអនុវត្តការងារល្អបំផុត និងបុគ្គលិកដែលមានគុណផលទាបបំផុត បន្ទាប់មកយើងកំណត់បុគ្គលិកដែលមានពិន្ទុទាបបន្ទាប់គ្នា ទាំងខ្ពស់ទាំងទាបជាគូៗនឹងគ្នា។ ជាធម្មតាយើងមានភាពងាយស្រួលក្នុងការកំណត់រវាងបុគ្គលិក ដែលមានលទ្ធផលការងារល្អប្រសើរ និងបុគ្គលិកដែលមានលទ្ធផលការងារទាប។

- វិធីសាស្ត្រប្រៀបធៀបជាគូ ជាវិធីដែលធ្វើឱ្យការដាក់ចំណាត់ថ្នាក់កាន់តែច្បាស់ សម្រាប់រាល់លក្ខណៈវិនិច្ឆ័យ (បរិមាណការងារ គុណភាពការងារ ។ល។) ដោយយើងប្រៀបធៀបបុគ្គលិកម្នាក់ជាមួយបុគ្គលិកផ្សេងទៀត។ ឧទាហរណ៍៖ ដោយជ្រើសរើសបុគ្គលិកប្រាំនាក់មកដាក់ពិន្ទុ ដោយប្រើតារាងប្រៀបធៀបលក្ខណៈវិនិច្ឆ័យនៃបុគ្គលិកទាំងអស់។ បន្ទាប់មកជ្រើសរើសថា អ្នកណាជាបុគ្គលិកដែលល្អជាង។

- វិធីសាស្ត្រផ្តល់ពិន្ទុដោយកំណត់ចំនួនភាគរយ ស្រដៀងគ្នាទៅនឹងការដាក់កម្រិតលើខ្សែកោង។ ដោយការប្រើវិធីសាស្ត្រនេះ អ្នកគ្រប់គ្រងដាក់ចំនួនភាគរយនៃអត្រាដែលបានកំណត់ទុកជាមុនទៅក្នុងប្រភេទនៃការអនុវត្តការងារ។ ឧទាហរណ៍៖ អង្គភាពមួយបានកំណត់ឱ្យបុគ្គលិកដែលអនុវត្តការងារខ្ពស់បំផុត ១៥% (ជាប្រភេទបុគ្គលិកលេខ១) ៧៥% (ជាប្រភេទបុគ្គលិកលេខ២) និង១០% (ជាប្រភេទបុគ្គលិកលេខ៣ ដែលត្រូវតែបញ្ឈប់ពីការងារ)”។ រីឯ ក្រុមហ៊ុន GE បានអនុញ្ញាតឱ្យមានការវាយតម្លៃដោយដាក់កំណត់ ២០% សម្រាប់បុគ្គលិកដែលអនុវត្តការងារខ្ពស់បំផុត ៧០% សម្រាប់បុគ្គលិកដែលអនុវត្តការងារមធ្យម និង១០% សម្រាប់បុគ្គលិកដែលអនុវត្តការងារមានគុណផលទាប ដើម្បីឱ្យអ្នកគ្រប់គ្រងផ្ទាល់វាយតម្លៃបុគ្គលិករបស់ខ្លួន។

- វិធីសាស្ត្រកំណត់ត្រាឧប្បត្តិហេតុសំខាន់ៗ គឺជាវិធីសាស្ត្រដែលអ្នកគ្រប់គ្រងផ្ទាល់កត់ត្រាឧប្បត្តិហេតុសំខាន់ៗទាំងវិជ្ជមាននិងអវិជ្ជមាន (ឧប្បត្តិហេតុសំខាន់ៗ) នៃអាកប្បកិរិយាទាក់ទងនឹងការងាររបស់បុគ្គលិកក្រោមបង្គាប់។ រៀងរាល់ ៦ខែម្តង អ្នកគ្រប់គ្រងផ្ទាល់និងបុគ្គលិកក្រោមបង្គាប់ជួបគ្នាដើម្បីពិភាក្សាពីការអនុវត្តការងាររបស់គេដោយប្រើឧប្បត្តិហេតុសំខាន់ៗនេះជាឧទាហរណ៍។

### ២.២.២- សមិទ្ធកម្មរបស់ក្រុម

ជាប្រភេទសមិទ្ធកម្មដែលបង្ហាញអំពីការបំពេញការងាររបស់ក្រុមនីមួយៗ ដែលបានកំណត់ដោយអង្គភាព។ យោងតាម KATZENBACH និង SMITH (2013:37) សមិទ្ធកម្មរបស់ក្រុមរួមមានទាំងលទ្ធផលបុគ្គល និងអ្វីដែលយើងហៅ "ផលិតផលការងាររួម"។ ផលិតផលការងាររួម គឺជាការងារដែលសមាជិកពីរនាក់ ឬច្រើននាក់ធ្វើជាមួយគ្នា ដូចជាការសម្ភាសន៍ ការស្ទង់មតិ ឬពិសោធន៍។ ទោះបីជាយ៉ាងណា វាគឺជាផលិតផលការងារសមូហភាព ឆ្លុះបញ្ចាំងពីការរួមវិភាគទានរបស់សមាជិកក្រុម។ ក្រុមការងារមានលក្ខណៈទូទៅនិងមានប្រសិទ្ធភាពនៅក្នុងអង្គភាពធំៗ ដែលគណនេយ្យភាពរបស់បុគ្គលម្នាក់ៗមានសារៈសំខាន់បំផុត។ ក្រុមការងារដែលល្អបំផុតរួមគ្នាចែករំលែកព័ត៌មាន ទស្សនវិស័យ និងការយល់ដឹង ធ្វើការសម្រេចចិត្តដែលជួយសមាជិកម្នាក់ៗ ឱ្យធ្វើការងាររបស់ខ្លួនកាន់តែប្រសើរ និងដើម្បីពង្រឹងស្តង់ដារអនុវត្តការងាររបស់បុគ្គលម្នាក់ៗ។

បើតាម KATZENBACH និងSMITH (2013:40-41) ដដែលនេះបានលើកឡើងថា ដើម្បីកសាងសមិទ្ធកម្មរបស់ក្រុម យើងគួរតែអនុវត្តតាមវិធីសាស្ត្រដូចខាងក្រោម៖

**១-បង្កើតភាពបន្ទាន់ដែលទាមទារឱ្យមានស្តង់ដារ និងទិសដៅនៃការអនុវត្តការងារ៖** សមាជិកក្រុមទាំងអស់ត្រូវជឿជាក់ថា ក្រុមមានគោលបំណងបន្ទាន់និងមានគោលបំណងដែលមានតម្លៃ ហើយពួកគេចង់ដឹងថាតើការរំពឹងទុកអ្វីខ្លះ។ ជាការពិតណាស់ ហេតុផលកាន់តែបន្ទាន់ និងមានខ្លឹមសារវាទំនងជាថា សមាជិកក្រុមនេះនឹងបំពេញតាមសក្តានុពលនៃការអនុវត្តការងាររបស់ខ្លួន ដូចករណីសេវាកម្មអតិថិជនដែលក្រុមត្រូវបានគេប្រាប់ថាត្រូវការការកែលម្អបន្ថែមទៀត ដើម្បីក្រុមហ៊ុនទាំងមូលអាចរស់រៀនបាន។ សមាជិកក្រុមធ្វើការបានល្អបំផុត នៅក្នុងបរិបទគួរឱ្យទាក់ទាញអារម្មណ៍។ នេះហើយជាមូលហេតុដែលក្រុមហ៊ុនមានក្រមសីលធម៌ក្នុងការអនុវត្តការងារខ្លាំង តែងតែបង្កើតក្រុមការងាររបស់ខ្លួនរួចជាស្រេច។

**២- ជ្រើសរើសសមាជិកក្រុមដែលមានជំនាញ និងសក្តានុពលជំនាញ តែមិនមែនបុគ្គលិកលក្ខណៈទេ៖** គ្មានក្រុមមួយណាទទួលបានជោគជ័យដោយគ្មានជំនាញទាំងអស់ដែលត្រូវការ ដើម្បីបំពេញគោលបំណង និងគោលដៅនៃការអនុវត្តការងារនោះទេ។ ប៉ុន្តែក្រុមភាគច្រើនគិតអំពីជំនាញដែលពួកគេនឹងត្រូវការបន្ទាប់ពីក្រុមត្រូវបានបង្កើតឡើង។ អ្នកគ្រប់គ្រងដែលឆ្លាតវៃនឹងជ្រើសរើសមនុស្សសម្រាប់ជំនាញដែលមានស្រាប់ និងសក្តានុពលរបស់ពួកគេដើម្បីកែលម្អជំនាញដែលមានស្រាប់និងរៀនជំនាញថ្មីៗ។

**៣- ជ្រើសយកចិត្តទុកដាក់ ជាពិសេសចំពោះការប្រជុំនិងសកម្មភាពដំបូង៖** ចំណាប់អារម្មណ៍ដំបូងតែងតែមានអត្ថន័យច្រើន។ នៅពេលក្រុមមានសក្តានុពលប្រមូលផ្តុំដំបូង មនុស្សគ្រប់គ្នាតាមដានសញ្ញាដែលផ្តល់ដោយអ្នកដទៃ ដើម្បីបញ្ជាក់ផ្អាកឬបញ្ចប់ការសន្មតនិងកង្វល់នានា។ ពួកគេយកចិត្តទុកដាក់ជាពិសេសចំពោះអ្នកដែលមានអំណាច៖ ប្រធានក្រុម និងនាយកប្រតិបត្តិណាមួយ ដែលបានបង្កើតក្រុមឡើង គ្រប់គ្រងឬមានឥទ្ធិពលលើក្រុម។ ហើយជានិច្ចជាកាល អ្វីដែលមេដឹកនាំធ្វើគឺសំខាន់

ជាងអ្វីដែលពួកគេនិយាយ។ ឧទាហរណ៍៖ ប្រសិនបើនាយកប្រតិបត្តិចាកចេញពីក្រុម ដើម្បីចាប់ផ្តើមធ្វើការហៅទូរសព្ទ ១០(ដប់)នាទីបន្ទាប់ពីការប្រជុំបានចាប់ផ្តើម ហើយគាត់មិនត្រឡប់មកប្រជុំវិញទេ សមាជិកក្រុមនឹងទទួលបានសារនៃទង្វើរបស់មេដឹកនាំបែបនេះ។

**៤- កំណត់វិធានច្បាស់លាស់នៃអាកប្បកិរិយា៖** ក្រុមដែលមានប្រសិទ្ធិភាពទាំងអស់បង្កើតវិធាននៃការប្រព្រឹត្តនៅដើមដំបូង ដើម្បីជួយឱ្យពួកគេសម្រេចបាននូវគោលបំណង និងគោលដៅនៃការអនុវត្តការងារ។ វិធានដំបូងដែលសំខាន់បំផុតទាក់ទងនឹងការចូលរួម ឧទាហរណ៍៖ (មិនមានការរំខានក្នុងការហៅទូរសព្ទ) ការពិភាក្សា (មិនមានឋានៈពិសេសដែលត្រូវគោរព) ការសម្ងាត់ (តែមួយគត់អ្វីៗដែលត្រូវចាកចេញពីបន្ទប់នេះ គឺជាអ្វីដែលយើងយល់ព្រមគ្នា) វិធីសាស្ត្រវិភាគ (អង្គហេតុមានភាពរួសរាយរាក់ទាក់) ការតម្រង់លើគោលដៅចុងក្រោយ (មនុស្សគ្រប់គ្នាទទួលបានការងារធ្វើហើយធ្វើវា) ការប្រឈមមុខដាក់គ្នា(មិនចង្អុលម្រាមដៃដាក់គ្នា) និងជាញឹកញាប់ការចូលរួមវិភាគទានសំខាន់បំផុត (មនុស្សគ្រប់គ្នាខិតខំធ្វើការងារយ៉ាងពិតប្រាកដ)។

**៥- កំណត់ និងចាប់យកភារកិច្ចនិងគោលដៅដែលផ្តោតលើការអនុវត្តភ្លាមៗ៖** ក្រុមដែលមានប្រសិទ្ធិភាពបំផុត តាមដានការរីកចម្រើនរបស់ពួកគេចំពោះព្រឹត្តិការណ៍សំខាន់ៗនៃការអនុវត្តការងារ។ ព្រឹត្តិការណ៍បែបនេះអាចត្រូវបានកំណត់ នៅក្នុងចលនាដោយបង្កើតភ្លាមៗគោលដៅប្រកួតប្រជែងមួយចំនួនដែលអាចសម្រេចបានដំណាក់កាលដំបូង មិនមានក្រុមណាមួយពិតប្រាកដដែលគ្មានលទ្ធផលនៃការអនុវត្តការងារនោះទេ។

**៦-ដាក់បញ្ហាមកឱ្យក្រុមជាទៀងទាត់ជាមួយនឹងអង្គហេតុនិងព័ត៌មានថ្មីៗ៖** ព័ត៌មានថ្មីធ្វើឱ្យក្រុមធ្វើការកំណត់ និងបង្កើនការយល់ដឹងរបស់ខ្លួនបន្ថែមអំពីបញ្ហាប្រឈមនៃការអនុវត្តការងារ។ ដោយហេតុនេះ វាជួយឱ្យក្រុមមានគោលបំណងរួមកំណត់គោលដៅច្បាស់លាស់ និងកែលម្អវិធីសាស្ត្ររួម។

**៧- ចំណាយពេលច្រើនជាមួយគ្នា៖** គំនិតជាទូទៅប្រាប់យើងថា សមាជិកក្រុមត្រូវតែចំណាយពេលច្រើនជាមួយគ្នា រៀបចំផែនការនិងមិនទាន់កំណត់ពេលវេលា ជាពិសេសនៅដើមដំបូង។ ជាការពិតការយល់ដឹងប្រកបដោយការច្នៃប្រឌិតក៏ដូចជាការផ្សារភ្ជាប់ផ្ទាល់ខ្លួន តម្រូវឱ្យមានការប្រាស្រ័យទាក់ទង និងទំនាក់ទំនងធម្មតាដូចជា ការវិភាគសៀវភៅបញ្ជី និងសម្ភាសន៍អតិថិជន។ នាយកប្រតិបត្តិនិងអ្នកគ្រប់គ្រងរវល់ពេក ជាញឹកញាប់មានចេតនាបង្រួមអប្បបរមាពេលវេលាដែលពួកគេចំណាយពេលជាមួយគ្នា។ ក្រុមជោគជ័យដែលយើងបានសង្កេតឃើញទាំងអស់បានផ្តល់ពេលវេលាដល់ពួកគេ ដើម្បីរៀនធ្វើជាក្រុម។ នាពេលបច្ចុប្បន្នមិនចាំបាច់ចំណាយពេលជាមួយគ្នាទល់មុខទេ សារអេឡិចត្រូនិក និងពេលវេលាទូរសព្ទក៏អាចរាប់បានដែរ ដូចជាពេលវេលាដែលចំណាយជាមួយគ្នា។

### ២.២.៣- សមិទ្ធកម្មរបស់អង្គភាព

ជាប្រភេទសមិទ្ធកម្មដែលបង្ហាញអំពីការបំពេញការងាររបស់អង្គភាពមួយ ដើម្បីសម្រេចនូវបេសកកម្ម និងទស្សនវិស័យរបស់ខ្លួនដែលបានកំណត់។ ដើម្បីវាស់វែងសមិទ្ធកម្មរបស់អង្គភាព តាម Alexander Schwandt (2009:132-138) យើងអាចប្រើប្រាស់វិធីសាស្ត្រដូចខាងក្រោម៖

## ១- ការវាស់វែងបែបបុគ្គលនិយម

ការវាស់វែងបែបបុគ្គលនិយមត្រូវបានពិភាក្សាយ៉ាងទូលំទូលាយ នៅក្នុងអក្សរសិល្ប៍បច្ចុប្បន្នមិនយ៉ាងហោចណាស់ដោយសារតែបញ្ហាដែលបុគ្គលិកបង្កឡើង។ ជាពិសេស ភាពលម្អៀងនៃការយល់ដឹងអាចមានឥទ្ធិពលលើការវាស់វែងដែលមានជាអាទិ៍។ អ្នកចូលរួមមានទំនោរមើលខ្លួនឯង ក្នុងភាពវិជ្ជមានពេក ហើយនឹងបង្កើតលក្ខណៈវិនិច្ឆ័យខាងក្រៅ ដើម្បីផ្លូវផ្តងកម្លាំងរបស់ពួកគេ។ នៅឆ្នាំ១៩៨០ CHAKRAVARTHY បានពិភាក្សារួចមកហើយអំពីការប្រើប្រាស់វិធានការណ៍សម្រាប់វាស់វែងលទ្ធផលជាយុទ្ធសាស្ត្រ។ ក្នុងឆ្នាំបន្តបន្ទាប់ការសិក្សាជាច្រើនដែលមានលក្ខណៈទូលំទូលាយនៃគំនិតប្រើវិធីសាស្ត្រវាស់វែងបែបបុគ្គលនិយម។ ពួកគេរាប់ពីធាតុតែមួយដើម្បីវាយតម្លៃការអនុវត្តការងារជាទូទៅដោយ DESS / ROBINSON ដល់ធាតុបួនឬច្រើនបញ្ចូលគ្នា ដើម្បីវាយតម្លៃពីទិដ្ឋភាពផ្សេងៗគ្នានៃការអនុវត្តការងាររបស់អង្គការដោយ DELANEY / HUSELID ប្រើវិធីសាស្ត្រវាស់វែងបែបបុគ្គលនិយម។

## ២- ការវាស់វែងបែបកម្មវត្ថុនិយម

ការវាស់វែងបែបកម្មវត្ថុនិយមត្រូវបានប្រើជាទូទៅ ដើម្បីវាយតម្លៃការអនុវត្តរបស់អង្គភាពទាំងមូល។ ជាទូទៅវាអាចធ្វើទៅបាន ដើម្បីបែងចែកភាពខុសគ្នារវាងក្រុមពីរនៃការវាស់វែងបែបកម្មវត្ថុនិយម គឺវាស់វែងគណនេយ្យ និងវាស់វែងទីផ្សារហិរញ្ញវត្ថុ។ ទោះបីវាមានគុណវិបត្តិមួយចំនួនក៏ដោយវាស់វែងបង្ហាញថាសមស្របបំផុតសម្រាប់ការសិក្សា។ ផ្នែកខាងក្រោមនឹងផ្តល់នូវការពិភាក្សាអំពីគណនេយ្យផ្អែកលើទីផ្សារហិរញ្ញវត្ថុនិងការវាស់វែងចម្រុះគ្នាសម្រាប់វាយតម្លៃសមិទ្ធកម្មរបស់អង្គភាព។

**២.១- ការវាស់វែងផ្អែកលើគណនេយ្យ៖** គំនិតនៃការអនុវត្តការងារនៅតែត្រូវបានគ្រប់គ្រងដោយគណនេយ្យដោយមាន ៧៤% នៃការសិក្សាជាក់ស្តែងទាំងអស់ដោយប្រើការវាស់វែងនេះដើម្បីវាយតម្លៃការអនុវត្តការងារ។ ហេតុផលសម្រាប់បញ្ហានេះដំបូងឡើយសុពលភាពនៃវិធានការណ៍គណនេយ្យនៃការអនុវត្តដែលត្រូវបានផ្តល់ឱ្យដោយការពិតដែលថា ពួកគេត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដោយក្រុមហ៊ុនដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងសកម្មភាពផ្ទាល់ខ្លួនរបស់ពួកគេ។ ទីពីរទិន្នន័យអាចរកបានដោយសារការទាមទាររបស់រដ្ឋាភិបាល ក៏ដូចជាម្ចាស់ភាគហ៊ុន តម្រូវការព័ត៌មានដែលទាមទារឱ្យមានការបោះពុម្ពផ្សាយជាប្រចាំអំពីទិន្នន័យហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

**២.២- ការវាស់វែងទីផ្សារហិរញ្ញវត្ថុ៖** ភាពជោគជ័យជាក់ស្តែងនៃការវាស់វែងទីផ្សារហិរញ្ញវត្ថុបញ្ជាក់ថា មតិរបស់មនុស្សដែលប្រាប់ពីតម្លៃទីផ្សារគឺអាចយកឈ្នះលើការបំភ្លៃជាច្រើន ដែលការវាស់វែងកិច្ចការគណនេយ្យត្រូវប្រឈមមុខ។ ផ្ទុយពីការវាស់ផ្អែកលើគណនេយ្យ ការវាស់វែងទីផ្សារហិរញ្ញវត្ថុកំពុងឆ្ពោះទៅមុខ។ ដូច្នេះ ពួកគេតំណាងឱ្យទិដ្ឋភាពសំខាន់បំផុតនៃការស្ថាបនាពហុវិស័យនៃការអនុវត្តការងាររបស់អង្គភាព។ លើសពីនេះទៅទៀត ការវាស់វែងទីផ្សារហិរញ្ញវត្ថុ គឺសមស្របសម្រាប់វាស់វែងការអនុវត្តរបស់អង្គភាព ចាប់តាំងពីពួកគេអនុញ្ញាតឱ្យមានគណនេយ្យភាពនៃទ្រព្យអរូបីដែលមានប្រសិទ្ធភាពជាងទិន្នន័យគណនេយ្យ។ អត្ថប្រយោជន៍ធំទីពីរផ្ទុយពីការវាស់វែងផ្អែកលើគណនេយ្យគឺថាពួកគេមិនងាយគ្រប់គ្រងបានទេ ហើយពួកគេមិនងាយទទួលឥទ្ធិពលពីការផ្លាស់ប្តូរគោលនយោបាយ

គណនេយ្យ ឬផលប៉ះពាល់ពេលវេលា។ ដែនកំណត់សំខាន់មួយទាក់ទងនឹងការវាស់វែងទីផ្សារហិរញ្ញវត្ថុ គឺថាពួកគេអាចប្រើបានតែលើកម្រិតក្រុមហ៊ុនប៉ុណ្ណោះ។

ការសិក្សានេះ ផ្តោតលើការអនុវត្តជារួមរបស់ក្រុមហ៊ុន ការវាស់វែងទីផ្សារហិរញ្ញវត្ថុអាចអនុវត្តបាន។ ទោះយ៉ាងណាក៏ដោយវាជាការសំខាន់ដែលត្រូវចងចាំថា ដោយសារតែជួរផ្សារភាគហ៊ុនធំទូលាយ ការវាស់វែងទីផ្សារហិរញ្ញវត្ថុច្រើន តែឆ្លុះបញ្ចាំងពីឥទ្ធិពលបរិស្ថាន ដែលមិនពាក់ព័ន្ធការអនុវត្តស្ថាប័នជាក់លាក់នោះទេ។ ការស្រាវជ្រាវផ្នែកហិរញ្ញវត្ថុបានបង្ហាញថា ចំណែកនោះការផ្លាស់ប្តូរតម្លៃភាគច្រើនបណ្តាលមកពីការប្រែប្រួលទីផ្សារសន្ទុះ និងការផ្គត់ផ្គង់ឥរិយាបទ។

ការវាស់វែងទីផ្សារហិរញ្ញវត្ថុគឺសមស្រប ដើម្បីវាយតម្លៃវិមាត្រទាក់ទងនឹងម្ចាស់ភាគហ៊ុនការសម្តែងរបស់អង្គភាព។ ដូច្នេះសូចនាករ "ចំណូលក្នុងមួយភាគហ៊ុន" ត្រូវបានប្រើដោយវាគឺជាវិធានការសមស្របដើម្បីវាយតម្លៃក្រុមហ៊ុនទាក់ទងនឹងចំនួនភាគហ៊ុនដែលបានចេញ។ ដូចនេះ សូចនាករត្រូវបានគណនាជាមធ្យមរយៈពេល៥(ប្រាំ)ឆ្នាំ ដើម្បីលុបចោលផលប៉ះពាល់រយៈពេលខ្លីម្តងទៀត។ លើសពីនេះទៀតតម្លៃទីផ្សារចង្អុលបង្ហាញត្រូវបានអនុវត្ត ដើម្បីវាយតម្លៃប្រសិទ្ធភាពរបស់អង្គភាពផងដែរពីទស្សនវិស័យទីផ្សារ។

**២.៣- ការវាស់វែងដោយដាក់ចម្រុះគ្នារវាងទីផ្សារនិងគណនេយ្យ៖** ការកំណត់ទាំងការវាស់វែងគណនេយ្យនិងការវាស់វែងផ្អែកលើទីផ្សារហិរញ្ញវត្ថុបានធ្វើឱ្យមានការអភិវឌ្ឍទីផ្សារចម្រុះ និងការវាស់វែងគណនេយ្យ។ ជាលទ្ធផលវិធីសាស្ត្រទាំងនេះអាចត្រូវបានប្រើសម្រាប់ការប៉ាន់ស្មាននៃការអនុវត្តការងារនាពេលអនាគត។ ពួកវាមិនសូវមានលក្ខណៈជាប្រវត្តិទេ អាចត្រូវបានកែតម្រូវសម្រាប់ហានិភ័យអាចរកបាននិងអនុវត្តចំពោះអង្គភាពអាជីវកម្ម និងកម្រិតមុខងារហើយអាចរកបានកាន់តែងាយស្រួល។

### ២.២.៤- សមិទ្ធកម្មរបស់កម្មវិធី

ជាប្រភេទសមិទ្ធកម្មដែលបង្ហាញអំពីបណ្តាសកម្មភាពនៅក្នុងកម្មវិធីត្រូវបានអនុវត្ត ហើយសម្រេចទៅតាមគោលបំណងកម្មវិធីដែលបានកំណត់។ យោងតាម Kevin M. Callahan (2018:13) មានវិធីសាស្ត្របីយ៉ាងដើម្បីវាស់វែងសមិទ្ធកម្មរបស់កម្មវិធីគឺ៖

ដំណាក់ទី១៖ ចាប់ផ្តើមដោយបង្កើតបញ្ជីសេវាកម្មកម្មវិធី ឬដំណើរការដែលអ្នកចង់យល់កាន់តែច្បាស់។ បន្ទាប់មកសម្រាប់សេវាកម្ម ឬដំណើរការនីមួយៗនៅក្នុងបញ្ជីរបស់អ្នកបង្កើតការវាស់វែងមួយដែលនឹងប្រាប់អ្នកថាវាត្រូវបានសម្រេចបានប៉ុន្មាន (ឧទាហរណ៍ កម្មវិធីរបស់អ្នកបានផ្តល់ការបណ្តុះបណ្តាល វង្វាស់ថាតើការបណ្តុះបណ្តាលបានផ្តល់ចំនួនប៉ុន្មាន អាចជាចំនួនមនុស្សដែលបានបណ្តុះបណ្តាល)។

ដំណាក់ទី២៖ បន្ទាប់មកបង្កើតការវាស់វែងមួយដែលនឹងប្រាប់អ្នកថាតើសេវាកម្ម ឬដំណើរការនីមួយៗនៅក្នុងបញ្ជីរបស់អ្នកត្រូវបានសម្រេចយ៉ាងម៉េច (ប្រើការបណ្តុះបណ្តាល ជាឧទាហរណ៍ម្តងទៀត វង្វាស់ថា តើកម្មវិធីរបស់អ្នកបានផ្តល់ការបណ្តុះបណ្តាលយ៉ាងម៉េច អាចជាភាគរយនៃសិក្ខាកាមដែលពេញចិត្តយ៉ាងខ្លាំងជាមួយការបណ្តុះបណ្តាល ឬភាគរយនៃសិក្ខាកាមដែលបានបង្កើនចំណេះដឹង

ឬជំនាញរបស់ពួកគេនៅក្នុងផ្នែកដែលកម្មវិធីបានបណ្តុះបណ្តាល ពួកគេជាជម្រើសពីព្រោះប្រសិទ្ធភាពកម្មវិធីក៏ជារង្វាស់នៃការអនុវត្តន៍កម្មវិធីបានល្អដែរ អ្នកអាចវាស់តម្លៃក្នុងមួយវគ្គសម្រាប់គ្រូបណ្តុះបណ្តាល។ អត្រា ឬពេលវេលារង់ចាំរហូតដល់ការបណ្តុះបណ្តាលចាប់ផ្តើម)។

ដំណាក់ទី៣៖ ហើយចុងក្រោយបង្កើតការវាស់វែងមួយដែលនឹងប្រាប់អ្នកថា តើមនុស្សដែលបានចូលរួមក្នុងសេវាកម្មឬដំណើរការនេះប្រសើរយ៉ាងណានៅពេលក្រោយមក។

## ៣- សេចក្តីសន្និដ្ឋាន

ពាក្យថា សមិទ្ធកម្មក្នុងបរិបទនៃព្រះរាជាណាចក្រកម្ពុជាឃើញមានប្រើពាក្យនេះដំបូងគេនៅក្នុងគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី តាមរយៈប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[៩] មានប្រើពាក្យថា "របាយការណ៍លទ្ធផល/សមិទ្ធកម្ម" ដោយពាក្យនេះមានន័យប្រហែលនឹងពាក្យលទ្ធផលដែរ។ របាយការណ៍សមិទ្ធកម្មនេះ សម្រាប់តាមដានការអនុវត្តកម្មវិធី/អនុកម្មវិធី/ចង្កោមសកម្មភាពប្រចាំឆ្នាំឆមាសឬប្រចាំឆ្នាំរបស់អង្គភាពអនុវត្តថវិកាកម្មវិធី។ ដោយបានបញ្ជាក់ច្បាស់ថា "របាយការណ៍សមិទ្ធកម្មគឺឆ្លុះបញ្ចាំងអំពីការវាស់វែងលទ្ធផល និងវាយតម្លៃអំពីវឌ្ឍនភាពនៃការអនុវត្តចង្កោមសកម្មភាពអនុកម្មវិធី និងកម្មវិធីដើម្បីឈានឆ្ពោះទៅសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួងស្ថាប័ន។ ព័ត៌មាននេះអាចជាបច្ច័យនាំទៅដល់ការសម្រេចចិត្ត ដើម្បីផ្លាស់ប្តូរយុទ្ធសាស្ត្រកម្មវិធីកែសម្រួលទំហំថវិកាឬផ្លាស់ប្តូររបៀបគ្រប់គ្រងកម្មវិធី។ ក្នុងន័យនេះ ដើម្បីធានាបានគណនេយ្យភាព និងការទទួលខុសត្រូវចំពោះលទ្ធផលនៃចំណាយសាធារណៈ ពិសេសដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តថវិកាក្រសួងស្ថាប័ន និងមន្ទីរជំនាញរាជធានីខេត្តទាំងអស់ត្រូវតាមដានការអនុវត្តថវិការបស់ខ្លួនជាប្រចាំ និងធ្វើរបាយការណ៍អំពីវឌ្ឍនភាពលើសូចនាករលទ្ធផលក្នុងឆ្នាំជាចាំបាច់ និងសូចនាករលទ្ធផលចុងក្រោយតាមដែលអាចធ្វើបាន ដោយអនុលោមទៅតាមទម្រង់តារាងរួម ដែលបានពណ៌នាក្នុងតារាងឧបសម្ពន្ធទី២៤ និងទី២៥។ របាយការណ៍សមិទ្ធកម្មទាំងអស់ត្រូវធ្វើឡើង និងផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ) តាមការិយបរិច្ឆេទកំណត់។ របាយការណ៍សមិទ្ធកម្មប្រចាំឆមាសត្រូវផ្ញើមកយ៉ាងយូរបំផុត ១៥ថ្ងៃ បន្ទាប់ពីបញ្ចប់នៃឆមាស រីឯរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ ខែមករា ឆ្នាំបន្ទាប់" [១០]។ របាយការណ៍សមិទ្ធកម្មនេះ សម្រាប់តាមដានការអនុវត្តកម្មវិធី/អនុកម្មវិធី/ចង្កោមសកម្មភាពប្រចាំឆ្នាំឆមាស ឬប្រចាំឆ្នាំរបស់អង្គភាពអនុវត្តថវិកាកម្មវិធី។

---

[៩] ប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ***ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*** ទំព័រ ១៦។

[១០] -ដ- ទំព័រ ៣៦។

# ការផ្សព្វផ្សាយស្នាដៃរឿងសាមកុកនៅកម្ពុជា

និស្សិតៈ កៅ ស៊ីវ៉ាញ
ជំនាញៈ អក្សរសិល្ប៍

## សេចក្តីផ្តើម

ក្នុងសម័យបច្ចុប្បន្ននេះ យើងសង្កេតឃើញស្នាដៃអក្សរសាស្ត្រចិនដែលពេញនិយម លេចធ្លោ និងមានប្រជាប្រិយភាពជាងគេក្នុងសង្គមខ្មែរគឺ "រឿងសាមកុក"។ "រឿងសាមកុក" ដែលយើងលើកយកមកសិក្សា គឺជាប្រលោមលោកប្រវត្តិសាស្ត្រដ៏ល្បីមួយនៅលើពិភពលោក ដោយរៀបរាប់តាមរឿងពិតដែលកើតមានឡើងនៅក្នុងប្រទេសចិន នាចុងរជ្ជកាលរាជវង្ស ហាន់ កាលពីប្រមាណជាង ១៧០០ឆ្នាំមកហើយ។

កំណើតរឿងសាមកុកមានប្រវត្តិជារឿងដែលមានការពេញនិយម ពីដំបូងជា "រឿងនិទាន" និងជា"ល្ខោន"។ នៅចុងបញ្ចប់នៅសម័យរាជវង្សថាំងរឿងសាមកុកបានមានភាពពេញនិយមក្នុងលក្ខណៈជាអក្សរសិល្ប៍ប្រជាប្រិយ។ នៅក្នុងរជ្ជកាលសុង រឿងសាមកុកបានមានប្រជាប្រិយភាព តាមរយៈការសម្តែងរបស់សិល្បៈករ។ រីឯរឿងប្រលោមលោកដែលយករឿងសាមកុកធ្វើជាប្រធានបទនោះ ក៏មានជាយូរណាស់មកហើយដែរ ប៉ុន្តែដែលមាននៅសល់ក្នុងពេលបច្ចុប្បន្ននេះគឺជាសៀវភៅ "ប្រវត្តិសាស្ត្រសាមកុក" ដែលត្រូវបានចេញផ្សាយនៅរជ្ជកាលយាន។

សៀវភៅ "ប្រវត្តិសាស្ត្រសាមកុក" មានបីក្បាល ហើយអ្នកនិពន្ធមិនត្រូវបានគេស្គាល់ច្បាស់ទេ។ សៀវភៅនោះបានលើកយកការរីកចម្រើន និងការដួលរលំនៃក្រុមស៊ូហាន់ជាគោលនិយាយរៀបរាប់អំពីប្រវត្តិសាស្ត្រសាមកុក។ សៀវភៅនេះមានការរចនាអក្សរមិនច្បាស់លាស់ ទម្រង់ងាយស្រួល តែខ្វះការពន្យល់ និងការបកស្រាយចាំបាច់ជាច្រើននៅក្នុងនិទានវិធី ប៉ុន្តែយ៉ាងណាវានៅតែជាសៀវភៅដំបូងគេដែលពន្យល់ពីជម្លោះរវាង វុយ ស៊ូ និង អ៊ូ។ សាមកុកបានលេចចេញជារូបរាងច្បាស់លាស់ដំបូងដោយអ្នកនិពន្ធ ឡាគាន់ជុង រវាងឆ្នាំ១៣៣០ ដល់១៤០០ ក្នុងរជ្ជកាលមិញ (១៣១៨ដល់១៦៤៤) ហើយក្រោយមកត្រូវបានលោក ម៉ៅ លន់ និង ម៉ៅ តូនគៀម កែលម្អបន្ថែម (ម៉ៅ លន់ ជាឪពុកជាអ្នកឱ្យយោបល់ ម៉ៅ តូនគៀម ជាអ្នកសរសេរ)។

បន្សាយរឿងសាមកុក នៅក្នុងប្រទេសកម្ពុជាវិញ គឺមិនមែនមានត្រឹមតែរយៈមួយឆ្នាំ ឬពីរឆ្នាំប៉ុណ្ណោះទេ គឺចាំបាច់ត្រូវប្រើរយៈពេលវែង។ អ្វីដែលគួរបញ្ជាក់ផងដែរនោះ គឺការផ្សាយនៃអក្សរសិល្ប៍មកកាន់ទីតាំងមួយបាន លុះត្រាតែវណ្ណកម្មនោះសមស្របតាមផ្នត់គំនិតនៃប្រជាជនក្នុងទីតាំងនោះ ថែមទាំងផ្តល់នូវពុទ្ធិ និងសម្បទានទស្សនៈដ៏ធំធេញផងដែរ។

នៅប្រទេសកម្ពុជា រឿងសាមកុកដ៏ល្បីល្បាញនេះត្រូវបានផ្សព្វផ្សាយចូលមកតាមរយៈមធ្យោបាយចម្បងៗ ដូចជាៈ

- រឿងសាមកុក ផ្សព្វផ្សាយមកក្នុងប្រទេសកម្ពុជា តាមរយៈសៀវភៅ

- រឿងសាមកុក ផ្សព្វផ្សាយមកក្នុងប្រទេសកម្ពុជា តាមរយៈខ្សែភាពយន្ត
- រឿងសាមកុក ផ្សព្វផ្សាយមកក្នុងប្រទេសកម្ពុជា តាមការការតំណាលតគ្នា
- រឿងសាមកុក ផ្សព្វផ្សាយមកក្នុងប្រទេសកម្ពុជា តាមរយៈរឿងល្ខោនហ៊ី
- រឿងសាមកុក ផ្សព្វផ្សាយមកក្នុងប្រទេសកម្ពុជា តាមរយៈល្បែងអ៊ីនធឺណេត

## ១- ការផ្សព្វផ្សាយជាសៀវភៅ

សៀវភៅគឺជាប្រភពនៃចំណេះដឹង ឯអំណានជាតម្រូវការមួយនៃការរស់នៅរបស់យើង។ អំណានអាចនាំយើងឱ្យដើរចេញពីភាពល្ងង់ខ្លៅបាន ព្រមទាំងផ្តល់នូវចំណេះដឹងឥតគណនា ជាបន្តបន្ទាប់ពីមួយថ្ងៃទៅមួយថ្ងៃ។ ដើម្បីជាការពង្រីកនូវវិសាលភាពនៃចំណេះដឹង មានអ្នកភាសាវិទ្យា ទស្សនវិជ្ជាជាច្រើនបានប្រើប្រាស់នូវចំណេះដឹងភាសាដើម្បីបកប្រែ ក៏ដូចជាកែសម្រួលនូវសៀវភៅដែលទាក់ទងនឹងទស្សនៈផ្សេងៗ ដើម្បីបន្ថែមភាពទូលំទូលាយនៃចំណេះដឹង ព្រមទាំងអាចឱ្យគេបានឃើញនិងយល់ដឹងអំពីតថភាពពីខាងក្រៅ។

ដើមដំបូងនៃរឿងសាមកុកនៅកម្ពុជាពឹងផ្អែកលើសៀវភៅក្នុងការផ្សព្វផ្សាយ ពិសេសពឹងផ្អែកលើសៀវភៅរឿងសាមកុក ដែលបកប្រែរៀបរៀងដោយឧកញ៉ាវិបុលរាជសេនា នូ កន ដើម្បីផ្សព្វផ្សាយនិងជះឥទ្ធិពល។ រឿងសាមកុក បកប្រែដោយ នូ កន ចុះក្នុងទស្សនាវដ្តីកម្ពុជសុរិយា ជាដំបូងនៅឆ្នាំ ១៩៤៨ លេខ២។ លោកបានបញ្ជាក់ថា រឿងនេះចែកជាកណ្ឌ ឬភាគមានទាំងអស់ ៧៨កណ្ឌ យើងបានឃើញចុះក្នុងទស្សនាវដ្តីខាងលើនេះតាំងពីដើមកណ្ឌទី១ រហូតដល់ឆ្នាំ១៩៦៩ លេខ៦ ឃើញបានដល់ដើមកណ្ឌទី៧០ តែទស្សនាវដ្តីនេះបានបោះផ្សាយរហូតមកដល់ឆ្នាំ១៩៧៤ យើងឥតបានអានទេ ព្រោះលេខទាំងនេះ(ចាប់ពីលេខ៧ ឆ្នាំ១៩៦៧)រកមិនឃើញមាននៅក្នុងបណ្ណាល័យនាទីក្រុងប៉ារីស៍។

លោក ញ៉ុក ថែម ជានិពន្ធនាយកទស្សនាវដ្តីកម្ពុជសុរិយា បានធ្វើពាក្យបរិយាយដើមនៃរឿងសាមកុក ក្នុងលេខ២ ឆ្នាំ១៩៤៨ ថា "ចំពោះប្រទេសសៀម គេបានប្រែរឿងសាមកុកចេញពីភាសាចិនជាដំបូងកាលពីព.ស.២៣៤៤ ត្រូវនឹងគ.ស.១៨០២ ក្នុងសម័យដែលមិនទាន់មានរោងពុម្ពសម្រាប់បោះពុម្ពផ្សាយសៀវភៅនៅឡើយទេ។ ដល់សម័យកើតរោងពុម្ពសម្រាប់បោះពុម្ពសៀវភៅផ្សេងៗបានហើយ គេក៏បានចាត់ការបោះពុម្ពរឿងសាមកុកនេះផ្សាយជាច្រើនលើកដែរ"។ រឿងសាមកុក ដែលគេចាត់ការបោះពុម្ពលើកក្រោយបង្អស់ក្នុងព.ស.២៤៧០ (គ.ស.១៩២៧) ប្រហែលជាច្បាប់បោះពុម្ពលើកក្រោយនេះហើយ ដែលអ្នកឧកញ៉ាវិបុលរាជសេនា នូ កន ជាអ្នកតំណាងរាស្ត្រ បានប្រែចេញជាខេមរភាសាចប់សព្វគ្រប់ តែគ្មានឱកាសនឹងផ្សាយរឿងនេះតមកជាច្រើនឆ្នាំ។ ក្រោយបំផុត លោកបានយកសំណើប្រែរឿងសាមកុកមកប្រគល់ឱ្យពុទ្ធសាសនបណ្ឌិត្យ ដើម្បីចាត់ការបោះពុម្ពផ្សាយតាមត្រូវការ។ អ្នកតំណាងពុទ្ធសាសនបណ្ឌិត្យ បានពោលថ្លែងអំណរគុណចំពោះអ្នកឧកញ៉ាវិបុលរាជសេនា នូ កន ហើយសូមសរសើរសេចក្តីព្យាយាមដែលបានខិតខំខ្វល់ខ្វាយប្រែរឿងដ៏វែងនេះ ត្រាតែចប់សព្វគ្រប់។ ប៉ុន្តែក្នុងឱកាសពេលនោះ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ មិនអាចចាត់ការបោះពុម្ពផ្សាយជាសៀវភៅ

ដាច់ដោយឡែកទៅបានទើបនាំយករឿងនេះមកចុះផ្សាយក្នុងទំព័រទស្សនាវដ្ដីកម្ពុជសុរិយានេះជាបណ្ដើរៗទៅសិន។[១]

មុនពេលចេញផ្សាយរឿងសាមកុកជាភាសាខ្មែរ អ្នកអានជនជាតិខ្មែរបានចាប់ផ្ដើមយល់ដឹងអំពីរឿងសាមកុក ហើយបានពង្រឹងការទទួលយកនូវប្រវត្តិដ៏ពិតប្រាកដមួយ និងបានផ្ដល់នូវសារប្រយោជន៍ដល់ជនជាតិចិនមួយចំនួនធំដែលបានធ្វើចំណាកស្រុកមកកម្ពុជា ចាប់ពីពាក់កណ្ដាលសតវត្សរ៍ទី១៩ ដល់ដើមសតវត្សរ៍ទី២០ ក្នុងការបង្កើតបានជាសហគមន៍នៃជនជាតិចិន។ ជនជាតិចិនបានធ្វើចំណាកស្រុកមកប្រទេសកម្ពុជាមានប្រវត្តិរាប់ពាន់ឆ្នាំមកហើយ ដែលមានការទាក់ទងតាំងពីរាជវង្សសុងក្នុងប្រទេសចិន និងមានជនអន្តោប្រវេសន៍កាន់តែច្រើនទៀត បន្ទាប់ពីរាជវង្សឈីង។

បន្ទាប់ពីប្រទេសកម្ពុជា បានក្លាយជាប្រទេសក្រោមអាណានិគមបារាំងនៅឆ្នាំ១៨៦៣ អាជ្ញាធរអាណាព្យាបាលបារាំងបានបង្ហាញការស្វាគមន៍ជនជាតិចិនមកកម្ពុជា ដើម្បីដោះស្រាយបញ្ហានៃកម្លាំងពលកម្មមិនគ្រប់គ្រាន់សម្រាប់ចម្ការកៅស៊ូនិងម្រេច ចំនួនជនជាតិចិននៅកម្ពុជាក្រោមបានកើនឡើងយ៉ាងឆាប់រហ័ស នៅឆ្នាំ១៨៩០ ចំនួនសរុបបានកើនឡើងដល់ ១៣ម៉ឺននាក់។

នៅអំឡុងដើមសតវត្សរ៍ទី២០ ដោយសារការភ័យខ្លាចថាជនជាតិចិននៅប្រទេសកម្ពុជាបានគាំទ្រចលនាបដិវត្តដឹកនាំដោយលោក ស៊ុន ចុងសាន អាជ្ញាធរអាណានិគមបារាំងបានចាប់ផ្ដើមកំណត់ការឆ្លងដែនរបស់ប្រជាជនចិន ហើយចំនួនអណិកជនចិនដែលធ្វើអន្តោប្រវេសន៍មកប្រទេសកម្ពុជាបានធ្លាក់ចុះយ៉ាងខ្លាំង។

ក្នុងអំឡុងសង្គ្រាមលោកលើកទី២ ការគ្រប់គ្រងអាណាព្យាបាលបារាំងត្រូវបានប្រជាជនកម្ពុជាធ្វើការប្រឆាំងយ៉ាងខ្លាំង ចំនួនអណិកជនចិនដែលធ្វើអន្តោប្រវេសន៍មកប្រទេសកម្ពុជាបានកើនឡើងម្ដងទៀត។ បន្ទាប់ពីការបង្កើតប្រទេសចិនថ្មីក្នុងឆ្នាំ១៩៤៩ ចំនួនអណិកជនចិនដែលធ្វើអន្តោប្រវេសន៍មកប្រទេសកម្ពុជាបានធ្លាក់ចុះម្ដងទៀត។

ឯកសារស្ថិតិបានបង្ហាញថា នៅពាក់កណ្ដាលសតវត្សរ៍ទី២០ ឆ្នាំ១៩៦០ នៅក្នុងចំណោមអណិកជនចិននៅប្រទេសកម្ពុជា កូនចៅចិនជំនាន់ក្រោយដែលកើតនៅកម្ពុជាមានចំនួនច្រើនជាងពាក់កណ្ដាល។ ដូច្នេះសង្គមចិនដ៏ធំ និងមានស្ថិរភាពមួយត្រូវបានបង្កើតឡើងនៅកម្ពុជា លើសពីនេះទៅទៀត មនុស្សភាគច្រើននៅក្នុងសង្គមចិននេះនិយាយភាសាខ្មែរ និងចេះនិយាយគ្រាមភាសាចិន ពោលគឺរៀនវប្បធម៌ខ្មែរ និងថែរក្សាប្រពៃណីចិនរបស់ពួកគេ។

ដូច្នេះហើយ រឿងសាមកុកដែលរីករាលដាលនៅក្នុងប្រទេសកម្ពុជាក៏មានសង្គមមូលដ្ឋានមួយ ហើយក៏មានអ្នកទទួលយកយ៉ាងពិតប្រាកដមួយ នេះគឺជាតម្រូវការសំខាន់មួយសម្រាប់ការផ្សព្វផ្សាយរឿងសាមកុកនៅកម្ពុជា។

---

[១] យើង ហុកឌី "*ស្នាដៃអក្សរសិល្ប៍ចិនលើកម្ពុជានាសតវត្សទី១៩និងទី២០*" គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ ២០០៨ ទំព័រ២២។

ទាក់ទងនឹងសំណួរថា តើពេលណាដែលរឿងសាមកុក ត្រូវបានណែនាំចូលមកដល់ប្រទេសកម្ពុជា ថ្វីត្បិតតែមិនទាន់មានពេលវេលាជាក់លាក់ក៏ដោយ ប៉ុន្តែឆ្លងកាត់តាមការក្តោបក្តាប់ឯកសារដែលមាននាពេលបច្ចុប្បន្ន នៅដើមសតវត្សរ៍ទី២០ ក៏មានរឿងសាមកុកជាភាសាចិនបានផ្សព្វផ្សាយចូលមកដល់កម្ពុជា ប៉ុន្តែនិយាយសរុបទៅរឿងសាមកុកជាភាសាចិនមិនត្រូវបានផ្សព្វផ្សាយនៅក្នុងប្រទេសកម្ពុជាទេ ក៏មានកង្វះឥទ្ធិពលផងដែរ ហើយការរីករាលដាលនៅក្នុងប្រទេសកម្ពុជាត្រូវបានកំណត់ជាចម្បងចំពោះជនជាតិចិនមួយចំនួនតូច។

រហូតដល់ឆ្នាំ១៩៣៦ មានសមាជិកនៃក្រុមបញ្ញាជនថ្មីក្នុងរដ្ឋបាលបានបង្កើតកាសែតនគរវត្តជាភាសាខ្មែរ ក្រោមការដឹកនាំនៃខ្មែរកម្ពុជាក្រោមម្នាក់នាម សឺង ង៉ុកថាញ់ ហើយនៅក្នុងទំព័រនៃកាសែតនេះចុះផ្សាយរឿងចិនសាមកុក។ រឿងនេះមិនប្រាកដជាបកប្រែសម្រួលពីអត្ថបទចិនសុទ្ធសាធនោះទេ គឺប្រហែលជាប្រែសម្រួលពីអត្ថបទជាភាសាថៃ ឬពីភាសាវៀតណាម។ ប៉ុន្តែទោះយ៉ាងណាក៏ដោយការបកប្រែរឿងសាមកុកពីរឿងដើម ឬក៏ជាភាសាថៃ ភាសាវៀតណាម វានៅតែជាការបកប្រែដំបូងរឿងសាមកុកជាភាសាខ្មែរ បន្ទាប់មកអ្នកប្រាជ្ញនៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បានផ្តើមផ្តល់ដល់អ្នកអានខ្មែរនូវរឿងចិនសាមកុក ដែលបកប្រែជាភាសាខ្មែរដោយឧកញ៉ាវិបុលរាជសេនា នូ កន ចប់នៅឆ្នាំ១៩៣៣ ប្រែចេញពីច្បាប់ដើមជាភាសាថៃដែលបានបោះពុម្ពនាឆ្នាំ១៩២៧។

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យបានយករឿងសាមកុកមកចុះផ្សាយជាបន្តបន្ទាប់ នៅក្នុងទំព័រទស្សនាវដ្តីកម្ពុជសុរិយា ជាដំបូងនៅឆ្នាំ១៩៤៨ លេខ២។ រឿងសាមកុកត្រូវបានបកប្រែជាលើកដំបូងនៅក្នុងប្រទេសកម្ពុជា ហើយត្រូវបានបោះពុម្ពផ្សាយក្នុងអំឡុងពេលនេះប្រលោមលោកដែលសរសេរជាពាក្យរាយ នៅក្នុងរយៈពេលដ៏សំខាន់នៃការលេចចេញមកក្នុងរយៈពេល ៧០ឆ្នាំបន្ទាប់ ស្នាដៃរឿងសាមកុកបានរីកសាយទៅជាបណ្តើរៗ ទទួលបានការចូលចិត្តនិងកោតសរសើរយ៉ាងខ្លាំងពីប្រជាជនកម្ពុជាទទួលបានការវាយតម្លៃយ៉ាងខ្ពស់ ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញការអភិវឌ្ឍអក្សរសាស្ត្រខ្មែរទំនើបលើកកម្ពស់ប្រទេសកម្ពុជាជាមួយនឹងស្នាដៃអក្សរសាស្ត្រផ្សេងទៀត មកពីបារាំង និងថៃ។

ការកើតឡើងនូវប្រលោមលោកដែលសរសេរជាពាក្យរាយ បានជំរុញបន្ថែមទៀតប្រលោមលោក ការបង្កើតនិងការអភិវឌ្ឍពិភពអក្សរសាស្ត្រនៅកម្ពុជា បានបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់ការអភិវឌ្ឍអក្សរសាស្ត្រខ្មែរទំនើបបានចាក់គ្រឹះយ៉ាងល្អ។ មិនត្រឹមតែប៉ុណ្ណោះ បន្ទាប់ពីមានការលេចចេញនូវរឿងសាមកុកជាភាសាខ្មែររួមជាមួយនឹងការអភិវឌ្ឍឧស្សាហកម្មបោះពុម្ព និងបោះពុម្ពផ្សាយនៅកម្ពុជា អត្ថបទនៃរឿងសាមកុកបានចាប់ផ្តើមរីករាលដាលបន្តិចម្តងៗនៅកម្ពុជា។ ជាពិសេសជាមួយនឹងស្ថិរភាពនៃស្ថានការណ៍នយោបាយនៅកម្ពុជា ទំនាក់ទំនងមិត្តភាពកម្ពុជា-ចិន នាពេលបច្ចុប្បន្នត្រូវបានពង្រឹងជាបន្តបន្ទាប់ សៀវភៅរឿងសាមកុកមានភាពពេញនិយមពាសពេញប្រទេស ហើយមានសៀវភៅជាច្រើនប្រភេទដាក់លក់នៅតូបលក់សៀវភៅធំៗទាំងអស់ ហើយខ្លះទៀតនៅតែត្រូវបានចុះបញ្ជី។ ចំនួននៃការលក់គឺគួរឱ្យកត់សម្គាល់។

## ២- ខ្សែភាពយន្តរឿងសាមកុកនៅកម្ពុជា

នៅដើមសតវត្សរ៍ទី២០ ប្រទេសកម្ពុជាបានចាប់ផ្ដើមចាក់បញ្ចាំងខ្សែភាពយន្តនានា ពីប្រទេសផ្សេងៗរួមទាំងប្រទេសចិនផងដែរ ប៉ុន្តែក្នុងអំឡុងពេលនោះដោយសារបច្ចេកទេសក្នុងការចាក់ផ្សាយខ្សែភាពយន្ត និងស្ថានភាពក្នុងប្រទេសកម្ពុជា ថ្វីត្បិតតែខ្សែភាពយន្តប្រទេសចិនត្រូវបានចាក់ផ្សាយនៅកម្ពុជាក៏ពិតមែន ប៉ុន្តែចំនួនមិនច្រើនទេ។

បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ សេដ្ឋកិច្ចកម្ពុជាបានចាប់ផ្ដើមងើបឡើងវិញយ៉ាងឆាប់រហ័ស ហើយទូរទស្សន៍បានរីករាលដាលក្នុងចំណោមគ្រួសាររាប់សែនខ្នងនៅក្នុងប្រទេសកម្ពុជា។ បន្ថែមលើនេះ បន្ទាប់ពីទូរទស្សន៍ជាតិកម្ពុជាបានចាប់ផ្ដើមឡើងវិញនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្ថានីយទូរទស្សន៍ NHK ជប៉ុន ស្ថានីយ៍ទូរទស្សន៍ CCTV នៅប្រទេសចិន និងស្ថានីយ៍ទូរទស្សន៍ជាតិនៅក្នុងបណ្ដាប្រទេសអាស៊ានបានសហការគ្នា ហើយឧស្សាហកម្មទូរទស្សន៍នៅក្នុងប្រទេសកម្ពុជាបានរីកចម្រើនយ៉ាងឆាប់រហ័ស។ អំឡុងពេលនេះប្រទេសកម្ពុជាបានចាប់ផ្ដើមនាំចូលខ្សែភាពយន្តចិនជាច្រើន ដូចជាខ្សែភាពយន្តយុងហ្វូ រឿងអ្នកក្លាហាន រឿងប្រវត្តិសាស្ត្រ ខ្សែភាពយន្តកំប្លែង ខ្សែភាពយន្តខ្មោចជាដើម។ ក្នុងនោះ ខ្សែភាពយន្តរបស់ចូវស៊ីងឈើ និងខ្សែភាពយន្តយុងហ្វូរបស់ឈិនឡុង គឺជារឿងពេញនិយមបំផុតដែលប្រជាជនកម្ពុជាចូលចិត្ត។ ទោះបីជាក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដោយមានការចាក់បញ្ចាំងខ្សែភាពយន្តអាម៉េរិក និងរឿងភាគក្នុងទូរទស្សន៍ថៃ ភាពល្បីល្បាញនៃខ្សែភាពយន្តចិននៅក្នុងប្រទេសកម្ពុជាបានធ្លាក់ចុះ ប៉ុន្តែសាច់រឿងដ៏ល្អ ស្មារតីក្នុងការបង្កើតឈុតឆាកដ៏អស្ចារ្យ នៅតែទទួលបានការចូលចិត្តយ៉ាងខ្លាំងពីសំណាក់ប្រជាជនកម្ពុជា ខ្សែភាពយន្តរឿងសាមកុកគឺជាស្នាដៃនៅទីនេះ។

ខ្សែភាពយន្តរឿងសាមកុក ដែលត្រូវបានចាក់ផ្សាយក្នុងឆ្នាំ២០១០ ត្រូវបានថតថ្មីក្នុងឆ្នាំ២០០៨ ខ្សែភាពយន្តនេះបានចាក់ផ្សាយតាមប៉ុស្ដិ៍ទូរទស្សន៍ នៅតាមបណ្ដាខេត្តនានានៃប្រទេសចិននៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០១០ ខ្សែភាពយន្តនេះមានចំនួន ៩៥ភាគ និង៤០នាទីក្នុងមួយវគ្គ។ ខ្សែភាពយន្តនេះក្រោយពេលនាំចូលប្រទេសកម្ពុជា បានប្រើការបញ្ចូលសម្លេងពីជនជាតិខ្មែរពិតៗ ហើយបានចាក់ផ្សាយលើប៉ុស្ដិ៍ទូរទស្សន៍ធំៗ នៅប្រទេសកម្ពុជាដូចជា TVK SEATV KTTV... ជាដើម។ ឥឡូវនេះអស់រយៈពេល៨ឆ្នាំបានកន្លងផុតទៅហើយ យើងនៅតែអាចមើលឃើញថា ស្ថានីយទូរទស្សន៍មួយចំនួននៅកម្ពុជានៅតែបន្តចាក់ផ្សាយខ្សែភាពយន្តនេះដដែល និងនៅតែទទួលបានការពេញចិត្ត។[២]

## ៣- រឿងសាមកុកត្រូវបានតំណាលតៗគ្នានៅកម្ពុជា

ក្នុងការរស់នៅក្នុងសង្គមចាំបាច់ត្រូវតែមានការប្រាស័យទាក់ទងគ្នា ការនិយាយគ្នា ការប្តូរមតិយោបល់នឹងគ្នា។ ប្រជាជនកម្ពុជានាសម័យដែលបច្ចេកវិទ្យាមិនទាន់បានរីកចម្រើន គឺនិយមជួបជុំគ្នាដើម្បីនិយាយរឿងដំណាលផ្សេងៗ មិនថា ជារឿងប្រជាប្រិយ រឿងនិទាន រឿងប្រវត្តិសាស្ត្រ គឺយកមកជំនុំក្នុងវង់ដើម្បីជាការកម្សាន្ត ឬ ចែករំលែកនូវចំណេះដឹងផ្សេងៗ។

[២] បទសម្ភាសន៍ជាមួយបណ្ឌិតសភាចារ្យ ស៊ុំ ឈុំប៊ុន ម៉ោង �9:00 ព្រឹកថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ២០២៤ ។

រឿងសាមកុក ត្រូវបានចាត់ចូលជារឿងមួយ ដែលប្រជាជនកម្ពុជាមួយចំនួនចូលចិត្តយកមកជំនួបពិភាក្សាគ្នាផងដែរ ជាពិសេសគឺអ៊ុំពូដែលចូលចិត្តរឿងនយោបាយ និងទស្សនវិជ្ជាបែបការប្រកួតប្រជែងប្រាជ្ញា ចម្បាំងផ្សេងៗ ដោយលើកពីហេតុផលនេះហេតុផលនោះ រហូតមកដល់ពេលបច្ចុប្បន្ន នៅក្នុងពេលបង្រៀនសិស្ស នៅមានលោកគ្រូ អ្នកគ្រូមួយចំនួននៅពេលនិយាយដល់ទស្សនៈនៅក្នុងរឿងសាមកុក តែងតែលើនៅទស្សនៈទាំងនោះមកធ្វើជាទឡ្ហីករណ៍ មកធ្វើការពន្យល់និងវែកញែក។

ការជំណាលតៗគ្នា ឬការលើកយកទស្សនៈក្នុងរឿងសាមកុកមកធ្វើការវែកញែកនេះ បានធ្វើឱ្យរឿងសាមកុកចាក់ស្រេះចូលក្នុងទឹកចិត្តប្រជាជនកម្ពុជា បន្ថែមលើនោះទៅទៀត ទស្សនៈមួយចំនួនប្រាកដជាមានគុណតម្លៃក្នុងស្វែងរកគន្លឹះថ្មីៗក្នុងដំណើរជីវិតពួកគេ។

## ៤- ការផ្សព្វផ្សាយតាមរយៈល្ខោនហ៊ី

រឿងសាមកុក ជារឿងរ៉ាវមួយផ្អែកកាលពីក្នុងរវាងចុងសតវត្សរ៍ទីពីរ និងខាងដើមសតវត្សរ៍ទីបីនៃគ្រិស្តសករាជ។ កាលចាប់ផ្តើមកើតរឿងឡើង គេមិនបានកត់ត្រាជាអក្សរទុកមកតាំងពីដំបូងទេ គ្រាន់តែជារឿងនិយាយជំណាលតៗគ្នាមក។ ដល់សម័យតមកក្រោយទៀត ប្រជាជនជាតិចិននិយមយករឿងសាមកុកនេះទៅសម្តែងល្ខោន ដែលយើងហៅថា **លេងហ៊ី** ទើបនាំឱ្យរឿងសាមកុកនេះសាយភាយចេញទៅ មានអ្នកចេះដឹងរឿងរ៉ាវនេះកាន់តែច្រើនឡើងៗ ទើបអ្នកប្រាជ្ញចិនរួបរួមចងក្រងកត់ត្រាទុកជាអក្សរតមក។ ដល់សម័យស្រុកចិនចេះឆ្លាក់ពុម្ពអក្សរហើយ គេបានបោះពុម្ពផ្សាយរឿងសាមកុកនេះជាសៀវភៅឡើង ជាដើមហេតុនាំឱ្យរឿងសាមកុកសាយភាយទូទៅក្នុងប្រទេសចិន និងរហូតដល់ប្រទេសនានា។

ប្រទេសកម្ពុជា ក៏ជាប្រទេសមួយដែលមានវប្បធម៌អរិយធម៌ដ៏យូរលង់ណាស់មកហើយ ក៏ប៉ុន្តែការប្រាស្រ័យទាក់ទងគ្នារវាងជាតិសាសន៍នីមួយក្នុងពិភពលោកចាំបាច់ត្រូវតែមានការជ្រៀតចូល ឬលំហូរនៃវប្បធម៌បរទេស ល្អរក្សាទុក មិនល្អចាំបាច់ត្រូវធ្វើការកែសម្រួលឬទប់ស្កាត់។ ដោយឡែក ល្ខោនហ៊ីដែលគ្រប់គ្នាស្គាល់ថា ល្ខោនទ្រើងឃ្លោក ឬល្ខោនបាសាក់នេះ បានមានវត្តមានក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៣០ មកម៉្លេះ។ ល្ខោននេះអាចសម្តែងបានជាច្រើនរឿង ទៅតាមលទ្ធភាពរបស់អ្នកសម្តែង។

រឿងសាមកុកត្រូវបានស្គាល់ថា តែងតែមានវត្តមាននៅក្នុងក្រុមល្ខោនហ៊ីនេះ ដោយបង្ហាញនូវឈុតឆាកចម្បាំងយ៉ាងអង់អាចក្លាហាន ហើយលើសពីនេះនៅមានការច្រៀងរាំយ៉ាងមានអត្ថន័យ។ នេះជាកត្តាមួយផ្សេងទៀតដែលធ្វើឱ្យប្រជាជនកម្ពុជាមានយល់ដឹងមើលឃើញនូវរឿងសាមកុក បើទោះជាលេងក្នុងឈុតខ្លះមានសភាពកាត់ៗ ប៉ុន្តែតាមរយៈការសម្តែង ប្រជាជនកម្ពុជានឹងមានអារម្មណ៍ប្លែក ក៏ដូចជាសប្បាយរីករាយជាមួយផ្ទៃរឿង។

មកដល់សព្វថ្ងៃស្ទើរតែគ្មានអ្នកស្គាល់ល្ខោនហ៊ីទៅហើយ ប៉ុន្តែក្នុងដំណាក់កាលនៃការផ្សព្វផ្សាយដំបូងនៃវប្បធម៌ចិន ហើយមិនអាចមិនទទួលស្គាល់ថា ល្ខោនហ៊ី ឬ ល្ខោនបាសាក់ ឬ ល្ខោនទ្រើងឃ្លោកនេះពិតជាបានជួយផ្សព្វផ្សាយឱ្យប្រជាជនក្នុងជំនាន់នោះបានស្គាល់ និងដឹងអំពីទិដ្ឋភាពខ្លះៗនៃស្នាដៃរឿងសាមកុក។[៣]

[៣] បទសម្ភាសន៍ជាមួយបណ្ឌិតសភាចារ្យ ស៊ុំ ឈុំប៊ុន ម៉ោង 9:00 ព្រឹកថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ២០២៤។

## ៥- ការផ្សព្វផ្សាយតាមរយៈហ្គេមអនឡាញ ( Game Online )

សាមកុកគឺជាប្រភេទ Web Cambodia Online លំដាប់ថ្នាក់ពិភពលោក។ សាមកុកបានមកដល់ប្រទេសកម្ពុជា លើសពីនេះវាប្រភេទ Web Cambodia Online តែមួយគត់នៅក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។ មកដល់សព្វថ្ងៃនេះមានអ្នកលេងជាច្រើនលើសលុបបាននឹងកំពុងតែលេង Web Cambodia Online ក្នុងគោលបំណងកម្សាន្ត និងកាត់បន្ថយភាពស្មុគស្មាញ បន្ទាប់ពីការសិក្សា និងការងារ។ ដើម្បីលេងនូវប្រភេទ Web Cambodia Online ពួកគេគ្រាន់តែចូលទៅកាន់គេហទំព័រ http://samkok.vtc.com.kh។

សាមកុក Web Cambodia គឺមិនចាំបាច់តំឡើងកម្មវិធីនៅកុំព្យូទ័រទេគ្រាន់តែ Click and Play។ សព្វថ្ងៃនេះនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានហ្គេមសាមកុកចំនួន២ ដែលបាននាំចូលដោយ២ក្រុមហ៊ុន Sabay ផងដែរ។ ក្នុងចំណោមហ្គេមសាមកុកទាំង២ប្រភេទនេះ មាន១ត្រូវការតំឡើងកម្មវិធីនៅក្នុងកុំព្យូទ័ររបស់អ្នកដើម្បីលេង។ សាមកុក Web Cambodia ជាប្រភេទហ្គេមយុទ្ធសាស្ត្រដែលទាមទារឱ្យអ្នកលេងបញ្ចេញនូវសមត្ថភាពផ្ទាល់ខ្លួនដើម្បីអភិវឌ្ឍន៍នគររបស់ខ្លួនឱ្យទៅជាអាណាចក្រដ៏ធំមួយ។

បើយើងក្រឡេកមើលពីចំនួនអ្នកដែលបានដោនឡូតយកកម្មវិធីនេះ និងបានចុះឈ្មោះលេងនូវល្បែងអនឡាញនេះ មានយ៉ាងច្រើនលើសលុប បើតាមទិន្នន័យរបស់ប្រព័ន្ធAndroid មានរហូតដល់ចំនួន១២ម៉ឺននាក់។ ទិន្នន័យនេះបានបញ្ជាក់ឱ្យឃើញកាន់តែច្បាស់ថា ចំនួនប្រជាជនខ្មែរមួយចំនួនពិតជាបានយល់ដឹងយ៉ាងច្បាស់អំពីរឿងសាមកុក ជាពិសេសក្នុងស្រទាប់យុវវ័យ ដែលបានចូលរួមក្នុងដំណើរផ្សងព្រេងរបស់រឿងសាមកុក។

បើទោះជាក្នុងទម្រង់នេះ អ្នកដែលបានយល់ដឹងពីរឿងសាមកុក មិនមានលក្ខណៈសង្កេតបានយ៉ាងជ្រាលជ្រៅលើទ្រឹស្តី ពាក្យពេចន៍ ឬការវិភាគឱ្យបានស៊ីជម្រៅលើតួអង្គក៏ពិតមែន ប៉ុន្តែលក្ខណៈពិសេសរបស់អ្នកលេងហ្គេមនេះនឹងទទួលបានទិដ្ឋភាពមួយគឺហាក់ដូចជាគេបានស្ថិតនៅក្នុងយុគសម័យនោះពិត ដោយការស្រមើស្រមៃ បង្កើតជាអារម្មណ៍រំភើប ព្រឺព្រួច ការត្រេកត្រអាល តាមដំណើរនៃសាច់រឿង ដើម្បីធ្វើការប្រកួតប្រជែងគ្នាក្នុងពិភពហ្គេម។[៥]

## សេចក្តីសន្និដ្ឋាន

តាមរយៈការសិក្សាកន្លងមក យើងឃើញមានការហូរចូលយ៉ាងសម្បូរបែបនៃអក្សរសាស្ត្រចិនមកក្នុងសង្គមបរិយាកាសខ្មែរ រហូតដល់មានការសម្តែងល្ខោនចិនក្នុងបរិវេណរាជវាំង មានការសិក្សាភាសានិងអក្សរសិល្ប៍ចិន មានខ្សែភាពយន្តចិនជាច្រើនបញ្ចាំងទាក់ទាញទស្សនិកជនខ្មែរយ៉ាងកុះករ និងមានសៀវភៅរឿងចិន ដាក់លក់នៅពាសពេញតាមបណ្ណាគារនានា ដែលក្នុងនោះរួមមានទាំងស្នាដៃរឿងសាមកុក ដ៏ល្បីល្បាញជាសាកលផងដែរ។

---

[៥] http://samkok.vtc.com.kh ចូលមើល ខែមេសា ឆ្នាំ២០២៤។

រឿងសាមកុកដ៏ល្បីល្បាញនេះត្រូវបានផ្សព្វផ្សាយចូលមក តាមគ្រប់មធ្យោបាយ មានការផ្សាយជាសៀវភៅ ខ្សែភាពយន្ត តាមការតំណាលតគ្នា តាមរយៈរឿងល្ខោនហ៊ី អ៊ីនធឺណេត និងមានរហូតដល់ហ្គេមអនឡាញ។

ដោយវណ្ណកម្មនេះមានលក្ខណៈសមស្របតាមផ្នត់គំនិតនៃប្រជាជនកម្ពុជា និងថែមទាំងផ្តល់នូវពុទ្ធិដោយឆ្លុះបញ្ចាំងបានយ៉ាងត្រឹមត្រូវនូវជីវភាពពិតក្នុងប្រវត្តិសាស្ត្រ មានលក្ខណៈសិល្បៈខ្ពស់ និងផ្តល់សម្បទានទស្សនៈដ៏ធំធេងផងនោះ ទើបយើងឃើញវាមានឥទ្ធិពលយ៉ាងទូលំទូលាយលើផ្នត់គំនិតមហាជនខ្មែរ លើស្មារតីអ្នកនិពន្ធ និងលើទស្សនៈអ្នកនយោបាយ។

ក្រោយពីបានធ្វើការសិក្សាលើដំណើរដើមទងនៃការបន្សាយ និងឥទ្ធិពលរឿងសាមកុក នៅក្នុងប្រទេសកម្ពុជារួចហើយ យើងខ្ញុំពិតជាមានមោទនភាពជាខ្លាំងដោយរកឃើញថា វណ្ណកម្មអក្សរសិល្ប៍បុរាណចិនមួយនេះ បានក្លាយជាមូលដ្ឋានគ្រឹះនៃទស្សនៈនយោបាយ គំនិតទស្សនៈនៃការគ្រប់គ្រង ព្រមទាំងទទួលបានការលើកតម្កើងយ៉ាងពេញទំហឹងពីសំណាក់អ្នកអាន អ្នកស្តាប់ និងអ្នកទស្សនាក្នុងប្រទេសកម្ពុជា។

ប្រទេសចិននិងកម្ពុជាបានមានទំនាក់ទំនងតាំងពីសម័យបុរាណមកម្ល៉េះ ដូច្នេះការផ្សព្វផ្សាយទស្សនៈ វប្បធម៌ អក្សរសិល្ប៍ ភាសាជាដើមត្រូវតែមាន ប៉ុន្តែអ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺការផ្សព្វផ្សាយនៃអក្សរសិល្ប៍មកក្នុងប្រទេសកម្ពុជា តាមរយៈល្ខោនហ៊ី សៀវភៅ ភាពយន្ត អ៊ីនធឺណែត ហ្គេមអនឡាញ និងការនិយាយតៗគ្នា ដែលទាំងនេះគឺជាការពង្រីកវិសាលភាពនៃអក្សរសិល្ប៍ បានធ្វើឱ្យការសិក្សាអក្សរសិល្ប៍កាន់តែមានការរីកចម្រើនទូលំទូលាយឡើង ជាទឡ្ហីករណ៍ ដូចជារឿងសាមកុកនេះជាដើម។



# គន្ថនិទ្ទេស


១- ឃីង ហុកឌី *ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ* , Paris, L'Harmattan, 1997

២- - ដ -*មាលីបទអក្សរសិល្ប៍ខ្មែរសតវត្សទី១៩* បណ្ណាគារអង្គរ ភ្នំពេញ ឆ្នាំ២០០២

៣- - ដ -*អក្សរសិល្ប៍ខ្មែរសតវត្សទី២០* ភ្នំពេញ បណ្ណាល័យអង្គរ ឆ្នាំ២០០៤

៤- - ដ - *ស្នើកម្មអក្សរសិល្ប៍ចិនលើកម្ពុជានាសតវត្សទី១៩និងទី២០* ភ្នំពេញ ឆ្នាំ២០០៨

៥- ជា វណ្ណី *ឥទ្ធិពលអក្សរសិល្ប៍ចិនក្នុងសង្គមខ្មែរ* រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០២០

៦- ប៊ុន ធឿន *ទំនាក់ទំនងកម្ពុជាចិន* និក្ខេបបទបណ្ឌិតវិទ្យាសាស្ត្រនយោបាយ រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០១៤

៧- ពៅ សាមី *លក្ខណៈទំនោរនៃអក្សរសិល្ប៍ និង សិល្បៈ* ភាគ២ ឆ្នាំ១៩៩៣

៨- -ដ-*មូលដ្ឋានទ្រឹស្តីអក្សរសិល្ប៍ និងសិល្បវិទ្យា ភាគ១-២* ភ្នំពេញ ឆ្នាំ២០១២

៩- ម៉ុញ សារី *កាលបរិច្ឆេទសំខាន់ៗនៃអក្សរសិល្ប៍ខ្មែរ* ភ្នំពេញ ឆ្នាំ២០០១

១០- -ដ-*វេទនាធិប្បាយអក្សរសិល្ប៍ខ្មែរ* ភ្នំពេញ ឆ្នាំ១៩៩៩

១១- លាង ហាប់អាន *សិក្សាស្នាដៃអក្សរសិល្ប៍ខ្មែរ ភាគ១-២* ភ្នំពេញ ឆ្នាំ១៩៦៦

១២- -ដ-*ប្រវត្តិអក្សរសាស្ត្រខ្មែរ* ការផ្សាយរបស់បណ្ណាគារ គិម អេងភ្នំពេញ ឆ្នាំ១៩៦៧

១៣- លី ធាមតេង *ប្រវត្តិអក្សរសាស្ត្រខ្មែរ* បណ្ណាគារ សេង ងួន ហួត ភ្នំពេញ ឆ្នាំ១៩៦០

១៤- -ដ-*អ្នកនិពន្ធខ្មែរដែលមានឈ្មោះល្បី* សមាគមអ្នកនិពន្ធខ្មែរ ភ្នំពេញ ឆ្នាំ១៩៧២

១៥- ស៊ុំ ឈុំប៊ុន *អក្សរសិល្ប៍ចិន* សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ឆ្នាំ១៩៨៥

១៦- សូរ អឿ *ប្រវត្តិសាស្ត្រព្រះរាជាណាចក្រកម្ពុជា ជាមួយអណ្ណាមនិងសៀមចាប់ពីសតវត្សទី១៦* វិទ្យាស្ថានខ្មែរ សម្រាប់សហប្រតិបត្តិការ និងសន្តិភាព

១៧- សោម សុមុនី *វិវត្តន៍អក្សរសិល្ប៍ខ្មែរសតវត្សទី២០* ភ្នំពេញ ឆ្នាំ២០០៧

១៨- -ដ- *វិភាគទាននៃការសិក្សាអក្សរសិល្ប៍ (ភាគ១-២-៣-៤)* ភ្នំពេញ ឆ្នាំ២០១៤

១៩- -ដ- *ការចាប់ផ្តើមឡើងវិញនៃអត្តសញ្ញាណវប្បធម៌ចិនអំឡុងឆ្នាំ១៩៩០-១៩៩៥* បទបាឋកថា ឆ្នាំ២០១៨

# ចម្លាក់សហសម័យទម្រង់បង្គុំ

និស្សិតៈ អ៊ូ វណ្ណឌី
ជំនាញៈ វិចិត្រសិល្បៈ

## ១. សេចក្តីផ្តើម

ចម្លាក់គឺជាសិល្បៈដែលតំណាងឱ្យការច្នៃប្រឌិតរបស់សិល្បករ ដែលបានបង្ហាញពីកាលបរិច្ឆេទ និងការវិវឌ្ឍន៍របស់សិល្បៈវប្បធម៌។

ចម្លាក់សហសម័យមានភាពចម្រុះគ្របដណ្តប់អ្វីៗគ្រប់យ៉ាងពីតូចបំផុតដល់ការដំឡើងទ្រង់ទ្រាយធំ និងប្រព័ន្ធផ្សព្វផ្សាយឌីជីថល។

### ក. ចម្លាក់បង្គុំ និងរូបធាតុចម្រុះ

ចម្លាក់ទម្រង់បង្គុំគឺជាស្នាដៃសិល្បៈដែលសិល្បករឆ្លុះបញ្ចាំងពីបញ្ហាសង្គម និងចម្រុះវប្បធម៌ដោយប្រើរូបតំណាងបែបអរូបីក្នុងន័យស្លាបនា ឬរិះគន់ទៅលើចំណុចអ្វីមួយ ដែលបានបង្កប់នូវអត្ថន័យដែលសិល្បករចង់បង្ហាញក្នុងន័យអប់រំបរិស្ថាន។ រូបចម្លាក់សហសម័យអាចមានភាពស្មុគស្មាញដោយសារភាពចម្រុះរបស់វា ប៉ុន្តែវាពិតជាគួរឱ្យចាប់អារម្មណ៍ណាស់ ដែលឱ្យសិល្បករឆ្លុះបញ្ចាំងពីបញ្ហាសង្គមដោយប្រើរូបចម្លាក់តំណាងទម្រង់ជាអរូបី ឬរូបីដែលបង្កប់ទៅដោយខ្លឹមសារ។

សិល្បៈសហសម័យបានបំបែកក្បួនខ្នាតពីសិល្បៈបុរាណក្នុងគោលបំណងដើម្បីប្រែក្លាយខ្លួនប្រកបដោយគំនិតច្នៃប្រឌិត និងការផ្លាស់ប្តូរ។ គោលដៅដ៏សំខាន់បំផុតមួយនៃសិល្បៈសហសម័យគឺលែងយកចម្លាក់ជាវត្ថុនៃរូបតំណាងដោយជំនួសមកវិញនូវទស្សនៈវិស័យថ្មីចំពោះការងារ[១]។

ជាតុផ្សំសម្រាប់ដំឡើងចម្លាក់មានច្រើនប្រភេទដូចជា ឈើ ដែក ដីឥដ្ឋ លោហៈ សំរិទ្ធ អាលុយមីញ៉ូម ជ័រ ប្លាស្ទិក ស៊ីម៉ងត៍ ហើយអាចបង្កើតបាននៅគ្រប់ទីកន្លែង។ សិល្បៈនេះមានគោលបំណងផ្លាស់ប្តូរការយល់ឃើញរបស់អ្នកមើលដែលតែងតែគិតពីផលអវិជ្ជមានអំពីកាកសំណល់ដែលវាស្ថិតនៅ។ ចម្លាក់សហសម័យត្រូវបានគេប្រើយ៉ាងទូលំទូលាយគ្រប់សម័យកាល នៃភាពច្នៃប្រឌិត និងការបញ្ចេញមតិ ។

### ខ. ប្រវត្តិសិល្បៈបង្គុំ

ការកែច្នៃឡើងវិញមិនមែនជារឿងថ្មីនោះទេ ការកំណត់ពេលវេលានេះនឹងនាំអ្នកឆ្លងកាត់ព្រឹត្តិការណ៍ជាប្រវត្តិសាស្រ្តសំខាន់ៗមួយចំនួន នូវទិដ្ឋភាពសង្ខេបអំពីរបៀបនៃការផ្គុំសម្ភារៈដែលមិនមានតម្លៃឱ្យប្រែក្លាយទៅវត្ថុមានតម្លៃឡើងវិញ និងបានផ្លាស់ប្តូរការគិតរបស់មនុស្សចំពោះកាកសំណល់។

នៅឆ្នាំ១៨៩៧អ្នករស់នៅទីក្រុងញូវយ៉កបានប្រមូលវត្ថុធាតុដើម និងសម្ភារៈដែលឈប់ប្រើប្រាស់ហើយបោះចោល បានយកមកកែច្នៃឡើងវិញដូចជា លោហៈ ក្រដាស ក្រណាត់ និងសម្ភារៈប្រើប្រាស់ផ្សេងទៀត[២]។

---

[១] https://www.artalistic.com/en/blog/What-is-contemporary-sculpture/ ចូលមើលថ្ងៃទី២៣ កក្កដាឆ្នាំ២០២៤។

[២] https://www.artalistic.com/en/blog/What-is-contemporary-sculpture/ ចូលមើលថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤។

ក្នុងឆ្នាំ១៩១៧ វិចិត្រករជនជាតិបារាំង លោក Marcel Duchamp គឺជាមនុស្សដំបូងគេដែលប្រើ **គំនិតការប្រើប្រាស់រួច** Ready-made។ លោកបានបង្កើតស្នាដៃចម្លាក់ពីចានបង្គន់ ហើយស្នាដៃរបស់គាត់ត្រូវបានគេទទួលស្គាល់ថា ជាសិល្បៈដ៏ទំនើបបំផុតនៅសតវត្សទី២០។ បន្តិចក្រោយមកលោក Pablo Picasso ក៏បានយកវត្ថុដែលប្រើប្រាស់រួច ផលិតនៅក្នុងស្នាដៃសិល្បៈរបស់គាត់ដូចជា កែបកង់ និងដៃកង់ ដើម្បីបង្កើតជារូបចម្លាក់ក្បាលគោ( Bull's Head )[៣]។

ឆ្នាំ១៩៤៥ ជាឆ្នាំដែលសិល្បៈសហសម័យចាប់ផ្តើមជ្រាបចូលទៅក្នុងវិស័យសិល្បៈលោកខាងលិច និងជាទម្រង់សិល្បៈដ៏មានប្រជាប្រិយភាពកាន់តែខ្លាំងក្នុងស្រទាប់អ្នកស្រឡាញ់សិល្បៈ ដែលស្នាដៃរបស់វិចិត្រករជាស្នាដៃនៃការបញ្ចេញមតិ និងការគិត [៤]។




*រូបទី ១ ចម្លាក់បង្គន ស្នាដៃលោក Marcel Duchamp ឆ្នាំ១៩១៧*



*រូបទី 1 ចម្លាក់ក្បាលក្របីស្នាដៃលោក Pablo Picasso ឆ្នាំ១៩១៩*

ឆ្នាំ១៩៥៥ ទស្សនាវដ្តី LIFE បានបោះពុម្ពផ្សាយសៀវភៅមួយដែលមានចំណងជើងថា "**ការរស់នៅក្នុងគំនរសំរាម**" Throwaway Living ដោយជំរុញឱ្យមានការគិតឡើងវិញនៃជីវិតសម័យទំនើប។ អត្ថបទនេះបានជួយណែនាំពីរបៀបនៃការគិតដែលមិនសូវមានទំនួលខុសត្រូវ ហើយប្រើប្រាស់សម្ភារៈខ្ជះខ្ជាយ ដែលនាំឱ្យមានការបោះចោលសំរាមពាសវាលពាសកាល និងកង្វះការគិតពីបរិស្ថាន[៥]។

ពាក់កណ្តាលទីពីរនៃសតវត្សទី២០ ការប្រើប្រាស់កាកសំណល់ក្នុងសិល្បៈគឺជាការឆ្លុះបញ្ចាំងពីការវិវត្តន៍នៃសង្គម និងសិល្បៈ។ វិចិត្រករបានចាប់ផ្តើមទាញការបំផុសគំនិតរបស់ពួកគេ ដូចជាការបង្កើតស្នាដៃសិល្បៈពីកាកសំណល់ និងវត្ថុដែលគេបោះចោល។ វិចិត្រករបានរចនាសិល្បៈបែបនេះកាន់តែច្រើនឡើងៗដោយបានបង្កើតសិល្បៈចម្លាក់បង្កុំកាន់តែទូលំទូលាយនៅបណ្តាប្រទេសលោកខាងលិច។

---

[៣] https://blog.terracycle.com/2018/07/20/a-history-of-waste-in-art/ចូលមើលថ្ងៃទី១៧ខែកក្កដាឆ្នាំ២០២៤។

[៤] https://www.artalistic.com/en/blog/What-is-contemporary-sculpture/ចូលមើលថ្ងៃទី៩ខែកក្កដា២០២៤។

[៥] https://hintonswaste.co.uk/news/history-of-recycling-timeline/ចូលមើលថ្ងៃទី១៧ខែកក្កដាឆ្នាំ២០២៤។

នៅឆ្នាំ១៩៦១ វិចិត្រករជនជាតិបារាំងកាត់អាមេរិកដ៏ល្បីល្បាញគឺលោក Jim Dine's Dust Bin Arman បានបំផុសគំនិតក្នុងការយកសំរាម មកបង្កើតជាស្នាដៃដែលមានចំណងជើងថា "ការប្រមូលផ្តុំ" Accumulations គាត់បានប្រមូលសំរាមដាក់នៅក្នុងប្រអប់កញ្ចក់ មានរួមបញ្ចូលនូវវត្ថុធាតុដើម ដែលគេបោះចោលទៅក្នុងការងារសិល្បៈរបស់គាត់។ វិចិត្រកររូបនេះបានរំលេចពីសច្ចភាពសង្គមមួយ ដែលអ្វីៗទាំងអស់អាចបោះចោលបន្ទាប់ពីការប្រើប្រាស់តែមួយដង។



*រូបទី 2 ចម្លាក់ប្រមូលផ្តុំ ស្នាដៃលោក* Jim Dine's Dust Binនិង Arman ឆ្នាំ ១៩៦១

លោក John Chamberlain គឺជាសិល្បករដ៏សំខាន់បំផុត ដែលស្នាដៃរបស់គាត់ ត្រូវបានគេទទួលស្គាល់ថាជាអ្នកដំបូងគេ ដែលប្រើលោហៈនៃគ្រឿងបន្លាស់រថយន្ត ជាសម្ភារៈច្នៃប្រឌិតបង្កើតជាចម្លាក់[៦]។

ចំណែកនៅក្នុងប្រទេសកម្ពុជាយើង ចម្លាក់សហសម័យជាសិល្បៈទម្រង់បង្គុំមានច្រើនរបៀបណាស់ដែរ ការហូរចូលនៃសិល្បៈនេះមិនមានឯកសារ ឬមិនមានកាលបរិច្ឆេទណាមួយច្បាស់លាស់ ថាចូលតាមរយៈអ្នកណា? អ្នកណាចាប់ផ្តើមចម្លងទម្រង់សិល្បៈនេះមុនគេ?ហើយវាកើតឡើងពីឆ្នាំណាមកដែរ? ក៏ប៉ុន្តែការមកដល់នៃសិល្បៈនេះតាមរយៈនិស្សិតដែលបានទៅសិក្សានៅបរទេស ពេលត្រឡប់មកប្រទេសវិញបាននាំយកមកដើម្បីអភិវឌ្ឍ និងច្របាច់បញ្ចូលគ្នាជាមួយសិល្បៈរបស់ខ្លួន។ ម្យ៉ាងវិញទៀតគឺតាមរយៈមជ្ឈមណ្ឌលវប្បធម៌បារាំងដែលបានអញ្ជើញសិល្បករសិល្បៈការនី ពីបណ្តាប្រទេសលោកខាងលិចមកបង្ហាត់បង្រៀនដល់សិល្បករវ័យក្មេងកម្ពុជាក្នុងអំឡុងឆ្នាំ១៩៩៨-១៩៩៩។



*រូបទី ៤ កង់រចនាពីកាកសំណល់សង្គ្រាម ស្នាដៃលោកទួន ជនាគា ក្នុងឆ្នាំ២០០១៣*

ក្នុងឆ្នាំ២០០3សិល្បករផ្នែកចម្លាក់ជាច្រើនបានចូលរួមសិក្សា បង្កើនភាពច្នៃប្រឌិត ដោយសិល្បករខ្លះយកថង់ផ្លាស្ទិចដបទឹកសុទ្ធ បំណែកលោហៈនៃយានយន្ត និងកាកសំណល់អាវុធយុទ្ធភណ្ឌសង្គ្រាម មករចនាជាវត្ថុសិល្បៈទៅតាមគោលគំនិត និងចំណង់ចំណូលចិត្តរបស់ពួកគាត់រៀងៗខ្លួន[៧]។ ស្នាដៃទាំងនោះមានទាំងគំនិតអរូបី និងរូបីទោះក្នុងន័យវិជ្ជមាន ឬអវិជ្ជមានសុទ្ធតែបានជួយផ្សព្វផ្សាយពីទម្រង់សិល្បៈដ៏សម្បូរ

[៦] https://zarastro.art/contemporary-sculpture/ ចូលមើលថ្ងៃទី២៣ ខែកក្កដាឆ្នាំ២០២៤។

[៧] https://www.peaceartprojectcambodia.org/the-programme/ចូលមើលថ្ងៃទី៧កក្កដា២០២៣។

បែបរបស់ខ្មែរយើង និងមួយផ្នែកទៀតបានរួមចំណែកក្នុងការអប់រំបរិស្ថាន តាមរយៈគំនិតច្នៃប្រឌិត ដោយយកកាកសំណល់ដែលមាននៅជុំវិញខ្លួន លែងប្រើប្រាស់មករចនាដើម្បីបង្កើតជាវត្ថុសិល្បៈសម្រាប់ដាក់តាំងលម្អតាមរមណីយដ្ឋាន សណ្ឋាគារ សួនច្បារ សំណង់អាគារសាធារណៈឯកជន និងរដ្ឋមួយចំនួនដើម្បីជួយលើកសម្រស់អាគារ និងសួនច្បារបានមួយកម្រិតទៀត។

## ១.១ សិល្បៈដែលរចនាពីកាកសំណល់

ប្រទេសយើងមានសុខសន្តិភាព និងមានការអភិវឌ្ឍន៍ សម្ភារៈប្រើប្រាស់ក៏កាន់តែសម្បូរបែបមធ្យោបាយក៏កើនឡើងច្រើន ចំណែកឯកាកសំណល់ក្រោយពីប្រើប្រាស់មានកាន់តែច្រើនណាស់ដែរកាកសំណល់ទាំងនោះបង្កផលប៉ះពាល់ខ្លាំងដល់ជីវិត និងប្រព័ន្ធអេកូឡូស៊ីនៅលើផែនដី។ បើទោះបីជាមានការយកចិត្តទុកដាក់ពីសំណាក់ស្ថាប័នពាក់ព័ន្ធក្នុងការពន្យល់ណែនាំ និងអប់រំពីវិធីញែកកាកសំណល់វេចខ្ចប់ និងទុកដាក់ឱ្យបានត្រឹមត្រូវក៏ដោយ នៅមានកាកសំណល់ខ្លះនៅរាយប៉ាយនៅឡើយនេះដោយសារតែអ្នកប្រើប្រាស់នៅមិនទាន់យល់ដឹងទូលំទូលាយ និងខ្វះការចូលរួម។

បច្ចុប្បន្នសិល្បករវ័យក្មេងជាច្រើនបានងាកមកចាប់យកសិល្បៈបង្គុំ និងមានគំនិតច្នៃប្រឌិតខ្ពស់ប្រកបទៅដោយទេពកោសល្យ ប្អូនៗបានយកសិល្បៈមកផ្សារភ្ជាប់ជាមួយវប្បធម៌ សង្គម សាសនា និងបរិស្ថានដែលបង្កប់នៅអត្ថន័យអប់រំយ៉ាងជ្រាលជ្រៅ ហើយក៏ជាសារក្រើនរំលឹកដល់អ្នកមើលជាភ្ញៀវជាតិ និងអន្តជាតិទស្សនាទុកជាគតិនៃទស្សនវិស័យទៀតផង។

### ១.១.១ សិល្បៈកាកសំណល់រឹង និងវិធីដំឡើង

សិល្បៈទាំងអស់សុទ្ធតែមានគោលបំណងដូចជា៖

- អភិរក្សសិល្បៈទម្រង់បុរាណ
- អភិវឌ្ឍទម្រង់សិល្បៈបុរាណ ដោយផ្សារភ្ជាប់ទៅសិល្បៈទំនើប និងសហសម័យ
- បញ្ជ្រាបគំនិតអប់រំ សង្គម វប្បធម៌និងបរិស្ថាន តាមរយៈវត្ថុសិល្បៈដែលរចនាពីកាកសំណល់ដែលប្រើប្រាស់រួចគ្រប់ប្រភេទ និងផលប៉ះពាល់។
- បណ្តុះគំនិតឱ្យស្រឡាញ់គាំទ្រសិល្បៈច្នៃប្រឌិតគ្រប់ទម្រង់
- ជំរុញសិល្បៈប្រពៃណីឱ្យមានការវិវឌ្ឍទាន់សម័យសកលភាវូបនីកម្មនៃសិល្បៈពិភពលោក

### ក. ចម្លាក់រចនាពីកាកសំណល់សង្គ្រាម

ក្នុងឆ្នាំ២០០៣ រោងជាងសិល្បៈសន្តិភាពនៅកម្ពុជាបានបង្កើតឡើងដោយលោកស្រី Sasha Constable និងលោក Niel ដែលគម្រោងនេះមានការគាំទ្រពីអង្គការសហភាពអឺរ៉ុប(Eau Asac), Greffit University ដែលបានសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា ដោយផ្តោតលើសិល្បៈដែលរចនានិងបង្គុំពីកាកសំណល់សង្គ្រាម មានសិល្បករផ្នែកចម្លាក់៣០នាក់ បានចូលរួមសិក្សាបន្ថែមនៅទីនោះ

ដើម្បីទទួលយកបទពិសោធន៍ និងចំណេះជំនាញថ្មីៗ ដើម្បីអភិវឌ្ឍន៍សិល្បៈដ៏សម្បូរបែបរបស់ខ្លួន។ លោកស្រី Sasha Constable បានអញ្ជើញលោកគ្រូជាច្រើនរូបដែលមានជំនាញខាងសិល្បៈមកពីសហរដ្ឋ អាមេរិក ចក្រភពអង់គ្លេស មកបង្ហាត់បង្ហាញពីបច្ចេកទេសនៃសិល្បៈចម្លាក់បែបសហសម័យដល់សិល្បករចម្លាក់វ័យក្មេងកម្ពុជា ដែលចង់ចេះចង់ដឹងពីសិល្បៈបែបលោកខាងលិច[៨]។



*រូបទី ៥ ចម្លាក់ដំរី វិចិត្រករ អ៊ូ វណ្ណឌី ឆ្នាំ២០១៧*

ថ្ងៃទី១៩ខែកញ្ញាឆ្នាំ២០០៩ចម្លាក់នាគរាជសន្តិភាព និងការអភិវឌ្ឍន៍ជាចម្លាក់ដំបូងគេ បានប្រាកដខ្លួនយ៉ាងត្រដែតនៅសួនច្បារកណ្ដាលក្រុងបាត់ដំបងនាមាត់ស្ទឹងសង្កែ។ ចម្លាក់នេះច្នៃពីអាវុធធុនតូចចំនួន២៥ប្រភេទ និងប្រើប្រាស់អស់ចំនួន២៧០០ដើមមានកំពស់ជិត៤ម៉ែត្រ មានទម្ងន់ជាង៣តោន។ ចម្លាក់នេះជាចំណងមិត្តភាពរវាងរាជរដ្ឋាកម្ពុជា និងជាមួយប្រជាជនជប៉ុនតាមរយៈរាជរដ្ឋាភិបាលជប៉ុនប្រចាំនៅកម្ពុជា [៩]។





*រូបទី ៦ចម្លាក់នាគរាជសន្តិភាព និងការអភិវឌ្ឍន៍រចនាវិចិត្រករ អ៊ូ វណ្ណឌី តឡើងជាក្រុមឆ្នាំ២០០៩*

---

[៨] https://www.peaceartprojectcambodia.org/the-programme/ ចូលមើលថ្ងៃទី១៣ មិនា២០២៣។

[៩] តាមសម្ដី លោក ឈាង សែ ជានាយកតំបន់របស់អង្គការ J-sac ប្រចាំខេត្តបាត់ដំបង ដកស្រង់ពីកាសែតកោះសន្តិភាពថ្ងៃទី ២៣ ខែកញ្ញាឆ្នាំ២០០៩។

## ១.១.២ វិធីដំឡើង



រូបទី ៩ រចនាវិចិត្រករ
អ៊ូ វណ្ណឌី ឆ្នាំ២០២១

ដំបូងខ្ញុំគូរសាកល្បងពីរទៅបីទម្រង់ជាមុនទើបសម្រេចចិត្តយកទម្រង់ណាមួយមកបង្កើតជាចម្លាក់ជាក់លាក់មួយ ដែលអាចទទួលយកបាន។

**- ដំណាក់គូរលម្អិត**

បន្ទាប់ពីសម្រេចបាននៅគំនូរព្រាងជាច្រើនសន្លឹករួចមក ខ្ញុំសម្រេចយកតែមួយសន្លឹកតែប៉ុណ្ណោះ ហើយចាប់ផ្តើមគូរលម្អិត និងបញ្ចេញគំនិតនៅលើរូបគំនូរនោះនៅអ្វីដែលខ្ញុំស្រឡាញ់ ហើយគូរលម្អិតក្បាច់ជាទម្រង់លោហៈមួយចំណុចម្តងៗ ចាប់ពីក្រោមឡើងទៅលើតាមអ្វីដែលបានគិតទុកជាមុន។ ទើបផ្តើមបំលែងក្បាច់នៃគ្រឿងអលង្កការ ពីទម្រង់បុរាណមកទម្រង់សម័យដោយយកលំនាំតែប៉ុណ្ណោះ។

## ក. ដំណាក់កាលដំឡើងស្នាដៃចម្លាក់

ជាដំបូងត្រូវកំណត់កំពស់រួចចាប់ផ្តើមត្រូវបែងក្រឡា ដើម្បីក្រិតខ្នាតនៅលើក្តារកុងប្លាកេឱ្យរួចស្រេចជាមុនសិនដោយយកខ្នាតក្បាល់ជាគោល និងបែងជា ៦ខ្នាតទើបចាប់ផ្តើមគូរជាគំនូរព្រាងលើក្តារមួយចំណុចម្តងៗឡើងវិញម្តងទៀតទៅតាមខ្នាតដែលបានកំណត់។

**- ដំឡើងគ្រោងដំបូង**

ជាដំបូងខ្ញុំត្រូវដំពន្លាដែកសសៃឱ្យត្រង់ទៅតាមចំនួនដែលចង់បាន បន្ទាប់មកត្រូវយកដែកទាំងនោះមកពត់តាមរាងរៅទៅតាមគំនូរព្រាងលើក្តារកុងប្លាកេ។ ពេលពត់គ្រោងជារាងទូទៅរួចរាល់ចប់សព្វគ្រប់ហើយ ខ្ញុំចាប់ផ្តើមផ្សារភ្ជាប់គ្រប់ចំណុចសំខាន់ៗនៃគ្រោងដែកឱ្យរួចរាល់ជាមុនសិន។ លើកគ្រោងដែកបញ្ឈរដើម្បីផ្សារភ្ជាប់ជាមួយបន្ទះដែកជើងទម្រ។ ផ្សារគ្រោងឆ្អឹងឱ្យជាប់មាំល្អទើបផ្សារបណ្តុះដែកសសៃបន្ថែមទៀតដោយជើងម្ខាងបណ្តុះបន្ថែម ២ដើមថែមទៀត សម្រាប់កាច់ឱ្យចេញជារាង៣វិមាត្រ(៣D)។

**- ដំឡើងគ្រោងលម្អិត**

បន្ទាប់បណ្តុះសសៃដែកបន្ថែមរួចរាល់ហើយ ខ្ញុំចាប់ផ្តើមពត់ឆ្អឹងលម្អិតចេញពីជើងឡើងទៅលើដោយបំពាក់កងពីខាងក្នុងសសៃដែកតាមទម្រង់ពីជើងដេញទៅជង្គង់ ចង្កេះ ទ្រូង ស្មា ក ក្បាល ព្រមទាំងអវៈយវៈលើឱ្យរួចរាល់ជាមុនទើបបំពាក់បំណែកលោហៈ។

- **បំពាក់គ្រឿងបង្គុំបំណែកលោហៈ**

បំពាក់សាច់លោហៈខាងក្រៅចម្លងតាមអ្វីដែលរចនាលើក្រដាសព្រាង។ ប៉ុន្តែការរចនាលើគំនូរព្រាងមិនអាចយកតាម ១០០%បានឡើយ ពីព្រោះថា គំនូរវាខុសពីចម្លាក់គំនូររាបស្មើលើផ្ទៃក្រដាសយើងមិនអាចមើលបានជុំវិញឡើយ។

បង្គុំសាច់ជាក់ស្តែងត្រូវតែកែសម្រួល បញ្ចេញបញ្ចូលបន្ថែមនៅគំនិតថ្មីៗខ្លះ ហើយត្រូវដកចេញខ្លះៗនៅគំនិតដែលមានស្រាប់។ ធ្វើរបណ្តើរគិតបណ្តើរបន្ថែមបន្ថយបណ្តើរៗទៅតាមការអនុវត្តន៍ជាក់ស្តែង។ បំពាក់រួចរាល់ហើយត្រូវដកឃ្លាមកពិនិត្យមើល ដើម្បីឱ្យប្រាកដថាត្រឹមត្រូវទៅតាមអ្វីដែលចង់បានហើយឬនៅ? ប្រសិនមិនសមត្រង់ចំណុចណាគាស់ដកចេញ និងបញ្ចូលគំនិតថ្មីជំនួសវិញ។



*រូបទី ១០ ចម្លាក់ហនុមាន ស្នាដៃវិចិត្រករ*
*អ៊ូ វណ្ណឌី ឆ្នាំ២០២១*

- **រចនាគ្រឿងលម្អ**

ការតុបតែងគ្រឿងលម្អរបស់សិល្បៈបង្គុំខុសពីគំនូរ និងចម្លាក់ទម្រង់បុរាណ ឬទម្រង់ប្រពៃណីព្រោះថា គំនូរចម្លាក់ប្រពៃណីត្រូវតែច្បាស់លាស់ និងយល់ច្បាស់ពីក្បាច់ដែលប្រើសម្រាប់តុបតែងលម្អ។



*រូបទី ១១ គ្រឿងលម្អលើចម្លាក់ហនុមាន ស្នាដៃវិចិត្រករ អ៊ូ វណ្ណឌី ឆ្នាំ២០២១*

## ខ.ការសម្អាត

ត្រូវរៀបកន្លែងឱ្យសមសួនជាមុនសិនទើបចាប់ផ្ដើមដំណើរការសម្អាតតែម្តង ពេលសម្អាតដាច់ខាតមិនមានមនុស្សចូលឡើយ ពីព្រោះអាចមានគ្រោះថ្នាក់ពីចំណាំងផ្លាតនៃផ្លែខ្វាតត្រូវ សម្អាតសព្វទីកន្លែងមិនឱ្យសល់ប្រឡោះកន្លែងណាឡើយ សម្អាតដេញពីជើងរហូតដល់ក្បាល ដោយសេចក្ដីព្យាយាម និងអត់ធ្មត់បំផុត។ ពេលសម្អាតរួចរាល់ហើយទើបអាចបំបោសពណ៌ទឹកមាស ឬពណ៌ទង់ដែងក៏បាន ទៅតាមចំណង់ចំណូលចិត្ត និងបំបោសរួចរាល់ហើយយកវ៉ែកនីមកបាញ់ពីលើមួយ ឬពីរជាន់ជាការស្រេច។



*រូបទី ១២ ចម្លាក់ ហនុមាន ស្នាដៃវិចិត្រករ អ៊ូ វណ្ណឌី ឆ្នាំ២០២១*

## សេចក្តីសន្និដ្ឋាន

ចម្លាក់បង្គុំជាទម្រង់សិល្បៈសហសម័យដែលឱ្យសិល្បករបញ្ចេញគំនិតរបស់ពួកគេបាន តាមរយៈស្នាដៃដែលរចនា ដើម្បីឱ្យអ្នកទស្សនាយល់នូវគោលបំណងរបស់សិល្បករដែលបានបង្កប់នៅក្នុងស្នាដៃសិល្បៈទាំងន័យវិជ្ជមាន និងអវិជ្ជមាន ស្នាដៃសិល្បៈនោះមិនបានបង្ហាញន័យដោយត្រង់ទៅអ្នកមើលទេ ប៉ុន្តែពួកគាត់ត្រូវចេះវិភាគខ្លឹមសារអត្ថន័យដែលចង់បង្ហាញក្នុងន័យអប់រំជាប្រយោល ។

# គន្ថនិទ្ទេស

## ១.ភាសាជាតិ

### ១.១ សិក្ខាសាលា

- សិក្ខាសាលាពិភាក្សាពីការអភិវឌ្ឍន៍ និងច្នៃប្រឌិតផ្នែកចម្លាក់នៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ថ្ងៃទី១៧ខែឧសភាឆ្នាំ២០២៣
- ចូលរួមពិពណ៌និងសក្ខាសាលាសិល្បៈសហសម័យនៅកម្ពុជា រៀបចំដោយនាយកដ្ឋានសិល្បៈសូនរូបនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅសារៈមុន្ទីខ្លែង ក្រុងភ្នំពេញ នៅថ្ងៃទី១០ខែធ្នូឆ្នាំ២០២១។
- សិក្ខាសាលាផ្សព្វផ្សាយលទ្ធផលអំពី ការចូលរួមពីដៃគូពាក់ព័ន្ធក្នុងវិស័យឧស្សាហកម្មវប្បធម៌ ដែលរៀបចំឡើងដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅទីស្ដីការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៣។
- លោក ហេង មុនីផល បទបង្ហាញពី ទ្រឹស្ដីចម្លាក់ នៅអាគាឥន្រ្ទទេវី រាជបណ្ឌិតសភាកម្ពុជា ថ្ងៃទី23ខែមករាឆ្នាំ២០២៣។

### ១.២ សម្ភាសន៍

- សម្ភាសផ្ទាល់ជាមួយវិចិត្រករ ហេង មុនីផល នៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ(ការជ្រើសរើសប្រធានបទទស្សនាវដ្ដី)នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៤។
-សម្ភាសផ្ទាលជាមួយលោក ទូត ប៊ុនឈៀង ព្រឹទ្ធបុរសរងមហាវិទ្យាល័យសិល្បៈសូនរូប នៅសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ(ចម្លាក់ក្នុងលម្ហ)នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៤។
- សម្ភាសន៍ជាមួយវិចិត្រករ នូ សារី នៅហាងកាហ្វេរសារៈមុន្ទីជាតិភ្នំពេញថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៤

## ២. ភាសាបរទេស

### ២.១ ស្នាដៃនិពន្ធបោះពុម្ពផ្សាយ

1. Contemporary Sculpture: An Evolution in Volume and Space by Giedion-Welcker, Carola Comp (ISBN: 9781258219444)
2. Materials and Processes of Contemporary Sculpture by Mahamoud M Farag (ISBN: 1-5275-4471-0) Release Date: 5th February 2020

### ២.២ គេហទំព័រ

- https://www.artalistic.com/en/blog/What-is-contemporary-sculpture/ (Accessed 5 Jully 202៣)
- https://blog.terracycle.com/2018/07/20/a-history-of-waste-in-art/ (Accessed 15 Jully 2024)
- https://hintonswaste.co.uk/news/history-of-recycling-timeline/# (Accessed on 17 Jully 2024)
- https://www.peaceartprojectcambodia.org/the-programme/ (Accessed on 7 August 2024)
- https://zarastro.art/contemporary-sculpture/(Accessed23 July2024)

© ២០២៤ រាជបណ្ឌិត្យសភាកម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង
គ្មានផ្នែកណាមួយនៃទស្សនាវដ្ដីនេះនឹងត្រូវបានបោះពុម្ពឡើងវិញ
ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីរាជបណ្ឌិត្យសភាកម្ពុជាឡើយ។

©2024 Royal Academy of Cambodia
All rights reserved,
no part of this book may be reproduced,
in any form, by any means, without permission in writing from
Royal Academy of Cambodia.




**Royal Academy of Cambodia**
Russian Federation Blvd
P.O.Box: 531 Phnom Penh
Kingdom of Cambodia
Tel: (855) 23 890 180
Fax: (855) 23 890 180
Email: info@rac.gov.kh
Website: www.rac.gov.kh

**រាជបណ្ឌិត្យសភាកម្ពុជា**
**មហាវិថីសហព័ន្ធរុស្ស៊ី**
**ប្រអប់សំបុត្រលេខ ៥៣១ ភ្នំពេញ**
**ព្រះរាជាណាចក្រកម្ពុជា**
**ទូរសព្ទលេខ**: (៨៥៥)២៣ ៨៩០១៨០
**ទូរសារលេខ**: (៨៥៥)២៣ ៨៩០១៨០
**អ៊ីមែល**: info@rac.gov.kh
**គេហទំព័រ**: www.rac.gov.kh